ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



◆ អំពើប្រល័យពូជសាសន៍ខ្មែរក្រហមប្រឆាំងនឹងជនជាតិចាម

◆ តើប្រជាជនចាមត្រូវបានសម្លាប់ដោយសារអត្តសញ្ញាណរបស់ខ្លួនឬ?

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ១៨៩ ខែកញ្ញា ឆ្នាំ២០១៥

ស្វែងរកការពិត

ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ១៨៩ ខែកញ្ញា ឆ្នាំ២០១៥

## មាតិកា

◆ អំពើប្រល័យពូជសាសន៍ប្រឆាំងនឹងជនជាតិ ........ ១

**ផ្នែកឯកសារ**

◆ ចម្លើយសារភាពរបស់ ទិក ហ៊ន ហៅ វ៉ាល់ ........ ៤

◆ ដំណើរយុវជន-យុវនារីបដិវត្តន៍ ........ ៨

◆ កំណត់ហេតុអង្គប្រជុំគណៈអចិន្ត្រៃយ៍ ........ ១៨

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ រូបថតគ្រួសារ សោ ភឹម ប្រធានភូមិភាគបូព៌ា ........ ២០

◆ កម្មាភិបាលខ្មែរក្រហមម្នាក់ត្រូវសម្លាប់នៅក្នុង ........ ២២

◆ គុកនៅភ្នំទ្រយោងជាកន្លែងដាក់ក្រុមគ្រួសារ ........ ២៤

◆ ការឈឺចាប់ដែលដក់ជាប់នៅក្នុងចិត្ត ........ ២៨

◆ ចាប់ពីរបបខ្មែរក្រហមដល់ឧប្បត្តិហេតុ ហាំបាលី ........ ៣១

**ផ្នែកច្បាប់**

◆ សវនាការលើការបង្ហាញឯកសារគន្លឹះ ........ ៤០

◆ សវនាការស្ដាប់សក្ខីកម្មដើមបណ្ដឹង នួន ណារុំ ........ ៤២

◆ សវនាការស្ដាប់សក្ខីកម្មដើមបណ្ដឹង សំ សាក់ ........ ៤៤

◆ សេចក្ដីប្រកាសព័ត៌មានបទចោទប្រកាន់ ........ ៤៦

**វេទិកាពិភាក្សាសាធារណៈ**

◆ តើប្រជាជនចាមត្រូវបានសម្លាប់ដោយសារ ........ ៤៨

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ មានសំណាងព្រោះឆ្លើយថា «ខ្ញុំមិនចាំ» ........ ៥០

◆ រសាត់តាមខ្យល់ ........ ៥៣



បងប្អូនជនជាតិចាមអានទស្សនាវដ្ដីស្វែងរកការពិត

**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ០២៩១ពម.៩៩
ចុះថ្ងៃទី២ ខែសីហាឆ្នាំ១៩៩៩

រូបថតឯកសារៈមជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**ស្នេរលេខនេះ ៖** សូ ហ្វារីណា, ឡុង ដានី, ស៊ាន ចិន្តា, អេង កុកថាយ, ជិន ដួងចន្ទ្រាកែវលក្ខិនារីរតន៍, ឌី សុជាតា, មីន សាណាស់, ប៉ុក ប៉ុនសូម៉ាជ **អ្នកនិពន្ធនិងស្រាវជ្រាវ ៖** ទាវ សារៈមុន្និន្ទ និង ឆេង វើង **អ្នកបកប្រែ ៖** សុភ័ក្ត្រ ភាណា **និពន្ធនាយកទូទៅ ៖** ឆាំង យុ **ជំនួយការនិពន្ធនាយក ៖** សោម ប៊ុនថន **ក្រាហ្វិកកុំព្យូទ័រ ៖** សោម ប៊ុនថន **គ្រប់គ្រងការចែកផ្សាយ ៖** ឆេង វើង និង សន ល័ក្ខ Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org, www.truthcambodia.com

# អំពើប្រល័យពូជសាសន៍ខ្មែរក្រហមប្រឆាំងនឹងជនជាតិចាមត្រូវបានលើកមកកាត់ទោស

នាថ្ងៃច័ន្ទ ទី៧ ខែកញ្ញា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) បានបើកសវនាការដេញដោលលើភ័ស្តុតាងជាលើកដំបូងពីបទប្រល័យពូជសាសន៍លើមេដឹកនាំខ្មែរក្រហមទាក់ទងនឹងការប្រព្រឹត្តអំពើប្រល័យពូជសាសន៍លើជនជាតិចាមដែលជាក្រុមជនជាតិភាគតិចរស់នៅលើទឹកដីកម្ពុជាជាច្រើនទសវត្សរ៍មកហើយ ។ ជនជាតិចាមក្នុងប្រទេសកម្ពុជាចន្លោះពី ១០០.០០០ ទៅ៥០០.០០០ នាក់ ដែលប្រហែលនឹង៣៦ភាគរយនៃជនជាតិចាម ត្រូវបានសម្លាប់ក្នុងអំឡុងរបបខ្មែរក្រហម ។ ទោះបីជាយ៉ាងណា ពាក្យថា "ប្រល័យពូជសាសន៍" ត្រូវបានព្យួងបូងបង្អស់ដោយមនុស្សជាច្រើនក្នុងប្រទេសកម្ពុជា នៅក្នុងឆ្នាំ១៩៧៩ ។ ទន្ទឹមនឹងនោះ ក្នុងឆ្នាំជាមួយគ្នានេះដែរ ពាក្យ "ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍" ក៏ត្រូវបានបង្កើតឡើងដោយតុលាការបដិវត្តន៍ប្រជាជន ។ មានតែមេដឹកនាំជាន់ខ្ពស់ពីររូបប៉ុណ្ណោះ គឺ ប៉ុល ពត និង អៀង សារី ត្រូវបាននកាត់ទោសដោយកំបាំងមុខ ពីបទប្រល័យពូជសាសន៍ក្នុងឆ្នាំ១៩៧៩ ។ ទោះបីជាយ៉ាងណា សាលក្រមនោះ មិនត្រូវបានទទួលស្គាល់ដោយសហគមន៍អន្តរជាតិទេ ដោយសារតែវាមិនបានផ្តល់ឲ្យនូវសវនាការដ៏យុត្តិធម៌មួយសម្រាប់ជនជាប់ចោទ ។

ប្រជាជនចាមមូស្លីមរាប់រយនាក់ ត្រូវបានអញ្ជើញឲ្យមកចូលរួមស្តាប់សវនាការពីបទប្រល័យពូជសាសន៍នៅឯសាលសវនាការនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានាថ្ងៃនេះ ។ បទ



ជនជាតិចាម នៅភូមិកោះគរ ខេត្តកំពង់ចាម

ឧក្រិដ្ឋប្រល័យពូជសាសន៍ គឺជាបទឧក្រិដ្ឋដ៏ព្រៃផ្សៃមួយដែលបានបង្កើតជាសំណួរលើការប្រៀបធៀបពីកម្រិតនៃការឈឺចាប់ និងបាត់បង់ ការព្រាត់ប្រាស់ អារម្មណ៍ច្របូកច្របល់ រួមមាន ការអាក់អន់ចិត្ត និងមិនយល់ស្រប ឬការមិនសហការគ្នាក្នុងចំណោមជនរងគ្រោះ ។ ចាប់តាំងពីអតីតប្រទេសយូហ្គោស្លាវី រហូតដល់រ៉្វាន់ដា ដែលបទប្រល័យពូជសាសន៍ត្រូវបានចោទនៅចំពោះមុខតុលាការអន្តរជាតិ ហើយការស្អប់ខ្ពើមទៅលើជនជាតិមូស្លីមរ៉ូហ៊ីងយ៉ាដែលកើតមានបន្តបន្ទាប់នៅក្នុងប្រទេសភូមា បង្កឲ្យមានការរិះគន់ និងឧបសគ្គចម្បងៗចំពោះដំណើរការស្វែងរកយុត្តិធម៌ និងការពិត និងបង្កឲ្យមានដំណើរការប្រជាធិបតេយ្យ ។ បើយោងតាមនិយមន័យរបស់អង្គការសហប្រជាជាតិ ពាក្យ "ប្រល័យពូជសាសន៍" គឺជាសកម្មភាពដោយចេតនាក្នុងការសម្លាប់ទាំងស្រុង ឬដោយផ្នែកនៃសមាជិកក្រុមជាតិពន្ធុ ក្រុមសាសនា ពូជសាសន៍ ឬក្រុមនៃជាតិសាសន៍ណាមួយ ។ សកម្មភាពនេះរួមមាន ការប៉ុនប៉ងសម្លាប់លើក្រុមគោលដៅជាក់លាក់ណាមួយ ។ នេះមានន័យថា ជនរងគ្រោះដែលជាសមាជិកនៃក្រុមជាតិពន្ធុភាគតិចជាក់លាក់ណាមួយ ត្រូវទទួលបាននូវការចាប់អារម្មណ៍ និងទទួលស្គាល់ជាពិសេស នៅអំឡុងដំណើរការស្វែងរកយុត្តិធម៌ដែលផ្តល់ឲ្យអ្នកទាំងនេះនូវបទពិសោធន៍ដ៏ខុសប្លែកមួយ ។

ទោះបីជាយ៉ាងណា ករណីរបស់កម្ពុជាមានលក្ខណៈខុសប្លែកបន្តិចពីករណីខាងលើ ។ ទោះបីបទប្រល័យពូជសាសន៍ត្រូវបានលើកឡើងនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ចំពោះសកម្មភាពប៉ុនប៉ងរបស់មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ប្រឆាំងនឹងជនជាតិភាគតិចចាម និងវៀតណាម ភាពបែងចែកគ្នា ឬស្អប់ខ្ពើមមានកម្រិតទាបបំផុត ។ ក៏ប៉ុន្តែ ស្មារតីរួបរួមគឺមានលក្ខណៈប្រសើរបំផុត ។ ក្នុងប្រជាជនភាគច្រើន គឺប្រជាជនខ្មែរយល់ថា ខ្លួនក៏រងទុក្ខពីអំពើប្រល័យពូជសាសន៍ ។ ដូច្នេះ ក៏រួបរួមជាមួយនឹងអ្នករស់រានមានជីវិតដទៃទៀតដើម្បីស្វែងរកយុត្តិធម៌នៅក្នុងសាលាក្តីនេះដែរ ។

បទប្រល័យពូជសាសន៍ត្រូវបានលើកឡើងដោយ (អ.វ.ត.ក) តាំងពីឆ្នាំ២០១០ ក៏ប៉ុន្តែវាត្រូវបានពន្យារពេលយ៉ាងយូរ ។ ទោះបីជាជនជាតិវៀតណាមក៏ត្រូវបានដាក់បញ្ចូលទៅក្នុងបទចោទប្រកាន់នេះដែរ ។ ផ្នែកនៃបទប្រល័យពូជសាសន៍នេះនឹងផ្តោតលើតែជនជាតិចាមប៉ុណ្ណោះ ។ សវនាការដេញដោលនេះត្រូវបានជឿជាក់ថា នឹងដើរតួនាទីស្របតាមបទដ្ឋានអន្តរជាតិ ដោយសារតែតុលាការនេះបានធ្វើការធានាអះអាងលើដំណើរការច្បាប់ និងសវនាការដ៏យុត្តិធម៌សម្រាប់ជនរងគ្រោះ និងជនជាប់ចោទ ។

អំពើឃោរឃៅរបស់ខ្មែរក្រហម សមស្របទៅនឹងនិយមន័យរបស់អង្គការសហប្រជាជាតិលើពាក្យ "ប្រល័យពូជសាសន៍" ឬយ៉ាងណា កំពុងស្ថិតក្នុងការពិភាក្សាវែកញែក ។ បទសម្ភាសន៍ជាមួយនឹងជនជាតិចាម និងខ្មែរផ្តល់ច្រកចេញដល់បញ្ហានេះ ។

ម៉ាត់ ហ៊ីម មកពីខេត្តកំពត ជឿជាក់ថា ខ្មែរក្រហមប្រព្រឹត្តនូវអំពើប្រល័យពូជសាសន៍ចំពោះទាំងជនជាតិខ្មែរ និងចាម លើកលែងតែជនជាតិចាមមួយភាគតូចដែលកាន់ដំណែងដឹកនាំក្នុងជួររដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យប៉ុណ្ណោះ ។ ហ៊ីម បានឃើញជនជាតិខ្មែរសម្លាប់ជនជាតិចាម ឬជនជាតិខ្មែរសម្លាប់ជនជាតិខ្មែរផ្ទាល់នឹងភ្នែក ក៏ប៉ុន្តែគាត់មិនធ្លាប់ឃើញ ឬឮថាជនជាតិចាម


ជនជាតិចាមថ្វាយបង្គំនៅព្រះវិហារ

សម្លាប់ជនជាតិខ្មែរទេ ។ ខណៈពេលដែលគាត់ទទួលស្គាល់ពីការឈឺចាប់របស់ជនជាតិចាម និងខ្មែរ ដែលបានទទួលរងក្នុងរបបនោះ ហ៊ីម បានសួរថា តើហេតុអ្វីបានជាខ្មែរក្រហមប្រព្រឹត្តអំពើព្រៃផ្សៃចំពោះប្រជាជនគាត់ សូម្បីតែអ្នកទាំងនោះមិនបានបង្កបញ្ហាធំដុំអ្វីចំពោះរបបនោះ ឬទាមទារកាន់កាប់តំបន់ណាមួយ ។

ចំពោះ សាន សុខ ដែលជាជនជាតិខ្មែរមកពីខេត្តតាកែវវិញ គាត់គាំទ្រចំពោះបទចោទប្រល័យពូជសាសន៍នេះ ដោយគ្មានមន្ទិលសង្ស័យ ។ ចំពោះគាត់ពាក្យប្រល័យពូជសាសន៍ មានន័យថា ការកាប់សម្លាប់រង្គាលលើប្រជាជន និង «ចំពោះអ្នកទាំងឡាយណាដែលប្រឆាំងនឹងគោលនយោបាយរបស់ខ្មែរក្រហម» ។ ទាំងនេះ «អាចចាត់ទុកថា ជាអំពើហិង្សា ផ្តាច់ការ និងបដិវត្តន៍» ។ ជាទូទៅគាត់ទទួលស្គាល់ថា ទាំងជនជាតិខ្មែរ និងចាម សុទ្ធតែទទួលរងទុក្ខវេទនាដោយសារអំពើប្រល័យពូជសាសន៍ខ្មែរក្រហម ។

ទោះបីជាមិនមានការកំណត់ដ៏ជាក់លាក់ណាមួយក្តី តែមានការយល់ដឹងជាទូទៅយ៉ាងច្បាស់ថា នៅពេលដែល «អំពើប្រល័យពូជសាសន៍» កើតឡើង អ្នកទាំងអស់រងទុក្ខវេទនា ។

អ្វីដែលគួរឲ្យកត់សម្គាល់នោះគឺ ការប៉ុនប៉ងដែលផ្តោតលើជនជាតិចាម បានប្រព្រឹត្តឡើងនៅក្នុងភូមិភាគបូព៌ា និងនិរតី នៅមុនពេលដែលមានការតស៊ូប្រដាប់អាវុធកើតឡើងក្នុងភូមិចាមទៅទៀត ។ ទោះបីការប៉ុនប៉ងនេះមានទំហំតូចក្តី ។ ខ្មែរក្រហមបានហាមផ្តាច់នូវរាល់ទម្រង់នៃការប្រណិបតន៍សាសនាទាំងអស់របស់ជនជាតិចាម និងបានបញ្ជាឲ្យប្រមូលគម្ពីរគួរអានបំផ្លាញចោល ។ វិហារអ៊ីស្លាមជាងមួយរយដែលបាននបន្សល់ទុកពីទសវត្សរ៍ឆ្នាំ ១៩៧០ ត្រូវបានប្រើប្រាស់ខុសពីគោលដៅសាសនា ឬបំផ្លាញ ហើយមេដឹកនាំ និងគ្រូបង្រៀនសាសនាអ៊ីស្លាម ត្រូវបានឃុំខ្លួន និងបន្ទាប់មកក៏បាត់ខ្លួនក្នុងអំឡុងរបបនោះ ។ បន្ទាប់ពីជនជាតិចាមមួយចំនួនធ្វើការប្រឆាំង និងចាប់ផ្តើមការតស៊ូប្រដាប់អាវុធប្រឆាំងនឹងខ្មែរក្រហមនៅក្នុងតំបន់នានាក្នុងប្រទេសកម្ពុជា ដូចជា កោះផល និងភូមិស្វាយឃ្លាំង ក្នុងខេត្តកំពង់ចាម ស្ថានភាពបានប្រែក្លាយកាន់តែអាក្រក់ឡើង ។

អ្នកភូមិចាមជាច្រើនក្នុងភូមិភាគបូព៌ាត្រូវបានឲ្យតម្រង់ជួរ និងសួរថា «តើមិត្តជាជនជាតិខ្មែរ ឬចាម? ប្រសិនបើអ្នកទាំងនោះឆ្លើយថា ជាជនជាតិចាម គេនឹងសម្លាប់ចោល តែប្រសិនបើគេឆ្លើយថាជាជនជាតិខ្មែរ គេនឹងបង្ខំឲ្យបរិភោគសាច់ជ្រូក ។ ប្រសិនបើបដិសេធ ឬមិនពេញចិត្តចំពោះការបរិភោគនេ គេក៏សម្លាប់ចោលដែរ ។

រឿងរ៉ាវអស់ទាំងនេះអាចនឹងធ្វើឲ្យសវនាការកាលពីថ្ងៃច័ន្ទនេះ និងផ្នែកទាំងមូលនៃសវនាការដេញដោល គួរឲ្យចាប់អារម្មណ៍តាមរយៈការផ្តល់ឲ្យដោយរឿងរ៉ាវនៃការយល់ជារួមចេញពីទស្សនៈក្នុងស្រុក ។ ការយល់ដឹងអំពីប្រល័យពូជសាសន៍ចេញមកពីបទពិសោធន៍ផ្ទាល់អាចនឹងមិនសាកសមនឹងនិយមន័យរបស់អង្គការសហប្រជាជាតិចំពោះពាក្យ ប្រល័យពូជសាសន៍ ទេក៏ប៉ុន្តែអ្នកទាំងនេះដឹងថា ខ្លួនបានរងទុក្ខវេទនាដោយសារតែអំពើឃោរឃៅនេះ ។

ស្មារតីសាមគ្គីភាព និងភាពរួបរួមទទួលយកឈ្នះភាពបែកបាក់ ដោយសារតែអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមមានការយល់ឃើញថា ខ្មែរក្រហមបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មដទៃទៀត ប្រឆាំងនឹងប្រជាជនទាំងអស់ ហេតុនេះហើយ គេក៏ទទួលយកអត្តសញ្ញាណជាអ្នករួចរស់ជីវិត និងចូលរួមនៅក្នុងដំណើរការស្វែងរកការពិត និងយុត្តិធម៌នេះទាំងអស់គ្នា ។

ខណៈដែលវាមានការពិបាកក្នុងការសន្និដ្ឋានថា ការប្រព្រឹត្តលើជនជាតិចាម អាចចាត់ទុកថាជា «បទប្រល័យពូជសាសន៍» ដោយផ្អែកលើនិយមន័យរបស់វា «មានភស្តុតាងជាសក្តានុពលមួយចំនួនដែលអាចបង្កើតឡើងក្នុងសំណុំរឿងនេះ ។ ហេតុនេះខ្ញុំគិតថា វាជាពេលដ៏ល្អមួយសម្រាប់យើងក្នុងការយល់ដឹងអំពីសក្ខីភាព និងការតស៊ូមតិបច្ចុប្បន្ន ព្រមទាំងផ្នែកទាំងមូលនៃសវនាការដោយសក្ខីកម្មទាំងនេះ ថាតើអ្នកទាំងនោះអាចកំណត់នូវនិយមន័យបាន ឬនិយមន័យនោះគួរតែត្រូវគាំទ្រ ។ តាមរយៈការចូលរួម និងការតាមដានយ៉ាងជិតដល់ដំណើរការសវនាការ អ្នករស់រានមានជីវិតជនជាតិចាមអាចធ្វើការសម្រេចចិត្តអំពីដីកាពីបទប្រល័យពូជសាសន៍ នៅថ្ងៃខាងមុខ ថាតើវាយុត្តិធម៌ឬទេ ។ សកម្មភាពនៃការចងចាំ និងការនាំមកនូវយុត្តិធម៌ដល់ជនរងគ្រោះនេះ គឺជាជំហានឆ្ពោះទៅកាន់ការសម្រេចបាននូវការសះស្បើយ និងការរារាំងអំពើប្រល័យពូជសាសន៍ ការរំលោភ សិទ្ធិមនុស្សក្នុងទ្រង់ទ្រាយធំ កុំឲ្យកើតឡើងជាថ្មីម្តងទៀត ។ **សូ ហ្វារីណា**

# ចម្លើយសារភាពរបស់ ឱក ហ៊ិន ហៅ វ៉ាល់ ប្រធាន កងចល័តតំបន់៥ ភូមិភាគពាយ័ព្យ

*(ដកស្រង់ចេញពីឯកសារចម្លើយសារភាពលេខ ១៩៦ បបគ១)*

ឱក ហ៊ិន ហៅ វ៉ាល់ ភេទប្រុស អាយុ៣៩ឆ្នាំ កើតនៅភូមិស្រះព្រីង សង្កាត់បាធាយ ស្រុកជើងព្រៃ ខេត្តកំពង់ចាម ។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ វ៉ាល់ មានតួនាទីជាប្រធានកងចល័តតំបន់៥ ។ វ៉ាល់ ត្រូវបានអង្គការចាប់ខ្លួនពីបទធ្វើសកម្មភាព សេ.អ៊ី.អា ក្បត់ប្រឆាំងនឹងអង្គការ ។ ខាងក្រោមនេះជាសេចក្ដីសង្ខេប នៅក្នុងចម្លើយសារភាពរបស់ វ៉ាល់ ៖

ឆ្នាំ១៩៥៨ វ៉ាល់ ចូលរៀននៅកំពង់ចាម ហើយបានស្នាក់នៅជាមួយឪពុកមាម្នាក់ឈ្មោះ យឹម ភួង ។ ក្រោយមក នៅឆ្នាំ



កងកុមារលើកទំនប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

១៩៥៥ វ៉ាល់ បានត្រឡប់មករស់នៅជាមួយឪពុកម្តាយរបស់ខ្លួនវិញ និងបានបួសធ្វើជាសង្ឃនៅវត្តស្រះព្រីង ។ ប្រាំមួយខែក្រោយមក វ៉ាល់ បានបន្តទៅរៀននៅវត្តចាន់មូលី ស្ថិតនៅសង្កាត់ផ្សារ ស្រុកជើងព្រៃ ខេត្តកំពង់ចាម រយៈពេល២ឆ្នាំទៀត ។ បន្ទាប់មក វ៉ាល់ បានត្រឡប់មករៀននៅវត្តស្រះព្រីងវិញបានមួយឆ្នាំ ហើយបានសឹកនៅឆ្នាំ១៩៦១ ។ ក្រោយមកទៀត នៅឆ្នាំ១៩៦៤ វ៉ាល់ បានដាក់ពាក្យចូលធ្វើការជាកម្មករពុះខសនៅត្រែងត្រយឹង ខេត្តកំពង់ស្ពឺ ។ ពីរខែក្រោយមកឈ្មោះ តាំ បានអប់រំ វ៉ាល់ រួមជាមួយឈ្មោះ កយ, តុង និង សរ ដែលជាកម្មករពុះខសដូចគ្នាធ្វើជាគិញ ដើម្បីធ្វើការស៊ើបអង្កេតរកពួកខ្មែរក្រហម ។

ឆ្នាំ១៩៦៥ តាំ បាននាំ វ៉ាល់, កយ, តុង, និង សរ មកជួបតាយឹម ឌីត នៅភ្នំពេញដើម្បីបញ្ចូលជាសមាជិក សេ.អ៊ី.អា ។ ការបញ្ចូលសមាជិក សេ.អ៊ី.អា នេះ មានរៀបចំពិធីគោរពទង់ជាតិ និងមានធ្វើការសច្ចាប្រណិធានព្រមទាំងផឹកទឹកសម្បថទៀតផង ដែលមានឈ្មោះ តាំ ជាអ្នកនាំចូល និងតា យឹម ឌីត ជាអ្នកទទួលស្គាល់ ។ ក្រោយពីផឹកទឹកសម្បថហើយ តាយឹម ឌីត បានដាក់ភារកិច្ចឲ្យអនុវត្តគឺទី១ ម្នាក់ៗត្រូវចេះរក្សាការសម្ងាត់ឲ្យបានដាច់ខាតដើម្បីរកពួកខ្មែរក្រហមដែលពួនសម្ងំបង្កប់លាក់ខ្លួនក្នុងមន្ទីរ ក្រសួង រោងចក្រ និងលាក់ខ្លួន នៅក្នុងចំណោមប្រជាជននៅតាមភូមិឃុំនានា ។ ទី២ យកចិត្តទុកដាក់ឃោសនាអប់រំក្នុងចំណោមប្រជាជន កម្មករតាមក្រសួង មន្ទីរ ឬរោងចក្រ ធ្វើយ៉ាងណាកុំឲ្យពួកគាត់មានជំនឿជឿជាក់លើការដឹកនាំរបស់ពួកខ្មែរក្រហម និងទី៣ ត្រូវរាយការណ៍តាមខ្សែរយៈឲ្យបានទៀតទាត់ ។ ក្រោយមក តា យឹម ឌីត បានចាត់តាំង វ៉ាល់ ឲ្យទៅធ្វើជាកម្មករនៅក្រសួងសុរិយោដីកំពង់សោម និងបានណែនាំឲ្យធ្វើសកម្មភាពជាមួយឈ្មោះ ពក សាញ់ អតីតចាងហ្វាងក្រសួងសុរិយោដីកំពង់សោម, ឈ្មោះ ប៉ូ អតីតចាងហ្វាងក្រសួងរថភ្លើងកំពង់សោម, ឈ្មោះ សារី កម្មករកំពង់ផែកំពង់សោម ។

ឆ្នាំ១៩៦៦ វ៉ាល់ បានផ្លាស់មករកស៊ីនៅដំណាក់ស្ដៅឯ ខេត្តបាត់ដំបងវិញ ។ ពេលនោះ ពក សាញ់ បានណែនាំឲ្យទាក់ទងខ្សែរយៈមួយចំនួននៅដំណាក់ស្ដៅមានឈ្មោះ ខៀវ ស៊ិន, កែវ, ហឿង ដើម្បីងាយស្រួលទាក់ទងគ្នាពេលធ្វើសកម្មភាពរកពួកខ្មែរក្រហមនៅតាមកន្លែងនីមួយៗ នៅពេលទទួលបានព័ត៌មានហើយ ត្រូវរាយការណ៍ទៅឲ្យឈ្មោះ បាន នៅប៉ៃលិន ។

ឆ្នាំ១៩៦៨ វ៉ាល់ ត្រូវបានចាត់តាំងឲ្យទៅប៉ៃលិន ។ នៅប៉ៃលិន វ៉ាល់ បានជួប បាន និងបានរាយការណ៍ពីសកម្មភាពដែលខ្លួននិងបក្សពួកបានធ្វើកន្លងមក ។ បន្ទាប់មក បាន បានបើកការប្រជុំមួយដែលមានសមាជិកចូលរួមដូចជា វ៉ាល់, ស្រី បឹង, ជេន និង ជុន ។ ខ្លឹមសារនៃអង្គប្រជុំគឺ ស៊ើបអង្កេតរកខ្មែរក្រហមតាមភូមិនីមួយៗឲ្យបានច្បាស់លាស់ ឃោសនាបំផុសចលនាកម្មករជីកត្បូងកុំឲ្យមានជំនឿលើខ្មែរក្រហម និងខិតខំកសាងកម្លាំងឲ្យបានច្រើន ។ ពេលនោះ វ៉ាល់ កសាងកម្លាំង សេ.អ៊ី.អា បានបីនាក់ មានឈ្មោះ យោ កម្មករជីកត្បូងនៅប៉ៃលិន, ជុន កម្មករជីកត្បូងនៅប៉ៃលិន, និង ថេត កម្មករជីកត្បូងនៅប៉ៃលិន ។

ឆ្នាំ១៩៧០ ដោយពីមានការយល់ព្រមពី បាន វ៉ាល់ បានផ្លាស់ប្តូរទីកន្លែងទៅរកស៊ីជីកត្បូងនៅបឡាង សង្កាត់សំឡូត ស្រុកគិរីរតនៈខេត្តបាត់ដំបង ។ ក្រោយមកឈ្មោះ ពុំ បានមកឃោសនាបញ្ចុះបញ្ចូលឲ្យ វ៉ាល់ ចូលធ្វើបដិវត្តន៍ ។ ពេលនោះ វ៉ាល់ បានរាយការណ៍ប្រាប់ទៅ បាន បាន ក៏ចាត់តាំង វ៉ាល់ ឲ្យចូលបដិវត្តន៍តាមការអូសទាញរបស់ ពុំ ព្រោះងាយស្រួល និងបង្កប់ខ្លួនជ្រាតចូលទៅក្នុងជួរបដិវត្តន៍នៅភូមិភាគពាយ័ព្យ តំបន់៥ និងបានធ្វើការណែនាំឲ្យទាក់ទងជាមួយ តាណៃ ដែលជាកម្មាភិបាលបដិវត្តន៍ និងជាខ្សែរយៈរបស់ខ្លួន ។ រំលងបាន ៥ ខែក្រោយមក អង្គការបានចាត់តាំង វ៉ាល់ ឲ្យមកសៀមរាបដើម្បីកសាងមូលដ្ឋានបង្អែក ។ ដោយចៃដន្យពេលដែលធ្វើដំណើរមកដល់បុស្សធំ ព្រំប្រទល់តំបន់៥ វ៉ាល់ ក៏បានជួបតាណៃ ដែលកំពុងតែធ្វើដំណើរឡើងទៅជួបអង្គការថ្នាក់លើដែរ ។ ពេលនោះ តាណៃ បានណែនាំ វ៉ាល់ ឲ្យស្វែងរកឈ្មោះ តាំ យឿន ដែលជាខ្សែរយៈរបស់ខ្លួនពេលទៅដល់ទីនោះភ្លាម ។ នៅពេលមកដល់សៀមរាប វ៉ាល់ បានស្វែងរកឈ្មោះ តាំ យឿន តាមការណែនាំរបស់ តាណៃ ភ្លាមៗដែរ ប៉ុន្តែរកមិនឃើញ ឈ្មោះ តាំ យឿន នោះទេ ។

ចុងឆ្នាំ១៩៧១ វ៉ាល់ បានមកភូមិបត់ តំបន់១០៦ សៀមរាប ដើម្បីរៀនសូត្រផ្នែកបច្ចេកទេសយោធា ។ ពេលរៀនចប់ អង្គការបានចាត់តាំង វ៉ាល់ ឲ្យរៀបចំកង១០២ ហើយចុះមកតំបន់៥ ខេត្តសៀមរាប ។ មុនពេលចុះមកតំបន់៥ ខេត្តសៀមរាប តាណៃ

បានណែនាំឲ្យទាក់ទងខ្មែរយៈរបស់ខ្លួនមួយចំនួនទៀតមានឈ្មោះ តាំ ឃីន អតីតប្រធានកង១០២ (ស្លាប់), ហ៊ីង្ស អង្គការចាប់ខ្លួនហើយ, ប៉ៅង អង្គការចាប់ខ្លួនហើយ, ម៉ៅ អតីតមេព្រៃប្រចាំកង ១០២ តំបន់៥ (អង្គការចាប់ខ្លួនហើយ), ហេង អតីតអនុប្រធានពាណិជ្ជកម្មតំបន់៥ (អង្គការចាប់ខ្លួនហើយ), គុង យូន អតីតប្រធានពាណិជ្ជកម្មតំបន់៥ (ស្លាប់), ឈឿង អតីតសមាជិកពាណិជ្ជកម្មតំបន់៥ (ស្លាប់), អេង អតីតសមាជិកពាណិជ្ជកម្មតំបន់៥ (ស្លាប់), នៅ អតីតប្រធានកងធំតំបន់៣ (ស្លាប់), ឆៃ អតីតកម្មាភិបាលចលនាប្រជាជននៅភូមិបត់ សង្កាត់លេខ១១ (ស្លាប់), ហឿន អតីតកម្មាភិបាល ចលនាប្រជាជនសង្កាត់លេខ១១ (ស្លាប់), រុង (ស្លាប់) ប៊ុច អតីតកម្មាភិបាលចលនាប្រជាជនសង្កាត់លេខ១១ (ស្លាប់), រ៉ាន់ អតីតកម្មាភិបាលចលនាប្រជាជនសង្កាត់លេខ១១ (ស្លាប់), ឡូយ អតីតអនុកងធំ១០២ (ស្លាប់), ម៉ែន អតីតសមាជិកកងធំ១០២ (ស្លាប់), អ៊ុក សារឿន អតីតទាហានពាក់ស័ក្តិបីដើម្បីងាយស្រួលពេលធ្វើសកម្មភាព ។ ក្រោយពីទទួលបានការណែនាំពីតាណៃ ហើយ វ៉ាល់ បានទៅធ្វើការនៅតាមដងស្ទឹងក្រឡាញ់ ព្រំប្រទល់តំបន់៥ ខេត្តបាត់ដំបង ហើយកសាងកម្លាំងបានបីនាក់ទៀត ។ ក្រោយពេលបំពាក់បំប៉នគោលជំហរសតិអារម្មណ៍រួចរាល់ហើយ វ៉ាល់ បានចាត់តាំងអ្នកទាំងបីឲ្យបំពេញភារកិច្ចតាមផែនការ សេ.អ៊ី.អា ដែលបានអនុវត្តកន្លងមកជាហូរហែ ។

ឆ្នាំ១៩៧៣ តាណៃ បានបើកការប្រជុំមួយដែលមានអ្នកចូលរួម ៖ តាំង ឃីន, ឡូយ, ម៉ែន, ហឿង, រ៉ុន, គុង យូន, ហេង, ឈឿង ឈឿអេង, ប៊ុច និង រ៉ាន់ ។ ខ្លឹមសារនៃអង្គប្រជុំគឺលើកទិសដៅផែនការសម្រាប់អនុវត្តឆ្នាំ១៩៧៤-១៩៧៥ ដើម្បីរំដោះតំបន់៥ យកមកធ្វើជាមូលដ្ឋានបង្អែក និងឈានទៅរំដោះទឹកន្លែងផ្សេងៗទៀត ។ ពេលនោះ តាណៃ បានបន្តថា យើងអាចធ្វើកិច្ចការនេះបាន ទាល់តែយើងមានទុនគ្រប់គ្រាន់ដូចជា កម្លាំងកងទ័ព សម្ភារប្រើប្រាស់ និងស្បៀងអាហារជាដើម ។ តែទិសដៅនៃផែនការនេះ នៅមិនទាន់បានកំណត់ពីពេលវេលាឲ្យច្បាស់លាស់នៅឡើយទេ ពេលក្រោយយើងនឹងជួបពិភាក្សាគ្នាទៀត ដើម្បីបែងចែកភារកិច្ចឲ្យបានច្បាស់លាស់យកមកអនុវត្តរៀងៗខ្លួន ។

ឆ្នាំ១៩៧៤ ពេលបែកការណ៍ តាណៃនិងខ្មែរយៈសេ.អ៊ី.អា របស់គាត់ទាំងអស់ ត្រូវបានអង្គការចាប់ខ្លួន និងបោសសម្អាត ។ ក្រោយពីបោសសម្អាតខ្មែរយៈ តាណៃ អស់ហើយ វ៉ាល់ បានទៅជួប ហ៊ីង្ស នៅតំបន់១០៦ សៀមរាប ។ ពេលនោះ ហ៊ីង្ស ក៏បានណែនាំ វ៉ាល់ ឲ្យស្គាល់កម្លាំង សេ.អ៊ី.អា របស់ខ្លួនមួយចំនួនមានឈ្មោះ ហាត់, សន, ឆាត, រ៉ុត, យុយ, សំអាត និង ឡុង ។ បន្ទាប់មក វ៉ាល់ រួមជាមួយ សន, ម៉ោង និង ម៉ៅ បានធ្វើសកម្មភាពឃោសនាអប់រំប្រជាជនក្នុងភូមិនីមួយៗ កុំឲ្យពួកគាត់មានជំនឿលើការដឹកនាំរបស់អង្គការ ។ នៅសមរភូមិស្ពានធំ តំបន់៥ បក្ខពួករបស់ វ៉ាល់ បានធ្វើឲ្យបែកការណ៍សម្ងាត់បណ្ដាលឲ្យខកខាន លែងបានវាយខ្មាំង ហើយថែមទាំងបានដឹកនាំទ័ពដើរជាន់ស្រូវក្នុងស្រែធ្វើឲ្យខូចស្រូវអស់ជាច្រើន ។

ឆ្នាំ១៩៧៥ ឈ្មោះ មោង បានបញ្ជូន វ៉ាល់ ឲ្យមកនៅតាមដងស្ទឹងក្រឡាញ់ព្រំប្រទល់តំបន់១០៦ ។ មួយរយៈពេលដែលបានមករស់នៅទីនេះ វ៉ាល់ កសាងកម្លាំងបានបីនាក់មានឈ្មោះ គុង ឆាយ អតីតមេភូមិថ្មីទឹក ស្រុកព្រះនេត្រព្រះ (ស្លាប់), ភឿត (ស្លាប់), និង វឿន (ស្លាប់) ។ បន្ទាប់មកក្នុងអំឡុងចុងឆ្នាំ១៩៧៥ ហ៊ីង្ស បានដក វ៉ាល់ ឲ្យមកនៅក្នុងកងចល័តតំបន់៥វិញ ។ នៅក្នុងកងចល័ត វ៉ាល់ បានឆ្លៀតឱកាសកសាងកម្លាំង សេ.អ៊ី.អា បាន៦នាក់ថែមទៀតមានឈ្មោះ សែ ប្រជាជន១៧មេសា នៅស្រុកព្រះនេត្រព្រះ,


កងនារីស្ទូងស្រូវនៅវាលស្រែ

ខុន អតីតប្រជាជន១៧មេសា ក្រោយមកនៅសេដ្ឋកិច្ចដឹកជញ្ជូនពីស្វាយស៊ីសុផុនមកកងចល័ត ឃួន ទទួលធ្វើជាជំនួយស្ថិតិបញ្ជីយុវជនក្នុងកងចល័តតំបន់៥ , រ៉ូ អតីតប្រជាជន១៧មេសា ក្រោយមកបានទទួលការចាត់តាំងឲ្យធ្វើជាអ្នកគ្រប់គ្រងសេដ្ឋកិច្ចកងចល័តតំបន់៥ , ឈួង អតីតប្រជាជន១៧មេសា ជាអ្នកនេសាទកងចល័តតំបន់៥ , នង់ អតីតប្រជាជន១៧មេសា ទទួលខាងសេដ្ឋកិច្ចកងចល័តតំបន់៥ ។ ក្រោយមក ហឹង្ស បានមកជួប វ៉ាល់ នៅអូររន្ទះបាញ់ ។ ពេលនោះ វ៉ាល់ ក៏បានរាយការណ៍ពីសកម្មភាពរបស់ខ្លួនរួមជាមួយបក្ខពួកដែលបានអនុវត្តកន្លងមក ប្រាប់ទៅ ហឹង្ស ។ ក្រោយពីបានស្តាប់សេចក្តីរាយការណ៍ពី វ៉ាល់ ហើយ ហឹង្ស ក៏បានធ្វើការណែនាំបន្ថែមឲ្យ វ៉ាល់ ខិតខំយកចិត្តទុកដាក់ពង្រឹងកម្លាំងចាស់ និងកសាងកម្លាំងថ្មីថែមទៀត ដើម្បីរួមកម្លាំងគ្នាធ្វើសកម្មភាពប្រឆាំងនឹងអង្គការបដិវត្តន៍ ជាពិសេសធ្វើឲ្យប្រជាជនកាន់តែអស់ជំនឿទៅលើការដឹកនាំរបស់បក្ស ។ បន្ទាប់មក ហឹង្ស ក៏បានណែនាំកម្លាំងរបស់ខ្លួនមួយចំនួនទៀតឲ្យ វ៉ាល់ បានស្គាល់មានឈ្មោះ សា វ៉ាត អតីតប្រធានពាណិជ្ជកម្មតំបន់៥ (អង្គការចាប់ខ្លួនហើយ) ចយ អតីតបច្ចេកទេសជួសជុលគ្រឿងម៉ាស៊ីនតំបន់៥ (អង្គការចាប់ខ្លួនហើយ) វ៉ុម អតីតប្រធានម៉ាស៊ីនស្រូវតំបន់៥ , ឡេង អតីតប្រធានចម្ការកប្បាសតំបន់៥ , លាំ អតីតប្រធានកសិដ្ឋានរដ្ឋតំបន់៥ (អង្គការចាប់ខ្លួនហើយ) , ភី អតីតប្រធានវរៈ៥១៣ យោធាតំបន់៥ (អង្គការចាប់ខ្លួនហើយ) , ចាន់ អតីតខាងបច្ចេកទេសឡានតូចតំបន់៥ ។ ក្រោយមក នៅពេលដែលអង្គភាពរបស់ វ៉ាល់ ត្រូវទៅជួយដាំកប្បាសនៅកងវ៉ា វ៉ាល់ និងបក្ខពួកម្នាក់ទៀតឈ្មោះ ឡេង មិនបានធ្វើសកម្មភាពដាំកប្បាសឲ្យបានទាន់ដើមរដូវកាលទេ បែរជានាំគ្នាទៅកាប់ព្រៃទៅវិញ លុះដល់ចុងរដូវកាលទើបនាំគ្នាមកដាំកប្បាស ដែលបណ្តាលឲ្យខូចកប្បាសអស់ជាច្រើនហិកតាដោយសារដង្កូវស៊ី ។ ឆ្លៀតក្នុងឱកាសនោះដែរ វ៉ាល់ កសាងកម្លាំង សេ.អ៊ី.អា បានចំនួនបួននាក់ទៀតមានឈ្មោះ សាលឿន យុវជន១៧មេសា, ស្រេស យុវជន១៧មេសានៅភូមិដូនជ្រែង, ធ្វិ ប្រជាជន១៧មេសានៅភូមិដូនជ្រែង, វ៉ុត អតីតយុវជន១៧មេសានៅភូមិដូនជ្រែង ។ ក្រោយមក ហឹង្ស បានមកជួប វ៉ាល់ ម្តងទៀត ។ វ៉ាល់ ក៏បានរាយការណ៍ពីកម្លាំងដែលខ្លួនកសាងបានមួយរយៈកាលចុងក្រោយនេះប្រាប់ទៅ ហឹង្ស ។ ក្រោយពីបានស្តាប់សេចក្តីរាយការណ៍ហើយ ហឹង្ស ក៏បានណែនាំឲ្យ វ៉ាល់ បានស្គាល់កម្លាំងរបស់ខ្លួនមួយចំនួនទៀតមានឈ្មោះ ប៉ែន ទឿន ប្រធានស្ថិតិបញ្ជីប្រជាជនតំបន់៥ (អង្គការចាប់ខ្លួនហើយ) , ហេង ជំនួយការផាររនៅក្នុងតំបន់៥ , ផ៉ាល់ ជំនួយការផាររនៅក្នុងតំបន់៥ , ខូត ជំនួយការផាររនៅក្នុងតំបន់៥ , ជូ ជំនួយការពាណិជ្ជកម្មតំបន់៥ (អង្គការចាប់ខ្លួនហើយ) , ជួន ពេទ្យនៅតំបន់៥ (ស្លាប់) , សារី ជំនួយការការផាររក្នុងតំបន់៥ ។

ដើមឆ្នាំ១៩៧៧ នៅការដ្ឋានត្រពាំងថ្ម វ៉ាល់ កសាងកម្លាំង សេ.អ៊ី.អា បានចំនួន៥នាក់ទៀត មាន ឈ្មោះ ខូវ, ស៊ឹម, ម៉ន, ឈត់, និងត្រៀម ។ ចំពោះខ្លឹមសារដែល វ៉ាល់ លើកយកមកឃោសនាអប់រំបញ្ចុះបញ្ចូល អូសទាញអ្នកទាំង៥នោះគឺ ឲ្យមិត្តយើងមុនពេលរំដោះ ឬកំពុងតែរំដោះ សប្បាយចិត្តណាស់ មិត្តចង់ទៅណាមកណាក៏បាន គ្មានលំបាកគិតគូរអីវែងឆ្ងាយ ដើរស៊ីផឹក លេងសើចស្រី ស្រា ល្បែងស៊ីសង អាវ៉ាសែតាមចិត្ត ។ មកដល់សព្វថ្ងៃនេះ យើងលំបាកណាស់ អ្វីៗទាំងអស់សុទ្ធតែជារបស់សមូហភាពគួរឲ្យលំបាកចិត្តណាស់ ។ បើមិត្តតាមខ្ញុំ គ្មានលំបាកទេ ទិសដោះស្រាយរបស់យើង បើចង់សប្បាយ ត្រូវនាំគ្នាធ្វើសកម្មភាពប្រឆាំងនឹងបដិវត្តន៍ ហើយខំកសាងកម្លាំងយើងឲ្យបានច្រើន ដើម្បីបំផ្លាញបដិវត្តន៍ឲ្យរេចរឹល ធ្វើឲ្យប្រជាជនមើលឃើញជាក់ស្តែង គាត់នឹងអស់ជំនឿលើបដិវត្តន៍ ។

ក្រោយមក នៅការដ្ឋានត្រពាំងថ្ម វ៉ាល់ បានចាត់តាំងកម្លាំងកងចល័តឲ្យធ្វើទ្វារទឹកឃឹតៗ ដើម្បីកុំឲ្យការផាររនេះមានដំណើរការទាន់ផែនការរបស់ថ្នាក់លើ ។ សកម្មភាពនេះ វ៉ាល់ និងបក្ខពួកបានធ្វើជាបន្តបន្ទាប់ រហូតដល់ថ្ងៃអង្គការចាប់ខ្លួនតែម្តង ។

វ៉ាល់ ត្រូវបានអង្គការចាប់ខ្លួននៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ១៩៧៧ រួចបានបញ្ជូនមកមន្ទីរឃុំឃាំងស-២១ ភ្នំពេញ ។ ចម្លើយសារភាពរបស់ វ៉ាល់ ជាឯកសារសរសេរដោយដៃ មានចំនួន៤៥ទំព័រ ធ្វើនៅថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ១៩៧៨ ។ នៅចុងបញ្ចប់នៃចម្លើយសារភាពមានចុះហត្ថលេខា និងស្នាមផ្តិតមេដៃរបស់ វ៉ាល់ និងមានចុះហត្ថលេខារបស់អ្នកសួរចម្លើយ ព្រមទាំងមានចុះកាលបរិច្ឆេទនៃការធ្វើឯកសារគឺ ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ១៩៧៨ ។

**ឆេង ខ៉េង**

# ដំណឹងយុវជន-យុវនារីបដិវត្តន៍

*(ដកស្រង់ចេញពីទស្សនាវដ្តីយុវជន និងយុវនារីបដិវត្តន៍លេខ១០ ចេញផ្សាយខែតុលា-វិច្ឆិកា ឆ្នាំ១៩៧៧*

*ឯកសារលេខ D២១៨០៥)*

**១) លោកទស្សនៈ វណ្ណៈអធន របស់យុវជន យុវនារីកម្ពុជាយើង**

យុវជន យុវនារីយើងជំនាន់នេះ សុទ្ធតែបានរស់នៅក្នុងរបបសង្គមចាស់ ដ៏ខ្មៅងងឹត អយុត្តិធម៌របស់ចក្រពត្តិនិយម អាណានិគមនិយមចាស់ ថ្មីពួកអាក្បត់ជាតិគ្រប់ប្រភេទ និងពួកវណ្ណៈសក្តិភូមិនាយទុន ដែលមានអាយុជាង២០០០ឆ្នាំមកហើយ ។ ដូច្នេះ ពីមួយជំនាន់ទៅមួយជំនាន់ទៀត ពួកវាបានផ្សព្វផ្សាយឃោសនាអប់រំបំពុកបំពុលយុវជន យុវនារីយើង នូវលោកទស្សនៈមិនបដិវត្តន៍ច្រើនបែបច្រើនយ៉ាងណាស់ ។ ក្នុងនោះ មានលោកទស្សនៈបុគ្គលនិយម សេរីនិយម អាជ្ញានិយម យោធានិយម នាម៉ឺននិយម ការិយាល័យនិយម និងសីលធម៌ពុករលួយ ពាលាអាវ៉ៃសែ ស្រីស្រា ល្បែងស៊ីសង ភ្លើតភ្លើន ហ៊ឺហា អួតក្អេងក្អាង មុខមាត់ បុណ្យស័ក្តិ នាទីតំណែង លោភលន់ ប្រណែននិន្ទាឈ្នានីស ។ល ។ ទាំងអស់នេះជាគោលជំហរ និងជាលោកទស្សនៈរបស់វណ្ណៈជិះជាន់គ្រប់ប្រភេទ ដែលថោកទាបស្អុយអសោច ហើយប្រឆាំងពេញទី និងលោកទស្សនៈបដិវត្តន៍នៃវណ្ណៈអធនរបស់បក្សយើង ។

ចាប់តាំងពីឆ្នាំ១៩៦០ ពិសេសក្រោយថ្ងៃមហាជ័យជម្នះ ១៧ មេសា ១៩៧៥ រហូតមកដល់បច្ចុប្បន្ននេះ ដោយបានទទួល



យុវនារីកងចល័តនៅស្រុកស្អាង កំពុងបោកបែនស្រូវ ដើម្បីឲ្យបានរួចរាល់ឆាប់រហ័ស

នូវការឃោសនាអប់រំជាបន្តបន្ទាប់របស់បក្សកុម្មុយនីស្តកម្ពុជា យុវជន យុវនារីយើង មានការភ្ញាក់រឭកនយោបាយខ្ពស់ ។ យុវជន យុវនារីកូនចៅប្រជាជនក្រីក្រ មានភ្លើងកំហឹងជាតិ និងភ្លើងកំហឹងវណ្ណៈយ៉ាងពុះពោរសន្ធោសន្ធៅចំពោះចក្រពត្តិអាណានិគមនិយមពិសេសចក្រក្រពត្តិអាមេរិក ពួកអាក្បត់ជាតិ ពួកវណ្ណៈសក្តិភូមិនាយទុន គ្មានថ្ងៃណាសាបរលាប ឬរលត់ទៅវិញបានឡើយ ។ យុវជន យុវនារីយើងស្អប់ខ្ពើមជាទីបំផុត និងបានប្តេជ្ញាចិត្តប្រយុទ្ធវាយកម្ទេចនូវលោកទស្សនៈចាស់គំរិល ឱនថយរបស់ពួកវាឲ្យអស់រលីងពីក្នុងខ្លួន និងពីក្នុងសង្គមជាតិយើងទាំងមូល ។ នេះជាការតស៊ូវណ្ណៈដ៏ខ្លាំងក្លាជ្រាលជ្រៅ នៅលើសមរភូមិសតិអារម្មណ៍ ។ ដោយយុវជន យុវនារីយើងធ្វើបដិវត្តន៍សង្គមនិយមបានល្អ បានខ្លាំងក្លា ពិសេសពង្រឹង និងពង្រីកលោកទស្សនៈវណ្ណៈអធនរបស់បក្ស បានរឹងមាំដាច់ខាត គ្រប់ពេលវេលាយ៉ាងនេះហើយ បានជាកិច្ចការពារប្រទេស និងកសាងប្រទេសយើង ក្នុងដំណាក់កាលបដិវត្តន៍សង្គមនិយមនេះល្អប្រសើរ រឹងប៉ឹងខ្លាំងក្លា និងរីកចម្រើនយ៉ាងឆាប់រហ័សលើគ្រប់វិស័យ ។ ជាក់ស្តែងជីវភាពប្រជាជនយើងនៅទូទាំងប្រទេសដែលកាលពីសង្គមចាស់ ធ្លាប់តែក្រខ្សត់អត់ឃ្លាន និងឈឺចាប់ខ្លោចផ្សារកទីបំផុតគ្មាន ឥឡូវនេះ កាន់តែបានលើកស្ទួយឲ្យធូរធាជាលំដាប់ ហើយអត្តភាពបក្សកុម្មុយនីស្តកម្ពុជា អត្តភាពជាតិ ប្រជាជន និងចលនាបដិវត្តន៍យើង ក៏កាន់តែឡើងខ្ពស់ត្រដែតត្រដឹម លើឆាកអន្តរជាតិថែមទៀតដែរ ។

ជ័យជម្នះដ៏ត្រចេះត្រចង់នេះ ជាមោទកភាពបដិវត្តន៍ដ៏ខ្ពង់ខ្ពស់របស់យុវជនយុវនារីយើងចំពោះបក្សកុម្មុយនីស្តកម្ពុជាដ៏ត្រឹមត្រូវ និងភ្លឺស្វាង ។ ទោះបីឃើញសភាពការណ៍បដិវត្តន៍វិវត្តន៍ទៅមុខក្នុងសភាពល្អប្រសើរយ៉ាងនេះក៏ដោយ ក៏យុវជន យុវនារីបដិវត្តន៍យើង នៅតែយល់យ៉ាងច្បាស់ថា ភារកិច្ចបដិវត្តន៍របស់យើងមិនទាន់ចប់ត្រឹមនេះទេ ។ ភារកិច្ចបដិវត្តន៍របស់យើង នៅវែងឆ្ងាយ ធ្ងន់តទៅទៀត ។ ពោលគឺបក្សយើង ក៏ដូចជាប្រជាជនកម្ពុជាយើងទាំងមូលដែរ ចង់ប្រែក្លាយមាតុភូមិកម្ពុជាជាទីស្នេហា ពីប្រទេសកសិកម្មឱនថយ ឲ្យទៅជាប្រទេសកសិកម្មសម័យ ក្នុងរយៈពី១០ ទៅ១៥ឆ្នាំ ហើយកសាងឲ្យទៅជាប្រទេសឧស្សាហកម្មក្នុងរយៈពេលពី១៥ ទៅ២០ឆ្នាំ ។ តើអ្នកណាជាអ្នកសម្រេចកិត្តិយសដ៏ឧត្តុង្គឧត្តមនេះ? គ្មានអ្នកណាក្រៅពីមិត្តយុវជន យុវនារីបដិវត្តន៍យើងទេ ។ មិត្តយុវជន យុវនារីយើង កំពុងស្ថិតនៅក្នុងវ័យដែលមានកម្លាំងក្លៀវក្លា ស្វាហាប់ ជាកម្លាំងស្រួច ប្រយុទ្ធមោះមុត អង់អាចក្លាហាន ឈានមុខជាដរាប និងជាម្ចាស់ប្រទេស ម្ចាស់បដិវត្តន៍ ម្ចាស់លើវាសនាអនាគតខ្លួនពេញទី និងយ៉ាងពិតប្រាកដ ។ ភារកិច្ចបន្តធ្វើបដិវត្តន៍សង្គមនិយមនេះ មិនមែនជាភារកិច្ចធម្មតាទេ ។ គឺជាការធ្វើបដិវត្តន៍តឹងតែង ស៊ិតស្វាញ យូរអង្វែង លំបាកវេទនា តែប្រាកដជាឈ្នះ ។

នេះជាការពិតជាក់ស្តែង ។ ដូច្នេះ ភារកិច្ចបន្តធ្វើបដិវត្តន៍សង្គមនិយម និងការកសាងសង្គមនិយម តាមសន្ទុះលោតផ្លោះនេះ គឺជាការប្រយុទ្ធវណ្ណៈស្លាប់រស់ រវាងលោកទស្សនៈមិនបដិវត្តន៍របស់វណ្ណៈជិះជាន់ និងលោកទស្សនៈបដិវត្តន៍នៃវណ្ណៈអធនរបស់បក្ស ។ បើលោកទស្សនៈមិនបដិវត្តន៍នៃវណ្ណៈជិះជាន់វាឈ្នះហើយ នោះយុវជនយុវនារីយើងច្បាស់ជាអសកម្ម រាថយ ខ្លាចលំបាក មិនរីករាយជ្រះថ្លា ក្លៀវក្លា ស្វាហាប់នឹងការងារបដិវត្តន៍ទេ ។ សតិអារម្មណ៍មិនបដិវត្តន៍នេះ បើវាពួនសម្ងំនៅក្នុងខ្លួនយើងយូរ វាកាន់តែពង្រីងពង្រីកខ្លួនវាជាលំដាប់ ហើយវាស៊ីរូងគោលជំហរវណ្ណៈអធនរបស់បក្ស ឲ្យរលំដួលបានដោយងាយ ។ ទស្សនៈមិនបដិវត្តន៍នេះ មុនដំបូងវាមិនចេញជាសកម្មភាពជាក់ស្តែង ប្រឆាំងបដិវត្តន៍ក៏ពិតមែន តែយ៉ាងហោចណាស់ ក៏វារារាំងបន្ទុចបន្ទាក់ដល់ការងារបដិវត្តន៍ ដល់ការកសាងគោលជំហរ និងលោកទស្សនៈបដិវត្តន៍របស់បក្សមួយកម្រិតណាដែរ ។ ហើយដល់យូរៗទៅ វាប្រឆាំងបដិវត្តន៍ ប្រឆាំងបក្សដោយចេញមុខចំហតែម្តង ។ ឃើញគ្រោះមហន្តរាយនៃលោកទស្សនៈមិនបដិវត្តន៍យ៉ាងដូច្នេះហើយ បានជាយុវជន យុវនារីយើងតែងពាក់ព័ន្ធពិនិត្យមើលខ្លួនជាប្រចាំ ហើយបំពាក់បំប៉នពង្រីង និងពង្រីកលោកទស្សនៈវណ្ណៈអធនរបស់បក្ស ឲ្យរឹងមាំ ឲ្យណែនជាប់ជានិច្ច នៅគ្រប់កាលៈទេសៈទាំងអស់មិនដែលភ្លេចភ្លាំង ឬអត្តនោម័តិឡើយ ។

លោកទស្សនៈវណ្ណៈអធនរបស់បក្ស គឺជាលោកទស្សនៈបដិវត្តន៍របស់វណ្ណៈត្រូវគេជិះជាន់ ដែលស្អប់ខ្ពើមពួកវណ្ណៈជិះជាន់គេ ជាចក្រពត្តិអាណានិគមនិយម ពួកអាក្បត់ជាតិ ពួកវណ្ណៈសក្តិភូមិនាយទុន ហើយមានកំហឹងឆាបឆេះសន្ធោសន្ធៅនឹងពួកវាជាប់ជានិច្ច ។ លោកទស្សនៈវណ្ណៈអធនរបស់បក្ស គឺសកម្មប្រយុទ្ធបំផុត

ស្រឡាញ់ការងារពលកម្ម ស្រឡាញ់ការស្អាតស្អំ យុត្តិធម៌ សុភាព រាបសារបដិវត្តន៍ ស្មោះត្រង់នឹងបដិវត្តន៍ ហើយហ៊ានលះបង់អ្វីៗទាំងអស់ ទាំងកម្លាំងកាយ ទាំងកម្លាំងចិត្ត កម្លាំងប្រាជ្ញា រហូតដល់ហ៊ានលះបង់អាយុជីវិតរបស់ខ្លួនទៀតដើម្បីបក្សបដិវត្តន៍ ដើម្បីវណ្ណៈក្រីក្រដោយឥតលក្ខខណ្ឌ ។ វណ្ណៈអធនមិនរើសអើងការងារអ្វីឡើយ ឲ្យតែបក្ស បដិវត្តន៍ និងប្រជាជនប្រគល់ជូន គឺគេរីករាយបំពេញដោយអស់ពីចិត្តពីថ្លើម គ្មានទោមនស្សថ្នាំងថ្នាក់ ឬចង្អៀតចង្អល់អ្វីទាំងអស់ ។ ទោះការងារនោះ តូចក្តី ធំក្តី ធ្ងន់ក្តី ស្រាលក្តី គេឃើញក្តី មិនឃើញក្តី ឬលំបាកស្មុគស្មាញយ៉ាងណាក្តី វណ្ណៈអធនឈានមុខប្រយុទ្ធបំពេញយ៉ាងអង់អាចក្លាហាន ស៊ិតស៊ាញ ស្វាត់ស្វៀម អំណត់អត់ធន និងទទួលខុសត្រូវខ្ពស់ជាប់ជានិច្ចចំពោះបក្សបដិវត្តន៍ និងប្រជាជន ។ វណ្ណៈអធនគ្មានគិតគូរពីផលប្រយោជន៍សួនតួ គ្មានត្អូញត្អែរពីការនឿយហត់ផ្ទាល់ខ្លួន ឬគ្មានបង្កប់សតិអារម្មណ៍បុគ្គលនិយមមុខមាត់បុណ្យស័ក្តិ នាទីតំណែង វាយឫកវាយពារ គំរោះគំរើយ ធ្វើការបញ្ឆោះបទ្យោក រមាំងរម៉ោក ខ្ជីខ្ជាខ្ជះខ្ជាយ ឬក៏ថាគេថាឯងប្រាស់ឆ្អេះពាសវាយពាសកាលទេ ។ វណ្ណៈអធនរបស់បក្សលះបង់ខ្ពស់បំផុត ទាំងកម្មសិទ្ធិសម្ភារ កម្មសិទ្ធិសតិអារម្មណ៍ មនោសញ្ចេតនា កម្មសិទ្ធិអំណាច ដោយរីករាយជ្រះថ្លា គ្រប់ពេលវេលា ។ វណ្ណៈអធនសន្សំសំចៃ ឆ្នៃប្រឌិតកសាងរស់រវើក និងចម្រើនជឿនលឿន ទាំងខាងនយោបាយសតិអារម្មណ៍ចាត់តាំង និងបច្ចេកទេស វិទ្យាសាស្ត្រសព្វបែបយ៉ាង ។

ម្យ៉ាងទៀត លោកទស្សនៈវណ្ណៈអធនរបស់បក្ស ប្រឆាំងដាច់ខាត ចំពោះលោកទស្សនៈវណ្ណៈអនុធនគ្រប់ប្រភេទដែលធ្វើការអ្វីៗគិតតែត្រឹមឲ្យបានរួចខ្លួន ធ្វើល្មមៗ សម្ងំសុខមិនប្រយុទ្ធដាច់ខាតមិនស៊ុះស៊ាញ មិនឈានមុខ បណ្តែតតាមចលនា ឬក៏តោងកន្ទុយចលនា ។ ឬម្យ៉ាងទៀត ឲ្យតែធ្វើអ្វីបានបន្តិចបន្តួច ច្រើនតែភ្លើតភ្លើន មុខមាត់ស្នាដៃ ។ល ។ តាមពិសោធន៍កន្លងមក បើមានលោកទស្សនៈវណ្ណៈអនុធន ខ្លាំងអូសទាញឲ្យធ្វើខ្ញុំបម្រើវាបានជាទូទៅ ។ ព្រោះលោកទស្សនៈវណ្ណៈអនុធននេះ ពេលជួបការលំបាកច្រើនញោច រាថយ ឃ្លេងឃ្លោង ប៉េលប៉ាល ស្មុគស្មាញ អស់សង្ឃឹម អសកម្ម ចេញជាបច្ច័យអាក្រក់ ទប់ចលនាបដិវត្តន៍ ទោមនស្សនឹងបដិវត្តន៍ និងមានគ្រោះថ្នាក់ណាស់ចំពោះចលនាបដិវត្តន៍ ក៏ដូចចំពោះបុគ្គលខ្លួនដែរ ។ ដូច្នេះ យុវជន យុវនារីកម្ពុជាយើង គ្មានហេតុផលអ្វី ឲ្យលោកទស្សនៈវណ្ណៈអនុធន ក៏ដូចជាលោកទស្សនៈវណ្ណៈជិះជាន់គ្រប់ប្រភេទ វាប៉ិចពន្លក ឬបោះទីតាំងវានៅក្នុងខ្លួនយើងបានឡើយ ។

សរុបមក ឋានៈខ្លួនជាកងទ័ពស្រួចឈានមុខ មោះមុត អង់អាចក្លាហានរបស់បក្សកុម្មុយនីស្តកម្ពុជាដ៏រុងរឿង យុវជន យុវនារីកម្ពុជាយើង ប្តេជ្ញាសម្រួចគោលជំហរវណ្ណៈអធនរបស់បក្សឲ្យកាន់តែរឹងមាំ ស្រួចមុតថ្លាថែមទៀត កុំឲ្យលោកទស្សនៈវណ្ណៈជិះជាន់ផ្សេងៗវាជ្រៀតចូលក្នុងខ្លួនយើងបាន ដើម្បីធ្វើបដិវត្តន៍សង្គមនិយម កសាងសង្គមនិយម រហូតដល់កុម្មុយនីស្តនិយម ឲ្យបានជោគជ័យទាំងស្រុងដាច់ខាត គ្មានខ្មាំងសត្រូវណា ទោះជិតក្តីឆ្ងាយក្តី ឬជនក្បត់ជាតិណាម្នាក់ មកបំភ្លៃឆ្កឹះទំនាស់ វាយប្រហារបន្តុះបង្អាប់ ជាន់ឈ្លីសេរីរមាគ៌ាបក្សបានឡើយ ។ ដូច្នេះ ការកសាងពង្រឹងពង្រីក និងអនុវត្តឲ្យចេញជាសាច់ការជាក់ស្តែងនូវលោកទស្សនៈវណ្ណៈអធនរបស់បក្ស គឺជាភារកិច្ច កិត្តិយសរុងរឿង ឧត្តុង្គឧត្តម និងថ្លៃថ្លាបំផុតរបស់យុវជន យុវនារីយើងនៅជំនាន់នេះ ដែលជាអ្នកបន្តវេនបដិវត្តន៍ការពារប្រទេស និងកសាងប្រទេសឲ្យរឹតតែរឹងប៉ឹងខ្លាំងក្លា សម្បូរថ្កុំថ្កើងក្រហមឆ្អិនឆ្អៅ និងកាន់តែក្រហមឆ្អិនឆ្អៅឡើងជារៀងរហូត ។ យុវជន យុវនារីកម្ពុជាយើងទាំងនៅតាមសហជីព កម្មករ ទាំងនៅសហករណ៍កសិករ ទាំងនៅតាមអង្គភាពកងទ័ព និងនៅតាមក្រសួងមន្ទីរអង្គភាពនានា ប្តេជ្ញាវាយកម្ចាត់នូវកាកសំណល់ដែលជាឥទ្ធិពលនៃរបបសង្គមចាស់ ពុករលួយ ពាលាអាវ៉ាសែ ឲ្យអស់រលីងពីក្នុងខ្លួន និងពីក្នុងសង្គមជាតិយើងដាច់ខាត ហើយខិតខំពង្រឹង និងពង្រីកបំពាក់គោលជំហរវណ្ណៈអធនរបស់បក្ស ឲ្យដល់ខ្លួនជាប់ជានិច្ច ទាំងខាងលោកទស្សនៈ ទាំងខាងការប្រព្រឹត្តជាក់ស្តែង ដើម្បីកសាងខ្លួនឲ្យទៅជាជនបដិវត្តន៍ស្អាតស្អំក្រហមឆ្អិនឆ្អៅជារៀងរហូត ។

**២) យុវជន យុវនារីយើងនៅស្រុកប្រសូត្រ ប្តេជ្ញាវាយសម្រុកបង្កើនផលស្រូវ សម្រេចផែនការរបស់បក្ស និងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យយើង នៅឆ្នាំ៧៧នេះ ឲ្យបានជោគជ័យទាំងស្រុង និងឲ្យលើសពីផែនការនេះថែមទៀត**

ចាប់តាំងពីបក្សកុម្មុយនីស្តកម្ពុជា ដ៏រុងរឿងនៃយើង បានរំដោះមាតុភូមិកម្ពុជាបានទាំងស្រុង និងជាស្ថាពរមក យុវជន យុវនារីយើងនៅស្រុកប្រសូត្រ បានធ្វើពលិកម្មសព្វបែបយ៉ាង ដើម្បីបន្តធ្វើ

បដិវត្តន៍សង្គមនិយម ការពារប្រទេស និងកសាងសង្គមនិយមតទៅទៀតយ៉ាងអង់អាចក្លាហាន ។ នៅក្នុងមហាចលនាធ្វើបដិវត្តន៍សង្គមនិយម ការពារប្រទេស កសាងសង្គមនិយមដ៏ក្តៅគគុករបស់បក្សនេះ យុវជន យុវនារីយើង បានឈានមុខប្រយុទ្ធពុះពារជម្នះគ្រប់ឧបសគ្គ ប្រកបដោយវីរភាពខ្ពង់ខ្ពស់ណាស់ ។

ជាក់ស្តែង នៅក្នុងរយៈពេលជាងពីរឆ្នាំក្រោយរំដោះកន្លងទៅនេះ យុវជនយុវនារីស្រុកប្រសូត្រ បានរួមចំណែកយ៉ាងសំខាន់ក្នុងការជំរុញចលនាធ្វើបដិវត្តន៍សង្គមនិយម ការពារប្រទេស កសាងសង្គមនិយមយ៉ាងសកម្មក្លៀវក្លា ។ យុវជន យុវនារីយើង បានបន្តបោសសម្អាត និងវាយកម្ទេចទស្សនៈ គោលជំហររបស់ចក្រពត្តិអាណានិគមនិយមវណ្ណៈសក្តិភូមិ វណ្ណៈនាយទុន វណ្ណៈអធន និងវណ្ណៈដទៃផ្សេងទៀត ដែលប្រឆាំងនឹងទស្សនៈគោលជំហររបស់វណ្ណៈអធនរបស់បក្សពីក្នុងជួរយុវជន យុវនារីបដិវត្តន៍យើង និងពីក្នុងសង្គមជាតិយើងយ៉ាងខ្លាំងក្លា និងជ្រាលជ្រៅណាស់ ។ បងប្អូនបានខិតខំបំពាក់បំប៉នទស្សនៈ គោលជំហរបដិវត្តន៍គ្រប់ផ្នែក តាមមាគ៌ាវណ្ណៈអធនរបស់បក្ស ឲ្យដល់ខ្លួនកាន់តែរឹងប៉ឹងឡើងជាប់ជានិច្ច ។ ព្រមជាមួយនេះ យុវជន យុវនារីយើងនៅស្រុកប្រសូត្រ បានប្រកាន់តួនាទីជាកម្លាំងស្នូល ក្នុងការពង្រឹងពង្រីកសហករណ៍ ពង្រឹងពង្រីករបបសមូហភាព ការពារប្រទេស និងកសាងសង្គមនិយមទៀត ។ បងប្អូនបានចុះប្រឡូកយ៉ាងសកម្មនៅគ្រប់សមរភូមិទាំងអស់ ។ ជាពិសេសនៅសមរភូមិវាយផ្តាច់បីតោន និង៦តោននៅឆ្នាំ១៩៧៧នេះ ។ នៅឆ្នាំ១៩៧៦ កន្លងទៅនេះ យុវជន យុវនារីយើងនៅស្រុកប្រសូត្របានរួមជាមួយពុកម៉ែ កសិករ សហករណ៍យើងវាយសម្រុកសម្រេចផែនការរបស់បក្សបានដោយជោគជ័យ ។ ពិតមែនតែស្រុកបងប្អូនមានដីអន់ ខ្វះប្រភពទឹក ហើយស្ថិតនៅជាប់និងព្រំដែនក៏ដោយក៏ប៉ុន្តែដោយបងប្អូនមានគោលជំហរប្រយុទ្ធស្រួចស្រាវមោះមុតមានប្រព័ន្ធសំណង់ចាត់ចែងទឹកច្រើនស្អេកស្កះ បងប្អូនបានវាយដាច់ផែនការបីតោន មួយហិកតារបស់បក្សបានទាំងស្រុង ។ លទ្ធផលដ៏ត្រចេះត្រចង់នេះ ពិតជាបានមកពីបងប្អូនធ្វើបដិវត្តន៍សង្គមនិយមដាច់ខាត ការពារប្រទេសដាច់ខាត កសាងសង្គមនិយមដាច់ខាត



យុវជន និង យុវនារីផ្នែកដែក កំពុងចងដែក

តាមមាគ៌ាដ៏ត្រឹមត្រូវ និងភ្លឺស្វាងរបស់បក្សកុម្មុយនីស្តកម្ពុជាយើង ។

នៅឆ្នាំ១៩៧៧នេះ បក្សលើកផែនការវាយសម្រុកបង្កើនផលស្រូវឲ្យបាន៣តោន និង៦តោន ក្នុងមួយហិកតា ។ សំណូមពរ៣តោន និង៦តោនក្នុងមួយហិកតានេះ ដើម្បីលើកស្ទួយជីវភាពប្រជាជនយើង ការពារប្រទេស កសាងសង្គមនិយម និងដើម្បីជំរុញចលនាបដិវត្តន៍សង្គមនិយមនៅកម្ពុជាយើងឲ្យកាន់តែលឿនលោតផ្លោះថែមទៀត ។ដូច្នេះ យុវជនយុវនារីយើងនៅស្រុកប្រសូត្រក៏ដូចប្រជាជនយើងនៅទូទាំងប្រទេសដែរ បានឯកភាពគ្នាជាធ្លុងមួយប្តេជ្ញាវាយផ្តាច់ផែនការនេះឲ្យបានជោគជ័យដាច់ខាត ។ ដូច្នេះហើយ បានជានៅរដូវវស្សានេះ យុវជនយុវនារីយើង បានប្រយុទ្ធបំពេញភារកិច្ចស្នូលរបស់បងប្អូន នៅតាមមុខព្រួញនីមួយៗ ក្នុងសន្ទុះវាយសម្រុកក្តៅគគុកជាប់ជានិច្ច ។ នៅតាមមុខព្រួញវាយសម្រុកធ្វើស្រែដែលជាមុខព្រួញសំខាន់ជាងគេបំផុត យុវជនយុវនារីយើង បានធ្វើពលិកម្មខ្ពស់សព្វបែបយ៉ាងទាំងអស់ ។ រហូតមកដល់ចុងខែកញ្ញាកន្លងទៅនេះ បងប្អូនបានវាយសម្រុកភ្ជួររាស់ដកស្ទូងស្រូវវស្សាបានហើយរួចរាល់ជាទូទៅហើយ ។ ហើយសព្វថ្ងៃនេះ បងប្អូនកំពុងបន្តវាយសម្រុកធ្វើស្រូវកណ្តាលចុងឆ្នាំតទៅទៀតយ៉ាងមមាញឹក ។ នៅតាមមុខព្រួញទឹក មុខព្រួញដី នៅតាមមុខព្រួញផ្សំថ្នាំកសិកម្ម ។ យុវជន យុវនារីយើងនៅស្រុកប្រសូត្រ បានប្រយុទ្ធពុះពារប្រមូលសន្សំទឹក និងផ្សំជីរ ផ្សំថ្នាំកម្ចាត់សត្វល្អិតយ៉ាងខ្លាំងក្លា ។ បងប្អូនសប្បាយរីករាយជ្រះថ្លានឹងភារកិច្ចរបស់បងប្អូនណាស់ ។ នេះគឺមកពីបងប្អូនយល់ជ្រួតជ្រាបយ៉ាងច្បាស់លាស់ថា ភារកិច្ចដែលបក្សឬសមូហភាពប្រគល់ឲ្យ មានទំហំធំធេង និងមានខ្លឹមសារជ្រាលជ្រៅឧត្តុង្គឧត្តមណាស់ ។ពិតមែនតែបងប្អូនមិនបានកាន់អាវុធជាកាំភ្លើងតូច កាំភ្លើងធំ ។ល ។ យាមល្បាតការពារទឹកដី ការពាររដ្ឋអំណាចបដិវត្តន៍ ការពារបក្សតែតាមរយៈដែលបងប្អូនបំពេញភារកិច្ចស្នូលរបស់ខ្លួន ដោយសេចក្តីប្តេជ្ញាចិត្តខ្ពស់បំផុត សម្រេចផែនការឆ្នាំ១៩៧៧នេះ របស់បក្សឲ្យបានជោគជ័យទាំងស្រុង និងឲ្យលើសផែនការនេះទៀត ក៏ជាការរួមចំណែកការពារប្រទេស រួមបោសសម្អាតនិងកម្ទេចខ្មាំងសត្រូវគ្រប់ប្រភេទពីសង្គមជាតិយើងទាំងមូល និងទប់ទល់ខ្មាំងខាងក្រៅ ដែលប៉ុនប៉ងលេបទឹកដីយើង យ៉ាងស័ក្តិសិទ្ធិដែរ ហើយតាមរយៈនៃភារកិច្ចនេះទៀត បងប្អូនបានលត់ដំពង្រឹងពង្រីកគោលជំហរសតិអារម្មណ៍បដិវត្តន៍ តាមមាគ៌ាវណ្ណៈអធនរបស់បក្ស បានកាន់តែរឹងប៉ឹងឡើង និង រួមជំរុញការកសាងសង្គមនិយមនៅកម្ពុជាប្រជាធិបតេយ្យយើង បានកាន់តែលឿនលោតផ្លោះថែមទៀត ។ ដូច្នេះហើយ បានជាសព្វថ្ងៃនេះ យុវជនយុវនារីយើងនៅស្រុកប្រសូត្រកំពុងលើកជ្រោងគ្រវីទង់វាយសម្រុកបំពេញភារកិច្ចប្រកបដោយគោលជំហរតស៊ូវណ្ណៈជ្រាលជ្រៅ និងមានៈព្យាយាម ស៊ិតស៊ាញ អង់អាចក្លាហានបំផុត ។ ទោះបីជាការងារបង្កបង្កើនផលឆ្នាំនេះ មមាញឹកយ៉ាងណាក៏ដោយ ទាមទារឲ្យបងប្អូនលះបង់ខ្ពស់យ៉ាងណាក៏ដោយ ក៏បងប្អូនបានយកចិត្តទុកដាក់ប្រយុទ្ធបំពេញដោយអស់ពីចិត្តពីថ្លើម និងរីករាយជ្រះថ្លាគ្រប់ពេលវេលា ។ ជាលទ្ធផលជាក់ស្តែង នៅវាលថ្នល់ទទឹង គគីរសោមប្រកម្ទេស វាលគ្រញូង ចំបក់ពាម វាលត្រពាំងចក និងនៅឃុំស្វាយរំពារ ។ល ។ ស្រូវវស្សារបស់បងប្អូនកំពុងដុះលូតលាស់ល្អជាងឆ្នាំទៅមិញច្រើនណាស់ ។ ពិសេសសព្វថ្ងៃនេះ បងប្អូនកំពុងវាយសម្រុកដកស្ទូងស្រូវកណ្តាលចុងឆ្នាំ នៅលើការដ្ឋានជាច្រើនកន្លែង ដូចជានៅជិតអាងទឹកត្រពាំងព្រីងបាក់ កំពង់ចំបក់ តាមដងព្រែកជីកពពែត ទំនប់បឹងធ្លក ។ល ។ យ៉ាងសស្រោកសស្រាំ ។ នៅតាមការដ្ឋានទាំងនេះ យុវជនយុវនារីយើងនៅស្រុកប្រសូត្រ បានយកអស់កម្លាំងកាយកម្លាំងចិត្ត និងសមត្ថភាពរបស់ខ្លួន វាយសម្រុកជំរុញចលនាធ្វើស្រូវកណ្តាលចុងឆ្នាំនេះ យ៉ាងផុសផុល និងដោយស្មារតីទទួលខុសត្រូវខ្ពស់បំផុត ។

ការបំពេញភារកិច្ច ដោយភ្ញាក់រឭកវណ្ណៈខ្ពស់ និងដោយសន្សំសំចៃពេលវេលាបានណែនល្អនេះ បានជំរុញការងាររបស់បងប្អូននៅតាមការដ្ឋាននីមួយៗ បានកាន់តែលឿន និងបានកែប្រែសេចក្តីប្តេជ្ញាចិត្តសម្រេចផែនការបង្កើនផលស្រូវ នៅឆ្នាំ៧៧នេះរបស់បក្ស និងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យយើង ទៅជាការពិតជាក់ស្តែងជាបណ្តើរៗហើយ ។ មហាចលនាវាយសម្រុកបំពេញភារកិច្ចយ៉ាងខ្លាំងក្លានេះ វាចេញមកពីប្រភពមិនចេះរីងស្ងួតនៃគោលជំហរសមូហភាពវណ្ណៈអធនរបស់បក្ស និងស្មារតីស្នេហាជាតិស្នេហាបក្ស និងស្នេហាប្រជាជនយ៉ាងជ្រាលជ្រៅរបស់បងប្អូនដែលជ្រួតជ្រាបទៅជាទស្សនៈគោលជំហរធ្វើជាម្ចាស់ប្រទេស ម្ចាស់បដិវត្តន៍ និងម្ចាស់លើភោគផលសព្វបែបយ៉ាង ។ ម្យ៉ាងទៀត ដោយ

បងប្អូនមានគោលជំហររាបសាបដិវត្តន៍ជានិច្ច ហើយជាពិសេស នៅឆ្នាំ១៩៧៦កន្លងទៅនេះ ស្រុកបងប្អូនជាស្រុកគំរូ បានទទួលទង់ក្រហមកិត្តិយសពីបក្ស ក៏រឹតតែធ្វើឲ្យបងប្អូនមានកម្លាំងចិត្ត កម្លាំងកាយ មោះមុតខ្លាំងក្លាថែមទៀត ក្នុងការឈានមុខសម្រេចផែនការគ្រប់ផ្នែកដែលបក្ស និងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យយើងបានលើកឡើង ។

យុវជន យុវនារីយើងនៅស្រុកប្រសូត្រ ប្ដេជ្ញាពង្រឹង និងពង្រីកគោលជំហរអធនរបស់បក្ស ឲ្យក្រហមឆ្អិនឆ្អៅជានិច្ច និងជារៀងរហូត ដើម្បីវាយផ្ដាច់ផែនការ៣គោន និង៦គោន របស់បក្ស និងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យយើង នៅឆ្នាំ១៩៧៧នេះ ឲ្យបានជោគជ័យទាំងស្រុងដាច់ខាត និងឲ្យលើសពីផែនការនេះថែមទៀត រួមជំរុញចលនាបដិវត្តន៍សង្គមនិយម ការពារប្រទេស និងកសាងសង្គមនិយមនៅកម្ពុជាប្រជាធិតេយ្យយើងឲ្យកាន់តែរឹងប៉ឹងខ្លាំងក្លា និងរីកចម្រើនលូតលាស់លើគ្រប់វិស័យដោយល្បឿនលោតផ្លោះ ។

**៣) កងទ័ពបដិវត្តន៍កម្ពុជាប្រជាធិបតេយ្យយើង ប្ដេជ្ញាបន្តពង្រឹងពង្រីកវីរភាពបដិវត្តន៍ ដ៏ខ្ពង់ខ្ពស់តទៅទៀតដើម្បីការពារ និងកសាងកម្ពុជាប្រជាធិបតេយ្យឲ្យកាន់តែល្អប្រសើរថែមទៀត**

ក្នុងចលនាតស៊ូបដិវត្តន៍គ្រប់កាលសម័យ ពិសេសក្នុងសម័យសង្គ្រាមបដិវត្តន៍ ដ៏សន្ធោសន្ធៅជាង៥ឆ្នាំ ប្រឆាំងទល់នឹងសង្គ្រាមឈ្លានពានដ៏កំណាចឃោរឃៅរបស់ចក្រពត្តិអាមេរិក បរិវារ និងបក្ខពួកក្បត់ជាតិគ្រប់ប្រភេទ កងទ័ពបដិវត្តន៍កម្ពុជាយើង ក្រោមការដឹកនាំដ៏ត្រឹមត្រូវ និងភ្លឺស្វាងនៃបក្សកុម្មុនីស្តកម្ពុជា បានប្រយុទ្ធតទល់នឹងខ្មាំងសត្រូវយ៉ាងអង់អាចក្លាហាន ដើរតួជាគំរូឈានមុខ លះបង់គ្រប់បែបយ៉ាងកម្រិតខ្ពស់បំផុត ដើម្បីបុព្វហេតុរំដោះជាតិ រំដោះប្រជាជន និងរំដោះវណ្ណៈក្រីក្រ ។ ក្នុងចលនាតស៊ូបដិវត្តន៍ដ៏សន្ធោសន្ធៅនេះ យុវជន យុវនារី និងកម្មាភិបាលកងទ័ពបដិវត្តន៍ កម្ពុជាយើង បានឆ្លងកាត់នូវការប្រយុទ្ធដ៏តឹងតែង ស៊ិតស្វាញ ជូរចត់ បត់បែន ស្មុគស្មាញ លំបាកវេទនាច្រើនឥតគណនា ។ តាមរយៈនេះ បងប្អូនក៏បានលត់ដំ និងកសាងពង្រឹងពង្រីកគោលជំហរបដិវត្តន៍គ្រប់ផ្នែករបស់ខ្លួនបានយ៉ាងរឹងប៉ឹង ។

កងទ័ពបដិវត្តន៍កម្ពុជាយើង សុទ្ធសឹងជាកូនចៅប្រជាជនកម្មករ កសិករក្រីក្រទាំងអស់ ។ កាលនៅក្នុងសម័យសង្គ្រាមបដិវត្តន៍ដ៏សន្ធោសន្ធៅកន្លងទៅនេះ កងទ័ពបដិវត្តន៍យើងមានតែបាតដៃទទេ តែបងប្អូនហ៊ានវាយតទល់នឹងចក្រពត្តិអាមេរិក ព្រមទាំងបរិវារគ្រប់ប្រភេទ ដែលមានអាវុធ សម្ភារបែប និងទំនើបៗ ។ ក្រោមការដឹកនាំដ៏ត្រឹមត្រូវ និងភ្លឺស្វាងរបស់កប្បកុម្មុយនីស្តកម្ពុជាយើង កងទ័ពបដិវត្តន៍កម្ពុជា បានអនុវត្តមាគ៌ាសង្គ្រាមឈ្លបវាយរំខានខ្មាំងវាយរំលោះកម្លាំងជារៀងរាល់ថ្ងៃ ធ្វើឲ្យខ្មាំងរីកវរវិលក្បុង និងកាន់តែចុះថមថយខ្សោះខ្សោយកម្លាំងទៅជាលំដាប់ ។ បងប្អូនវាយខ្មាំងដោយប្រើអាវុធបូរាណ មានធ្នូ ស្នា ខ្នារ ចម្រូង អន្ទងចម្រូង ។ល ។ ជាសំខាន់ និងអនុវត្តមាគ៌ាដណ្ដើមអាវុធពីខ្មាំង វាយខ្មាំងវិញយ៉ាងរស់រវើក ។ កងទ័ពបដិវត្តន៍កម្ពុជាយើងបានសាមគ្គីគ្នាយ៉ាងជិតស្និទ្ធជាមួយប្រជាជនកម្ពុជា និងយុវជន យុវនារីកម្ពុជាយើងទូទាំងប្រទេស នៅក្រោមទង់បក្សកុម្មុយនីស្តកម្ពុជាដ៏រុងរឿង វាយសម្រុកបុកទម្លាយខ្មាំងយ៉ាងអង់អាចខ្លាហាន និងខ្លាំងក្លាគ្រប់ពេលវេលា ក្នុងឋានៈជាអ្នកវាយសម្រុកជាប់ជានិច្ច ។

ទន្ទឹមនឹងនេះ កងទ័ពបដិវត្តន៍កម្ពុជាយើង ក៏បានពង្រឹងពង្រីកខ្លួន បានរឹងប៉ឹងចម្រើនធំធាត់យ៉ាងឆាប់រហ័ស ទាំងខាងបរិមាណ និងទាំងខាងគុណភាពក្លាយទៅជាកងទ័ពបដិវត្តន៍មួយដែលខ្លាំងក្លាបំផុតមានសមត្ថភាពដ៏ខ្ពង់ខ្ពស់ អាចវាយកម្ទេចខ្មាំងបានជាបន្តបន្ទាប់រហូតដល់វាយបណ្ដេញ និងវាយកម្ទេចចក្រពត្តិអាមេរិក បរិវារ និងបក្ខពួកក្បត់ជាតិគ្រប់ប្រភេទ ឲ្យវិនាសខ្ទេចខ្ទីអស់ពីលើទឹកដីកម្ពុជា រំដោះប្រទេសជាតិ រំដោះប្រជាជន និងរំដោះវណ្ណៈក្រីក្របានទាំងស្រុង និងជាស្ថាពរ នៅថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ។

នេះជាអត្តភាព និងជាកិត្យានុភាពដ៏រុងរឿង និងជាវីរភាពបដិវត្តន៍ដ៏ខ្ពង់ខ្ពស់អស្ចារ្យរបស់កងទ័ពបដិវត្តន៍កម្ពុជា ក្រោមការដឹកនាំដ៏ត្រឹមត្រូវ និងភ្លឺស្វាងមហាអស្ចារ្យនៃបក្សកុម្មុយនីស្តកម្ពុជាយើង ។ ក្រោយពីបានរំដោះប្រទេសជាតិមាតុភូមិកម្ពុជា ជាទីស្នេហាបានទាំងស្រុង និងជាស្ថាពរមក យុវជន យុវនារី និងកម្មាភិបាលនៃកងទ័ពបដិវត្តន៍កម្ពុជាយើង បានទទួលភារកិច្ចថ្មីធំពីរពីបក្សកុម្មុយនីស្តកម្ពុជា គឺការពារ និងកសាងប្រទេសឲ្យរឹងប៉ឹងខ្លាំងក្លា និងរីកចម្រើនយ៉ាងឆាប់រហ័សជាបន្តទៀត ។

បន្ទាប់ពីបានទទួលភារកិច្ចថ្មីដ៏ថ្លៃថ្លាខ្ពង់ខ្ពស់ឧត្ដមនេះមក

យុវជន យុវនារី និងកម្មាភិបាលនៃកងទ័ពបដិវត្តន៍កម្ពុជាយើង បានវាយសម្រុកការពារ និងកសាងប្រទេសយ៉ាងសកម្មខ្លាំងក្លាប្រកបដោយវីរភាពបដិវត្តន៍យ៉ាងខ្ពង់ខ្ពស់ត្រដែតត្រដឹម ។ អស់រយៈពេលជាងពីរឆ្នាំកន្លងមកនេះ យុវជន យុវនារី និងកម្មាភិបាលនៃកងទ័ពបដិវត្តន៍កម្ពុជាយើង ដែលនៅប្រចាំការពារព្រំដែនគោក ព្រំដែនទឹក និងនៅលើផ្ទៃប្រទេសទាំងមូល បានលើកកំពស់ស្មារតី ប្រុងប្រយ័ត្នបដិវត្តន៍ខ្ពស់ជាប់ជានិច្ច ។ បងប្អូនមានគោលជំហរទទួលខុសត្រូវខ្ពស់ចំពោះជាតិ និងប្រជាជន ប្រយុទ្ធលះបង់ និងធ្វើពលិកម្មគ្រប់បែបយ៉ាង ជាបន្តបន្ទាប់គ្មានរុញរាឡើយ ទោះបីជាស្ថិតនៅក្នុងកាលៈទេសៈណាក៏ដោយ ។ បងប្អូនតែងដើរ និងបើកបរកាណូត កប៉ាល់ល្បាតយាមកាម តាមដានសកម្មភាពខ្មាំង និងវាយកម្ទេចនូវរាល់សកម្មភាពរបស់ខ្មាំង ទាំងយប់ទាំងថ្ងៃ ទាំងប្រាំងទាំងវស្សា ដោយប្រយុទ្ធពុះពារជម្នះគ្រប់ឧបសគ្គតូច ធំ និងជំនឺតម្កាត់សព្វបែបយ៉ាង អត់ធ្មត់លត់ដំទ្រាំទ្រលំបាកវេទនាគ្រប់ពេលវេលា ដើម្បីការពារទឹកដី ព្រៃព្រឹក្សា ការពារសម្បត្តិធម្មជាតិនៅក្នុងលំហសមុទ្រ កោះ ការពារបក្ស ការពារប្រជាជន ការពារ រដ្ឋអំណាចបដិវត្តន៍កម្មករ កសិករ និងការពារជ័យផលបដិវត្តន៍ ឲ្យនៅគង់វង្សស្ថិតស្ថេរជារៀងរហូត ។ បងប្អូនមើលឃើញច្បាស់លាស់នូវគោលបំណងជាយុទ្ធសាស្ត្រដ៏ខ្មៅខ្ព្រិជ្ជរបស់មារសត្រូវគ្រប់ប្រភេទ ទោះជិតក្តី ឆ្ងាយក្តី ដែលប៉ុនប៉ងវាយកម្ទេចបដិវត្តន៍កម្ពុជា និងប៉ុនប៉ងរំលោភឈ្លានពាន លេបទឹកដីប្រទេសកម្ពុជាយើង ឬដាក់នឹមអាណានិគមនិយមថ្មីរបស់វាលើកម្ពុជា ដើម្បីយកកម្ពុជាធ្វើជាឈ្នាន់ ឈ្លានពានអាស៊ីអាគ្នេយ៍ទាំងមូល ។

អាស្រ័យដោយយុវជន យុវនារី កម្មាភិបាលនៃកងទ័ពបដិវត្តន៍កម្ពុជាយើង មានទស្សនៈគោលជំហរត្រឹមត្រូវច្បាស់លាស់ដូច្នេះហើយ បានជាមកដល់ថ្ងៃនេះ បងប្អូនបានវាយសម្រុកការពារប្រទេសទទួលបានលទ្ធផលបានយ៉ាងល្អប្រសើរ ។ ជាក់ស្តែង បងប្អូនបានការពារប្រទេសជាតិ ការពារបក្សកុម្មុយនីស្តកម្ពុជា ជាទីគោរពស្នេហា ការពារប្រជាជន ការពាររដ្ឋអំណាចបដិវត្តន៍ កម្មករ កសិករ និងការពារជ័យផលបដិវត្តន៍ បានគង់វង្សស្ថិតស្ថេរ និងល្អប្រសើរជាអតិបរមា ។

ទន្ទឹមនិងភារកិច្ចស្នូលការពារប្រទេសដ៏មមាញឹកនេះ បងប្អូននៅបានឆ្លៀតបង្កបង្កើនផលឧបត្ថម្ភខ្លួន បានដោយឯករាជ្យម្ចាស់ការមួយកម្រិតសំខាន់ និងរួមវាយសម្រុកបង្កើនផលស្រូវជាមួយប្រជាជនកសិករសហករណ៍យើង យ៉ាងសកម្មខ្លាំងក្លាជាប់ជានិច្ចទៀត ។ ពិសេស បងប្អូនបានចូលរួមប្រយុទ្ធធ្វើប្រព័ន្ធសំណង់ចាត់ចែងទឹកបានជាច្រើន ដូចជា ធ្វើអាងទឹកនៅស្ទឹងកោះស្លា អាងទឹកនៅភ្នំបាសាក់ អាងទឹក១៧មករា អាងទឹកត្រពាំងថ្ម អាងទឹកបឹងក្រចាប់ អាងទឹក១៧មេសា ទំនប់ និងព្រែកជីកនៅស្ទឹងជីនិត ទំនប់នៅស្ទឹងពោធិ៍សាត់ ទំនប់នៅស្ទឹងសង្កែ ទំនប់នៅស្ទឹងព្រែកត្នោត ទំនប់នៅស្ទឹងសៀមរាប និងស្ទឹងក្រឡាញ់ជាដើម ។ នៅរដូវវស្សានេះ បងប្អូនបានរួមប្រយុទ្ធរាស់ សាបព្រោះ ដក ស្ទូង ធ្វើស្រូវវស្សា ធ្វើស្រូវកណ្តាលចុងឆ្នាំ និងរួមដាំដំណាំស្បៀងរួមផ្សំ និងបន្លែបង្កាគ្រប់មុខ យ៉ាងសស្រោកសស្រាំខ្លាំងក្លា ។ ក្រៅពីនេះ បងប្អូននៅបានរួមប្រយុទ្ធសង់ស្ពាន សង់មន្ទីរពេទ្យ សាលារៀន រួមសង់ផ្ទះសម្បែងជូនប្រជាជនកសិករសហករណ៍ ។ល ។ យ៉ាងផុសផុលទៀត ។ ដោយឡែកតែឧបករណ៍កសិកម្មផ្សេងៗ ដូចជានង្គ័ល រនាស់ រទេះ រហាត់ទឹក ស្នាច ម៉ាស៊ីនបូមទឹក ម៉ាស៊ីនបោកស្រូវ និងម៉ាស៊ីនដាំពោត សណ្តែក កប្បាសជាដើម បងប្អូនឆ្លៀតប្រយុទ្ធ ធ្វើបានជាច្រើនដោយឯករាជ្យម្ចាស់ការ ហើយបានផ្តល់ជូនសហករណ៍យើងជាបន្តបន្ទាប់ ។

ឆ្លងតាមការបំពេញភារកិច្ចបដិវត្តន៍ដ៏ក្តៅគគុកនេះ យុវជន យុវនារី និងកម្មាភិបាលនៃកងទ័ពបដិវត្តន៍កម្ពុជាយើង បានរួមចំណែកលើកស្ទួយជីវភាពប្រជាជនយើង ឲ្យកាន់តែសម្បូរធូរធារជាលំដាប់ និងក៏បានរួមចំណែកកសាងប្រទេសឲ្យរីកចម្រើនលោតផ្លោះយ៉ាងឆាប់រហ័សទៀត ។

ដោយក្តាប់ជាប់នូវធាតុពិតរបស់ខ្លួន ដែលជាកងទ័ពបដិវត្តន៍កូនចៅប្រជាជនកម្មករ កសិករ សមូហភាព និងជាឧបករណ៍ផ្តាច់ការដ៏បរិសុទ្ធរបស់បក្ស យុវជន យុវនារី និងកម្មាភិបាលនៃកងទ័ពបដិវត្តន៍យើង ប្តេជ្ញាថែរក្សា និងពង្រឹងពង្រីកធាតុប្រយុទ្ធ ឈានមុខមោះមុតស្រួចស្រាវ អង់អាច ក្លាហាន និងត្រៀមធ្វើពលិកម្មសព្វបែបយ៉ាងជូនបក្ស វណ្ណៈ និងជូនប្រជាជន ដោយឥតលក្ខខណ្ឌតទៅទៀត និងប្តេជ្ញាលើកកម្ពស់ស្មារតីប្រុងប្រយ័ត្នបដិវត្តន៍ខ្ពស់ជាប់ជានិច្ច ដើម្បីការពារប្រទេស និងរួមកសាងប្រទេសឲ្យកាន់តែរឹងប៉ឹងខ្លាំងក្លា និងរីកចម្រើនថ្កុំថ្កើងរុងរឿង ដោយល្បឿនមហាលោតផ្លោះ មហាអស្ចារ្យ ។

**ឆេង ខេង**

# ការិយាល័យព័ត៌មានសាធារណៈ

“ការិយាល័យព័ត៌មានសាធារណៈ” របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងអំពីប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ និងព្រឹត្តិការណ៍វិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម ។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត ។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ ។ ប្រភេទឯកសារទីពីរគឺជាបទសម្ភាសដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសជាមួយជនរងគ្រោះនិងអតីតកម្មាភិបាលខ្មែរក្រហម ។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម ។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារប្រភេទទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត ។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចអាននឹងស្រាវជ្រាវឯកសារទាំងនេះបាន ។ ឯកសារខ្លះទៀតរួមមាន ៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្ថនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥ ។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ជា ផល្លា តាមរយៈ ទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែល *truthphalla.c@dccam.org* ។





















# ថ្នាក់រៀននៅទួលស្លែង

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតថ្នាក់រៀនសាធារណៈមួយនៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ។ ថ្នាក់រៀននេះត្រូវបានបង្កើតឡើងក្នុងខែវិច្ឆិកា ឆ្នាំ២០១១ ដោយមានកិច្ចសហការរវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។ សារមន្ទីរទួលស្លែងគឺជាអតីតសាលារៀនដ៏ទំនើបមួយដែលបានសង់ឡើងជាលើកដំបូងនៅក្នុងឆ្នាំ១៩៦២ ។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខ្មែរក្រហមបានប្រែក្លាយសាលារៀននេះទៅជាគុកដ៏សម្ងាត់បំផុតមួយក្នុងចំណោមគុកចំនួន១៩៦ទូទាំងប្រទេស ។ អ្នកទោសភាគច្រើនដែលត្រូវបញ្ជូនទៅទួលស្លែង គឺជាកម្មាភិបាលខ្មែរក្រហមដែលត្រូវបានចោទប្រកាន់ពីបទប្រព្រឹត្តអំពើក្បត់ជាតិដូចជា ការសហការជាមួយរដ្ឋាភិបាលបរទេស ឬធ្វើជាអ្នកស៊ើបការណ៍ឲ្យសេ.អ៊ី.អា ឬ កា.ហ្សេ.បេ ជាដើម ។



ចាប់តាំងពីការប្រែក្លាយពីកន្លែងរៀនសូត្រមួយទៅជាកន្លែងដ៏គួរឲ្យរន្ធត់ និងមហន្តរាយមួយ ទួលស្លែងមិនដែលទទួលបានមុខងាររបស់ខ្លួនដូចកាលពីដើមវិញឡើយ ។ ទោះបីជាយ៉ាងនេះក្តី នៅពេលអនាគតដើម្បីទាមទារមកវិញនូវកេរដំណែលអប់រំដែលមានលក្ខណៈវិជ្ជមានរបស់ទួលស្លែង និងដើម្បីបន្ថែមសមាសភាពអប់រំមួយទៅក្នុងសារមន្ទីរនេះ ថ្នាក់រៀននេះ ត្រូវបានបង្កើតឡើងដើម្បីផ្តល់ការបង្រៀន និងការពិភាក្សាដោយឥតគិតថ្លៃអំពីប្រវត្តិសាស្ត្ររបបខ្មែរក្រហម និងប្រធានបទដែលជាប់ទាក់ទង ដូចជា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ថ្នាក់រៀននេះ ក៏ជាវេទិកាសាធារណៈមួយសម្រាប់ឲ្យអ្នកមកទស្សនា និងអ្នកដែលនៅរស់រានមានជីវិតចែករំលែកព័ត៌មានគ្នាក្នុងការថែរក្សារយៈកាលនៃប្រវត្តិសាស្ត្រកម្ពុជាដ៏មានសារសំខាន់មួយទុកឲ្យអ្នកជំនាន់ក្រោយបានរៀនសូត្រ ។

បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ដែលមានសញ្ញាបត្រមកពីបរទេស និងបានទទួលវិញ្ញាបនបត្រពីក្រសួងអប់រំ យុវជន និងកីឡា ផ្នែកការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩) ព្រមទាំងមានការចូលរួមពីអ្នកជំនាញជាតិ និងអន្តរជាតិដែលមានជំនាញលើប្រវត្តិសាស្ត្រប្រទេសកម្ពុជា និងអ្នកដែលនៅរស់រានមានជីវិតពីមន្ទីរស-២១ នឹងបង្រៀននៅថ្នាក់រៀននេះ ។ ព័ត៌មានទាក់ទងនឹងថ្នាក់រៀននេះ សូមទាក់ទង ម៉ែន ពិចិត្រ តាមរយៈទូរសព្ទលេខៈ ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែលៈ *truthmpechet@dccam.org* ។

**◆ ទីកន្លែង ៖ អគារ "ក" ជាន់លើ ◆ ពេលវេលា ៖ ច័ន្ទ ២-៣រសៀល, ពុធ ៩-១០ព្រឹក, សុក្រ ២-៣រសៀល**

# គេហទំព័រទស្សនាវដ្តីស្វែងរកការពិតជាភាសាខ្មែរ

## www.truthcambodia.com

ទស្សនាវដ្តីស្វែងរកការពិត បង្កើតគេហទំព័រ www.truthcambodia.com ក្នុងគោលបំណងផ្សព្វផ្សាយ និងអប់រំឲ្យបានកាន់តែទូលំទូលាយអំពីរបបកម្ពុជាប្រជាធិបតេយ្យ (របបខ្មែរក្រហម) ដើម្បីសម្រេចឲ្យបាននូវការចងចាំ យុត្តិធម៌ និងការផ្សះផ្សាជាតិក្នុងសង្គមដែលទទួលរងនូវការបែកបាក់ និង សង្គ្រាមជាច្រើនទសវត្សរ៍ ។

គេហរទំព័រ www.truthcambodia.com ក៏នឹងដើរតួនាទីដ៏សំខាន់ផងដែរក្នុងការចែករំលែកព័ត៌មានអំពីដំណើរការសវនាការកាត់ទោសមេដឹកនាំខ្មែរក្រហមជាមួយសាធារណជន និងជួយសាលាក្តីក្នុងការរំលែកព័ត៌មានទាក់ទងប្រវត្តិសាស្ត្រខ្មែរក្រហម នៅខណៈពេលអត្ថបទមួយចំនួននៅក្នុងគេហទំព័រនេះត្រូវបានយកទៅប្រើប្រាស់ជាភ័ស្តុតាងដើម្បីដាក់បន្ទុកមេដឹកនាំខ្មែរក្រហម ។

គេហទំព័រ www.truthcambodia.com បែងចែកជា៥ផ្នែកសំខាន់ គឺ១) ផ្នែកឯកសារ ២) ផ្នែកប្រវត្តិសាស្ត្រ ៣) ផ្នែកច្បាប់ ៤) ផ្នែកវេទិកាពិភាក្សាជាសាធារណៈ និង ៥) ផ្នែកស្រាវជ្រាវស្វែងរកក្រុមគ្រួសារដែលបានស្លាប់ ឬបាត់ខ្លួនក្នុងរបបខ្មែរក្រហម ។ នៅក្នុងគេទំព័រ www.truthcambodia.com ក៏មានផ្ទុកនូវឯកសារជាវីដេអូ, សំឡេង, រូបថត និងឯកសារដើមរបស់ខ្មែរក្រហមដែរ ។

អត្ថបទសម្រាប់ផ្នែកទី១) នឹងរៀបរៀងឡើង ដោយស្មេរមជ្ឈមណ្ឌលឯកសារកម្ពុជា ដោយផ្អែកលើឯកសារដើមទាំងស្រុង ។ សរសេរឲ្យស្រួលអាន គឺការសង្ខេបចេញពីឯកសារដើមមកជាអត្ថបទ ។ គោលបំណងនៃផ្នែកនេះ គឺចង់ជម្រាបជូនសាធារណជនថាតើមានឯកសារអ្វីខ្លះដែលតម្កល់នៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ផ្នែកទី២) គឺជាអត្ថបទវិភាគលើប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហម ។ អត្ថបទផ្នែកនេះគឺជាអត្ថបទចូលរួមមកពីអ្នកជំនាញជាន់ខ្ពស់លើប្រវត្តិសាស្ត្រខ្មែរក្រហម ហើយមានទិសដៅសម្រិតសម្រាំងប្រវត្តិសាស្ត្រនេះឲ្យមានភាពកាន់តែសុក្រឹតទៅឡើងទៀត ។ ផ្នែកទី៣) គឺជាផ្នែកច្បាប់ដែលធ្វើការវិភាគដោយមេធាវី ឬចៅក្រម ឬអ្នកជំនាញការច្បាប់អន្តរជាតិ ។ ការវិភាគនេះនឹងជួយជាគំនិតលើផ្នែកច្បាប់ថា តើឧក្រិដ្ឋកម្មអ្វីខ្លះដែលបានកើតឡើងក្នុងរបបខ្មែរក្រហម ហើយថា តើឧក្រិដ្ឋកម្មនីមួយៗត្រូវតែដោះស្រាយតាមនីតិវិធីបែបណា ដើម្បីរកឲ្យបាននូវយុត្តិធម៌ពិតប្រាកដមួយដល់ជនរងគ្រោះ ។ ផ្នែកទី៤) គឺជាវេទិកាពិភាក្សា និង ផ្តល់គំនិតនានាលើបញ្ហាខ្មែរក្រហម ។ អត្ថបទទីនេះ គឺជាវិភាគទានចូលរួមពីសំណាក់អង្គការក្រៅរដ្ឋាភិបាលនានា សមាជិករាជរដ្ឋាភិបាល គ្រូ សិស្ស និស្សិត ជាដើម ។ល ។ ផ្នែកទី៥) គឺជាទំព័រស្រាវជ្រាវស្វែងរកក្រុមគ្រួសារដែលបានស្លាប់ ឬ បាត់ខ្លួនក្នុងរបបខ្មែរក្រហម ឬការសាកសួររកព័ត៌មានអំពីមិត្តភក្តិ សាច់សារលោហិតដែលបានស្លាប់ដោយសាររបបខ្មែរក្រហម ។ ជាទំព័រឈឺចាប់ អាណោចអាធ័ម ប៉ុន្តែក៏ជាទំព័ររម្ងាប់ការមន្ទិលសង្ស័យដើម្បីសេចក្តីសុខក្នុងខ្លួនជាអមតៈ ។

សរុបសេចក្តីទៅផ្នែកទាំង៥ ខាងលើនៃគេហទំព័រ www.truthcambodia.com នឹងបើកចំហជូនដល់ការចូលរួមស្វែងរកការពិតពីសាធារណជនគ្រប់ស្រទាប់ ជាន់ថ្នាក់ ដោយមិនប្រកាន់ពណ៌សម្បុរ ភេទ អាយុ ឬនិន្នាការនយោបាយណាមួយឡើយ ។ គេហទំព័រ www.truthcambodia.com នឹងបម្រើដល់សាធារណជន និងដើម្បីជួយជ្រោមជ្រែងស្វែងរកយុត្តិធម៌ជូនដល់ប្រជាជនកម្ពុជាគ្រប់រូប ។ គ្រប់លិខិត ឬអត្ថបទ ដែលផ្ញើមកកាន់គេហទំព័រ www.truthcambodia.com សូមដាក់ឈ្មោះ មុខងារ អាសយដ្ឋាន និងលេខទូរសព្ទសម្រាប់ធ្វើសេចក្តីបញ្ជាក់លើខ្លឹមសារនៃលិខិត ឬអត្ថបទមុនការចេញផ្សាយ ។

គេហទំព័រ www.truthcambodia.com សូមរក្សាសិទ្ធិក្នុងការកែលម្អពាក្យពេចន៍នៃលិខិតទាំងឡាយ ក្នុងន័យថែរក្សានូវអត្ថន័យដើមទាំងស្រុង ។ ប៉ុន្តែ គេទំព័រ www.truthcambodia.com នឹងចុះផ្សាយទាំងស្រុងចំពោះអត្ថបទចូលរួមទាំងឡាយ ។

# កំណត់ហេតុ អង្គប្រជុំគណៈអចិន្ត្រៃយ៍

## យប់ថ្ងៃទី២២ កុម្ភៈ ឆ្នាំ១៩៧៦

សមាសភាពៈ ស.ម លេខា, ស.ម អនុលេខា, ស.ម វ៉ាន់, ស.ម វន, ស.ម ខៀវ, ស.ម ធុច, ស.ម ហែម, ស.ម ឌឿន ។

**របៀបវារៈ** បញ្ហាការពារប្រទេស ។

### ១) សេចក្តីរាយការណ៍អំពីសភាពការណ៍ខាងការពារប្រទេស

**១) សភាពការណ៍នៅព្រំដែនខាងកើត ៖**

ស.ម ខៀវ រាយការណ៍ថា ចាប់តាំងពីដើមខែកុម្ភៈមក វៀតណាមធ្វើសកម្មភាពយ៉ាងខ្លាំងនៅតាមព្រំដែនយើងខាងកើត ពិសេសនៅរតនគិរី ស្វាយរៀង និងក្អមសំណរ ។ វាចូលបោះនៅក្នុងដីយើងចម្ងាយពី២០០ម៉ែត្រ ឬ៣គីឡូម៉ែត្រពីព្រំដែន ។ កន្លែងខ្លះវាលួចបន្ទិតបង្គោលព្រំដែន យើងដេញវា វាទៅវិញ កន្លែងខ្លះវាមកបោះនៅក្នុងបន្ទាយចាស់របស់ អានលំ មានកម្លាំងទ័ពពីមួយអនុសេនាតូច ទៅមួយអនុសេនាធំ ។ វាថាមដ្ឋិមវាឲ្យមក ។

នៅខាងព្រំដែនលាវ ក៏មានជនជាតិលាវមកនៅត្រើយអូរខាងដីយើង ។ ឯនៅតាមព្រំដែនសមុទ្រគ្មានហេតុភេទអ្វីសំខាន់ទេ ។

**២) បញ្ហាជំនួយចិនទាក់ទងខាងអាកាស និងជើងទឹក ៖**

ស.ម ខៀវ បានលើកបញ្ហាជំនួយចិនទាក់ទងខាងអាកាស និងខាងជើងទឹក ហើយស្នើមតិអង្គការ ពិសេសបញ្ហាៈ

- យុទ្ធជនរៀនបើកយន្តហោះ
- យុទ្ធជនរៀនធ្វើរំសេវ
- សំណង់រោងចក្រធ្វើអាវុធ - មូលដ្ឋាននាវា - ព្រលានយន្តហោះ - កប៉ាល់ចម្បាំង
- អ្នកបច្ចេកទេស៦៨នាក់មកដល់ថ្មី ។

**៣) បញ្ហាដឹកគ្រប់រំសេវ ៖**

វៀតណាមស្នើកន្លែងថ្មីសម្រាប់ប្រគល់សម្ភារដែលសល់ពីឆ្នាំ១៩៧៥ ឲ្យយើង២កន្លែង ៖ ឬស្វាយរៀង ឬមេមត់ ។ គេថាដឹកតាមកប៉ាល់ចូលមិនចុះ ។

**៤) ពេទ្យយោធា ៖**

ស.ម ខៀវ ស្នើអង្គការបង្កើតមន្ទីរពេទ្យមួយសម្រាប់យោធាយើង ហើយស្នើយកមន្ទីរពេទ្យព្រះកេតុមាលាចាស់ ។

### ២) មតិណែនាំរបស់អង្គការ

**១) បញ្ហានៅព្រំដែន ៖**

សកម្មភាពរំកិលព្រំដែនរបស់វៀតណាម មានទិដ្ឋភាព២យ៉ាង ៖

◆ ទី១ វាចង់ប្រេះប្រចឹបដីយើង ជាទិសរួមរបស់វា ។

◆ ទី២ ឬមួយខាងលើវាណែនាំ ឬមួយជាសកម្មភាពផ្ទាល់របស់ប្រជាជន ដែលទៅពីកម្ពុជាយើង និងរបស់ពួកកងល្បាតវានៅតាមព្រំដែន ។

**វិធានការរបស់យើង ៖**

**ក)** ជាគោលការណ៍ យើងចរចាជាមួយវាក៏ចរចា តែសំខាន់ត្រូវរៀបចំកម្លាំងការពារ ។ បើអនុវត្តតែនយោបាយទទេ ហើយគ្មានវិធានការយោធាដល់វាមកច្រើនស្មុគស្មាញ យើងពិបាកដោះស្រាយ ។ ត្រូវពិនិត្យកន្លែងខ្លាំង កន្លែងខ្សោយ ហើយប្រុងប្រៀបប្រយុទ្ធ វាមកជ្រុលដាក់វាភ្លាម ។

**ខ)** ត្រូវសហការឲ្យជាប់ជាមួយមូលដ្ឋាន ។ ដូច្នេះ យោធារាយការណ៍ទៅមូលដ្ឋាន ហើយរាយកាណ៍មកសេនាធិការជាព័ត៌មាន ។ ខាងមណ្ឌលគិរី មានស.ម ឡាំង ខាងរតនគិរី មានស.ម យ៉ា ទទួលខុសត្រូវ ។ សំខាន់គឺកងទ័ព និងមូលដ្ឋានឯកភាពគ្នា និងជាប់គ្នា ។

**គ)** ត្រូវប្រុងប្រយ័ត្នការពារកម្លាំងយើង កុំឲ្យវាកម្ទេចកម្លាំងយើងបាន ហើយយកចិត្តទុកដាក់លើបញ្ហារក្សាការណ៍សម្ងាត់ កុំឲ្យបង ប្អូនភ្ញាក់ផ្អើល ។ ទាក់ទងគ្នាក៏ត្រូវស្ងាត់ ។

**២) បញ្ហាជំនួយចិនទាក់ទងខាងអាកាស និងខាងជើងទឹក ៖**

**ក)** រៀនបើកយន្តហោះ តថ្ងៃគេត្រឹម២ឆ្នាំ ។ ស្នើឲ្យរៀបចំចុះ ហើយឲ្យមានគណៈកម្មាធិការបក្សមួយយ៉ាងរឹង សម្រាប់ដឹកនាំអ្នកដែលត្រូវទៅរៀននោះផង ។

**ខ)** រៀនធ្វើរំសេវ ៈ ត្រូវរៀនគ្រប់យ៉ាង ។ ឯអ្នករៀន មកពីសេនាធិការខ្លះ មកពីមូលដ្ឋានខ្លះ ពិសេសពីភាគធំៗ ។

**គ)** រោងចក្រអាវុធ ៈ ក៏ត្រូវត្រៀមទាំងអស់ ។

**ឃ)** កប៉ាល់ការពារ ៈ យករាមធ្វើជាកន្លែងជួសជុលកប៉ាល់ ឆុនវីដែត ។ នៅរាមទុកពីរគ្រឿងយ៉ាងច្រើន កប៉ាល់ឯទៀតទុកនៅវុងសន្ធឹម ។ កប៉ាល់ការពារធុនធំ កប៉ាល់ប្រឆាំងនាវាមុជទឹកយើងកុំអាលយក ។ ចាំឲ្យកម្មាភិបាល និងយុទ្ធជនយើងទៅរៀនឯ ស្រុកគេ ។

**ង)** ព្រលានយន្តហោះ ៈ ស្នើឲ្យពិនិត្យកន្លែងថ្មី ជ្រោយបន្ទិច ដូចជាម្តុំត្បូងពង ឬកំពង់ឆ្នាំង ។

**ច)** ឃ្លាំង ៈ ក៏ត្រូវរៀបចំនៅកន្លែងឆ្ងាយដែរ ។

**៣) បញ្ហាដឹកគ្រាប់ពីវៀតណាម ៖**

◆ ត្រូវរៀបចំដឹកឲ្យហើយ ស្នើច្រកបី គឺ ស្នួល ស្នាច់ ឬមេមត់ ។ យើងទទួលនៅព្រំដែន កុំឲ្យចូលមកក្នុងដីយើង ។

**៤) បញ្ហាមន្ទីរពេទ្យយោធា ៖**

◆ អង្គការយល់ព្រមឲ្យរៀបចំមន្ទីរពេទ្យយោធា តាមសេចក្តីស្នើរបស់សេនាធិការ ។

**បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា**

# រូបថត គ្រួសារ សោ ភឹម ប្រធានភូមិភាគបូព៌ា

នៅថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០១៥ បុគ្គលិកគម្រោងជំរុញឲ្យមានការទទួលរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានស្រាវជ្រាវរកឃើញរូបថតរបស់មេដឹកនាំខ្មែរក្រហម សោ ភឹម និងប្រពន្ធរបស់គាត់យាយ ការ៉ូ ។ រូបថតនេះត្រូវបានថែរក្សាដោយកូនស្រីរបស់ សោ ភឹម ឈ្មោះ កាដេវ ដែលកំពុងរស់នៅក្នុងភូមិដាច់ស្រយាលមួយស្ថិតនៅជាប់ព្រំដែន កម្ពុជា-ថៃ ។ កាដេវ បាននិយាយប្រាប់ក្រុមការងារថា រូបថតនេះគឺឪពុកម្តាយរបស់គាត់បានថតនៅប្រាសាទអង្គរវត្ត នៅពេលដែលពួកគាត់ទៅចូលរួមប្រជុំជាមួយគណៈប្រតិភូក្នុងខេត្តសៀមរាប បន្ទាប់ពីខ្មែរក្រហមរំដោះប្រទេសកម្ពុជាបានភ្លាមៗ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។

តាមរយៈរូបថតនេះបានបង្ហាញឲ្យឃើញថា មេដឹកនាំខ្មែរក្រហមក៏មានជីវិតរស់នៅជាលក្ខណៈគ្រួសារដែរ ។ ពួកគេបាន


សោ ភឹម និងប្រពន្ធ យាយ ការ៉ូ ថតនៅមុខប្រាសាទអង្គរវត្ត ឆ្នាំ១៩៧៥

ចំណាយពេលរស់នៅជាលក្ខណៈប្តី ប្រពន្ធ បងប្អូន ពួកគេស្រឡាញ់សមាជិកគ្រួសាររបស់ខ្លួន និងបានថតរូបទុកជាអនុស្សាវរីយ៍សម្រាប់ផ្ទាល់ខ្លួន និងសម្រាប់កូនៗ បើទោះបីខ្មែរក្រហមបានបង្ខំឲ្យប្រជាជនធ្វើការងារជាទម្ងន់ រស់នៅបែកបាក់ពីសមាជិកគ្រួសារ និងហាមមិនឲ្យមាននោសញ្ចេតនាររវាងគ្នាទៅវិញទៅមកក៏ដោយ ។

សោ ភឹម កើតនៅឃុំគគីរសោម ស្រុកប្រសូត្រ ខេត្តស្វាយរៀង ។ សោ ភឹម បានចូលរួមជាមួយចលនាខ្មែរឥស្សរៈនៅអំឡុងចុងទសវត្សរ៍ឆ្នាំ១៩៤០ ហើយគាត់បានរស់នៅក្នុងព្រៃនៃស្រុករមាសហែក ខេត្តស្វាយរៀង, ស្រុកកំចាយមា ខេត្តព្រៃវែង និងស្រុកពញាក្រែក ខេត្តកំពង់ចាម ។ សោ ភឹម បានឡើងជាប្រធានភូមិបូព៌ា តាំងពីមុនឆ្នាំ១៩៧០ និងបន្តរហូតដល់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ចន្លោះពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៨ ។ សោ ភឹម ក៏ជាបងធំទី៤ក្នុងចំណោមមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាដែរ ។ ចំណែកប្រពន្ធរបស់ សោ ភឹម យាយ ការ៉ូ មានស្រុកកំណើតនៅខេត្តព្រៃវែង និងជាប្រធានមន្ទីរកសិដ្ឋានភូមិភាគបូព៌ានៅទួលព្រាប និងទួលសំរោង ក្នុងអំឡុងរបបខ្មែរក្រហម ។ សោ ភឹម និង យាយ ការ៉ូ បានរៀបការជាមួយគ្នាក្នុងអំឡុងដើមទសវត្សរ៍ឆ្នាំ១៩៥០ ។ អ្នកទាំងពីរមានកូនប្រុសស្រីចំនួន៦នាក់ ។ កូនទី១) ឈ្មោះ ណាត ជាប្រធានមន្ទីរពេទ្យព-១ នៅរការខ្នុរ ។ កូនទី២) ឈ្មោះ ស៊ី ត្រូវជាកូនប្រសាររបស់ រស់ ញឹម លេខាភូមិភាគពាយ័ព្យ ។ ស៊ី បានរៀបការជាមួយកូនប្រុសរបស់ រស់ ញឹម ឈ្មោះ ជាល ជាគណៈតំបន់៥ ភូមិភាគពាយ័ព្យ ។ កូនទី៣) ឈ្មោះ កាដេវ រស់នៅកងកុមារក្នុងមន្ទីរទួលសំរោង ។ កូនទី៤) ឈ្មោះ ខួច ។ កូនទី៥) ឈ្មោះ ឃុច និង កូនទី៦) ស្រី ។

នៅខែមិថុនា ឆ្នាំ១៩៧៨ សោ ភឹម ត្រូវបានចោទប្រកាន់ថា ក្បត់នឹងបក្សកុម្មុយនីស្តកម្ពុជា និង ប៉ុល ពត ។ សោ ភឹម ត្រូវបានឡោមព័ទ្ធ ដោយកងទ័ពមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា នៅស្រុកស្រីសន្ធរ តំបន់២២ ភូមិភាគបូព៌ា ហើយគាត់បានធ្វើអត្តឃាដ

ខ្លួនឯងនៅពេលនោះ ។ បន្ទាប់មក ខ្មែរក្រហមបានតាមចាប់ខ្លួន និង សម្លាប់សមាជិកគ្រួសាររបស់គាត់ម្តងមួយៗ ។ ចុងបញ្ចប់ សោ ភឹម នៅសល់តែកូនស្រីម្នាក់ ឈ្មោះ កាដេវ ប៉ុណ្ណោះ ។ កាដេវ ជាកូនទី៣ ក្នុងចំណោមកូនទាំងអស់របស់ សោ ភឹម ដែលនៅរស់រានមានជីវិតពីការសម្លាប់ ដោយសារតែគាត់ទៅលេងជាមួយបងស្រីរបស់គាត់ នៅស្វាយស៊ីសូផុន នៅពាក់កណ្តាល ឆ្នាំ១៩៧៨ ។ បន្ទាប់ពីស្នាក់នៅស្វាយស៊ីសុផុនប្រហែលមួយសប្តាហ៍ កម្មាភិបាលភូមិភាគនិរតី បានចាប់ខ្លួនបងស្រីរបស់គាត់ និង ជាល គណៈតំបន់៥ ដោយប្រាប់ថាយកទៅរៀនសូត្រ ។ កាដេវ ឲ្យដឹងថា ខ្លួនគាត់មានសំណាងបានរស់រានដោយសារកម្មាភិបាលទាំងនោះមិនបានស្គាល់គាត់ថាជាកូនស្រីរបស់ សោ ភឹម ។ នៅឆ្នាំ១៩៧៩ កាដេវ បាន ភៀសខ្លួនទៅរស់នៅក្នុងជំរំជនភៀសខ្លួននៅក្នុងទឹកដីថៃ ។ បន្ទាប់មក កាដេវ បានរៀបការជាមួយបុរសម្នាក់ និងផ្លាស់មករស់ក្នុងទឹកដីខ្មែរវិញ ។ សព្វថ្ងៃ កាដេវ មានកូន៣នាក់ ។

កាដេវ បាននិយាយថា គាត់មានការសោកសង្រេងណាស់ នៅពេលមើលរូបថតឪពុកម្តាយ ហើយថែមទាំងធ្វើឲ្យគាត់កាន់តែឈឺចាប់ និងនឹករឭកដល់ឪពុកម្តាយ នៅពេលគ្រួសារគាត់មានអាហារឆ្ងាញ់ហូបម្តងៗ ។ កាដេវ ក៏បានរំឭកថា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យឆ្នាំ១៩៧៥-៧៨ គ្រួសាររបស់គាត់រស់នៅជុំគ្នាសប្បាយរីករាយណាស់ ។ ឪពុករបស់គាត់ជាអ្នកមានអំណាចម្នាក់នៅក្នុងរបបនោះ ។ ដូច្នេះ គាត់និងសមាជិកគ្រួសារមានអ្វីគ្រប់យ៉ាង និងអាចដើរទៅណាមកណាតាមតែពួកគាត់ចង់ទៅ ។ **ឡុង ដានី**

# ខ្សែភាពយន្តឯកសាររឿង «ក្បង់ទឹកទន្លេ»

“ក្បង់ទឹកទន្លេ” គឺជាខ្សែភាពយន្តឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលទទួលបានការគាំទ្រ និងទិដ្ឋាការពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។ មកដល់ពេលនេះ ខ្សែភាពយន្ត “ក្បង់ទឹកទន្លេ” ទទួលបានពានរង្វាន់លំដាប់ពិភពលោកចំនួន១៦ហើយ ។ “ក្បង់ទឹកទន្លេ” បង្ហាញនូវដំណើរជីវិតមួយដ៏វិសេសវិសាល និងមិនធ្លាប់មានពីមុនមក ដែលផ្តើមចេញពីតំបន់ជនបទ ចុងកាត់មាត់ញកព្រៃភ្នំ និងភូមិនេសាទនៅលើផ្ទៃទឹករបស់តួអង្គទាំងបី ។ ខ្សែភាពយន្តនេះបានចាក់បញ្ចាំងនៅសារមន្ទីរសិល្បៈទំនើប សហរដ្ឋអាមេរិក ចាប់ពីថ្ងៃទី១២ ដល់ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣ និងប្រទេសអូទ្រីស បែលហ្ស៊ិក អាល្លឺម៉ង់ កូរ៉េខាងត្បូង អ៊ីតាលី អង់គ្លេស និងប្រទេសសិង្ហបុរី ។ ខ្សែភាពយន្តឯកសារនេះ ក៏គ្រោងនឹងដាក់បញ្ចាំងតាមសាកលវិទ្យាល័យ និងភូមិចំនួន៦០ ទូទាំងប្រទេសកម្ពុជា ដើម្បីបើកឲ្យមានការពិភាក្សាស្តីពីការផ្លាស់ប្តូរបរិស្ថាន ដើម្បីស្វែងរកដំណោះស្រាយ ។ ខ្សែភាពយន្តនេះក៏មានចាក់បញ្ចាំងជូនទស្សនារៀងរាល់ថ្ងៃសុក្រនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ព័ត៌មានបន្ថែមសូមទាក់ទង កញ្ញា សា ហ្វាទីលី តាមរយៈទូរស័ព្ទលេខ ៖ ០១២ ៥១១ ៩១៤ ។ អ៊ីម៉ែល ៖ truthfatily.s@dccam.org គេហទំព័រ ៖ www.ariverchangescourse.com





# កម្មាភិបាលខ្មែរក្រហមម្នាក់ត្រូវសម្លាប់ក្នុងព្រឹត្តិការណ៍ជនជាតិចាមបះបោរនៅឃុំស្វាយឃ្លាំងនៅដើមឆ្នាំ១៩៧៥




ឌុល ផាត ជាអតីតយុវនារីខ្មែរក្រហមម្នាក់ដែលស្ថិតនៅក្នុងហេតុការណ៍ជនជាតិចាមបះបោរ នៅឃុំស្វាយឃ្លាំង បានរៀបរាប់ថា នៅដើមឆ្នាំ១៩៧៥ គាត់ និងយុវនារីបីនាក់ទៀតត្រូវបានខ្មែរក្រហមផ្លាស់ឲ្យទៅនៅភូមិ៦ ក្នុងឃុំស្វាយឃ្លាំង ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម (អតីតតំបន់២១ ភូមិភាគបូព៌ា ក្នុងរបបខ្មែរក្រហម) ដើម្បីចុះទៅជួយ និងបង្រៀនបងប្អូនជនជាតិចាមធ្វើស្រែ និងដកស្ទូង ។ ផាត ថែមទាំងត្រូវខ្មែរក្រហមចាត់តាំងឲ្យទទួលភារកិច្ចជាអ្នកឃោសនាដល់បងប្អូនជនជាតិចាមនារីៗឲ្យកាត់សក់ខ្លី ដើម្បីកុំឲ្យពិបាកបួងសក់ឡើងលើ នៅពេលចុះស្ទូងម្តងៗ ។ ខណៈពេលនោះ មាននារីក្មេងៗជនជាតិចាមនៅក្នុងភូមិជាច្រើនបាននាំគ្នាមកកាត់សក់ខ្លី តាមគាត់ ហើយថ្ងៃខ្លះនារីចាមទាំងនោះ មកកាត់សក់រហូតដល់ម៉ោង១០យប់ទៀត ។

ផាត បានបន្តថា «នៅពេលនោះយើងមិនបង្ខំឲ្យបងប្អូនជនជាតិចាមកាត់សក់ ឬចូលសាសនាខ្មែរទេ បើគេគិតថាស្រួល គេកាត់ ប៉ុន្តែបើមិនស្រួល គឺស្រេចតែបុគ្គលប៉ុណ្ណោះ មិនបង្ខំទេ» ។

នៅវេលាម៉ោង៥ល្ងាច (រយៈពេល៥ថ្ងៃបន្ទាប់ពីការឃោសនារបស់ ផាត) ប្រធានភូមិ៦ ជាជនជាតិចាមដែលស្និទ្ធស្នាលនឹង ផាត បានមកប្រាប់ឲ្យ ផាត និងក្រុមការងាររបស់គាត់ រៀបចំឥវ៉ាន់ចាកចេញពីភូមិ ព្រោះបងប្អូនជនជាតិចាមបានរៀបចំប្រជុំបះបោរ និងមានបំណងសម្លាប់ក្រុមគាត់ហើយ ។ ផាត និងនារីបីនាក់ទៀតធ្វើការនៅក្នុងភូមិជាមួយគ្នា រួមទាំងសមមិត្ត ចែត ដែលជាយុវជនទទួលជាប្រធានខាងវប្បធម៌ឃុំស្វាយឃ្លាំងបានដិះរទេះសេះដែលមេភូមិរកឲ្យដើម្បីចាកចេញ ។ ប៉ុន្តែ ចែត បានឲ្យ ផាត ចេញទៅមុន ព្រោះគាត់ភ្លេចឯកសារ និងរបស់របរត្រូវត្រឡប់មកយកនៅភូមិបងប្អូនជនជាតិចាមវិញ ។ ចែត «ត្រូវបានបងប្អូនជនជាតិចាមចាប់ និងសម្លាប់ដោយអន្ទង់សាច់ប្រឡាក់អំបិល» ។ បងប្អូនជនជាតិចាមថែមទាំងបានបិទផ្លូវលែងឲ្យមានការចេញចូលភូមិទៀតផង ។ ផាត បានរង់ចាំសមមិត្ត ចែត ទាំងភ័យរន្ធត់ រហូតដល់យោធាខ្មែរក្រហមឡើងពីស្រុកក្រូចឆ្មារ មកបង្ក្រាបបងប្អូនជនជាតិចាមដែលបះបោរទាំងនោះ ទើបខ្មែរក្រហមអាចយកសាកសព ចែត ចេញពីភូមិបាន ។ បន្ទាប់មកខ្មែរក្រហមបានចាត់វិធានការចាប់ជនជាតិចាមនៅភូមិ៦ ក្នុងឃុំស្វាយឃ្លាំងនេះ ។ យោធាខ្មែរក្រហមបានចងបងប្អូនជនជាតិចាមទាំងខ្សែៗ ដែលក្នុងមួយខ្សែមានចំនួនប្រមាណ ពី២០-៣០នាក់ បញ្ជូនចេញទៅទិសខាងកើតភូមិ ។ ប៉ុន្តែ ផាត មិនដឹងថា ខ្មែរក្រហមយកជនជាតិចាមទៅទីណាទេ ។ បន្ទាប់ពីចាប់នៅឃុំស្វាយឃ្លាំង យោធាខ្មែរក្រហមបានបន្តចាប់ជនជាតិចាមនៅកន្លែងផ្សេងៗទៀតនៅក្នុងស្រុកក្រូចឆ្មារ ។ ក្រោយហេតុការណ៍នោះ ផាត ត្រូវបានផ្លាស់ឲ្យទៅជួយស្ទូងប្រជាជនខ្មែរនៅភូមិវត្តឧបរការិញ ។

រយៈពេលមួយខែក្រោយមក (ត្រូវនឹងរយៈពេលកន្លះខែក្រោយពីកងទ័ពខ្មែរក្រហមបានទទួលជ័យជម្នះនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥) អង្គការជ្រើសរើស ផាត និងនារីៗនៅស្រុកក្រូចឆ្មារ សរុបប្រមាណ២០០នាក់ ឲ្យទៅហ្វឹកហាត់ក្បួនយុទ្ធសាស្ត្រយោធារយៈពេលមួយខែនៅវត្តមេបុណ្យក្នុងភូមិចក ខេត្តព្រៃវែង ។ បន្ទាប់ពីហាត់ចប់ អង្គការបានបែងចែងនារីៗទាំងនោះឲ្យទៅនៅតាមក្រសួងផ្សេងៗ ដោយឡែក ផាត ត្រូវទៅខាង


ជនជាតិចាម

ក្រសួងកសិកម្ម ដោយទទួលភារកិច្ចជាប្រធានក្រុមនៅការដ្ឋានទី៧ ភូមិអន្តរជ័យ ស្រុកកៀនស្វាយ ខេត្តកណ្តាល ។ នៅការដ្ឋានអន្តរជ័យ មានជិកសរុបទាំងអស់៤០០នាក់ និងមានភារៈកិច្ចរៀងៗខ្លួន ដូចជាពាស់ស្មៅ ជញ្ជូនស្មៅចេញពីស្រែ ស្ទូង និង ច្រូតស្រូវ ដោយមានសមមិត្តនារី លី និង សារ៉ាត ជាអ្នកគ្រប់គ្រង ។ សមាជិកទាំងអស់ត្រូវចេញទៅធ្វើការងារនៅព្រឹកព្រលឹម ហើយថ្ងៃខ្លះត្រូវធ្វើការងារបន្តរហូតដល់ម៉ោង១១យប់ក៏មានចំណែករបបអាហារវិញភាគច្រើនមានតែព្រលិត និងក្រកួនប៉ុណ្ណោះ ។ ប៉ុន្តែនៅពេលនោះ ថាត អាចស្នើសុំទៅខាងចុងភៅឲ្យធ្វើម្ហូបផ្សេង ដូចជាទឹកប្រហុកជ្រលក់ជាមួយព្រលិត និងត្រកួនដែលដើរបេះដោយខ្លួនឯងបាន ។

នៅអំឡុងពេលនោះ ថាត បានមកចូលរួមមីទីងនៅស្តាតអូឡាំពិក ដែល នួន ជា បានឡើងបំផុសឲ្យកម្មាភិបាលទាំងអស់ខិតខំធ្វើការងារដែលក្រសួងប្រគល់ឲ្យដើម្បីធ្វើឲ្យប្រជាជនទាំងអស់មានជីវភាពរីកចម្រើន ។ ទន្ទឹមនឹងនោះ ថាត ក៏បានមកចូលរួមប្រជុំដោយមាន ខៀវ សំផន ជាអធិបតី និងបានអប់រំគាត់ឲ្យខំប្រឹងប្រែងធ្វើស្រែ ធ្វើយ៉ាងណាឲ្យអធនទាំងនិយាយស្តីសុភាពរាបសារ ដើម្បីជាគំរូដល់ប្រជាជន ។ រហូតដល់ឆ្នាំ១៩៧៧ ទើបអង្គការដកគាត់ឲ្យមកដាំបន្លែ ដុតផ្គុំទៅរោងបាយនៅបុរី១០០ខ្នង នៅក្នុងក្រុងភ្នំពេញវិញ ។ នៅទីនោះប្រធានមន្ទីរបានបង្ខំឲ្យ ថាត យកគ្រួសារដោយលើកឡើងថា គាត់ (ថាត) ចាស់ទុំហើយ អាចធ្វើជាមេគ្រួសារបានហើយ ។ ប៉ុន្តែ ថាត បានបដិសេធដោយយំអង្វរ និងប្រាប់ប្រធានមន្ទីរវិញថា គាត់មិនទាន់ចង់បានទេ ដោយក្នុងចិត្តគាត់មិនស្រឡាញ់បុរសនោះម្យ៉ាងទៀតគាត់បែកពីឪពុកម្តាយ ។

ក្រោយមក អង្គការចាប់ផ្តើមធ្វើប្រវត្តិរូប ដោយសួរឈ្មោះភូមិកំណើត និងឪពុកម្តាយគាត់ ដោយឲ្យគាត់ឆ្លើយឲ្យច្បាស់លាស់ ព្រោះអង្គការនឹងបញ្ជូនឲ្យទៅលេងស្រុកកំណើត ។ ប៉ុន្តែដោយមានការចោទប្រកាន់ថា ខាងប៉ូព៌ក្បត់ ទើបអង្គការឈប់ឲ្យគាត់មកស្រុក ។ ខណៈនោះដែរ សារ៉ាត អនុប្រធានមន្ទីរបានហៅសមមិត្តសំអន (នៅក្រសួងជាមួយ ថាត) ដែលត្រូវជាកូនរបស់គណៈស្រុកក្រូចឆ្មារឈ្មោះ តាអោក មកសួរថា "ក្អួយ អន បើសិនជាឪពុកម្តាយក្អួយ អន ឯងក្បត់ គេឲ្យក្អួយ អន ឯងទៅសម្លាប់ឪពុកម្តាយក្អួយហ៊ានសម្លាប់ទេ?" ស្រាប់តែ អន ឆ្លើយថា "ខ្ញុំចូលបក្សគឺបម្រើបក្ស បើសិនជាម៉ែឪខ្ញុំក្បត់ ខ្ញុំពិតជាសម្លាប់ចោលតែម្តងឲ្យតែគេក្បត់ពិតប្រាកដ" ពេលឮមិត្ត អន និយាយដូច្នេះ ទើបអង្គការទុកជីវិតឲ្យគាត់រស់ និងលើកតួនាទីឲ្យគាត់ធ្វើការនៅក្រសួងបន្តទៀត ។ ចំណែក ថាត ចាប់ផ្តើមភ័យ ហើយប្រុងប្រយ័ត្នជានិច្ចទាំងការនិយាយស្តីមិនឲ្យមានការ ប៉ះពាល់ដល់អង្គការឡើយ ។

ថាត ធ្វើការក្នុងក្រសួងនៅភ្នំពេញ រហូតវៀតណាមវាយចូលមកឆ្នាំ១៩៧៩ ទើបគាត់រត់ភៀសខ្លួនជាមួយកម្មករនៅតាមក្រសួងផ្សេងៗទៅនៅជិតនៅទល់ដែនថៃ ដែលនៅទីនោះហើយដែលគាត់ទទួលដំណឹងថាម្តាយ និងប្អូនរបស់គាត់ស្លាប់ ។

**សោម ប៊ុនថន**

# គុកនៅភ្នំត្រយោងជាកន្លែងដាក់ក្រុមគ្រួសារ ដែលបានរត់គេចទៅប្រទេសថៃ

គុកភ្នំត្រយោងមានទីតាំងស្ថិតនៅក្នុងឃុំភ្នំលៀបស្រុកព្រះនេត្រព្រះតំបន់៥ ។ គុកនេះត្រូវបានបង្កើតឡើងនៅខណៈពេលដែលកម្មាភិបាលភូមិភាគនិរតីផ្លាស់មកកាន់អំណាចនៅភូមិភាគពាយ័ព្យ និង តំបន់៥ និងក្នុងខណៈដែលកម្មាភិបាលភូមិភាគនិរតីឈ្មោះ យាយ ចែម មកទទួលជាគណៈតំបន់៥ និងជាលេខាស្រុកព្រះនេត្រព្រះនៅក្នុងឆ្នាំ១៩៧៧ ។ នៅក្នុងអំឡុងឆ្នាំ១៩៧៧ និង១៩៧៨ មានប្រជាជន និងក្រុមគ្រួសារដែលរស់នៅក្នុងស្រុកថ្មពួក, ស្រុកសេរីសោភ័ណ, ស្រុកព្រះនេត្រព្រះ ជាច្រើនបានព្យាយាមរត់គេចទៅរស់នៅប្រទេសថៃហើយត្រូវបានខ្មែរក្រហមចាប់បញ្ជូនមកលត់ដំ និងដាក់គុកនៅភ្នំត្រយោង ។

ប្រវត្តិរឿងរ៉ាវសង្ខេបរបស់អតីតអ្នកទោសចំនួន៥គ្រួសារដែលត្រូវបានខ្មែរក្រហមចាប់បញ្ជូនមកគុក ភ្នំត្រយោងមានដូចខាងក្រោម ៖

## ១) គ្រួសារ ហែម សឿន


ហែម សឿន

ហែម សឿន សព្វថ្ងៃកំពុងនៅស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ បានរៀបរាប់ថា គាត់មានស្រុកកំណើតនៅភូមិគោកស្វាយ ឃុំភូមិថ្មី ស្រុកថ្មពួក ខេត្តបាត់ដំបង ។ សឿន ជាកូនទី៦ក្នុងចំណោមបងប្អូន៧នាក់ ។ សឿន បានរៀបការនៅឆ្នាំ១៩៦៨ និងប្រកបមុខរបរធ្វើស្រែ ។ នៅដើមឆ្នាំ១៩៧៥ សឿន បានចូលបម្រើកងទ័ព លន់ នល់ ហើយត្រូវបានបញ្ជូនទៅរៀនវគ្គសិក្សាពីយុទ្ធសាស្ត្រសង្គ្រាម ។ សឿន បានបម្រើជាទាហាន លន់ នល់ ក្នុងរយៈពេលខ្លីតែប៉ុណ្ណោះ ក៏ដល់ពេលដែលខ្មែរក្រហមកាន់កាប់អំណាចនៅខែមេសាឆ្នាំ១៩៧៥ ។

សឿន បានវិលត្រឡប់មកភូមិកំណើតរបស់ខ្លួនវិញ និងត្រូវចាត់តាំងធ្វើការងារនៅតាមសហករណ៍ធម្មតាដូចប្រជាជននៅក្នុងភូមិដីទៃទៀតដែរ ។ ប៉ុន្តែនៅពេលដែលកម្មាភិបាលភូមិភាគនិរតីចូលមកដល់ស្រុកថ្មពួកនៅក្នុងឆ្នាំ១៩៧៧ និង១៩៧៨ ខ្មែរក្រហមបានតាមដានដឹងថា សឿន និងមនុស្ស១៨នាក់នៅក្នុងភូមិផ្សេងទៀតធ្លាប់ធ្វើជាទាហាន លន់ នល់ ។ សឿន និងអតីតទាហាន លន់ នល់ ១៨នាក់នោះបារម្ភខ្លាចខ្មែរក្រហមចាប់យកទៅសម្លាប់ចោល ក៏បានសម្រេចចិត្តរត់គេចខ្លួនទៅប្រទេសថៃ ដោយមិនយកសមាជិកគ្រួសារទៅជាមួយខ្លួនឡើយ ។ គោលបំណងនៃការរត់គេចទៅប្រទេសថៃនេះត្រូវបរាជ័យ ដោយសារខ្មែរក្រហមដាក់វាយកម្លាំងទ័ពរបស់ខ្លួនយ៉ាងច្រើននៅតាមព្រំប្រទល់ដែន ។ សឿន និងអតីតទាហាន១៨នាក់ទៀត បានសម្រេចចូលទៅរស់នៅភូមិបេង ស្រុកបន្ទាយអំពិល តំបន់សៀមរាប-ឧត្តរមានជ័យ ជាជំនួសការវិលត្រឡប់ទៅភូមិកំណើតវិញ ។ នៅក្នុងភូមិបេងនេះមានប្រជាជនដែលរត់ពីស្រុកថ្មពួកតំបន់៥មករស់នៅច្រើន ។ សឿន ត្រូវបានប្រធានសហករណ៍ឈ្មោះ វ៉ាង ឲ្យទៅធ្វើស្រែដូចប្រជាជនមូលដ្ឋានក្នុងភូមិដែរ ។

ប្រហែលជា៣ខែក្រោយមក ប្រធានសហករណ៍ឈ្មោះ វ៉ាង បានទទួលសំបុត្រពីតំបន់៥ ឲ្យរៀបចំបញ្ជូនអ្នករត់គេចខ្លួនមកពីតំបន់៥ទាំងអស់ត្រឡប់ទៅតំបន់៥វិញ ។ បន្ទាប់ពីដឹងថានឹងត្រូវបញ្ជូនត្រឡប់មកវិញ អតីតទាហានដែលរត់ជាមួយ សឿន ចំនួន១០នាក់បានរត់គេចខ្លួនមិនព្រមត្រឡប់ទៅតំបន់៥វិញឡើយ ។ ចំណែក សឿន និង អតីតទាហាន៨នាក់ទៀតមិនបានរត់គេចទេ ទោះបីបានដឹងថា ប្រហែលជាមិនអាចរួចខ្លួនឡើយនៅពេលទៅដល់តំបន់៥វិញ ។ សឿនរួមនឹងប្រជាជនដែលរត់គេចប្រមាណជា ២០០នាក់ត្រូវបានខ្មែរក្រហមនាំចេញពីភូមិបេងឆ្ពោះទៅក្រុងសំរោង (ខេត្តឧត្តរមានជ័យ) ។ អ្នកខ្លះដែលមានគ្រួសារទៅជាមួយបានបររទេះគោ ចំណែកឯខ្លះទៀតទៅដោយថ្មើរជើង ដោយ

មានកងឈ្លបខ្មែរក្រហមបណ្តើរពីខាងក្រោយ ។ សឿន និងប្រជាជនបានធ្វើដំណើរជិតមួយថ្ងៃទើបទៅដល់ក្រុងសំរោង នៅម៉ោងប្រហែល៧យប់ ។

នៅពេលព្រឹកថ្ងៃបន្ទាប់ សឿន និងប្រជាជនទាំងអស់ត្រូវបានខ្មែរក្រហមដឹកតាមរថយន្តទ្រុងបន្តមកដាក់នៅគុកភ្នំត្រយោងរបស់តំបន់៥ ។ សឿន បានបញ្ជាក់ថា «នៅភ្នំត្រយោងមានមនុស្សរាប់ពាន់នាក់កំពុងតែជាប់ឃុំនៅទីនោះ» ដោយសារខ្វះខាងជាងឈើដើម្បីធ្វើខ្នោះ និងសង់ផ្ទះ សឿន និង បងប្រុសបង្កើតម្នាក់ទៀតត្រូវបានចាត់តាំងឲ្យធ្វើខាងផ្នែកជាងឈើ ។ នៅពេលភ្លាមៗនោះ ខ្មែរក្រហមបានបញ្ជាឲ្យក្រុមរបស់ សឿន ធ្វើខ្នោះជើងសម្រាប់ដាក់អ្នកទោស ។ បន្ទាប់ពីក្រុមរបស់ សឿន ធ្វើបានប្រហែល ១០០ខ្នោះនោះ សន្តិសុខខ្មែរក្រហមបានយកខ្នោះទាំងនោះទៅដាក់អ្នកទោសភ្លាម ។ នៅពេល សឿន ត្រឡប់មកធ្វើការនៅព្រឹកថ្ងៃបន្ទាប់ អ្នកទោសដែលជាប់ខ្នោះទាំងនោះត្រូវបានបាត់ខ្លួន ។ សឿន បានឃើញយាយ ចែម តែងតែមកប្រជុំជាមួយប្រជាជនដែលជាប់ឃុំឃាំង និងបាននិយាយថា «អ្នកទោសទាំងអស់ត្រូវខិតខំកសាងខ្លួន និងធ្វើការបង្កបង្កើនផល ។ បន្ទាប់ពី សឿន ជាប់នៅគុកភ្នំត្រយោងបានរយៈពេលប្រហែលជា១ខែមក កងទ័ពវៀតណាមក៏បានចូលមកដល់ព្រះនេត្រព្រះ ហើយអ្នកដឹកនាំខ្មែរក្រហមនៅគុកភ្នំត្រយោងបាននាំគ្នារត់ចូលព្រៃ ។ សឿន ក៏បានវិលត្រឡប់មកភូមិកំណើតរបស់ខ្លួនវិញ ដោយរត់ឆ្លងកាត់ព្រៃមាន់ទៅភ្នំស្រុក និងបន្តមកភូមិកំណើតវិញនៅឆ្នាំ១៩៧៩ ។

## ២) គ្រួសារ គីប ឡាយ


គីប ឡាយ

គីប ឡាយ មានអាយុ៦៨ឆ្នាំ ជាកសិករនៅក្នុងស្រុកថ្មពួក ខេត្តឧត្តរមានជ័យ បានរៀបរាប់ថា បន្ទាប់ពីខ្មែរក្រហមឡើងកាន់អំណាចឆ្នាំ១៩៧៥ ឡាយ និងក្រុមគ្រួសារត្រូវបានខ្មែរក្រហមដាក់ឲ្យរស់នៅក្នុងសហករណ៍ និងចាត់តាំងឲ្យទៅដកស្ទូង និងច្រូតកាត់ ។ ខ្មែរក្រហមឲ្យហូបតែបបររាវក្នុងមួយថ្ងៃ២ពេល (ពេលថ្ងៃ និងល្ងាច) ។ នៅពេលនោះមានមនុស្សជាច្រើនបានស្លាប់ ដោយសារតែរបបអាហារមិនគ្រប់គ្រាន់ ។ នៅឆ្នាំ១៩៧៨ គ្រួសាររបស់ ឡាយ និងគ្រួសារផ្សេងទៀត (ប្រហែល២០គ្រួសារ) នៅស្រុកថ្មពួក បានសម្រេចចិត្តលួចរត់ចេញពីភូមិទៅរស់នៅក្នុងភូមិបេង ឃុំបេង ស្រុកបន្ទាយអំពិល តំបន់សៀបរាប-ឧត្តរមានជ័យ ដោយសង្ឃឹមថានិងមានរបបអាហារគ្រប់គ្រាន់ ។

បន្ទាប់ពីទៅដល់ភូមិបេងបានកន្លះខែ គ្រួសាររបស់ ឡាយ និងគ្រួសារផ្សេងទៀតត្រូវបានបញ្ជូនទៅលត់ដំនៅគុកភ្នំត្រយោង ។ នៅខណៈពេលដែលក្រុមគ្រួសាររបស់គាត់មកដល់គុកភ្នំត្រយោងដំបូង ប្តីរបស់ ឡាយ ឈ្មោះ ឌុន ជឿន ត្រូវបានសន្តិសុខខ្មែរក្រហមចាប់ដាក់ខ្នោះ និងបញ្ជូនទៅឃុំឃាំងភ្លាមៗ ។ ឡាយ មិនដឹងអំពីមូលហេតុដែលសន្តិសុខខ្មែរក្រហមចាប់ប្តីគាត់ដាក់ខ្នោះឡើយ ។ ឡាយ មានឱកាសទៅសួរសុខទុក្ខប្តីរបស់គាត់ដែលកំពុងជាប់ឃុំនិងជាប់ខ្នោះជើងជាមួយអ្នកទោសផ្សេងទៀតបានតែម្តង បន្ទាប់មកប្តីរបស់ ឡាយ ត្រូវបានខ្មែរក្រហមយកទៅសម្លាប់ចោល ។ ចំណែក ឡាយ និងសមាជិកគ្រួសារផ្សេងទៀត រួមមាន ឪពុកម្តាយរបស់ ឡាយ និងកូនតូចៗចំនួន៣នាក់ទៀតត្រូវបានខ្មែរក្រហមដាក់ឲ្យរស់នៅកន្លែងលត់ដំគុកភ្នំត្រយោង រហូតដល់ទាហានវៀតណាមចូលមកនៅដើមឆ្នាំ១៩៧៩ ។

## ៣) គ្រួសារ ហ៊ុំ ហេវ


ហ៊ុំ ហេវ

ហ៊ុំ ហេវ និងក្រុមគ្រួសាររស់នៅស្រុកថ្មពួកតំបន់៥ ខណៈពេលដែលខ្មែរក្រហមឡើងកាន់អំណាចទូទាំងប្រទេសឆ្នាំ១៩៧៥ ។ ហេវ បានឲ្យដឹងថា ប្រជាជននៅក្នុងភូមិរបស់គាត់ជាច្រើនបានស្លាប់ដោយសារតែអត់អាហារ និងយកទៅសម្លាប់បន្ទាប់ពីខ្មែរក្រហមបែងចែកប្រជាជនឲ្យរស់នៅ និងធ្វើការតាមសហករណ៍ ។ នៅឆ្នាំ១៩៧៨ ហេវ និងក្រុមគ្រួសារបានសម្រេចចិត្តរត់គេចចេញពីស្រុកថ្មពួកធ្វើដំណើរទៅកាន់ភូមិបេង ស្រុកបន្ទាយអំពិល តំបន់សៀមរាប-ឧត្តរមានជ័យ ។ បន្ទាប់ពីមកដល់ភូមិបេង ហេវ និងគ្រួសារត្រូវបានចាត់តាំងឲ្យធ្វើ

ស្រែ និងទទួលបានរបបអាហារហូបចុកគ្រប់គ្រាន់ ។ ខ្មែរក្រហមបានបញ្ជូន ហេវ និងក្រុមគ្រួសារមកលត់ដំនៅគុកភ្នំត្រយោងវិញ បន្ទាប់ពីក្រុមគ្រួសាររបស់គាត់រស់នៅភូមិបេងបានរយៈពេល៣ខែ ។ ហេវ បានបន្តទៀតថា គាត់និងគ្រួសារត្រូវបានដឹកតាមរថយន្តទ្រុងពីក្រុងសំរោង (ឧត្តរមានជ័យ) ទៅកាន់ភ្នំត្រយោង ។ បន្ទាប់ពីទៅដល់គុកភ្នំត្រយោង ហេវ ត្រូវបានបង្ខំឲ្យធ្វើការបែកពីគ្រួសារ ។ ខ្មែរក្រហមចាត់តាំង ហេវ ឲ្យវាយបំបែកថ្ម និងកាប់ព្រៃ ដោយទទួលរបបអាហារបានតែពីពេលក្នុងមួយថ្ងៃ ។ ចំណែកប្រពន្ធ ត្រូវចាត់តាំងឲ្យដកស្ទូងស្រូវ ។

ហេវ បានបញ្ជាក់ថា យាយ ចែម និងឈ្មោះ សឿន ជាអ្នកគ្រប់គ្រងធំនៅគុកភ្នំត្រយោង ។ ហេវ បានឲ្យដឹងទៀតថា មានអ្នកទោសជាច្រើនដែលជាប់ឃុំ នៅគុកភ្នំត្រយោងត្រូវបានសន្តិសុខខ្មែរក្រហមយកទៅសម្លាប់ជារៀងរាល់យប់ ។ ជារៀងរាល់ព្រឹក នៅពេលចេញទៅធ្វើការ ហេវ និងប្រពន្ធតែងតែឃើញស្នាមដានសន្តិសុខខ្មែរក្រហមអូសសាកសពដែលសម្លាប់រួចយកទៅកប់ ។ មនុស្សមួយចំនួនទៀតបានស្លាប់ដោយការអត់ឃ្លាន និងជំងឺ នៅពេលដែលត្រូវបានបញ្ជូនមកលត់ដំនៅគុកភ្នំត្រយោងនេះ ។ ដោយសារការអត់ឃ្លាន និងការភ័យខ្លាច ត្រូវខ្មែរក្រហមយកទៅសម្លាប់ដែរនោះ ហេវ និងមិត្តភ័ក្រម្នាក់ទៀតឈ្មោះ កែវ បានសម្រេចចិត្តថា និងរត់ចេញពីគុកភ្នំត្រយោងដោយមិនមានការពិភាក្សាជាមួយប្រពន្ធឡើយ ។

នៅថ្ងៃរត់គេចនោះ កែវ ត្រូវខ្មែរក្រហមចាត់តាំងឲ្យទៅមើលគោក្បែរកន្លែងដែល ហេវ កំពុងវាយថ្ម ។ ហេវ និង កែវ បានពួនរង់ចាំរហូតដល់ពេលយប់ទើបចាប់ផ្តើមរត់ចេញពីភ្នំត្រយោង ។ បន្ទាប់ពីការរត់គេចរបស់ ហេវ ខ្មែរក្រហមបានទៅតាមដានកន្លែងរបស់ប្រពន្ធគាត់រយៈពេល៣-៤ថ្ងៃជាប់ៗគ្នា ។ ខ្មែរក្រហមបានសួរនាំប្រពន្ធអំពីដំណើររបស់ ហេវ ។ ប៉ុន្តែប្រពន្ធរបស់ ហេវ មិនដឹងពីការរត់គេចនេះឡើយ ។ ប៉ុន្មានថ្ងៃក្រោយមក មានមិត្តភ័ក្ររបស់ ហេវ បីនាក់ផ្សេងទៀត ក៏មានផែនការរត់ចេញពីភ្នំត្រយោង ក៏ប៉ុន្តែជាអកុសលអ្នកទាំងបីនាក់នោះត្រូវបានខ្មែរក្រហមបាញ់ស្លាប់ខណៈពេលកំពុងប៉ុនប៉ងរត់គេចខ្លួន ។ ហេវ និង កែវ បានរត់ត្រឡប់មករស់នៅក្នុងភូមិបេងវិញបានរយៈពេលកន្លះខែ ទើបកងទ័ពវៀតណាមចូលមកប្រទេសកម្ពុជា ។ ឆ្នាំ១៩៧៩ ហេវ បានជួបជុំក្រុមគ្រួសារវិញ នៅពេលដែលប្រពន្ធកូនរត់មកដល់ខាងជើងភូមិបេង ។

## ៨) គ្រួសារ ប៊ិន ណាន់


ឌុល ផាត

ប៊ិន ណាន់ អាយុ៨១ និងកូនប្រុសឈ្មោះ រិន ខេង អាយុ៥០ បានឲ្យដឹងថា បន្ទាប់ពីខ្មែរក្រហមឡើងកាន់អំណាចនៅឆ្នាំ១៩៧៥ ក្រុមគ្រួសារគាត់រស់នៅឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ តំបន់៥ ។ ប្តីរបស់ ណាន់ ឈ្មោះ ដឿ សែ ត្រូវបានចាត់តាំងឲ្យជួយធ្វើការងារ តា វ៉ាល់ ប្រធានកងចល័តតំបន់៥ ។ ចំណែក ណាន់ ត្រូវចាត់តាំងឲ្យធ្វើការនៅក្នុងកងនារីដើម្បីដកស្ទូង និងច្រូតកាត់ស្រូវ ។ នៅឆ្នាំ១៩៧៧ កម្មាភិបាលភូមិភាគនិរតីចូលមកដល់ តាវ៉ាល់ ត្រូវបានចាប់ខ្លួន ។ ចំណែកប្តីរបស់គាត់មានការភ័យខ្លាចការចាប់ខ្លួនដែរ ក៏សម្រេចចិត្តរត់គេចខ្លួនទៅប្រទេសថៃ ។ បន្ទាប់មក ណាន់ និងកូនប្រុសឈ្មោះ ខេង ត្រូវបានចាប់យកទៅដាក់នៅគុកភ្នំត្រយោង ។ ណាន់ ត្រូវបង្ខំឲ្យធ្វើស្រែ និងហូបតែទឹកបបរក្នុងមួយពេលតែមួយវែក (មួយថ្ងៃមានពីរពេល គឺពេលថ្ងៃ និងពេលល្ងាច) ។ ចំណែក ខេង មានអាយុប្រមាណ១១ឆ្នាំនៅពេលនោះ ត្រូវបានចាត់តាំងឲ្យទៅកាប់ដើមទន្ទ្រានខែត្រយកមកធ្វើជី និងហូបចុកមិនគ្រប់គ្រាន់ដូចម្តាយដែរ ។ ខេង បានឃើញអ្នកទោសផ្សេងទៀតត្រូវបានខ្មែរក្រហមដាក់ខ្នោះជើងនៅក្នុងរោងវែងៗ ។

## ៩) គ្រួសារ សាន់ លឹមហ៊ូវ


សាន់ លឹមហ៊ូវ

សាន់ លឹមហ៊ូវ មានអាយុ៦២ឆ្នាំ មានស្រុកកំណើតនៅ ឃុំសំរោង ស្រុកសេរីសោភ័ណ ខេត្តបន្ទាយមានជ័យ បានឲ្យដឹងថា ប្អូនស្រីរបស់គាត់ឈ្មោះ លឹមហ៊ាក ដែលមានប្តីឈ្មោះ ហុក ឈួក ជាអតីតពេទ្យទាហាន លន់ នល់ បាន



របងគុកទួលស្លែង ក្រោយរបបខ្មែរក្រហមដួលរលំឆ្នាំ១៩៧៩

រស់នៅស្វាយស៊ីសូផុន ។ បន្ទាប់ពីខ្មែរក្រហមចូលកាន់កាប់ប្រទេសនៅខែមេសា ឆ្នាំ១៩៧៥ លីម ហ៊ាក និងប្ដីបានត្រឡប់មករស់នៅជួបជុំគ្រួសារភូមិកំណើតនៅឃុំសំរោង ស្រុកសេរីសោភ័ណវិញ ។ នៅពេលនោះខ្មែរក្រហមបានចាត់តាំងឲ្យក្រុមគ្រួសាររបស់គាត់ធ្វើស្រែដូចប្រជាជនផ្សេងទៀតដែរ ។ ប៉ុន្តែមួយរយៈក្រោយមកមានដំណឹងថាខ្មែរក្រហមបានកំពុងរកចាប់អ្នកដែលធ្លាប់ធ្វើជាទាហាន លន់ នល់ យកទៅសម្លាប់ ។ ដោយសារការភ័យខ្លាច ហុក ឈួក និងអតីតទាហានមួយចំនួនទៀតបានរត់ភៀសខ្លួនទៅប្រទេសថៃ ។ ប៉ុន្តែបន្ទាប់ពី ហុក ឈួក បានទៅដល់ទឹកដីថៃរយៈប្រហែលជាកន្លះខែ អាជ្ញាធរថៃក៏បានបញ្ជូនគាត់ត្រឡប់មកខ្មែរវិញ ដោយសារខឹងនឹងគាត់ព្យាយាមស្វែងរកមាសដែលមន្ត្រីគយថៃយកពីគាត់ ខណៈពេលពេលដែលគាត់ចូលទៅក្នុងទឹកដីថៃ ។

បន្ទាប់មក ហុក ឈួក ត្រូវបានខ្មែរក្រហមចាប់ខ្លួន និងបាត់ដំណឹងរហូតមកដល់សព្វថ្ងៃ ។ ចំណែកគ្រួសាររបស់ លីមហ៊ួរ និងគ្រួសារផ្សេងទៀតដែលមានសាច់ញាតិរត់នៅប្រទេសថៃត្រូវបានបញ្ជូនទៅលត់ដំនៅភ្នំលៀប, ភ្នំត្រយោង ស្ថិតនៅក្នុងស្រុកព្រះនេត្រព្រះ ដែលមានកម្មាភិបាលមកពីភូមិភាគនិរតីឈ្មោះ យាយ ថែម ជាអ្នកដឹកនាំ ។ អ្នកដែលត្រូវលត់ដំនៅភ្នំលៀប ភ្នំត្រយោងនេះ មិនទទួលបានរបបអាហារគ្រប់គ្រាន់ទេ ។ ឪពុកម្ដាយរបស់ លីមហ៊ួរ បានកើតជមឺហើម ពីព្រោះតែគាត់ហូបមិនបានឆ្អែត ។ បន្ទាប់ពីមិនអាចទ្រាំនឹងការងារ និងហូបចុកមិនគ្រប់គ្រាន់ ក្រុមគ្រួសារ លីមហ៊ួរ បានសម្រេចលួចរត់ត្រឡប់មកស្រុកកំណើតវិញ ។

រស់នៅភូមិកំណើតបានមួយរយៈពេលខ្លី ខ្មែរក្រហមបានទៅយកក្រុមគ្រួសារ លីម ហ៊ួរ ត្រឡប់ទៅភ្នំលៀប, ភ្នំត្រយោងវិញ ។ ក្រុមគ្រួសារ លីមហ៊ួរ និងគ្រួសារអ្នករត់ផ្សេងទៀតត្រូវដឹកតាមឡានGMC ត្រឡប់ទៅភ្នំលៀបវិញ ។ ខណៈដែលកំពុងតែធ្វើដំណើរតាមផ្លូវជិតទៅដល់ភ្នំលៀប មានឈ្មោះ ពត ដែលជាប្រធានក្រុមរបស់ លីមហ៊ួរ ដែលបានស្រឡាញ់រាប់អានជាមួយ លីមហ៊ួរ ក៏អនុញ្ញាតឲ្យ លីមហ៊ួរ និងក្រុមគ្រួសារចុះ ចេញពីឡានទៅឈរក្បែរគល់ដូង ។ ចំពោះអ្នកដែលសេសសល់នៅលើឡានប្រហែល ១០ ទៅ១៥នាក់ ផ្សេងទៀតត្រូវបានដឹកយកទៅបន្តទៀត ។

បន្ទាប់មក លីមហ៊ួរ បានស៊ើបសួរហើយដឹងថាអ្នកទាំងនោះត្រូវបានខ្មែរក្រហមយកទៅសម្លាប់ចោលទាំងអស់ ។ បន្ទាប់មក លីមហ៊ួរ និងប្អូនស្រី លីមហ៊ាក ត្រូវបានខ្មែរក្រហមបញ្ជូនឲ្យទៅនៅក្នុងកងនេសាទនៅតាមដងទន្លេសាប ដែលមានឈ្មោះ តា គ្រើក ជាអ្នកគ្រប់គ្រង ។ ចំណែកឪពុកម្ដាយ និងសមាជិកគ្រួសារផ្សេងទៀតត្រូវដាក់ឲ្យនៅភ្នំលៀប, ភ្នំត្រយោងដដែល ។ លីមហ៊ួរ និងប្អូនស្រីត្រូវបានបញ្ជូនមកភ្នំលៀប, ភ្នំត្រយោងវិញ បន្ទាប់ពីកងនេសាទត្រូវរំសាយ ។ នៅពេលដែលវៀតណាមចូលមកដល់កម្ពុជានៅឆ្នាំ១៩៧៩ យាយ ថែម បាន ប្រមូលប្រជាជនដោយប្រាប់ថា "បងប្អូនទាំងអស់គ្នាត្រៀមសម្ភារគេច យើងត្រូវទៅជួបគ្នានៅអាងត្រពាំងថ្ម" ។ បន្ទាប់ពីឮដូច្នេះប្រជាជនបាននាំគ្នាចាកចេញដោយមានអ្នកខ្លះបររទេះទៅរដិបរដុបតាមផ្លូវ ហើយកងទ័ពវៀតណាមបានបាញ់ពីខាងក្រោយផង ។ បន្ទាប់មក យាយ ថែម បានប្រាប់ថា ឲ្យទៅបើកអង្ករនៅភ្នំស្រុក ។ ឮដូច្នេះ លីមហ៊ួរ និងអ្នកមួយចំនួនផ្សេងទៀតបានឆ្លើយថាឲ្យទៅមុនទៅចាំគោឲ្យស៊ីស្មៅបន្តិចសិន ។ បន្ទាប់ពីក្រុម យាយ ថែម ទៅអស់ ក្រុមគ្រួសារ លីមហ៊ួរ បានទៅបររទេះត្រឡប់មកស្រុកកំណើតវិញ ។ លីមហ៊ួរ និង លីម ហ៊ាក បានបាត់បង់កូនម្នាក់មួយនៅភ្នំលៀប ភ្នំត្រយោង ដោយសារតែមិនមានអាហារគ្រប់គ្រាន់ ។

**ស៊ាង ចិន្តា**

# ការឈឺចាប់ដែលដក់ជាប់ក្នុងចិត្ត «ឯណាប៉ារបស់ប៉ា?»



នាង ឡេង

ម្តាយមីងរបស់ខ្ញុំ នាង ឡេង គឺជាបុគ្គលរស់រាយម្នាក់ ដែលតែងតែរក្សានូវស្នាមញញឹមលើផ្ទៃមុខជានិច្ច ។ ប្រសិនបើក្រឡេកមើលគាត់ដំបូង ឃើញថា គាត់ហាក់បីដូចជាពុំមាននូវកង្វល់ឡើយ ប៉ុន្តែក្រោយពីធ្វើការរំឭកអំពីរបបខ្មែរក្រហម ភ្លាមៗនោះទឹកមុខរបស់ក៏ប្រែទៅជាសោកសៅ និងមានទុកជាទម្ងន់ដោយសារតែក្តីឈឺចាប់ក្នុងការបាត់នូវមនុស្សជាទីស្រឡាញ់របស់គាត់នៅក្នុងរបបដ៏ឃោរឃៅនេះ ។

នៅក្នុងឆ្នាំ ១៩៦៩ ម្តាយមីង និងពូរបស់ខ្ញុំបានរៀបការនិងកសាងនូវគ្រួសាររីករាយមួយ ព្រមជាមួយនឹងវត្តមាននៃកូនស្រីរបស់គាត់ ។ គាត់ទាំងពីនាក់រស់នៅយ៉ាងមានក្តីសុខ នៅកំពង់កន្ទួត ស្រុកអង្គស្នួល ខេត្តកណ្តាល ប៉ុន្តែ ភាពសុខដុមនេះ ពុំបានឋិតថេរឡើយ ។ នាឆ្នាំ១៩៧២ ដោយសារតែសង្គ្រាមគ្រួសាររបស់ម្តាយមីងខ្ញុំ និងគ្រួសារឪពុកមាម្តាយមីងខ្ញុំមួយគ្រួសារទៀតបានចាកចេញពីភូមិកំណើតទៅកាន់ទីក្រុងភ្នំពេញ ។ នៅក្នុងទីក្រុងគាត់ទាំងពីនាក់ត្រូវចាប់ផ្តើមនូវជីវិតថ្មីឡើងវិញ ។ គាត់ទាំងពីនាក់ត្រូវស្នើសុំនូវដីអ្នកដទៃដើម្បីសាងសង់ខ្ទមតូចមួយសម្រាប់ស្នាក់នៅ ។ ពីរឆ្នាំកន្លងទៅ ស្ថានភាពរស់នៅរបស់គាត់ទាំងពីនាក់ក៏បានប្រសើរឡើងយ៉ាងណាមិញ នៅក្នុងឆ្នាំ១៩៧៤ ដោយសារតែការរីកសាយភាយនៃសង្គ្រាមស៊ីវិល រដ្ឋាភិបាលបានចាប់ផ្តើមធ្វើការកេណ្ឌទាហាន ។ មនុស្សប្រុសភាគច្រើនត្រូវទទួលរងនូវការបង្ខំឲ្យចូលបម្រើក្នុងជួរទាហានរបស់ លន់ នល់ ។ ដើម្បីចៀសផុត គ្រួសារម្តាយមីងខ្ញុំ និងគ្រួសារឪពុកមារបស់គាត់ (លើកលែងតែយាយខ្ញុំ, ម្តាយខ្ញុំ និងម្តាយមីងពីរនាក់ផ្សេងទៀត) ភៀសខ្លួនទៅប៉ោយប៉ែត ។ នៅពេលដែលមកដល់ស្រុកអូរជ្រៅ គ្រួសារទាំងពីរអាចចាប់ផ្តើមនូវជីវភាពថ្មីដែល ពុំសូវជាមានភាពព្រួយបារម្ភ ។

មួយឆ្នាំក្រោយមកនាថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានប្រកាសធ្វើការជម្លៀសអ្នកភូមិ ចេញពីផ្ទះចំនួនបីថ្ងៃទើបអនុញ្ញាតឲ្យត្រឡប់មកផ្ទះវិញ ។ អ្នកភូមិម្នីម្នារៀបចំដើម្បីចាកចេញ ។

អំឡុងពេលជម្លៀស មនុស្សគ្រប់គ្នាតម្រូវឲ្យដើរ ។ គ្រប់ផ្លូវទាំងអស់នៅក្នុងភូមិពោរពេញដោយមនុស្ស ។ ដោយសារទីតាំងដែលពួកគាត់ត្រូវឆ្ពោះទៅពុំសូវជាឆ្ងាយប៉ុន្មាន ដូច្នេះគាត់ពុំសូវជាជួបប្រទះភាពលំបាកច្រើនទេ ។ ទីបំផុតគ្រួសារម្តាយមីងខ្ញុំ និងគ្រួសារឪពុកមារបស់គាត់ ត្រូវបានបញ្ជូនឲ្យទៅកាន់ទំនប់តាប៉ោដែលស្ថិតនៅតំបន់មួយនៅក្នុងព្រៃ ។ ពេលទៅដល់ គ្រួសារមីងខ្ញុំនិងឪពុកមាគាត់ត្រូវស្វែងរកឈើដើម្បីសង់ខ្ទមតូចមួយសម្រាប់ស្នាក់នៅ ។ គ្រួសារទាំងពីររស់នៅជាមួយគ្នា ។ ដោយសារអង្គការពុំមានអាហារចែកជូន គ្រួសារទាំងពីរប្រើប្រាស់នូវអង្ករដែលបានយកមកជាមួយដើម្បីចម្អិន និងទៅរកចាប់ត្រីដើម្បីបរិភោគ ។ បន្ទាប់ពីរស់នៅក្នុងតំបន់នេះបានមួយរយៈ អង្គការក៏អនុញ្ញាតឲ្យ

គ្រួសារទាំងពីរ ទៅបើកអង្ករនៅឯភូមិ ។ ដោយសារការខ្វះខាតគ្រួសារម្ដាយមីងខ្ញុំ និងឪពុកមារបស់គាត់បានស្វែងរកស្លឹកឈើព្រៃដែលគ្មានជាតិពុលដើម្បីបរិភោគជាមួយបាយបន្ថែម ។

បន្ទាប់ពីស្នាក់នៅទំនប់តាបៅបានមួយរយៈ គ្រួសារម្ដាយមីងខ្ញុំត្រូវបានអង្គការបញ្ជូនទៅកាន់ភូមិដទៃគឺ ភ្នំជញ្ជាំង នៅឯក្រុងសេរីសោភ័ណ ។ ម្ដាយមីងខ្ញុំត្រូវឃ្លាតឆ្ងាយពីគ្រួសារឪពុកមារបស់គាត់ ។ នៅសេរីសោភ័ណ ម្ដាយមីងខ្ញុំត្រូវបានអង្គការចាត់តាំងឲ្យធ្វើការនៅក្នុងកងដាំកប្បាស ប្ដីរបស់គាត់ត្រូវធ្វើការជាឆ្មាំ ចំណែកកូនស្រីរបស់គាត់ត្រូវបានយកទៅផ្ញើឲ្យយាយៗជាអ្នកមើលថែទាំ ។ ម្ដាយមីងខ្ញុំត្រូវចាត់តាំងឲ្យដាំកប្បាស តែតាមការពិតទៅគាត់ត្រូវទៅគាស់គល់ឈើទៅវិញ ។ គាត់ត្រូវធ្វើការយ៉ាងធ្ងន់ធ្ងរ តែជាសំណាងល្អដែរ ដែលគាត់ទទួលបានបាយហូប ។

ថ្ងៃមួយ ប្រធានកងបានមករកម្ដាយមីងខ្ញុំដើម្បីសាកសួរពីប្ដីរបស់គាត់ ។ គាត់ដឹងភ្លាមថា គេនឹងយកប្ដីគាត់ទៅសម្លាប់ហើយ ដោយសារប៉ុន្មានថ្ងៃមុន ប្ដីរបស់គាត់បានរំឭកពីពេលអតីតកាលដែលពួកគាត់អាចរស់នៅបានយ៉ាងសុខស្រួល ។ គ្រួសារមួយផ្សេងទៀតដែលស្នាក់នៅក្នុងខ្ទមតែមួយនោះ បានរាយការណ៍ពាក្យសម្ដីនេះទៅអង្គការ ។ ប្រធានភូមិរូបនោះបានប្រាប់ម្ដាយមីងខ្ញុំថា គេហៅប្ដីរបស់គាត់ឲ្យទៅយាមនៅតំបន់ផ្សេង ។ មុនពេលចាកចេញ ឪពុកមារបស់ខ្ញុំបានប្រាប់ម្ដាយមីងខ្ញុំថា ប្រសិនបើគាត់ពិតជាត្រូវគេយកទៅសម្លាប់មែន គាត់នឹងរត់ឲ្យគេបាញ់ ជាជាងឲ្យគេវាយដំគាត់រហូតដល់ស្លាប់ ។ ម្ដាយមីងខ្ញុំទន្ទឹងរង់ចាំ តែពុំឃើញប្ដីគាត់ត្រឡប់មកវិញទេ ។ លុះដល់ពាក់កណ្ដាលយប់ ម្ដាយមីងខ្ញុំឮសូរសំឡេងកាំភ្លើង ។ គាត់ដឹងថាប្ដីរបស់គាត់រត់គេច ហើយក៏ត្រូវខ្មែរបាញ់សម្លាប់ហើយ ។ ដោយពុំអាចធ្វើអ្វីបាន គាត់មានតែបន់ស្រន់ដល់ព្រះឲ្យវិញ្ញាណក្ខន្ធប្ដីគាត់ទៅកាន់សុគតិភព ។ នៅប្រហែល



សុភ័ក្ត្រ ភាណា និងម្ដាយមីង នាង ឡេង ថតនៅខែវិច្ឆិកា ឆ្នាំ១៩៩៨

ជាម៉ោងមួយ ប្រធានកងមករកគាត់ម្តងទៀត ហើយសួរថា “បងឡេង! ខ្ញុំមកគោរពកូនកង (ប្តីរបស់ឡេង) ។ តើបងណាំ នៅទេ?” គាត់បានតបថា “គាត់មិននៅទេ” ។ តាមរយៈការសន្ទនានេះ បានបញ្ជាក់ឲ្យគាត់ដឹងច្បាស់ថា ប្តីរបស់គាត់បានស្លាប់ហើយ ។

នាព្រឹកបន្ទាប់ នៅតាមផ្លូវទៅការដ្ឋាន គាត់បានឮប្រជាជននិយាយអំពីការស្លាប់របស់ប្តីគាត់ ។ គាត់ក៏បានផ្តាំផ្ញើដល់អ្នកទាំងនោះថា “នៅតាមផ្លូវ ប្រសិនបើបងប្អូនឃើញសាកសពប្តីខ្ញុំ សូមបងជួយកប់គាត់ផង” ។ អ្នកទាំងនោះបានយល់ព្រម តែម្តាយមីងខ្ញុំពុំច្បាស់ថា អ្នកទាំងនោះបានធ្វើដូចការសន្យាយ៉ាងណានោះទេ ។ ដោយពុំឃើញឪពុករបស់ខ្លួនជាច្រើនថ្ងៃ កូនស្រីរបស់គាត់បានសួរគាត់ថា “ហេតុអ្វីបានជាមានចានតែពីរ? ជាធម្មតា គឺមានចានបី ឯណាចានរបស់ប៉ា? ហេតុអ្វីបានជាគាត់មិនមកញ៉ាំបាយជាមួយយើង? គាត់ទៅណាហើយ?” សំណួរទាំងនេះបានបាញ់ចំបេះដូងរបស់ម្តាយមីងខ្ញុំ ។ គាត់បានត្រឹមតែកុហកកូនស្រី ។ គាត់ប្រាប់កូនថា ឪពុករបស់កូនត្រូវបានចាត់តាំងឲ្យទៅរៀនសូត្រនៅឯកន្លែងឆ្ងាយ ហេតុនេះគាត់នឹងមិនមកវិញក្នុងពេលឆាប់ៗនេះទេ ។ ពេលវេលាចេះតែកន្លងទៅ កូនស្រីរបស់គាត់ក៏លែងសួររកឪពុករបស់នាងទៀតដែរ ។

បន្ទាប់ពីការស្លាប់របស់ប្តីគាត់ ម្តាយមីងខ្ញុំបន្តធ្វើការដោយបៀមជាប់នូវការឈឺចាប់ ។ អ្នកធ្វើការជាមួយគាត់ពុំរាប់រកគាត់ឡើយ ព្រោះប្តីគាត់គឺជាអ្នកទោស ។ ហេតុនេះទំនាក់ទំនងជាមួយគាត់ អាចនឹងនាំឲ្យពួកគេមានគ្រោះថ្នាក់ដល់ជីវិត ។ ដោយគ្មានជម្រើស គាត់ត្រូវផ្តាច់ខ្លួនចេញពីអ្នកដទៃ ។ កូនស្រីរបស់គាត់បានធ្លាក់ខ្លួនឈឺ ម្តាយមីងខ្ញុំបាននាំនាងទៅកាន់មន្ទីរពេទ្យ ។ មីងរបស់ខ្ញុំនិងកូនស្រីស្នាក់នៅទីនោះបានរយៈពេលពីរខែ ដោយស្ថិតក្រោមការឃ្លាំមើលរបស់កម្មាភិបាល ។ ដោយភ័យព្រួយនឹងការយកទៅសម្លាប់ ម្តាយមីងខ្ញុំបានស្នើចេញពីមន្ទីរពេទ្យ ។ ពេលត្រឡប់ទៅកាន់ភូមិវិញ គាត់ក៏បន្តការងាររបស់គាត់ ។ គាត់ត្រូវបានតម្រូវឲ្យទៅសាងសង់ទំនប់ជីខ្លួសឲ្យការគាស់គល់ឈើវិញ ។ ការងារមានសភាពធ្ងន់ធ្ងរ ចំណែកឯរបបអាហារវិញ គឺមានត្រឹមតែទឹកបបរប៉ុណ្ណោះ ។ ដោយគ្មានកម្លាំងកំហែង សុខភាពគាត់បានចុះទ្រុឌទ្រោម ។ ជើងរបស់គាត់ហើម តែដើម្បីរស់រាន គាត់ត្រូវបន្តបំពេញការងារ ។

ម្តាយមីងរបស់ខ្ញុំ បានផ្លាស់ទៅស្ទូងស្រូវវិញនៅពេលរដូវវស្សា ។ គាត់បានយកកូនទៅជាមួយ ដោយសារគ្មាននរណាមើលថែនាង ។ នៅឆ្នាំ១៩៧៨ បងប្អូនថ្លៃរបស់គាត់លួចរត់ទៅប្រទេសថៃ ។ ទង្វើនេះបានធ្វើឲ្យម្តាយមីងខ្ញុំជាប់ឈ្មោះនៅក្នុងបញ្ជី ។ លើសពីនេះទៅទៀត ប្រពន្ធរបស់ប្អូនប្រុសគាត់ (ប្អូនថ្លៃ) ដែលមានសញ្ជាតិដើមជាវៀតណាម (តែនិយាយខ្មែរច្បាស់) តែងតែមកទួញសោកដាក់គាត់ ។ ទាំងនេះ រឹតបន្ថែមនូវភាពស្មុគស្មាញដល់គាត់បន្ថែមទៀត ។ គាត់ត្រូវរស់នៅក្នុងភាពភ័យខ្លាចនឹងការយកទៅសម្លាប់ចោល ។

ថ្ងៃមួយ អ្នកជិតខាងរបស់គាត់ ដែលមានប្តីទើបតែលួចរត់ទៅប្រទេសថៃ បានបបួលគាត់លួចរត់ដើម្បីរស់ ។ គាត់ទាំងពីរនាក់ដឹងថា ប្រសិនបើបន្តស្នាក់នៅទីនោះទៀត គាត់ទាំងពីរនឹងស្លាប់ ។ ពួកគាត់បានលួចរត់ទាំងយប់ ។ ម្តាយមីងខ្ញុំកាន់ដៃកូនស្រីរត់កាត់ព្រៃ ។ ពួកគេពុំហ៊ានដើរលើផ្លូវឡើយ គឺចុះទៅតាមប្រឡាយដើម្បីងាយស្រួលលាក់ខ្លួន ។ នាពេលព្រលឹម គាត់ទាំងពីរនាក់បានមកដល់ភូមិរបស់អ្នកជិតខាងគាត់ ហើយម្តាយមីងខ្ញុំក៏បន្តដំណើរទៅកាន់ភូមិពន្លេច ។ ម្តាយមីងខ្ញុំបានស្នើកម្មាភិបាលឲ្យគាត់ជួបជុំជាមួយសាច់ញាតិគាត់វិញ ។ ដំបូងឡើយ កម្មាភិបាលបានបដិសេធ តែដោយសារការអង្វរកររបស់ម្តាយមីងខ្ញុំ កម្មាភិបាលនោះក៏អនុញ្ញាត ។ បន្ទាប់ពីបានជួបជុំសាច់ញាតិវិញ ម្តាយមីងខ្ញុំដឹងថា មីងរបស់ គាត់បានស្លាប់ដោយសារឆ្លងទន្លេមិនរួច ។ នៅសល់តែឪពុកមា និងប្អូនជីដូនមួយរបស់គាត់ប៉ុណ្ណោះ ។ អ្នកទាំងនោះរស់នៅក្នុងភូមិនោះរហូតដល់របបនេះដួលរលំ ។

របបដ៏ឃោរឃៅនេះ បានឆក់យកនូវប្តី និងសាច់ញាតិជាទីស្រឡាញ់របស់ម្តាយមីងខ្ញុំ ។ នៅរៀងរាល់បុណ្យភ្ជុំបិណ្ឌ គាត់តែងតែបន់ស្រន់ និងឧទ្ទិសដល់វិញ្ញាណក្ខន្ធនៃអ្នកទាំងនោះ ព្រមទាំងបន់ស្រន់ឲ្យពួកគាត់ទៅកាន់សុគតិភព ។ គាត់បន់ស្រន់ឲ្យរបបអមនុស្សធម៌នេះកុំឲ្យកើតឡើងជាថ្មី ។ បើទោះជាមានបទពិសោធន៍ឈឺចាប់យ៉ាងណា ម្តាយមីងខ្ញុំតែងតែកំបាំងនូវការឈឺចាប់នោះដោយស្នាមញញឹមដើម្បីបញ្ជាក់ថា គាត់មានភាពរឹងប៉ឹង ។

**សុភ័ក្រ្ត ភាណា**

# ចាប់ពីរបបខ្មែរក្រហម ដល់ឧប្បត្តិហេតុ ហាំបាលី : អត្តសញ្ញាណជនជាតិចាម នៅក្នុងយុគសម័យសកលភាវូបនីយកម្ម

**(តពីលេខមុន)**

***តួលេខនៃមរណភាពរបស់ជនជាតិចាមក្រោមសម័យខ្មែរក្រហម***

*វាជារឿងសំខាន់ក្នុងការស្វែងយល់ពីចំនួនសរុបនៃប្រជាជនចាមក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម ។ អ្នកស្រាវជ្រាវជាច្រើនបានបង្ហាញពីតួលេខមិនត្រូវគ្នានៃចំនួនប្រជាជនមូស្លីម ដែលបានស្លាប់នៅក្នុងសម័យខ្មែរក្រហម ដោយសារ ជំងឺ ការធ្វើឃាត ការធ្វើការដោយបង្ខំ និងការបង្អត់អាហារ ។ អ៊ីសា ឧស្មាន អតីតអ្នកស្រាវជ្រាវនៃមជ្ឈមណ្ឌលឯកសារកម្ពុជា បានរកឃើញចំនួននៃការស្លាប់របស់ប្រជាជនចាមយ៉ាងច្រើន ដោយគណនាតាមការប៉ាន់ប្រមាណរបស់អ្នកដឹកនាំសហគមន៍មូស្លីម ដែលនៅចងចាំពីរបាយប្រជាជនមូស្លីមមុនពេលខ្មែរក្រហមកាន់អំណាចនៅឆ្នាំ១៩៧៥ និងការប៉ាន់ប្រមាណចំនួនប្រជាជនមូស្លីម ដែលរស់រានជីវិតនៅឆ្នាំ១៩៧៩ ។ ជាលទ្ធផល ឧស្មាន បានប៉ាន់ប្រមាណថា ប្រជាជនមូស្លីមដែលមានស្លាប់នៅក្នុងសម័យខ្មែរក្រហម មានចំនួនចាប់ពី៤០០.០០០ ទៅ ៥០០.០០០នាក់នៃប្រជាជនចាមសរុបទាំងអស់៧០០.០០០ ក្នុងឆ្នាំ១៩៧៥ ។ ដូចនេះ ២ភាគ៣ នៃចំនួនប្រជាជនមូស្លីមសរុបត្រូវបានបាត់បង់ជីវិតនៅក្នុងសម័យខ្មែរក្រហម ។ តាមរយៈបទសម្ភាសន៍របស់ ឧស្មាន ជាមួយនឹង ហ្សាការីយ៉ា អាដាម (Zakarya*



គ្រួសារជនជាតិចាម

*Adam)* រដ្ឋលេខាធិការ បានបង្ហាញថា ប្រជាជនមូស្លីមមានចំនួនប្រហែល៧០០.០០០នាក់ នៅឆ្នាំ១៩៧៥ ដោយ ហ្សាការីយ៉ា អាដាមបានឃើញចំនួននេះក្នុងឯកសារស្ថិតិមួយរៀបរៀងដោយ មូសទី រេស ឡស់ *(Res Lah)* ។ វ៉ាន់ ម៉ាត់ *(Van Math)* ជាសមាជិកព្រឹទ្ធសភានៃគណបក្សប្រជាជនកម្ពុជាបានប្រាប់ ខស្មាន ថា គាត់បានឮការប្រកាសមួយដោយមេបញ្ជាការ ឡេស គសឹម *(Les Kosem)* ។ មានប្រជាជនមូស្លីមចំនួន ៧០០.០០០នាក់ នៅឆ្នាំ១៩៧៥ ។ ប្រជាជនមូស្លីម ដែលរស់រានមានជីវិតបានយល់ស្របថា មានប្រជាជនមូស្លីមប្រមាណជា ២០០.០០០នាក់ នៅប្រទេសកម្ពុជាក្នុងឆ្នាំ១៩៧៩ ។

ឯកសារខ្មែរក្រហមមួយបានបង្ហាញថា នៅខែវិច្ឆិកា ឆ្នាំ១៩៧៥ មានប្រជាជនមូស្លីមប្រហែលជា ១៥០.០០០នាក់ នៅភូមិភាគបូព៌ា និងស្រុកឆ្លូង ខេត្តក្រចេះ ។ ខស្មាន បានសន្និដ្ឋានថា មានប្រជាជនមូស្លីមប្រមាណ៨០ភាគរយនៃចំនួនប្រជាជនមូស្លីមសរុប បាននាំឲ្យ ខស្មាន ចេញជាតួលេខ ៧០០.០០០នាក់ ដោយសាគាត់បានយកតួលេខ ១៥០.០០០នាក់ នេះ បន្ថែមជាមួយនឹងចំនួនប៉ាន់ស្មាននៃប្រជាជនមូស្លីមនៅតំបន់ផ្សេងទៀតនៃប្រទេសកម្ពុជា ។ បើទោះបីជា ខស្មាន បានបង្ហាញពីវិធីថ្មីមួយក្នុងការប្រមើលមើលទៅលើរបាយប្រជាជន និងតួលេខនៃការស្លាប់របស់ប្រជាជនមូស្លីមក្រោមការដឹកនាំរបស់ខ្មែរក្រហមដោយផ្អែកទាំងស្រុងទៅលើការចងចាំរបស់មេដឹកនាំសហគមន៍មូស្លីមនានាក៏ដោយ ក៏ការគណនារបស់គាត់អាចបញ្ជាក់បានថា មានកំហុសបីយ៉ាង ។

ចំណុចទីមួយ មេដឹកនាំសហគមន៍មូស្លីមបានផ្តល់បទសម្ភាសន៍ដល់ ខស្មាន ដោយផ្អែកលើពាក្យចចាមអារ៉ាមស្តីអំពីចំនួនប្រជាជនមូស្លីមដែលបានស្លាប់បាត់បង់ជីវិតតែប៉ុណ្ណោះ ពោលគឺព័ត៌មានដែលទទួលបាន ត្រូវបានយកចេញពីប្រភពដែលមិនអាចគួរឲ្យជឿបាន ។ បើទោះបីជាក្រសួងធម្មការ និងសាសនា បានបង្ហាញពីចំនួនប្រជាជនមូស្លីមខុសៗគ្នានៅក្នុងឱកាសផ្សេងៗគ្នាក៏ដោយ ក៏ប្រភពអត្ថបទព័ត៌មាននានាសព្វថ្ងៃ កំណត់យោងចំនួនតួលេខប្រជាជនមូស្លីមពី ៤០០.០០០ ទៅ ៦០០.០០០នាក់ ។ ចំណុចទី២ ខស្មានមិនបានគិតពីចំនួនប្រជាជនមូស្លីម ដែលបានភៀសខ្លួនទៅនៅប្រទេសនានា និងនៅជំរំជនភៀសខ្លួននៅតាមព្រំដែននៅឆ្នាំចុងក្រោយនៃការគ្រប់គ្រងរបស់ខ្មែរក្រហមនោះទេ ។ ចំណុចទី៣ បើយោងទៅតាមរបាយប្រជាជនប្រជាជនមូស្លីម ដែលរស់នៅប្រទេសកម្ពុជាសព្វថ្ងៃដូចដែលបានសិក្សានៅក្នុងជំពូកទី២ នៃសៀវភៅនេះ ផ្នែកខ្លះនៃខេត្តកំពង់ចាមខាងកើតទន្លេមេគង្គតាមបណ្តោយខេត្តក្រចេះ ព្រៃវែង និងស្វាយរៀង ដែលបានរៀបរាប់នៅក្នុងទូរលេខរបស់ខ្មែរក្រហម បានបញ្ជាក់ថាមានប្រជាជនមូស្លីម នៅកម្ពុជាមានចំនួនប្រហែល៦០ទៅ៧០ភាគរយ ។ ហេតុដូចនេះ បើគិតពីតួលេខមួយនៃ១៥០.០០០នៅក្នុងតំបន់នេះ ចំនួនប្រជាជនមូស្លីមមិនអាចឡើងទៅដល់ចំនួន៧០០.០០០នាក់ នៅទូទាំងប្រទេសបានទេ ។

អ្នកប្រវត្តិវិទូ ប៊ែន ឃៀណាន់ *(Ben Kiernan)* បានបង្ហាញនូវតួលេខខុសគ្នាពីការស្លាប់របស់ប្រជាជនមូស្លីមនៅសម័យខ្មែរក្រហម ។ ការគណនារបស់គាត់ហាក់ដូចជាមានភាពជឿជាក់ជាងដោយហេតុផលថា ការគណនារបស់គាត់បានយកចិត្តទុកដាក់លើចំនួនប្រជាជនដែលចេញពីប្រទេស និងការកើនឡើងដោយធម្មជាតិ ។ ឃៀណាន់ *(Kiernan)* បានសរុបថា មានប្រជាជនមូស្លីមមានចំនួន ២៥០.០០០នាក់ នៅឆ្នាំ១៩៧៥ និង១៧៣.០០០ នៅខែមករា ឆ្នាំ១៩៧៩ ។ គាត់បានសន្និដ្ឋានថា ប្រជាជនមូស្លីមប្រហែល ៩០.០០០នាក់ ត្រូវបានសម្លាប់នៅក្នុងរបបខ្មែរក្រហម ឬប្រហែលជាស្មើនឹង១ភាគ៣នៃប្រជាជនមូស្លីម នៅក្នុងប្រទេសកម្ពុជា ។ ឃៀណាន់ *(Kiernan)* បានប្រើតួលេខ ៨៨.០០០ របស់រដ្ឋបាលនៅក្នុងសម័យអាណានិគមនិយមបារាំងនៅឆ្នាំ១៩៣៦ និងយកតួលេខនេះមកធ្វើការព្យាករណ៍ប៉ាន់ប្រមាណពីចំនួនប្រជាជននៅឆ្នាំ១៩៧៥ ដោយប្រើអត្រាកំណើនប្រជាជន២.៧ភាគរយ ។ គាត់បានប្រើតួលេខមួយគឺ ១៨២.២៥៦ នាក់ នៅឆ្នាំ១៩៨២ មកធ្វើការគណនាចំនួនប្រជាជនដែលប៉ាន់ស្មាន នៅខែមករា ឆ្នាំ១៩៧៩ និងអត្រាកំណើនប្រជាជន៣ភាគរយ ។ បន្ទាប់មក គាត់បានយកចំនួននេះទៅបន្ថែមលើចំនួនប្រជាជនដែលបានចាកចេញពីប្រទេសកម្ពុជា នៅក្នុងអំឡុងសម័យខ្មែរក្រហម ។ ឃៀណាន់ *(Kiernan)* ក៏បានពិចារណាលើកំណើនចំនួនទារក ១០.០០០ គិតជាអប្បបរិមានៃកំណើនធម្មជាតិ នៅក្នុងអំឡុងសម័យខ្មែរក្រហមផងដែរ ។ បញ្ហាចំបងនៃការគណនារបស់ ឃៀណាន់ *(Kiernan)* គឺការអាចជឿជាក់បាននូវតួលេខឆ្នាំ១៩៣៦ និង១៩៨២ និងអត្រាកំណើន

ប្រជាជនដែលដែលយកមកប្រើដើម្បីធ្វើការសន្និដ្ឋានលើតួលេខទាំងនេះ ។ ចំនួនប្រជាជនស្លាប់សរុប នៅក្រោមសម័យខ្មែរក្រហមត្រូវប៉ាន់ស្មានប្រហែលពី១.៧លាននាក់ នៃចំនួនប្រជាជនសរុបចំនួន៧លាននាក់នៅឆ្នាំ១៩៧៥ ។ដូចនេះ ស្មើរតែមួយភាគបួននៃប្រជាជនកម្ពុជាបានស្លាប់ នៅក្នុងសម័យខ្មែរក្រហម ។ បើដូចនេះមានន័យថា ការស្លាប់របស់ប្រជាជនមូស្លីមមានចំនួន សមាមាត្រខ្ពស់ជាងប្រជាជនខ្មែរកាន់ព្រះពុទ្ធសាសនាបន្តិច ប្រសិនបើផ្អែកទៅតាមការគណនារបស់ យៀណាន់ *(Kiernan)* ប្រហែលជាមួយភាគបី ហើយប្រសិនបើផ្អែកទៅតាមការគណនារបស់ ខស្មាន សមាមាត្រមានបរិមាណខ្ពស់ជាងច្រើន (គឺជិតពីរភាគបី) ។ ដោយសារតែខ្មែរក្រហម បានសំដៅបំផ្លាញជនជាតិចាមដោយប្រើវិធីសាស្ត្របំបាត់ពីលើចុះក្រោម ដូចជា ការសម្លាប់អ្នកចេះដឹង អ្នកគោរពប្រណិបតន៍សាសនា អ្នកដឹកនាំសហគមន៍ និងអ្នកភូមិជាច្រើនសូម្បីតែក្មេងស្រី ។ ការបំផ្លាញចំនួនប្រជាជនមូស្លីមអស់មួយភាគបីបានធ្វើឲ្យប្រជាជនមូស្លីមមានការប្រឈមយ៉ាងខ្លាំងក្នុងលទ្ធភាព ដែលអាចឲ្យពួកគេរក្សាអត្តសញ្ញាណស្នូលរបស់ពួកគេ ។ បើយោងតាម ខស្មាន មានអ្នកចេះដឹងជាជនជាតិចាមជាច្រើននាក់បានស្លាប់នៅក្នុងរបបខ្មែរក្រហម ។ ក្នុងចំណោម ហាគីម ចំនួន ៣៣៩នាក់ មានតែ៤៥នាក់ប៉ុណ្ណោះ ដែលនៅរស់រានមានជីវិតនៅឆ្នាំ១៩៧៩ ។ទូនចំនួន២៦២នាក់ក្នុងចំណោមទូន៣០០នាក់ត្រូវបានខ្មែរក្រហមសម្លាប់ ។ ហាជីស ប្រហែល១០០០នាក់នៅឆ្នាំ១៩៧៤ នៅសល់តែ៣០នាក់ប៉ុណ្ណោះ ដែលនៅរស់នៅឆ្នាំ១៩៧៩ ។ នៅក្នុងចំណោមនិស្សិត ដែលបានទៅរៀននៅក្រៅប្រទេសចំនួន ២៦នាក់ នៅសល់តែពីរនាក់ប៉ុណ្ណោះ ។ គ្រូនមូសទីរាជាធិបតី រេះ ឡស *(Grand Raja Thipadei Res Lah)* ជាមួយអនុប្រធានពីរនាក់ទៀតរបស់គាត់ក៏ត្រូវបានសម្លាប់ដែរ ។

ជាមួយនឹងការបំផ្លាញសាលារៀនអ៊ីស្លាម ព្រះវិហារ គម្ពីរគួរអាន ការផ្លាស់ប្តូរឈ្មោះ និងការហាត់ឃាត់មិនឲ្យប្រើភាសាចាម ប្រជាជនចាមត្រូវតែខិតខំប្រឹងប្រែងធ្វើយ៉ាងណា ដើម្បីស្តារឡើងវិញនូវអត្តសញ្ញាណរបស់ខ្លួន បន្ទាប់ពីរបបខ្មែរក្រហមត្រូវបានផ្តួលរំលំ ។

## ៧) សរុបសេចក្តី

ក្នុងជំពូកនេះ យើងរកឃើញថា ខ្មែរក្រហមបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍ប្រឆាំងនឹងចាម ដោយផ្អែកលើអត្តសញ្ញាណរបស់ជនជាតិចាមទាំងនោះ ។ ជនជាតិចាម ត្រូវបានខ្មែរក្រហមបង្ខំឲ្យរៀបការជាមួយប្រជាជនដែលមកពីក្រុមជាតិសាសន៍ផ្សេង ។ សាសនាអ៊ីស្លាមត្រូវបានហាមឃាត់ មិនឲ្យគោរពប្រណិបតន៍ ។ ភាសាចាមត្រូវបានហាមឃាត់មិនឲ្យនិយាយ ។ ប្រជាជនចាម ត្រូវបានបង្ខំឲ្យបរិភោគសាច់ជ្រូក ។ ស្ត្រីចាមត្រូវបានបង្ខំឲ្យចំហសក់ និងកាត់សក់ខ្លី ។ ចាមត្រូវបានបំបែកខ្ចាត់ខ្ចាយពីភូមិកំណើតចាស់បុរាណរបស់ខ្លួន និងទៅរស់នៅលាយឡំជាមួយក្រុមប្រជាជនផ្សេងទៀត ។ ការធ្វើដូចនេះ ខ្មែរក្រហមមានបំណងចង់បំបែកបំបាក់សាមគ្គីភាពរបស់ប្រជាជនចាម ។ ប្រជាជនចាមត្រូវបានគេឲ្យដាក់ជាឈ្មោះខ្មែរ ហើយពួកគេមិនត្រូវបានអនុញ្ញាតឲ្យប្រើឈ្មោះជាមូស្លីម ឬចាមទេ ។ នៅត្រឹមចុងឆ្នាំ១៩៧៨ យើងប៉ាន់ប្រមាណថា មានប្រជាជនចាមប្រហែលជា១ភាគ៣បានស្លាប់ ដោយសារការអត់ឃ្លាន ការធ្វើការដោយបង្ខំ ជំងឺ និងការសម្លាប់នៅក្នុងរបបខ្មែរក្រហម ។ នៅមុនរបបខ្មែរក្រហម ព្រះវិហារអ៊ីស្លាមចំនួន១១៣ នៅសល់តែ៥ប៉ុណ្ណោះនៅឆ្នាំ១៩៧៩ ។

ការប្រព្រឹត្តរបស់ខ្មែរក្រហមមកលើចាមនៅពេលដំបូងហាក់ដូចជាមានលក្ខណៈល្អប្រសើរ ប៉ុន្តែការអនុវត្តនេះបានផ្លាស់ប្តូរ នៅពេលដែលរបបនេះចាប់ផ្តើមរីកដុះដាលបន្ទាប់ពីខ្មែរក្រហមទទួលជ័យជម្នះពីរបបសាធារណរដ្ឋខ្មែរ ។ ប្រជាជនចាមធ្លាប់បានសង្ឃឹមថា នឹងមានជីវិតប្រសើរឡើង ពោលគឺមានសេរីភាពក្នុងការគោរពសាសនា និងបន្តរបៀបរបបរស់នៅក្រោមរបបកុម្មុយនីស្ត ។ ដូចនេះជនជាតិចាមបានប្រឆាំងតវ៉ានឹងការហាមឃាត់មិនឲ្យគោរពសាសនាអ៊ីស្លាម និងគាបសង្កត់ផ្សេងៗពីសំណាក់ខ្មែរក្រហម ។ នៅក្នុងករណីមួយចំនួនប្រជាជនចាមបានងើបឡើងតវ៉ា និងបះបោរ ដូចជា នៅភូមិទ្រា កោះផល និងស្វាយឃ្លាំង ។ ការតវ៉ា និងការបះបោរទាំងនេះកាន់តែធ្វើឲ្យខ្មែរក្រហមមានបំណងសម្លាប់ជនជាតិចាមជាជាងអប់រំជនជាតិចាមទាំងនោះ ។ ដោយសារតែសហគមន៍ចាមជាក្រុមមួយដែលមានសម្ពន្ធភាពយ៉ាងស្អិតរមួតចូលគ្នា និងការយល់ដឹងរបស់ខ្មែរក្រហមទៅលើវប្បធម៌ចាមតិចតួច បានធ្វើឲ្យខ្មែរក្រហមជួបការលំបាកក្នុងការបែងចែកឲ្យដាច់ពីគ្នាថាតើចាមរូបណាជា

សត្រូវ និងចាមរូបណាជាសមញ្ញជន ។ ជាការឆ្លើយតប ខ្មែរក្រហមមានតែប្រើការសម្លាប់ដោយប្រកាន់ពូជសាសន៍ ដោយមើលឃើញសមាជិកចាមទាំងអស់នៅក្នុងសហគមន៍ជាគោលដៅដែលមុនដំបូងខ្មែរក្រហមមកសំដៅតែទៅលើ ហាគីម, ទួន និងអ្នកមានចំណេះដឹងតែប៉ុណ្ណោះ ។ ចាមនៅក្នុងភូមិនានា ដូចជា រការពោធិ៍ប្រាំ (ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម) កោះគរ (ស្រុកកំពង់សៀម ខេត្តកំពង់ចាម) និងអូរត្រកួន (កោះសូទិន ខេត្តកំពង់ចាម) ត្រូវបានជ្រើសរើសដោយយោងតាមអត្តសញ្ញាណស្លូលរបស់ជនជាតិចាមទាំងនោះ ។ ជនរងគ្រោះត្រូវបានខ្មែរក្រហមចោទសួរថា តើជាជនជាតិចាម ឬជនជាតិខ្មែរ មុននឹងត្រូវបានជ្រើសរើសយកទៅសម្លាប់ ។

ខ្មែរក្រហមក៏បានបញ្ជាក់នៅក្នុងរដ្ឋមនុញ្ញរបស់ខ្លួនពីបំណងក្នុងការហាមប្រាមមិនឲ្យគោរពសាសនាអ៊ីស្លាមផងដែរ ។ ខណៈដែលខ្មែរក្រហមធ្លាប់បាននិយាយថា រាល់សាសនាទាំងអស់ត្រូវបានអនុញ្ញាតរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យបែរជាសម្រេចថាសាសនាមួយណាត្រូវបានអនុញ្ញាតឲ្យគោរពទៅវិញ ។ ជាការពិតខ្មែរក្រហមមិនបានអនុញ្ញាតឲ្យគោរពសាសនាណាមួយនោះទេ ។ សាសនាទាំងអស់ត្រូវបានចាត់ទុកថា ជាសាសនាប្រតិកិរិយា រួមទាំងសាសនាអ៊ីស្លាមផងដែរ ។ ឯកសារខ្មែរក្រហមមួយចំនួនទៀត ក៏បានបង្ហាញពីការប្រព្រឹត្តអំពើប្រល័យពូជសាសន៍របស់ខ្មែរក្រហមផងដែរ ។ ទោះបីជាក្នុងអំឡុងពេលជួបការលំបាក និងការបំបែកដោយខ្មែរក្រហម ប្រជាជនចាមនៅតែព្យាយាមទាក់ទងជាមួយប្រជាជនចាមមូស្លីមដទៃទៀតដែលរស់នៅក្រៅប្រទេស ។ ជាឧទាហរណ៍ ចាមមួយក្រុមបានបះបោរ នៅខេត្តកំពត និងបានព្យាយាមរកជំនួយពីប្រជាជនមូស្លីមនៅប្រទេសម៉ាឡេស៊ី ដើម្បីប្រឆាំងនឹងខ្មែរក្រហម ។ នេះជាករណីមួយនៃអ្នកទោសមន្ទីរស២១ឈ្មោះ ទេព យូនុស *(Tep Yunus)* ដែលជាសមាជិកមួយរបស់អ្នកបះបោរ ។

បើទោះបីជាខ្មែរក្រហមបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍ប្រឆាំងនឹងចាមក៏ដោយ ក៏ខ្មែរក្រហមមិនទទួលបានជោគជ័យក្នុងការលុបបំបាត់សាសនាអ៊ីស្លាម ការសម្លាប់ចាមទាំងអស់ និងការរៀបការជនជាតិមួយជាមួយជនជាតិខ្មែរនោះទេ ។ នៅចុងបញ្ចប់នៃរបបខ្មែរក្រហម ប្រជាជនចាមបានស្តារអត្តសញ្ញាណរបស់ឡើងវិញ ។ សាសនាអ៊ីស្លាមនៅតែមាន និងជនជាតិចាមនៅតែមាន បើទោះបីជាជនជាតិចាម ទាំងនោះបានបាត់បង់អ្នកចេះដឹងគម្ពីរសាសនា និងសមាជិករបស់ខ្លួនជាច្រើនក៏ដោយ ។ អ្វីដែលប៉ះពាល់ច្រើនជាងគេគឺអត្តសញ្ញាណខាងក្រៅ ឬបន្ទាប់បន្សំ (និកាយ នយោបាយ និងសេដ្ឋកិច្ច) ។ ប៉ុន្តែ ប្រជាជនចាមបានខិតខំកសាងនូវអត្តសញ្ញាណរបស់ខ្លួនឡើងវិញ នៅក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាដែលយើងនឹងលើកយកមកពិភាក្សានៅក្នុងជំពូកបន្ទាប់ ។

## ជំពូក៥ៈ ការស្តាបនាឡើងវិញនៃអត្តសញ្ញាណជាយក្រោយរបបប្រល័យពូជសាសន៍

ជំពូកនេះនឹងធ្វើការពិភាក្សារួមលើការស្តាបនាឡើងវិញនូវអត្តសញ្ញាណជាយរបស់ជនជាតិចាម រួមមាន និកាយ នយោបាយ និងសេដ្ឋកិច្ចក្រោយរបបប្រល័យពូជសាសន៍ខ្មែរក្រហម កិច្ចខិតខំប្រឹងប្រែងដើម្បីផ្សារភ្ជាប់ខ្លួនឡើងវិញទៅនឹងពិភពលោកខាងក្រៅ ទោះបីជាត្រូវផ្តាច់ខ្លួនពីប្រតិព័ន្ធលោកខាងលិចនៅក្នុងសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជាយ៉ាងណាក្តី និងពិភាក្សាអំពីតួនាទីរបស់ខ្លួន



ជនជនជាតិនៅខេត្តកំពង់ចាម អានសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

ក្នុងសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា ព្រមទាំងបទពិសោធន៍នានានៅតាមជំរំព្រំដែនប្រទេសកម្ពុជា និងថៃ ។

ការពិភាក្សាជាដំបូងនឹងផ្តោតសំខាន់លើការលូកដៃពីសកលលោក និងមុខងាររបស់ប្រទេសដែលគោរពសាសនាអ៊ីស្លាមចំពោះស្ថានភាពមិនប្រក្រតីដែលបានកើតឡើងចំពោះជនជាតិចាម ព្រមទាំងការបង្កើតស្ថាប័ន និងគោលនយោបាយប្រកាន់ខ្ជាប់ចំពោះជនជាតិចាមក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ។ ជាកិច្ចបន្តនឹងពិនិត្យលើកិច្ចខិតខំប្រឹងប្រែងផ្ទាល់លើមធ្យោបាយនានាដែលខ្លួនគួរធ្វើដើម្បីការអភិវឌ្ឍក្រោយរបបខ្មែរក្រហម ។ ជំពូកនេះក៏នឹងពិភាក្សាលើការចូលរួមរបស់ជនជាតិចាមក្នុង និងក្រៅប្រទេសនៅតុលាការប្រជាជនបដិវត្តន៍លើការថ្កោលទោសចំពោះ ប៉ុល ពត និង អៀង សារី ដោយសារអំពើប្រល័យពូជសាសន៍ និងបទឧក្រិដ្ឋនានា ។ លើសពីនេះទៀតនឹងលើកយកករណីរបស់ ម៉ាត់ លី ដែលជាតំណាងឲ្យសហគមន៍ចាមមកពិភាក្សា ។ ចុងក្រោយនៃការពិភាក្សានឹងផ្តោតលើការខិតខំប្រឹងប្រែងរបស់ជនជាតិចាមក្នុងការស្ថាបនាអត្តសញ្ញាណរបស់ខ្លួននៅក្រៅប្រទេសនានា ។ តាមន័យនេះ ចង់ផ្សារភ្ជាប់បទពិសោធន៍ខ្លួនផ្ទាល់នៅក្នុងជំរំជនភៀសខ្លួន ព្រមទាំងការប្រឹងប្រែងជាសកលដើម្បីស្ថាបនាខ្លួនក្លាយជាប្រទេសពោរពេញដោយសន្តិភាព ។

### ១) ការរំដោះខ្លួនពីរបបប្រល័យពូជសាសន៍

ឡោះ អាទីកាស (Loh Atikah) ជាស្ត្រីវ័យចំណាស់ម្នាក់ដែលបច្ចុប្បន្នមានអាយុ៧០ឆ្នាំ ។ មុនរបបខ្មែរក្រហម អាទីកាស រស់នៅម្តុំភូមិគីឡូម៉ែត្រលេខ៧ នៅភាគខាងលិចនៃទីក្រុងភ្នំពេញ ជាមួយប្តី និងកូនៗទាំង៧នាក់ទៀត ។ ប្តីរបស់អាទីកាស គឺជាជនជាតិចាមមានមុខងារជាមន្ត្រីប៉ូលិសចាត់ចែងភស្តុភារនានាក្នុងសម័យលន់ នល់ ។ អំឡុងរបបខ្មែរក្រហម អាទីកាស និងក្រុមគ្រួសារត្រូវជម្លៀសចេញពីភូមិគីឡូម៉ែត្រលេខ៧ទៅកាន់តំបន់ដាច់ស្រយាលនៅភូមិទួលខ្វង ស្រុកព្រែកទ្រាំង ខេត្តក្រចេះ ។ នេះជាភូមិមួយដាច់ស្រយាលចុងកាត់មាត់ញកតាមតំបន់ព្រៃភ្នំ ។ អាទីកាសរៀបរាប់ថា ជារឿយៗ គាត់តែងតែឃើញសត្វក្តាន់រត់នៅក្បែរខ្ទមគាត់ ហើយជួនកាលឃើញសត្វខ្លាថែមទៀតផង ។ដោយសារតំបន់នេះជាតំបន់ព្រៃភ្នំ ធ្វើឲ្យអ្នកភូមិភាគច្រើនឆ្លងជំងឺគ្រុនចាញ់ដែលនេះជាគោលនយោបាយរបស់ខ្មែរក្រហមក្នុងការបណ្តេញជនជាតិចាមឲ្យទៅកាន់តំបន់ដែលសម្បូរដោយជំងឺប្លែកៗ និងកាចសាហាវ ។ ជាក់ស្តែងស្វាមីរបស់ អាទីកាស និងកូនៗឆ្លងជំងឺបន្តបន្ទាប់គ្នា ។ មិនយូរប៉ុន្មានដោយសារស្ថានភាពបែបនេះ ស្វាមីរបស់ អាទីកាស ត្រូវអង្គការយកទៅសម្លាប់ រីឯកូន៦នាក់ទៀតស្លាប់ដោយសារភាពអត់ឃ្លាន ។ ចុងក្រោយ នៅសល់តែ អាទីកាស និងកូនស្រីដែលមានជីវិតនៅរស់ តែជាអកុសលកូនស្រីដែលនៅមានជីវិតម្នាក់នោះមានជំងឺខ្សោយស្មារតីក្នុងឆ្នាំ១៩៧៩ ដោយសារតែភាពភិតភ័យ និងការបាត់បង់បងប្អូនក្នុងរបបនោះ ។ ស្ថានភាពជំងឺកូនស្រី អាទីកាស បានធូរស្រាលឡើងវិញនៅអំឡុងទសវត្សរ៍ឆ្នាំ១៩៩០ ។

ដោយឡែក សេន សារុះ (Sen Saroh) ដែលត្រូវជាក្មួយស្រីបង្កើតរបស់ អាទីកាស និងជាមនុស្សម្នាក់ដែលបានធ្វើដំណើរទៅជាមួយគាត់ក្នុងពេលសង្គ្រាម បានឃើញអង្គការសម្លាប់ស្វាមីរបស់ អាទីកាស ដោយផ្ទាល់ភ្នែក ។ សារុះ រៀបរាប់ថា ដោយសារនៅថ្ងៃមួយខ្មែរក្រហមស៊ើបដឹងថាប្តី អាទីកាស ធ្លាប់ជាមន្ត្រីប៉ូលិសក្នុងរបបលន់ នល់ អង្គការក៏យកសឺរ៉ាំង (ម្ជុលចាក់ថ្នាំ) ពេញដោយទឹកសថ្លាចាក់ចូលក្នុងខ្លួនស្វាមី អាទីកាស ។ សេន សារុះ យល់ថានេះជាទឹកពីព្រោះមើលទៅថ្លាឆ្លុះទៅម្ខាង ។ តែមួយរំពេចក្រោយមក ស្វាមី អាទីកាស បានស្លាប់ និងមានបែកពពុះមាត់ថែមទៀត ។ សារុះ ធ្លាប់បានប្រាប់រឿងរ៉ាវស្លាប់នេះដល់ អាទីកាស ថា សាកសពស្វាមីគាត់ត្រូវបានរុំក្នុងបំពង់ឫស្សី និងកប់នៅកន្លែងណាមួយនៅខាងក្រោយមន្ទីរពេទ្យ ។ ម្តាយរបស់ សារុះ ក៏បានស្លាប់ដោយសារជំងឺអត់ឃ្លាននៅក្នុងតំបន់មួយទៀតក្នុងប្រទេសកម្ពុជា ។ សារុះ ជាអ្នករៀបរាប់សាច់រឿងភាគច្រើនពីព្រោះជៀសវាងអាចឲ្យ អាទីកាស យល់សប្តិអាក្រក់នៅពេលដែលរំឭកដល់រឿងនោះ ។

ឡោះ អាទីកាស និង សេន សារុះ ប្រាប់ថា នៅពេលដែលវៀតណាមចូលមកខ្មែរក្រហមនាំយកប្រជាជនទៅសម្ងំលាក់ខ្លួននៅក្នុងរូងភ្នំមួយក្បែរភូមិ ក្នុងគោលបំណងជម្លៀសអ្នកទាំងនោះទៅកាន់ទីឆ្ងាយ និងដកថយ ។ តែប្រហែលដោយសាឈ្លើយសឹក ព្យាយាមបន្អាក់ដំណើរហើយ ទើបធ្វើឲ្យកងទ័ពវៀតណាមកាន់តែពន្លឿនដំណើររូតរះបង្វែរទិសដៅមកកាន់ខេត្តក្រចេះ ពេលនោះខ្មែរក្រហមក៏ដកថយយ៉ាងប្រញាប់ ប៉ុន្តែមិនបាននាំយកប្រជាជនឈ្លើយសឹកដែលខ្លួនជម្លៀសមកទៅជាមួយនោះទេ ដោយទុកអ្នកទាំងនោះចោល

នៅក្នុងរូងភ្នំនោះ ។ ក្រោយមក មិនយូរប៉ុន្មាន កងទ័ពវៀតណាមក៏បានរកឃើញអ្នកទាំងនោះ ។

អ្នកទាំងពីរបានឮពាក្យចចាមអារ៉ាមអំពីជំរំជនភៀសខ្លួននៅតាមបណ្ដោយព្រំដែនខ្មែរ-ថៃនេះ ប៉ុន្តែដោយសារខ្មែរក្រហមបានធ្វើដំណើរឆ្ពោះទៅតាមផ្លូវនោះ អ្នកទាំងពីរសម្រេចចិត្តបង្វែរទិសដៅត្រឡប់មកកាន់ទីក្រុងភ្នំពេញវិញដោយសង្ឃឹមថាតាមផ្លូវនឹងបានជួបសាច់ញាតិរបស់ខ្លួនដែលនៅរស់រានមានជីវិតអាចចែករំលែកនូវទុក្ខសោកបាន ។ អ្នកទាំងពីរ និងប្រជាជនដទៃទៀតធ្វើដំណើរដល់ផ្លូវគីឡូម៉ែត្រលេខ៨នៅពាក់កណ្ដាលឆ្នាំ១៩៧៩ ដោយមានបង្គោលចម្ងាយចង្អុលបង្ហាញថានៅសល់ចម្ងាយ ៨គីឡូម៉ែត្រទៀតពីទីក្រុងភ្នំពេញ ។ តាមផ្លូវអ្នកទាំងនោះជួបនឹងការលំបាកក្នុងការរកឃើញសាច់ញាតិរបស់ខ្លួន ។ មានសាច់ញាតិតិចតួចបំផុតដែលបានជួបគ្នាសាជាថ្មី ។ នៅអំឡុងឆ្នាំ១៩៨០ និងឆ្នាំ១៩៨១ នៅពេលមានការរីកសាយភាយដំណឹងមួយទៀតថា ជនភៀសខ្លួនមួយចំនួនបានភៀសខ្លួនចេញពីជំរំទៅកាន់ "ប្រទេសម៉ាឡេស៊ី និងប្រទេសជិតខាង" អ្នកទាំងពីររូបនេះក៏មានទំនោរទៅកាន់ជំរំភៀសខ្លួននោះដែរដោយសង្ឃឹមថានឹងអាចរកនូវទីស្នាក់អាស្រ័យក្នុងប្រទេសមួយដែលប្រកបដោយសុខសន្តិភាព ។ តែក្រោយមក ការធ្វើដំណើរទៅកាន់ទីនោះបែរជាក្លាយជាការរកស៊ីចំពោះជនភៀសខ្លួនទៅវិញ ដោយសារអ្នកដែលចង់ភៀសខ្លួនត្រូវតែចំណាយជាសាច់មាសដុំទៅឲ្យភ្នាក់ងារនៅទីនោះដើម្បីជួយការពារសុវត្ថិភាពខ្លួនឆ្លងផុតពីតំបន់សង្គ្រាម និងចោរព្រៃនៅតាមជ្រលងភ្នំទៅកាន់ទីជំរំ ឬតាមព្រំដែន ។ ជំរំដែលត្រូវបានចាត់ទុកថា មានស្ថានភាពល្អជាងគេគឺ ជំរំខាវអ៊ីដាង ដែលនៅទីនោះមានឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន (UNHCR) ជាអ្នកមើលការខុសត្រូវ ។ ដោយឡែក ក្រុមនេះ ផ្ដល់ឱកាសច្រើនដល់ការតាំងលំនៅសាជាថ្មី ។ ត្រឡប់មកវិញ អ្នកទាំងពីរពុំមានមាសគ្រប់គ្រាន់ដើម្បីយកទៅដោះដូរជាមួយនឹងភ្នាក់ងារទាំងអស់នោះ បែរសម្រេចចិត្តបន្តរស់នៅក្នុងប្រទេសកម្ពុជាដូចដើម ។

អំឡុងរបបខ្មែរក្រហម អែល សារោះ (Elsaroh) ត្រូវបានជម្លៀសចេញពីទីក្រុងភ្នំពេញទៅកាន់ភូមិប៉ាព្រែង ឃុំស្ពឺ ស្រុកចម្ការលើ ខេត្តកំពង់ចាម ។ អែល សារោះ ព្រមទាំងក្រុមគ្រួសារស្នាក់នៅទីនោះរហូតដល់ឆ្នាំ១៩៧៧ គ្រាមួយនោះ អែល សារោះធ្លាក់ខ្លួនឈឺក្រោយពីសម្រាលកូនលើកទីមួយ ។ ពេលនោះគាត់ផ្លាស់ប្ដូរកន្លែងពីមន្ទីរពេទ្យស្រុកទៅកាន់មន្ទីរពេទ្យបង្អែកខេត្តកំពង់ចាម ដោយឡែក ប្ដីរបស់គាត់តាមថែរក្សា ។ គាត់សម្រាកព្យាបាលនៅទីនោះ អស់រយៈពេលបីខែទើបចេញពីមន្ទីរពេទ្យ ។ ក្រោយពី អែល សារោះ ចូលមកភូមិវិញនៅដើមឆ្នាំ១៩៧៨ កន្លែងដែលខ្លួនធ្លាប់រស់នៅត្រូវបានទុកចោល ។ មានអ្នកធ្វើដំណើរឆ្លងកាត់ប្រាប់គាត់ថា ប្រជាជនទាំងអស់ក្នុងភូមិដែលភាគច្រើនជាជនជាតិចាមត្រូវបានខ្មែរក្រហមយកទៅសម្លាប់ចោលគ្មានសេសសល់ ។ តែឃាតករទាំងនោះ ក្រោយមកត្រូវបានអង្គការភូមិភាគនិរតីយកទៅសម្លាប់ចោលដូចគ្នាក្រោយពេលធ្វើបន្សុទ្ធកម្មរួម ។ ដំណឹងនេះលេចឮដល់ អែល សារោះ និងស្វាមីធ្វើឲ្យមានការភ័យតក់ស្លុត ។ ជាការពិត អ្វីដែលជួយសង្គ្រោះជីវិតគាត់រហូតដល់សព្វថ្ងៃនេះ ដោយសារគ្មានបញ្ជីដាក់លាក់ណាមួយកំណត់ត្រាឈ្មោះនៅសល់ បញ្ជាក់ពីសមាសភាពអ្នកភូមិនៅទីនោះ ។

អែល សារោះ និងស្វាមី បានមកភូមិមួយទៀតដែលស្ថិតនៅក្នុងឃុំមួយជិតស្រុកចម្ការលើ ។ ស្ថានភាពរស់នៅទីនោះដំបូងមានសភាពល្អប្រក្រតី តែក្រោយមកនៅឆ្នាំ១៩៧៨ ការសម្លាប់រង្គាលបានកើនឡើងជារៀងរាល់សប្ដាហ៍ ។ គាត់ប្រាប់ថា ជាទូទៅការសម្លាប់ច្រើនធ្វើឡើងនៅម៉ោង៨ទៅ៩ល្ងាច តាមរទេះសេះ ។ អ្នកដែលត្រូវបញ្ជូនទៅសម្លាប់តាមរទេះសេះ មានសភាពស្គមស្គាំងបើមើលតាមរូបរាងខាងក្រៅយើងអាចមើលដឹងភ្លាមៗ ។ គាត់រៀបរាប់ពីស្ថានភាពនោះថាគាត់ឮសំឡេងរទេះសេះបោលកាត់ភូមិ ស្ដាប់ទៅគួរឲ្យខ្លាច តែ អែល សារោះ មិនអាចធ្វើអ្វីបានក្រៅពីឈរនៅស្ងៀមថ្មឹងក្នុងខ្ទមរបស់គាត់ ។ នៅពេលដែលកម្លាំងកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាចូលមកដល់ភូមិ នៅចុងឆ្នាំ១៩៧៨ បានជួយរំដោះ អែល សារោះ និងស្វាមីឲ្យ "រួចផុតពីរណ្ដៅនរក" ។ អ្នកទាំងពីរចាកចេញពីភូមិដោយទឹកមុខបង្ហាញខ្មែរក្រហមថា អ្នកទាំងអស់គ្នានឹងរស់នៅប្រសើរជាងជីវិតដែលស្ថិតក្រោមរបបខ្មែរក្រហមឆ្ងាយណាស់ តាមរយៈការផ្សះផ្សា និងស្ដាបនាឡើងវិញ ។

សាច់រឿងឆ្លុះបញ្ចាំងរបស់អ្នកទាំងពីររូបនេះ ស្រដៀងនឹងគ្រួសារចាមដទៃទៀតក្នុងប្រទេសកម្ពុជា ជាពិសេសចំពោះអ្នកដែល

រស់នៅក្នុងតំបន់ភូមិភាគកណ្តាល និងភូមិភាគបស្ចិម ។ ដូចដែលបានរៀបរាប់នៅក្នុងជំពូកមុនរួចរាល់ហើយថា ជនជាតិចាមទទួលរងភាពអយុត្តិធម៌ចំពោះការរើសអើងពូជសាសន៍ក្នុងរបបខ្មែរក្រហម ។ អាស្រ័យហេតុដូច្នេះហើយ អ្នកទាំងនោះរីករាយស្វាគមន៍ចំពោះអន្តរាគមន៍រំដោះខ្លួនពីរបបប្រល័យពូជសាសន៍ខ្មែរក្រហម ។ នៅខែតុលា ឆ្នាំ១៩៧៨ អតីតខ្មែរក្រហមមួយក្រុមដែលបានភៀសខ្លួនចេញពីភូមិភាគបូព៌ា រៀបចំកិច្ចប្រជុំមួយតាមតំបន់ព្រំដែនកម្ពុជាវៀតណាមក្នុងខេត្តកំពង់ចាម ។ ក្រុមនេះដឹកនាំដោយវត្តមានរបស់ ហេង សំរិន ។ ម៉ាត់ លី ក៏មានវត្តមាននៅទីនោះដែរ ដោយសារតែគាត់ធ្លាប់ជាទាហានកុម្មុយនីស្តដើងចាស់តាំងពីចលនាឥស្សរៈក្នុងទសវត្សរ៍៤០ ។ គ្រានោះ ហេង សំរិន ប្រកាសជាផ្លូវការបង្កើតបក្សរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ឬមួយ «ចលនារំដោះជាតិ» ។ ចលនានេះត្រូវដឹកនាំកម្លាំងរំដោះរួមមាន ក្រុមបះបោរជនជាតិចាមដែលមកពីស្រុកក្រូចឆ្មារ ខេត្តកំពង់ចាមដើម្បីជួយរំដោះប្រជាជនកម្ពុជា ជាពិសេសជនជាតិចាមផ្ទាល់រួចផុតពីការសម្លាប់ ។ នៅដើមខែក្រោយមក អតីតខ្មែរក្រហមទាំងនោះក៏ចាកចេញពីតំបន់ដែលជាទីតាំងប្រជុំនោះ ដោយទុកឲ្យប្រជាជននៅទីនោះគ្រប់គ្រងចលនាផ្ទាល់ ហើយដែលមានការគាំទ្រយ៉ាងខ្លាំងក្លាពីសំណាក់កងទ័ពវៀតណាម ។ ៧ថ្ងៃក្រោយមក គឺត្រូវនឹងថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៧៨ កម្លាំងរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និងកងទ័ពវៀតណាមចាប់ផ្តើមវាយសម្រុកកម្ទេចរបបកម្ពុជាប្រជាធិបតេយ្យ ។ កម្លាំងទាំងនោះចាកចេញតាមដងមហាវិថីនានា ដោយឆ្លងកាត់តាមព្រំដែនរវាងកម្ពុជា-វៀតណាមទាំងស្រុង ។ ប្រហែលជាពីរសប្តាហ៍ក្រោយមកទៀត កម្លាំងអតីតខ្មែរក្រហមបានលេចធ្លោនាំមុខគេ រួមគ្នាជាមួយនឹងចលនារំដោះ និងកងទ័ពវៀតណាមដែលដឹកនាំដោយឧត្តមសេនីយ៍ វ៉ាន់ ទៀនយុង ។ តំបន់ដែលសម្បូរទៅដោយជនជាតិចាមរស់នៅច្រើនជាងគេ មានខេត្តកំពង់ចាម និងស្រុកស្ទឹងត្រង់ត្រូវបានរំដោះយ៉ាងឆាប់រហ័ស ។ ជាក់ស្តែង ក្រុមខ្មែរក្រហមបានដកកម្លាំងជាច្រើនចេញទៅតាមព្រំដែនកម្ពុជា-ថៃ ជាមួយនឹងអ្នកភូមិដែលគាំទ្រក្រុមនេះក៏ដកថយទៅជាមួយដែរ ។ ស្ត្រីជនជាតិចាមម្នាក់បានរំឭកថា «ខ្មែរក្រហមប្រើពាក្យជាស់តឿនគំរាមថា ទាហានវៀតណាមគឺជាក្រុមបឹតជញ្ជក់ឈាម និងសម្លាប់កូនក្មេងដោយបោះក្រវាត់ឡើងលើ ហើយចាក់សម្លាប់នឹងចុងលំពែង» ។ ដូច្នេះហើយ ប្រជាជនដែលបានព្រុសុខចិត្តចាកចេញទៅតាមកាន់ព្រំដែនកម្ពុជាថៃតាមក្រុមខ្មែរក្រហម ។

បែរមកវិញ ការធ្លាក់ចុះនូវអំណាចរបស់ខ្មែរក្រហមគឺដោយសារកត្តាច្រើនយ៉ាង ។ កត្តាទាំងនោះមានដូចជា ទី១) ការធ្វើបន្សុទ្ធកម្មរបស់ខ្មែរក្រហមគ្នាឯងរវាងក្រុមកម្មាភិបាល បានធ្វើឲ្យសមាជិកមួយចំនួនរត់គេចខ្លួនទៅកាន់វៀតណាម រត់ចោលស្រុកទៅបង្កើតកម្លាំងតស៊ូប្រឆាំង ទី២) កម្លាំងយោធារបស់ខ្លួនកាន់តែចុះខ្សោយទៅៗ ដោយសារការសម្លាប់រង្គាល កង្វះប្រសិទ្ធភាពនៃការបណ្តុះបណ្តាល និងកង្វះសម្ភារ និងទី៣) ជម្លោះតាមព្រំដែនជាមួយនឹងវៀតណាម និងគោលការណ៍ដឹកនាំប្រឆាំងដាច់ខាតចំពោះវត្តមានរបស់ជនជាតិវៀតណាមលើទឹកដីកម្ពុជា បានជំរុញឲ្យវៀតណាមសហការជាមួយនឹងប្រជាជនរងគ្រោះ និងប្រជាជនចាមងើបឡើងបះបោរទ្រង់ទ្រាយធំប្រឆាំងនឹងរបបនេះ ។

ជាការពិត សមរភូមិរវាងរបបកម្ពុជាប្រជាធិតេយ្យ និងកងទ័ពវៀតណាម បន្តប្រឈមមុខដាក់គ្នាពេញមួយឆ្នាំរហូតដល់ចុងឆ្នាំ១៩៧៨ ។ កងទ័ពវៀតណាមផ្លាស់ប្តូរកងចល័តជាច្រើនតាមតំបន់ព្រំដែនជាមួយនឹងកម្ពុជា ។ នៅខែមេសា ឆ្នាំ១៩៧៨ វិទ្យុផ្សាយផ្ទាល់ពីទីក្រុងហាណូយ ប្រកាសជំរុញឲ្យកម្ពុជាបន្តការដកថយ និងចូលរួមតស៊ូប្រយុទ្ធជាមួយនឹងខ្មែរក្រហមតាមភូមិដែលខ្លួនរស់នៅផ្ទាល់ ។ ហេតុការណ៍កាន់តែបង្ហាញច្បាស់នៅចុងឆ្នាំ១៩៧៨ ពេលដែលខ្មែរក្រហមបាត់បង់នូវលទ្ធភាពត្រួតត្រារបស់ខ្លួនទាំងស្រុងតាមតំបន់បន្សុទ្ធកម្មភូមិភាគបូព៌ា ។ ដោយប្រឈមនឹងការសម្លាប់ធ្វើឲ្យកម្មាភិបាលជាច្រើនចុះចូលជាមួយនឹងវៀតណាមងើបឡើងតស៊ូ ប្រឆាំងនឹងកម្លាំងខ្មែរក្រហមដែលបញ្ជូនមកពីភូមិភាគនិរតី និងទីក្រុងភ្នំពេញឲ្យតាមចាប់ខ្លួនអ្នកទាំងនោះ ។ ប្រជាជនមួយចំនួនបានឆ្លងកាត់នូវស្ថានភាពទាំងពីរនេះ ។ ករណីរបស់ ម៉ាត់ លី គឺជាឧទាហរណ៍ស្រាប់ ។ ម៉ាត់ លី ព្រមទាំងក្រុមរបស់គាត់ រត់គេចខ្លួនពីការតាមសម្លាប់ និងបង្កើតចលនាតស៊ូតាមតំបន់ព្រៃភ្នំមុនពេញចាកចេញទៅកាន់ប្រទេសវៀតណាម ។

ក្រឡេកមកវិញ ខ្មែរក្រហមបានចំណាយពេលរង់ចាំអស់៣-៤ទសវត្សរ៍ទម្រាំតែខ្លួនបានបញ្ចុះបញ្ចូល និងទទួលបានអំណាច

ក្នុងដៃ ។ ជាដំបូង នៅពេលដែល លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្តេច សីហនុក្នុងឆ្នាំ១៩៧០ ខ្លួនត្រូវរង់ចាំរយៈពេល៥ឆ្នាំ មុននឹងទទួលបាន ការគ្រប់គ្រងអធិបតេយ្យភាពពេញលេញមកលើប្រទេសកម្ពុជា ។ តែវាសនាខ្លួនត្រូវបានផ្លាស់ប្តូរធ្លាក់ចូលក្នុងកណ្តាប់ដៃរបស់កងទ័ព វៀតណាម និងចលនារំដោះក្នុងរយៈពេលមិនដល់ពីសប្តាហ៍ផង ។ លើសពីនេះទៀត ជាលទ្ធផលអាក្រក់ ការសម្លាប់រង្គាល និងការស្រេកឃ្លាននាំមកនូវភាពមហន្តរាយអស់រយៈពេលដ៏យូរមុនការមកដល់នៃ កងទ័ពវៀតណាម ។ សម្រាប់ប្រជាជនចាមគ្រប់រូប ការដួលរលំនៃ របបនេះនាំមកនូវភាពសំណាង តែបើគិតចំពោះពេលវេលាគឺយូរបន្តិចហើយទម្រាំនឹងរបបនេះដួលរលំ ។

**២) ការលូកដៃពីប្រទេសជាសកល និងតួនាទីនៃប្រទេសកាន់សាសនាអ៊ីស្លាម**

វៀតណាមបានរៀបចំបង្កើតយុទ្ធសាស្ត្រទំនាក់ទំនងជាសាធារណៈរួចស្រេចទៅហើយ ក្រោយពីបញ្ជូនកងទ័ពរបស់ខ្លួនមកកាន់ប្រទេសកម្ពុជា ។ វៀតណាមផ្ទាល់ក៏បានជ្រួតជ្រាបពីការរំលោភបំពានសិទ្ធិមនុស្សជាទម្ងន់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដោយសារយោងតាមរបាយការណ៍ជនភៀសខ្លួនទៅប្រទេសវៀតណាម ព្រមទាំងទីភ្នាក់ងារសារព័ត៌មានអន្តរជាតិបានរាយការណ៍អំពីស្ថានភាពជនភៀសខ្លួនតាមជុំវិញព្រំដែនកម្ពុជា-ថៃ ។

ជាការពិត វៀតណាមបានលើកឡើងពីសកម្មភាពយោធារបស់ខ្លួនប្រឆាំងនឹងរបបកម្ពុជាប្រជាធិបតេយ្យ ក្នុងអង្គការសហប្រជាជាតិដោយសម្អាងលើធម្មនុញ្ញរបស់អង្គការសហប្រជាជាតិត្រង់ជំពូក៧ ដែលបានចែងពីការការពារ និងសង្គ្រោះប្រជាជនកម្ពុជាឲ្យរួចផុតពីអំពើប្រល័យពូជសាសន៍ និងបទឧក្រិដ្ឋនានាប្រឆាំងនឹងមនុស្សជាតិដោយសារខ្មែរក្រហម ។ ទោះបីជាអ៊ីចឹងក៏ដោយ នយោបាយសង្គ្រាមត្រជាក់បានរារាំងដល់ការបន្តពិភាក្សាបញ្ហានេះក្នុងអង្គការសហប្រជាជាតិ ។ ម្យ៉ាងទៀត ដោយសារប្រហែលជាវៀតណាមរំពឹងទុកពីប្រសិទ្ធភាពនៃការគ្រប់គ្រងប្រទេសកម្ពុជា ដែលជាផលចំណេញលើកុម្មុយនីស្តសកល ។ វៀតណាមនៅតែរំពឹងទុកថា នេះជាការប្រសើរដោយដើរតួក្នុងសកម្មភាពនេះផ្ទាល់ សហការជាមួយនឹងសហភាពសូវៀត និងប្លុកខាងបស្ចិមប្រទេស ។ ដូច្នេះហើយ បានជាវៀតណាមលើកយកករណីនេះឡើងមកបកស្រាយក្នុងឆាកអន្តរជាតិថា ការចូលរួមសកម្មភាពយោធារបស់ខ្លួនគឺជាការជួយរំដោះប្រទេសកម្ពុជា និងប្រជាជនឲ្យរួចផុតពីរបបប្រល័យពូជសាសន៍ ពុំមែនជាសកម្មភាពឈ្លានពាននោះទេ ។ សម្រាប់ប្រជាជនកម្ពុជា ជីវិតដែលរស់រានមកបានគឺអាស្រ័យដោយឯករាជ្យភាពផ្ទាល់ខ្លួន និងការទីពឹងខ្លួនឯងជាគោលការណ៍ចាំបាច់សម្រាប់រដ្ឋឯករាជ្យមួយ ។

លើសពីនេះ ការបញ្ឈប់អំពើប្រល័យពូជសាសន៍គឺជាគោលដៅចាំបាច់ ។ ទោះបីជាប្រទេសកម្ពុជា ធ្លាប់មានប្រវត្តិសាស្ត្រចងកំហឹងនឹងប្រទេសវៀតណាម ដូចគ្នាដែរចំពោះករណីរវាងប្រទេសកម្ពុជា និងថៃ ប្រជាជនកម្ពុជាអបអរសាទរចំពោះការធ្វើអន្តរាគមន៍របស់យោធាវៀតណាម ។

តែប្រជាជនមួយចំនួនទៀតបែរជាមានភាពច្របូកច្របល់ ដោយសារតែមានរបបខ្មែរក្រហមទើបមានចម្ងល់ចោទអំពីការលាតសន្ធឹងនៃវត្តមានរបស់វៀតណាមដែលធ្វើឲ្យប្រទេសកម្ពុជាជាប់គាំងទាំងព្រមលើអំពើប្រល័យពូជសាសន៍ និងការភ័យខ្លាចបាត់បង់ទឹកដី និងមុខតំណែង ។ នេះផ្តល់ឱកាសឲ្យខ្មែរក្រហមបង្កើតចលនាថ្មីនៅតាមព្រំដែនថៃ គឺទ័ពរណសិរ្សរួបរួម សាមគ្គីភាពជាតិមាតុភូមិ និងប្រជាធិបតេយ្យ ។

ឆ្លងកាត់អស់រយៈជាច្រើនឆ្នាំ មានមនុស្សតិចតួចណាស់ដែលហ៊ានងើបឈរឡើងបង្កើតគោលនយោបាយសកម្មប្រឆាំងនឹងថ្នាក់ដឹកនាំខ្មែរក្រហម ។ ដោយឡែក គ្រាមួយអតីតកម្មាភិបាលខ្មែរក្រហមដែលរត់គេខ្លួនពីបន្សុទ្ធកម្ម រួមមាន ហ៊ុន សែន និង ហេង សំរិន បានងើបឡើងធ្វើការផ្លាស់ប្តូរដឹបូងគេ ដែលធ្វើឡើងក្នុងប្រទេសវៀតណាម ។ យើងឃើញថា នៅពេលរបបមួយត្រូវបានទម្លាក់ ជម្លោះនៅតាមបណ្តោយព្រំដែនកម្ពុជាបានរីករាលដាល ។ សឺន សាន ដែលជាអតីតនាយករដ្ឋមន្ត្រី ចាប់ពីឆ្នាំ១៩៦៧ ដល់១៩៦៨ បង្កើតនូវក្រុមចលនាតស៊ូប្រឆាំងនឹងកុម្មុយនីស្ត មានឈ្មោះថារណសិរ្សរំដោះប្រជាជាតិខ្មែរ (KPNLF) ក្នុងឆ្នាំ១៩៧៩ ។ នៅឆ្នាំ១៩៨០ សម្តេចនរោត្តម សីហនុ បានងាកចេញពីជំនួយប្រទេសចិន និងខ្មែរក្រហម រឺតបន្តឹងចំណងខ្សែរាជវង្សបង្កើតគណបក្សរណសិរ្សរួបរួមជាតិ ដើម្បីកម្ពុជាឯករាជ្យ អព្យាក្រឹត សន្តិ ដែលហៅកាត់ថា គណបក្សហ្វុនស៊ិនប៉ិច ។ ទន្ទឹមគ្នានេះដែរ មានការបង្កើតរួមគ្នានូវ

រដ្ឋាភិបាលចម្រុះមួយក្នុងឆ្នាំ១៩៨២ ដែលមានវត្តមានរបស់ខ្មែរក្រហម បក្សប្រឆាំងនឹងរបបកុម្មុយនីស្ត ខាងខ្មែររាជវង្ស ហៅថា រដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ ។

ផ្ទុយទៅវិញ ឈ្មោះដែលរដ្ឋាភិបាលយកមកប្រើនេះ គឺពុំទទួលបានប្រជាប្រិយភាពទេ ដោយសារតែមានពាក្យ “កម្ពុជាប្រជាធិបតេយ្យ” ជាសញ្ញាសម្គាល់ ។ ប្រវត្តិសាស្ត្របានបង្ហាញពីការចងសម្ព័ន្ធមេត្រីភាពនៃកុម្មុយនីស្តប្រល័យពូជសាសន៍ប្រឆាំងនឹងកុម្មុយនីស្ត ក្រុមរាជវង្សសហការគ្នាប្រយុទ្ធប្រឆាំងនឹងក្រុមកុម្មុយនីស្ត បញ្ឈប់របបប្រល័យពូជសាសន៍ និងដល់ពេលវេលានៃការរស់រានរបស់ប្រជាជនកម្ពុជា ។ ត្រង់ចំណុចនេះនៅតែមានចម្ងល់សួរថា ហេតុអ្វីបានជាមិនបង្កើតរដ្ឋាភិបាលចម្រុះមួយទម្លាក់ខ្មែរក្រហម? ហើយថា ហេតុអ្វីបានជានៅតែមានវត្តមានរបស់ខ្មែរក្រហមចូលរួមពេលបង្កើតរដ្ឋាភិបាលចម្រុះ? ទាំងនេះគឺជាចម្ងល់ ពីព្រោះថាទាំង សឺន សាន និងសម្ដេច សីហនុ សុទ្ធតែជាអ្នកនយោបាយដែលស្អប់ខ្មែរក្រហម ។ ទោះបីនេះបង្ហាញច្បាស់ពីភាពទន់ជ្រាយតែជាក់ស្តែងទាំងនេះសុទ្ធតែជាឧបករណ៍នយោបាយ» សម្រាប់ប្រជាជនកម្ពុជា នេះគឺជាជម្រើសដ៏សែនពិបាកថា តើខាងណាដែលខ្លួនគួរតែគាំទ្រ និងចូលរួមសហការណ៍ ។ ជំនួសដោយការរំដោះឲ្យមានសេរីភាព បក្សនយោបាយទាំងនេះបែរជាធ្វើឲ្យជីវិតរបស់ប្រជាជនកាន់តែលំបាក ទាំងប្រជាជនរស់នៅក្នុងប្រទេស និងតាមជំរំព្រំដែនដែលបានខ្ចាត់ខ្ចាយ ក្រោយការដួលរលំរបបខ្មែរក្រហម ។

នៅថ្ងៃទី១០ ខែមករា ឆ្នាំ១៩៧៩ ក្រុមប្រឹក្សាបដិវត្តន៍ប្រជាជនកម្ពុជាបានប្រកាសឈ្មោះជាផ្លូវការរបស់ប្រទេសកម្ពុជាគឺរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ។ មួយសប្ដាហ៍ក្រោយមកក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា គេកត់សម្គាល់ថា មានតែក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិ គឺជារដ្ឋាភិបាលដើរគួរតែឯកឯងសម្រាប់ប្រទេសកម្ពុជា ។ គួរបញ្ជាក់ថាមានតែប្រទេសវៀតណាម គឺជាប្រទេសដំបូងដែលទទួលស្គាល់របបថ្មីនេះ ។ នៅខែកុម្ភៈ ឆ្នាំ១៩៧៩ កម្ពុជា និងវៀតណាម បានចុះកិច្ចព្រមព្រៀងលើសន្ធិសញ្ញាសន្តិភាព និងសហប្រតិបត្តិការដែលមានន័យថា “សុខសន្តិភាព និងសុវត្ថិភាពរវាងប្រទេសទាំងពីរ គឺមានទំនាក់ទំនងជិតស្និទ្ធនឹងគ្នា ហើយភាគីទាំងពីរមានចំណងកាតព្វកិច្ចដើម្បីជួយគ្នាទៅវិញទៅមកប្រឆាំងនឹងរាល់ផែនការ និងសកម្មភាពបំផ្លិចបំផ្លាញនានា របស់ជនសក្តិភូមិ ព្រមទាំងក្រុមកម្លាំងប្រតិកិរិយាអន្តរជាតិណាមួយ» ។ រដ្ឋាភិបាលទាំងពីរក៏បានចុះសន្ធិសញ្ញាសម្រាប់ការសហប្រតិបត្តិការលើវិស័យសេដ្ឋកិច្ច វប្បធម៌ អប់រំ សុខភាពសាធារណៈ រួមទាំងវិស័យពាក់ព័ន្ធនឹងវិទ្យាសាស្ត្របច្ចេកវិទ្យានានា ។ គួរបញ្ជាក់ថា សន្ធិសញ្ញានេះអនុញ្ញាតឲ្យវៀតណាមបន្តកិច្ចសហប្រតិបត្តិការរបស់ខ្លួនក្នុងប្រទេសកម្ពុជា និងផ្តល់ការគាំទ្រជំនួយគ្រប់ផ្នែកទៅឲ្យប្រទេសជាដៃគូ ។ ដោយឡែកវៀតណាមផ្ទាល់នឹងដកថយកម្លាំងយោធារបស់ខ្លួនពីប្រទេសកម្ពុជាឆ្នាំ១៩៩០ លឿនជាងគម្រោងដែលបានរំពឹងទុក ។

ប្រទេសកុម្មុយនីស្តផ្សេងទៀតខាងបស្ចិមប្រទេស ដូចជាសហភាពសូវៀត និងប្រទេសគាំទ្រសហភាពសូវៀតទទួលស្គាល់របបសាធារណរដ្ឋប្រជាមានិតកម្ពុជា ។ គិតត្រឹមខែមករា ឆ្នាំ១៩៨០ មានប្រទេសចំនួន២៩ ហើយដែលបានទទួលស្គាល់របបនេះ ។ ដោយឡែក ជិត៨០ ប្រទេសផ្សេងទៀត បែរជាមិនព្រមទទួលស្គាល់របបនេះទេ ផ្ទុយទៅវិញប្រទេសទាំងនេះបែរជាទទួលស្គាល់រដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យថា ស្របតាមច្បាប់ ។ ប្រទេសដែលប្រឆាំងមិនព្រមទទួលស្គាល់របបសាធារណរដ្ឋប្រជាមានិតកម្ពុជាគឺ ឥណ្ឌូនេស៊ី ម៉ាឡេស៊ី ហ្វីលីពីន និងសិង្ហបុរី ដែលដឹកនាំដោយប្រទេសថៃ ដែលពេលនោះថៃកំពុងតែរងការគំរាមកំហែងខាងផ្នែកសន្តិសុខសុវត្ថិភាពដោយសារព្រឹត្តិការណ៍ក្នុងប្រទេសកម្ពុជា និងកំពុងតែដោះស្រាយនូវបញ្ហាមនុស្សធម៌តាមតំបន់ព្រំដែន ។ សូម្បីតែជនជាតិចាមមួយចំនួនដែលទទួលរងអំពើពូជសាសន៍ក្នុងរបបខ្មែរក្រហម ព្រមទាំងប្រទេសសម្បូរទៅដោយជនជាតិមូស្លីមក៏ប្រឆាំងនឹងរបបនេះដែរ ប្រទេសទាំងនោះមានដូចជា ប្រទេសបង់ក្លាដេស អេហ្ស៊ីប ឥណ្ឌូនេស៊ី គុយវ៉ែត ម៉ាឡេស៊ី និងនីហ្សេរីយ៉ា ប៉ាគីស្ថាន អារ៉ាប់ប៊ីសាអូឌីត ស៊ូដង់ តួគី សហព័ន្ធអារ៉ាប់អេមេរ៉ាត់ និងប្រទេសម៉ូរីតានី ។ ប្រទេសមូស្លីមមួយចំនួនតូចប៉ុណ្ណោះដែលគាំទ្ររបបនេះមាន ប្រទេសអាហ្វហ្គានីស្ថង់ អាល់ហ្សេរី យេម៉ែន លីប៊ី ស៊ីរី និងប្រទេសឆាដ ។

(តទៅលេខក្រោយ)

អេង កុកថាយ

# សវនាការលើការបង្ហាញឯកសារគន្លឹះ គ្រូវមេធាវីការពារក្ដីធ្វើពហិការ

កាលពីថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៥ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានបើកសវនាការលើការបង្ហាញឯកសារគន្លឹះក្នុងសំណុំរឿងក្ដី០០២ ដំណាក់កាលទី២ ។ សវនាការនេះផ្ដល់ឱកាសដល់ភាគីដាក់បង្ហាញឯកសារគន្លឹះនានាដែលខ្លួនយល់ថា មានការពាក់ព័ន្ធ ជាពិសេសទៅនឹងអង្គហេតុនីមួយៗសម្រាប់ការជំនុំជម្រះ ។

សវនាការនេះធ្វើឡើង ដោយពិចារណាថា ឯកសារភ័ស្តុតាងទាំងអស់ ពុំមែនតែងតែត្រូវបានលើកយកមកបង្ហាញនៅក្នុងអំឡុងពេលនៃការសួរដេញដោលបុគ្គលដែលមកផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនោះទេ ។ ភ័ស្តុតាងមួយចំនួនត្រូវលើកឡើងនៅក្នុងសវនាការនេះ មានដូចជា វីដេអូ ការដកស្រង់អត្ថបទចេញពីសេចក្ដីថ្លែងការណ៍ សៀវភៅ និងសារព័ត៌មាន និងកំណត់ហេតុស្ដាប់ចម្លើយរបស់បុគ្គលមួយចំនួន ព្រមទាំងភ័ស្តុតាងផ្សេងទៀត ។ សវនាការនេះក៏បានផ្ដល់ឱកាសដល់សាធារណជនក្នុងការពិនិត្យមើលឯកសារ ដែលជាផ្នែកមួយនៃការជំនុំជម្រះឲ្យបានទូលំទូលាយនឹងប្រសើរផងដែរ ។

ទម្លាប់នៃការអនុវត្តសវនាការនេះបានធ្វើជាបន្តបន្ទាប់នៅក្នុងសំណុំរឿង០០២ ដំណាក់កាលទី១ នៅពេលសវនាការលើអង្គហេតុនីមួយៗត្រូវបានបញ្ចប់ ហើយត្រូវកម្រិតមកត្រឹមតែការពិភាក្សាលើឯកសារដែលពាក់ព័ន្ធនឹងអង្គហេតុដែលបានជំនុំជម្រះនីមួយៗតែប៉ុណ្ណោះ ។ សវនាការលើការបង្ហាញឯកសារគន្លឹះគឺខុសគ្នាពីនីតិវិធីនៃការទទួលយកឯកសារ ដោយសារ ភាគីអាចយោងទៅលើឯកសារដែលបានដាក់ចំពោះមុខអង្គជំនុំជម្រះរួចហើយ ព្រមទាំង ឯកសារទាំងឡាយដែលភាគីបានកំណត់ថា មាន



ខៀវ សំផន និងមេធាវីធ្វើការប្ដឹងជំទាស់អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា (រូបថត៖ អ.វ.ត.ក)

ភាពពាក់ព័ន្ធទៅនឹងសំណុំរឿង ។ ភាគីពុំគប្បីពិភាក្សាពីភាពទទួលយកបាន ឬមិនទទួលយកបាននៃឯកសារឡើយ ។ ភាគីនានា និងជនជាប់ចោទត្រូវអនុញ្ញាតឲ្យផ្តល់យោបល់លើឯកសារដែលភាគីម្ខាងទៀតបានដាក់បង្ហាញប្រសិនបើភាគីចង់ធ្វើបែបនេះ ។ នៅក្នុងសវនាការនេះ អង្គជំនុំជម្រះបានស្នើដល់ភាគីត្រូវជៀសវាងការបង្ហាញឯកសារច្រំដែលដោយមិនត្រូវជ្រើសរើសឯកសារទាំងឡាយណាដែលត្រូវបានពិភាក្សាពិស្តាក្នុងកិច្ចដំណើរការនីតិវិធីសវនាការពីមុនរួចហើយនោះទេ ។

ចំពោះសវនាការបង្ហាញឯកសារគន្លឹះនេះ ត្រូវធ្វើឡើងទាក់ទងនឹងប្រធានបទការដ្ឋានការងារ ទាំងបី រួមមាន ការដ្ឋានការងារទំនប់១មករា ការដ្ឋានការងារព្រលានយន្តហោះកំពង់ឆ្នាំង និងការដ្ឋានការងារទំនប់ត្រពាំងថ្ម ។ ខណៈដែលភាគីសហព្រះរាជអាជ្ញាកំពុងបង្ហាញឯកសារគន្លឹះទាក់ទងនឹងការដ្ឋានការងារ ទំនប់១មករា តំណាងសហព្រះរាជអាជ្ញាអន្តរជាតិបានស្នើដាក់ឯកសារកំណត់ហេតុស្តាប់ចម្លើយសាក្សី ដែលបានស្លាប់បាត់បង់ជីវិត និងសាក្សីដែលនៅរស់រានមានជីវិត ។ ប៉ុន្តែភាគីមេធាវីការពារក្តីអន្តរជាតិ វ៉ិចទ័រ កូប៉េ បានលើកឡើងថា សវនាការដែលអនុញ្ញាតឲ្យដាក់បង្ហាញឯកសារបៀបនេះ គឺមានលក្ខណៈជាសវនាការសន្និដ្ឋានបិទបញ្ចប់សំណុំរឿងទៅហើយ ។ ដូច្នេះការចូលរួមរបស់ខ្លួនពុំមានអត្ថន័យនោះឡើយ ។ បន្ទាប់មកមេធាវីការពារក្តីទាំងពីរក្រុមដែលការពារក្តីឲ្យ នួន ជា និង ខៀវ សំផន ទាំងមេធាវីជាតិ និងអន្តរជាតិបានសម្រេចចិត្តដើរចេញពីបន្ទប់សវនាការ ។ ភ្លាមៗភាគីសហព្រះរាជអាជ្ញា បានលើកឡើងជាសំណួរថា តើការដកខ្លួនរបស់មេធាវីនៅពេលនេះអាចនឹងត្រឡប់មកការពារក្តីវិញ ឬក៏គួរតែតែងតាំងមេធាវីបម្រុងជំនួសភ្លាម? ចំណែកមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីជាតិ ពេជ អង្គ ដែលពុំបានធ្វើការកត់សម្គាល់ភ្លាមៗនៅពេលដែលអង្គជំនុំជម្រះប្រគល់វេទិកានោះ ប៉ុន្តែ បន្ទាប់ពីអង្គជំនុំជម្រះធ្វើការពិភាក្សាខ្លីមួយ នៅក្នុងបន្ទប់សវនាការរួច បែរជាមេធាវី ពេជ អង្គ បានធ្វើការបញ្ជាក់ពីជំហរថាក្រុមរបស់ខ្លួនមិនគាំទ្រផ្លើរបស់មេធាវីការពារក្តីទេ ដោយសារមេធាវីការពារក្តីមានកាតព្វកិច្ចក្នុងការចូលរួមសវនាការដាក់បង្ហាញឯកសារគន្លឹះ មិនតែប៉ុណ្ណោះមេធាវីការពារក្តីអាចធ្វើសេចក្តីអត្ថាធិប្បាយ និងជំទាស់នៅពេលខាងមុខ ។ លោកបន្តថាការដកខ្លួនចេញពីសវនាការជាការ មិនសមស្របឡើយ ។

ដោយហេតុថា អវត្តមានមេធាវីទាំងភាគីជាតិ និងអន្តរជាតិពុំអនុញ្ញាតឲ្យអង្គជំនុំជម្រះសាលាដំបូងបន្តសវនាការបាន ព្រោះជនជាប់ចោទពុំអាចទទួលការជំនុំជម្រះដោយពុំមានមេធាវីការពារខ្លួនបាននោះ ប្រធានអង្គជំនុំជម្រះបានសម្រេចប្រកាសសម្រាកសវនាការក្នុងថ្ងៃនោះភ្លាម នៅមុនពេលសម្រាកអាហារថ្ងៃត្រង់ដើម្បីដោះស្រាយបញ្ហាដែលកំពុងកើតមាន ។

ដោយផ្អែកលើគោលបំណងនៃការបើកសវនាការលើការដាក់បង្ហាញឯកសារគន្លឹះ គឺដើម្បីបម្រើដល់ផលប្រយោជន៍យុត្តិធម៌ ក៏ដូចជាដើម្បីឲ្យសាធារណជន បានយល់ដឹងប្រសើរជាងមុន ដូច្នេះការលើកយកកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីអាចបម្រើដល់គោលបំណងដ៏សំខាន់នេះ ។ **ឌី សុជាតា**

# រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាន និងកំពុងសរសេរអត្ថបទ ឬ សៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោម ÷

ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥

ទូរស័ព្ទលេខៈ (៨៥៥) (១២) ៩៩៦ ៧៥០

ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨

Email: truthbunthorn.s@dccam.org

Home page: www.dccam.org

# សវនាការស្តាប់សក្ខីកម្មដើមបណ្តឹង រដ្ឋប្បវេណី នួន ណារុំ

នៅថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០១៥ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានបើកសវនាការដើម្បីស្តាប់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី នួន ណារុំ ទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្ម ទំនប់១មករា ។

នៅមុនពេលប្រគល់វេទិកាជូនភាគីទាំងអស់សួរដេញដោលចំពោះសាក្សី ប្រធានអង្គជំនុំជម្រះបានសាកសួរអំពីជីវប្រវត្តិសង្ខេបរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។ ដើមបណ្តឹងរដ្ឋប្បវេណី នួន ណារុំ កើតនៅឆ្នាំ១៩៥៦ នៅស្រុកចម្ការលើ ខេត្តកំពង់ចាម ។ ឪពុកឈ្មោះ អ៊ុយ ឆឹង ម្តាយឈ្មោះ នូ យ៉ែន ស្វាមីឈ្មោះ ពេជ្រ អានីន និងមានកូនចំនួន២នាក់ ។

នៅមុនចាប់ផ្តើមសវនាការ ប្រធានអង្គជំនុំជម្រះបានជម្រាបប្រាប់នូវសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការថ្លែងរៀបរាប់ពីទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្មដែលដើមបណ្តឹងរដ្ឋប្បវេណីធ្លាប់បានទទួលរងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានសាកសួរដើមបណ្តឹងរដ្ឋប្បវេណីអំពីប្រវត្តិសាវតា និងស្ថានភាពរស់នៅរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ដើមបណ្តឹងរដ្ឋប្បវេណីបានរៀបរាប់ថា នៅឆ្នាំ១៩៧៥ គាត់រស់នៅភ្នំពេញជាមួយសាច់ញាតិ និងបានភៀសខ្លួនមកនៅវត្តកោះមួយរយៈ ។ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដើមបណ្តឹងរដ្ឋប្បវេណី និងគ្រួសារ ត្រូវបានខ្មែរក្រហមជម្លៀសចេញពីវត្តកោះមកស្រុកកៀនស្វាយ ។ ពេលធ្វើដំណើរមានការលំបាកយ៉ាងខ្លាំងព្រោះឆ្លងកាត់ស្ពានច្បារអំពៅដែលមានមនុស្សប្រជ្រៀតគ្នា ។ ពេលមកដល់កៀនស្វាយ ខ្មែរក្រហមបានឲ្យគាត់បន្តដំណើររហូតដល់ស្រុកចម្ការលើខេត្តកំពង់ចាម ។ នៅខែមករា ឆ្នាំ១៩៧៧ ដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានចាត់ចូលជាកងចល័ត ធ្វើការនៅទំនប់១មករា ។ នៅទំនប់១មករា ការងារមានការលំបាកខ្លាំងធ្វើការទាំងយប់ទាំងថ្ងៃ គ្មានពេលឈប់សម្រាក បើមិនសកម្មនឹងការងារ និងត្រូវបាត់ខ្លួន ។ កន្លែងសម្រាកមានចម្ងាយ៣គីឡូម៉ែត្រពីការដ្ឋាន ហើយរបបអាហារម្នាក់ៗទទួលបាន១ចានក្នុងមួយពេលដែលមានរុយ៤ទៅ៥ក្បាលនៅក្នុងចាន និងទឹកសម្រាប់បរិភោគគឺជាទឹកប្រឡាយដែលប្រើប្រាស់រួមគ្នាសម្រាប់ផឹក និងសម្អាតខ្លួនប្រាណ ។ នៅពេលនោះ ដើមបណ្តឹងរដ្ឋប្បវេណីមានអាយុ១៨ឆ្នាំត្រូវប្រឹងប្រែងរែកដី ទោះបីជាឈឺ ក៏គាត់មិនដែលហ៊ានឈប់សម្រាកដែរ ។ គាត់ត្រូវបានបំបែកចេញពីម្តាយឲ្យមកធ្វើការនៅការដ្ឋាន ធ្វើឲ្យគាត់មានការនឹករឭកដល់ម្តាយជាពន់ពេក ។ នៅខែកក្កដា ឆ្នាំ១៩៧៧ មានភ្លៀងធ្លាក់ខ្លាំងនៅការដ្ឋានទំនប់១មករាការងារសាងសង់ទំនប់ក៏ត្រូវបានផ្អាក ។ នៅកងចល័ត ដើមបណ្តឹងរដ្ឋប្បវេណីបានធ្លាក់ខ្លួនឈឺក្រពះជាទម្ងន់ ហើយបានសម្រាកនៅពេទ្យចល័ត តែមិនបានធូរស្រាល ប្រធានកងក៏បញ្ជូនគាត់ទៅពេទ្យស្រុក ។ ក្រោយពីចេញពីពេទ្យស្រុក ដើមបណ្តឹងរដ្ឋប្បវេណីបានសុំច្បាប់សម្រាកទៅលេងផ្ទះជាមួយម្តាយបានរយៈពេលប្រហែល ២០ថ្ងៃ ។ រហូតដល់ខែមិថុនា ឬខែកក្កដា ឆ្នាំ១៩៧៨ គាត់ត្រូវខ្មែរក្រហមចាត់ឲ្យធ្វើស្រែ និង កាប់ពោតនៅចម្ការ ។ នៅពេលសម្រាកពីការងារ គាត់បានទទួលដំណឹងពីប្រជាជនផ្សេងទៀតថាម្តាយរបស់គាត់ ព្រមទាំងក្មួយៗ និងប្រជាជន១៧មេសានៅភូមិដែលពួកគាត់ស្នាក់នៅ ត្រូវខ្មែរក្រហមនាំយកទៅសម្លាប់ ។ គាត់មានការរន្ធត់ចិត្ត និងកើតទុក្ខជាខ្លាំងចំពោះដំណឹងនេះ ។

ដើមបណ្តឹងរដ្ឋប្បវេណីបានសាកសួរពីរសំណួរទៅកាន់ជនជាប់ចោទទាំងពីររូប ៖ សំណួរទី១) «ក្មួយតូចៗមិនដឹងអីទេ ប្រាំពីរប្រាំបីនាក់ លោកសម្លាប់មនុស្សម្តងហើយម្តងទៀត រង្គាល តើលោកសម្លាប់ខ្មែរ ចង់យកជាតិសាសន៍ណាមកដាក់?» សំណួរទី២) «ខ្មែរវេទនា លោកនៅឯណា?» ដើមបណ្តឹងរដ្ឋប្បវេណីបានបង្ហាញអារម្មណ៍របស់ខ្លួនបន្ថែមថា «លោកបញ្ជាឲ្យពួកមូលដ្ឋានធ្វើ

បាបពួកយើង សង្កេតការណ៍គ្រប់ទីកន្លែង ក្រសែភ្នែកមើលមកពួកយើងជាមនុស្សថោកទាប» ។

បន្ទាប់ពីការសាកសួរដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី សហព្រះរាជអាជ្ញា បានបន្តការសាកសួរចំពោះដើមបណ្តឹងរដ្ឋប្បវេណី អំពីស្ថានភាពការងារ និងទុក្ខលំបាកដែលដើមបណ្តឹង រដ្ឋប្បវេណីបានទទួលរងនៅការដ្ឋានទំនប់១មករា ។ ដើមបណ្តឹងរដ្ឋប្បវេណីបានថ្លែងរៀបរាប់ថា ការងារប្រចាំថ្ងៃដែលគាត់ និងប្រជាជនដែលជានារីៗផ្សេងទៀត ធ្វើនៅការដ្ឋាន គឺរែកដីមួយម៉ែត្រកន្លះ ឯបុរសៗកាប់ដីចំនួនពីរម៉ែត្រក្នុងមួយថ្ងៃ ។ នៅក្នុងការរែកដី ដើមបណ្តឹងរដ្ឋប្បវេណី មានការឈឺស្មា និងនឿយហត់អស់កម្លាំងជាខ្លាំង តែត្រូវតែទ្រាំធ្វើ ទាំងយប់ទាំងថ្ងៃ ដើម្បីបានរស់រានមានជីវិត ។ ដើមបណ្តឹងរដ្ឋប្បវេណីបានបន្តថា នៅការដ្ឋានមានឈ្លប និងប្រធានកងចាំសង្កេតការងាររបស់ប្រជាជន ។ នៅរៀងរាល់ពីរទៅបីថ្ងៃម្តង មានប្រជុំណែនាំនៅការដ្ឋាន ដោយកំណត់ថា អ្នកណាដែលខ្ជិលធ្វើការ រិលមិនទាន់កង់ប្រវត្តិសាស្ត្រនឹងត្រូវចាត់ទុកថាជាខ្មាំងប្រឆាំងបដិវត្តន៍ ។ នៅអំឡុងពេលធ្វើការនៅទំនប់១មករា រយៈពេល៦ទៅ៧ខែ ដើមបណ្តឹងរដ្ឋប្បវេណីបានដឹងថាមានអ្នកសន្លប់ព្រោះតែធ្វើការងារធ្ងន់ តែមិនដែលដឹងថាមានមនុស្សស្លាប់ទេ ។ គាត់នៅចាំបានថា នៅកងចល័តរបស់ខ្លួនមានមនុស្សម្នាក់ឈឺពោះរាក បានសុំច្បាប់សម្រាក តែប្រធានកងមិនអនុញ្ញាត ហើយថែមទាំងយកដងរែកវាយ និងបន្ថែមការងារដល់មនុស្សម្នាក់នោះទៀតផង ។

តបទៅនឹងការសួរដេញដោលរបស់មេធាវីការពារក្តីជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណីបានឆ្លើយថា នៅពេលធ្វើដំណើរជម្លៀសពីភ្នំពេញមកដល់ស្ទួង ស្ថិតនៅភូមិតាប៉ាវ ខ្មែរក្រហមបានដើរស្រង់ឈ្មោះ និងមុខរបររបស់ប្រជាជនដែលធ្លាប់ធ្វើការងារពីមុនមក ។ នៅពេលនោះ បងថ្លៃរបស់គាត់បានប្រាប់ទៅខ្មែរក្រហមតាមត្រង់ថា ធ្លាប់ធ្វើជាទាហាន លន់ នល់ ក្រោយមកក៏ត្រូវខ្មែរក្រហមនាំខ្លួនយកទៅបាត់ ។

សវនាការក្នុងការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី នួន ណារុំ បានបញ្ចប់នៅព្រឹកថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០១៥ ។

**ឌិន ជួចចន្ទ្រាកែវលក្ខីនារីរតន៍**



អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា

# សវនាការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី សំ សាក់

នៅថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានបើកសវនាការដើម្បីស្តាប់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី សំ សាក់ ទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្ម ទំនប់អាងត្រពាំងថ្ម ។

នៅមុនពេលប្រគល់វេទិកាជូនភាគីទាំងអស់សួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណី ប្រធានអង្គជំនុំជម្រះ បានសាកសួរអំពីជីវប្រវត្តិសង្ខេបរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។ សំ សាក់ កើតនៅថ្ងៃទី១ ខែសីហា ឆ្នាំ១៩៦៣ នៅទឹកដីកម្ពុជាក្រោម ប្រទេសវៀតណាម និងមានទីលំនៅបច្ចុប្បន្ននៅឃុំតាអូរ ស្រុកគិរីវង្ស ខេត្តតាកែវ ។ ឪពុកឈ្មោះ សំ សាន ម្តាយឈ្មោះ កឿង សុង ប្រពន្ធឈ្មោះ គង់ វណ្ណា និងមានកូនចំនួនពីរនាក់ ។

នៅមុនចាប់ផ្តើមសវនាការ ប្រធានអង្គជំនុំជម្រះបានជម្រាបប្រាប់នូវសិទ្ធិរបស់ដើមបណ្តឹងរដ្ឋ ប្បវេណីក្នុងការថ្លែងរៀបរាប់ពីទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្ម ដែលដើមបណ្តឹងរដ្ឋប្បវេណីធ្លាប់បានទទួលរងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានសាកសួរដើមបណ្តឹងរដ្ឋប្បវេណីឲ្យបញ្ជាក់ពីទីកន្លែងកំណើតរបស់ខ្លួន ដែលមានភាពខុសគ្នារវាងអត្តសញ្ញាណប័ណ្ណ និងការឆ្លើយជូនអង្គជំនុំជម្រះនាពេលនេះ ។ ដើមបណ្តឹងរដ្ឋប្បវេណី សំ សាក់ បានឆ្លើយប្រាប់ថា គាត់មានទីកន្លែងកំណើតនៅទឹកដីកម្ពុជាក្រោម ប្រទេសវៀតណាម តែនៅក្នុងអត្តសញ្ញាណប័ណ្ណដាក់ថា សំ សាក់ មានទីកន្លែង កំណើតនៅ ឃុំតាអូរ ស្រុកគិរីវង្ស ខេត្តតាកែវ ព្រោះដើមបណ្តឹងរដ្ឋប្បវេណីបានមករស់នៅទីនេះ ដែលជាស្រុកកំណើតខាងភរិយា ហើយលោកមានបំណងលាក់បាំងពីប្រវត្តិដែលធ្លាប់ធ្វើជាទាហាន និងជាខ្មែរកម្ពុជាក្រោម ។ ដើមបណ្តឹងរដ្ឋប្បវេណីបានថ្លែងរៀបរាប់ពីស្ថានភាពទុក្ខសោកវេទនា និងព្យសនកម្ម ដែលខ្លួនបានទទួលរងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យថា នៅមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ពេលគាត់រស់នៅភ្នំពេញ ។ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ វេលាម៉ោង៥ល្ងាច ខ្មែរក្រហមបានឲ្យគ្រួសាររបស់គាត់ចាកចេញពីភ្នំពេញដោយប្រាប់ថា “សូមបងប្អូនចាកចេញពីភ្នំពេញ ទៅនៅឆ្ងាយភ្នំពេញបីថ្ងៃ ចម្ងាយពីភ្នំពេញបីគីឡូម៉ែត្រ ទម្រាំអង្គការបោសសម្អាតទីក្រុងភ្នំពេញស្អាត” ។ គ្រួសាររបស់ដើមបណ្តឹងរដ្ឋប្បវេណី បានស្នាក់នៅអូរបែកក្អមរយៈពេលពីរបីថ្ងៃ ខ្មែរក្រហមបានបន្តជម្លៀសគ្រួសាររបស់គាត់ឲ្យធ្វើដំណើរបន្តទៅមុខទៀត ។ ពេលនោះគ្រួសាររបស់គាត់នឹកឃើញស្រុកកំណើតនៅកម្ពុជាក្រោម ក៏បាននាំគ្នាធ្វើដំណើរតាមផ្លូវជាតិលេខពីរឆ្ពោះទៅស្រុកកំណើត ។ ពេលធ្វើដំណើរដល់ថ្នល់ទទឹង គ្រួសាររបស់គាត់បានជួបទាហានខ្មែរក្រហម ហើយទាហានខ្មែរក្រហមក៏បានឲ្យគ្រួសារគាត់ទៅរស់នៅភូមិត្រយឹងវិញ ។ ក្រោយមក គ្រួសារគាត់ និងប្រជាជន១៧មេសា ផ្សេងទៀត ត្រូវបានជម្លៀសឲ្យទៅរស់នៅខេត្តពោធិ៍សាត់រយៈពេលពីរបីថ្ងៃ ទើបខ្មែរក្រហមយករថភ្លើងមកដឹកជញ្ជូនទៅស្នាក់នៅស្វាយស៊ីសុផុនមួយយប់ ។ ព្រឹកឡើង ខ្មែរក្រហមបានយកត្រាក់ទ័រមកដឹកប្រជាជនបន្តដំណើរទៅកាន់ទីតាំងផ្សេងៗ ។ គ្រួសារគាត់ត្រូវបានបញ្ជូនទៅនៅភូមិណាំតាវ ឃុំសំរោង ស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ ។ នៅភូមិណាំតាវ ដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានចាត់ឲ្យដើររើសអាចម៍គោ លើកភ្លឺ កាប់ព្រៃឫស្សី ឆ្ការព្រៃ ដើម្បីដាំដំឡូង និងបន្លែ ។ គាត់ស្ថិតនៅក្នុងវ័យកុមារ ត្រូវបង្ខំឲ្យធ្វើការគ្មានពេលកំណត់ ទោះមានភ្លៀង ផ្គរ ត្រជាក់ ក្តៅ យ៉ាងណាក៏ដោយ ។ ចំពោះរបបអាហារដែលទទួលបាន គឺអង្ករមួយកំប៉ុងសម្រាប់មនុស្ស១០នាក់ ។ មួយរយៈក្រោយមក អង្ករមួយកំប៉ុង ត្រូវបែងចែកឲ្យមនុស្ស២០នាក់ទៅ៣០នាក់ ដោយមានចិញ្ច្រាំត្រកួនលាយនៅក្នុងបបរនោះ ។ ខ្មែរក្រហមលាយកន្ទក់ឲ្យប្រជាជនបរិភោគ ដែលមានសុទ្ធតែដង្កូវ គ្មានអនាម័យ ធ្វើឲ្យប្រជាជនមានជំងឺហើម និង

គ្រុនចាញ់ ស្លាប់ជាបន្តបន្ទាប់ ។ ចំណែកការព្យាបាលគឺមានតែថ្នាំអាចម៍ទន្សាយ ដែលតម្រូវគ្រប់ប្រភេទជំងឺ ។ ដើមបណ្តឹងរដ្ឋប្បវេណីមានការឈឺចាប់ជាខ្លាំង ព្រោះតែការធ្វើបាបមកលើខ្លួនឲ្យរស់នៅតែម្នាក់ឯង ។ គាត់សុខចិត្តមកធ្វើជាកងចល័តនៅការដ្ឋានទំនប់អាងត្រពាំងថ្ម ដើម្បីបានបបរបរិភោគ ទោះបីជាខ្លួននៅជាកុមារនៅឡើយ ។ នៅអាងត្រពាំងថ្ម ក្នុងចំណោមកងចល័តគាត់មានវ័យក្មេងជាងគេ ដូចនេះខ្មែរក្រហមបានចាត់ឲ្យគាត់ដឹកខសតាមរទេះគោ យកមកឲ្យចុងភៅសម្រាប់ដាំស្ល ។ ក្រោយពីដឹកខសបានមួយរយៈ គាត់បានទៅរែកដីជាមួយនឹងប្រជាជននៅការដ្ឋាន ។ ការងាររែកដីពិតជាលំបាកខ្លាំង ធ្វើឲ្យគាត់អស់កម្លាំង និងឈឺគ្រុន តែទោះយ៉ាងណាដើមគាត់មិនហ៊ានឈប់ពីការងារ គឺខិតខំប្រឹងប្រែងធ្វើការទាំងឈឺទាំងជាដើម្បីបានរស់ ព្រោះខ្លាចថ្នាក់លើចាប់កំហុសថា ខ្លួនបន្លំធ្វើជាឈឺ ដោយខ្មែរក្រហមមានទ្រឹស្តីមួយថា “គ្រុនញាក់ គ្រុនញ័រ គ្រុនហូបបាយបាន គ្រុនសតិអារម្មណ៍” ។ ដើមបណ្តឹងរដ្ឋប្បវេណីបានឲ្យដឹងថា ទំនប់អាងត្រពាំងថ្មជាសមរភូមិក្តៅ ព្រោះត្រូវធ្វើការងារមិនដឹងថា ភ្លៀង ក្តៅ ផ្គរ រន្ទះ ដឹងតែដល់ម៉ោងចេញធ្វើការ ។ នៅសម័យខ្មែរក្រហម បើមិនធ្វើការងារហើយរួចរាល់តាមការកំណត់ ខ្មែរក្រហមនឹងកាត់របបអាហារ ឬធ្វើស៊ុយទិតៀន ។ ដោយសារការស្រេកឃ្លានពេក គាត់ត្រូវបង្ខំចិត្តដើររើសឆ្អឹងត្រី និងទឹកបាយដែលគេជញ្ជាត់ចោលមកបរិភោគ ។

នៅក្នុងកងចល័ត គាត់បានដឹងថា មានគេយកមនុស្សទៅសម្លាប់ ហើយមានអ្នកជំងឺឈឺគ្រុន និងខ្វាក់មាន់ ។ ខ្មែរក្រហមបានធ្វើពិសោធន៍អ្នកខ្វាក់មាន់ថា ពិតជាខ្វាក់មែន ឬធ្វើពុត ដោយឲ្យអ្នកដែលខ្វាក់មាន់ដើរចូលបង្គន់ បើអ្នកដែលខ្វាក់មាន់ពិតប្រាកដ ពេលដើរទៅប្រាកដជាធ្លាក់ចូលបង្គន់ ហើយអ្នកដែលបន្លំនឹងហក់រំលងបង្គន់ ។ បន្ទាប់ពីការពិសោធន៍ អ្នកដែលបន្លំថាខ្វាក់មាន់ នឹងត្រូវខ្មែរក្រហមនាំខ្លួនយកទៅបាត់ មិនឃើញត្រឡប់មកវិញ ។

នៅសម័យខ្មែរក្រហម ដើមបណ្តឹងរដ្ឋប្បវេណីមានការឈឺចាប់ព្រោះត្រូវបាត់បង់សាច់ញាតិខាងម្តាយរបស់ខ្លួនចំនួនពីរគ្រួសារ ។ ប្អូនម្តាយគាត់ម្នាក់ធ្លាប់ធ្វើជាទាហាន លន់ នល់ ពាក់សក្តិ៥ ត្រូវបានខ្មែរក្រហមសម្លាប់ទាំងគ្រួសារ ។

ឆ្លើយតបទៅសហព្រះរាជអាជ្ញា អំពីលក្ខខណ្ឌការងារនៅការដ្ឋានទំនប់អាងត្រពាំងថ្ម ដើមបណ្តឹងរដ្ឋប្បវេណីបានប្រាប់ថា ពេលវេលាធ្វើការមានបីពេល ព្រឹកម៉ោង៤ ឬម៉ោង៥ កងចល័តទាំងអស់ត្រូវក្រោកចេញទៅធ្វើការតាំងពីមិនទាន់មើលឃើញមុខគ្នាច្បាស់ គឺឮតែសំឡេងចបជីក និងបង្គី ។ នៅម៉ោង១១ថ្ងៃត្រង់ទើបសម្រាកបរិភោគអាហារ និងចាប់បន្តការងារនៅម៉ោង១រសៀលដល់ម៉ោង៥ ហើយចាប់ពីម៉ោង៧យប់ រហូតដល់ម៉ោង១០យប់ ។

ដើមបណ្តឹងរដ្ឋប្បវេណីបានឆ្លើយជូនសហមេធាវីការពារក្តីថា លោកចាប់ផ្តើមធ្វើការនៅទំនប់អាងត្រពាំងថ្មនៅឆ្នាំ១៩៧៧ រហូតដល់ថ្ងៃរំដោះ១៩៧៩ ។ ចំពោះស្ថានភាពអ្នកជំងឺនៅការដ្ឋាន គាត់មិនដែលដឹងថាមានការបញ្ជូនអ្នកជំងឺទៅព្យាបាលនៅមន្ទីរពេទ្យ ព្រោះពេលដែលគាត់មានជំងឺ គឺទទួលបានតែថ្នាំអាចម៍ទន្សាយសម្រាប់លេបតែប៉ុណ្ណោះ ។

**ឌិន ជួងចន្ទ្រាកែវលក្ស្មីនារីរតន៍**

# ដំណឹងស្វែងរកប្អូនស្រី

ខ្ញុំបាទឈ្មោះ ហង់ ខេត ភេទប្រុស អាយុ៦០ឆ្នាំ បច្ចុប្បន្នរស់នៅភូមិជ្រៃ ឃុំបឹងបេង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ។ សូមប្រកាសស្វែងរក ហង់ សាម៉ូត ភេទស្រី ត្រូវជាប្អូនស្រីពៅ (បច្ចុប្បន្ន អាយុប្រហែល៥៤-៥៥ឆ្នាំ) មានស្រុកកំណើតនៅភូមិត្រពាំងអណ្តើក ឃុំបឹងស្រងែ ស្រុកត្រាំកក់ ខេត្តតាកែវ ។ កាលពីសម័យខ្មែរក្រហម សាម៉ូត ធ្វើជាកងនារីតំបន់ ស្រុកត្រាំកក់ មានឪពុកឈ្មោះ ជ័យ ឃុន និងម្តាយ ឈឹម ណេង ។ មានបងប្អូនបង្កើត៧នាក់ (ប្រុស២ ស្រី៥នាក់) ។

បងប្អូនណាបានឮសូមទាក់ទងមេភូមិជ្រៃ ទូរស័ព្ទលេខ ០៩៧ ៣ ១៧៨ ៩៦៧ ឬ ទំនាក់ទំនងមកមជ្ឈមណ្ឌលឯកសារកម្ពុជា ផ្ទះលេខ៦៦, មហាវិថីព្រះសីហនុ, រាជធានី ភ្នំពេញ ឬ តាមរយៈទូរស័ព្ទ ០២៣ ២១១ ៨៧៥ ។

***សូមអរគុណ!***

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ភ្នំពេញ ថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០១៥

# សេចក្តីប្រកាសព័ត៌មាន
## បទចោទប្រកាន់អំពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ នឹងត្រូវលើកមកសួរដេញដោលជាលើកដំបូងនៅចំពោះមុខ អ.វ.ត.ក

ចាប់ពីថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១៥ តទៅ ហើយក៏ជាលើកទី១ដែរ ដែលអង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) នឹងបើកសវនាការដេញដោលលើភស្តុតាងទាក់ទងនឹងបទចោទប្រកាន់ពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ នៅពេលដែលការជំនុំជម្រះក្តីលើសំណុំរឿង ០០២/០២ ប្រឆាំងនឹងជនជាប់ចោទ ខៀវ សំផន និង នួន ជា បានឈានដល់ការជំនុំជម្រះលើអង្គហេតុថ្មីមួយទៀតផ្តោតលើការចោទប្រកាន់ទាក់ទងនឹងការប្រព្រឹត្តទៅលើក្រុមជនជាតិចាម។ សាក្សី និង ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១៤ រូប និង អ្នកជំនាញ ១រូប នឹងត្រូវកោះហៅមកផ្តល់សក្ខីកម្មនៅអំឡុងពេលនៃការជំនុំជម្រះលើអង្គហេតុនេះ។

ជនជាតិចាមគឺជាជនជាតិភាគតិចមួយនៅក្នុងប្រទេសកម្ពុជាដែលមានភាសាដូចគ្នា វប្បធម៌ដូចគ្នា និងសាសនាដូចគ្នាគឺសាសនាឥស្លាម។ យោងតាមដីកាដំណោះស្រាយ ជនជាតិចាមត្រូវបានគេកំណត់មុខសញ្ញា និងសម្លាប់ជាលក្ខណៈប្រព័ន្ធ ហើយបក្សកុម្មុយនីស្តកម្ពុជាបានអនុវត្តគោលនយោបាយបំផ្លិចបំផ្លាញទាំងស្រុង ឬ មួយផ្នែកលើក្រុមជនជាតិចាម។ ដីកាដំណោះស្រាយបានបង្ហាញថា ជនជាតិចាមត្រូវបានកំណត់គោលដៅជាលក្ខណៈប្រព័ន្ធ ហើយត្រូវបានសម្លាប់ ដោយសារតែសមាជិកភាពរបស់ពួកគេនៅក្នុងក្រុមជនជាតិចាមនេះ ហើយក៏ត្រូវបានផ្លាស់ទីលំនៅដោយបង្ខំ និង បានបញ្ចូលទៅក្នុងភូមិរបស់ប្រជាជនខ្មែរ ព្រមទាំងបានហាមឃាត់មិនឱ្យមានការគោរពប្រតិបត្តិសាសនារបស់ពួកគេផងដែរ។ តាមដីកាដំណោះស្រាយដដែល ថ្នាក់ដឹកនាំសាសនាឥស្លាម និង ប្រជាជនចាស់ទុំ និង អ្នកដែលនៅតែបន្តអនុវត្តសាសនារបស់ពួកគេនឹងត្រូវឃុំខ្លួន ហើយបន្ទាប់មកនឹងត្រូវសម្លាប់ចោល។ វប្បធម៌ និង ភាសាចាម ហើយនឹងសម្លៀកបំពាក់របស់បងប្អូនចាម ត្រូវបានហាមឃាត់។ ដីកាដំណោះស្រាយបានបង្ហាញភស្តុតាងថា ជនជាតិចាមប្រមាណ ៣៦% នៅក្នុងប្រទេសកម្ពុជាត្រូវបានសម្លាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ដីកាដំណោះស្រាយ ក៏បានចោទប្រកាន់ថា នួន ជា និង ខៀវ សំផន តាមរយៈតួនាទីផ្សេងៗរបស់គាត់ក្នុងបក្សកុម្មុយនិស្តកម្ពុជា គឺជាអ្នកទទួលខុសត្រូវជាបុគ្គលចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងប្រឆាំងនឹងក្រុមជនជាតិចាម។

សំណុំរឿង ០០២/០២ គឺជាការជំនុំជម្រះក្តីលើកទី២ ប្រឆាំងនឹង នួន ជា និង ខៀវ សំផន ដោយរាប់បញ្ចូលបទចោទប្រកាន់អំពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ប្រឆាំងនឹងជនជាតិចាម និង ជនជាតិវៀតណាម ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និង ការរំលោភផ្លូវភេទនៅក្នុងបរិបទនៃការរៀបអាពារហ៍ពិពារហ៍ដោយបង្ខំ ការ

បោសសម្អាតផ្ទៃក្នុង ការប្រព្រឹត្តមកលើពុទ្ធសាសនិកជន និង ការកំណត់គោលដៅមកលើអតីតមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅមន្ទីរសន្តិសុខចំនួន ៤ ការដ្ឋានការងារចំនួន ៣ និងសហករណ៍មួយ។ មុនពេលចាប់ផ្តើមការជំនុំជម្រះលើអង្គហេតុនៃការប្រព្រឹត្តិលើជនជាតិចាមនេះ អង្គជំនុំ-ជម្រះសាលាដំបូង សូមរម្លឹកឡើងវិញថា អង្គជំនុំជម្រះបានបញ្ចប់សវនាការសួរដេញដោលលើអង្គហេតុសហករណ៍ និង ការដ្ឋានការងារចំនួន ៣ ដោយបានស្តាប់សក្ខីកម្មរបស់បុគ្គលចំនួន ៦៥ រូបក្នុងនោះរួមមានសាក្សីចំនួន ៣៩ រូប ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ២៥ រូប និង អ្នកជំនាញចំនួន ១ រូប នៅក្នុងអំឡុងពេលសវនាការចំនួន ៩៨ ថ្ងៃ។

ព័ត៌មានបន្ថែមលើបទចោទប្រកាន់ទាក់ទងនឹងការប្រព្រឹត្តទៅលើជនជាតិចាម លោកអ្នកអាចស្វែងរកបាននៅលើគេហទំព័ររបស់អ.វ.ត.ក http://www.eccc.gov.kh/en/node/34168

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

**លោក ឡាស អូលសិន**
មន្ត្រីផ្នែកច្បាប់
ទូរស័ព្ទចល័តៈ +៨៥៥ (០) ១២ ៤៨៨ ០២៣
សារអេឡិកត្រូនិកៈ olsenl@un.org

**លោក នេត្រ ភក្ត្រា**
មន្ត្រីនាំពាក្យសាលាក្តីខ្មែរក្រហម
ទូរស័ព្ទចល័តៈ +៨៥៥ (០) ១២ ៤៨៨ ១៥៦
សារអេឡិចត្រូនិកៈ neth.pheaktra@eccc.gov.kh



*ជនជាតិចាមនៅវិហារ*

# តើប្រជាជនចាមត្រូវបានសម្លាប់ដោយសារតែអត្តសញ្ញាណរបស់ខ្លួនឬ?

ដោយមានការចាប់ផ្តើមនូវសវនាការដេញដោលពីបទប្រល័យពូជសាសន៍ លើមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមក្នុងសប្តាហ៍នេះ ការប្រព្រឹត្តលើជនជាតិចាម គឺជាចំណុចផ្តោត អមជាមួយនឹងការតស៊ូមតិថា តើរបប ប៉ុល ពត ត្រូវជាប់ចោទពីបទឧក្រិដ្ឋប្រល័យពូជសាសន៍ឬយ៉ាងណា ។

ខ្ញុំមានឱកាសសិក្សាអំពីជោគវាសនារបស់ជនជាតិចាមក្រោមរបបខ្មែរក្រហម ហើយខ្ញុំជឿថា អ្វីដែលបានកើតឡើងលើអ្នកទាំងនេះគឺបង្កឡើងដោយអំពើប្រល័យពូជសាសន៍ ។ ដើម្បីបញ្ជាក់ថា ឧក្រិដ្ឋកម្មរបស់ខ្មែរក្រហមលើជនជាតិចាមជាអំពើប្រល័យពូជសាសន៍ គេត្រូវស្វែងរកឲ្យឃើញថាជនជាតិចាមត្រូវបានសម្លាប់ដោយសារតែគេជាជនជាតិចាម ។

ខ្មែរក្រហមបានប៉ុនប៉ងជាច្រើនលើកច្រើនសារក្នុងការលុបបំបាត់អត្តសញ្ញាណចម្បងរបស់ជនជាតិចាម ។ ខ្មែរក្រហមបានប្រើប្រាស់ទាំងវិធីសាស្ត្រទន់ភ្លន់ និងឃោរឃៅ ដើម្បីសម្រេចគោលបំណងនេះ ។ វិធីសាស្ត្រទន់ភ្លន់របស់គេគឺ ការរារាំងសាសនាអ៊ីស្លាម រួមមាន បង្ខំជនជាតិចាមឲ្យបរិភោគសាច់ជ្រូក បង្ខំឲ្យស្ត្រីកាត់សក់ខ្លី ហាមឃាត់ការស្លៀកសម្លៀកបំពាក់បែបប្រពៃណី ដុតគម្ពីរគួរ៉ាន់ បិទឬបំផ្លាញវិហារអ៊ីស្លាម ហាមប្រាមមិនឲ្យថ្វាយបង្គំ ហាមប្រើប្រាស់ភាសាចាម និងប្តូរឈ្មោះពីជនជាតិចាម មកជាឈ្មោះខ្មែរវិញ ។

ខ្មែរក្រហមក៏បានបំបែកសហគមន៍ជនជាតិចាមឲ្យទៅជាគ្រួសារតូចៗ និងដាក់គ្រួសារទាំងនោះ ឲ្យរស់នៅក្នុងភូមិខ្មែរទូទាំង


ពិធីរៀបការឆ្លងសាសន៍ រវាងជនជាតិចាម និងជនជាតិខ្មែរ

ប្រទេស ។ កាលពីបូរាណកាល ប្រជាជនចាមត្រូវរស់នៅក្នុងសហគមន៍ប្រមូលផ្តុំ ដែលមានហេដ្ឋារចនាសម្ព័ន្ធបែបវប្បធម៌ និងសាសនា ដែលអាចផ្គត់ផ្គង់ខ្លួនបាន ។ វិធីសាស្ត្រដ៏ឃោរឃៅដែលខ្មែរក្រហមបានប្រើប្រាស់ក្នុងការសម្លាប់ជនជាតិចាមថ្នាក់ខ្ពស់ រួមមាន គ្រូសាសនា ដែលត្រូវបានហៅថា "ហាកឹម" និង "ទួន" អ្នកដែលបានបំពេញធម្មយាត្រា ហៅថា "ហាជីស" អ្នកនយោបាយ និងការសម្លាប់ជនជាតិចាមសាមញ្ញ ។

ជនជាតិចាមបានធ្វើការតស៊ូ និងបះបោរ នៅចុងខែកញ្ញា និងដើមខែតុលា ឆ្នាំ១៩៧៥ នៅ កោះផល និងស្វាយឃ្លាំង ដែលបង្កជាផលប៉ះពាល់ធ្ងន់ធ្ងរលើប្រជាជនចាមនៅក្រូចឆ្មារ ក៏ដូចជាអ្នកដែលនៅភូមិភាគបូព៌ាទាំងអស់ ព្រមទាំងតំបន់ផ្សេងទៀតផងដែរ ។ នៅក្នុងឆ្នាំ១៩៧៨ អ្នករស់រានមានជីវិតបានរាយការណ៍អំពីការសម្លាប់រាលដាលលើពូជសាសន៍ជនជាតិចាម ជាពិសេសការសម្លាប់ធ្វើឡើងដោយសារតែអ្នកទាំងនោះមានឈ្មោះ ចាម ឬដោយសារតែមានភ័ស្តុតាងខ្លះបញ្ជាក់ពីទំនាក់ទំនងរបស់អ្នកទាំងនោះទៅនឹងជាតិពន្ធុចាម ។ ការកាប់សម្លាប់ក៏អាចប្រព្រឹត្តទៅតាមរយៈការធ្វើបន្សុទ្ធកម្មឥតឈប់ឈរដែលកើតមានឡើងនៅក្នុងភូមិភាគកណ្តាល និងភូមិភាគបូព៌ានៅក្នុងរយៈពេលដូចគ្នានេះ ។

នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៧៥ កម្មាភិបាលជាន់ខ្ពស់ខ្មែរក្រហមឈ្មោះ ឆុន បានផ្ញើសារទូរលេខ លេខ១៥ ជូនដល់ ប៉ុល ពត និងចម្លងជូន នួន ជា ។ សារទូរលេខនេះ ក៏ត្រូវបានចម្លងទុកសម្រាប់មន្ត្រីខ្មែរក្រហមពីររូបទៀត ដែលមានឈ្មោះ ខៀន និង យែម ។ យោងតាមសារទូរលេខនេះ ឆុន បានសរសេរឆ្លើយតបនឹងបញ្ហាពីមុន ឬមុនៗ ស្តីពីការជម្លៀសប្រជាជនចាម ចេញពីតំបន់របស់គេ ដែលស្ថិតនៅតាមជ្រោយខាងកើតដងទន្លេមេគង្គ ដែលចេញបញ្ជាផ្ទាល់ដោយមជ្ឈិមបក្សនៅភ្នំពេញ ។ ឆុន បានបញ្ជាក់យ៉ាងច្បាស់ថា ជា "យុទ្ធសាស្ត្រពង្រាយប្រជាជន ដែលបានពិភាក្សាក្នុងកិច្ចប្រជុំកាលពីលើកមុន" ។ ឆុន បានសន្និដ្ឋានថា ជនជាតិចាមប្រមាណ ១៥០.០០០ នាក់ ក្នុងភូមិភាគបូព៌ា ត្រូវបានបញ្ជូនទៅកាន់ភូមិភាគពាយ័ព្យ និងឧត្តរ ។

តាមការប៉ាន់ស្មានពីមុនជនជាតិចាមដែលបានស្លាប់ក្រោមរបបខ្មែរក្រហម គឺមានប្រមាណមួយភាគបី ។ ស្មើជាងមួយភាគបួននៃប្រជាជនកម្ពុជាទាំងអស់ដែលបានស្លាប់ក្នុងរបបខ្មែរក្រហម ។ នេះមានន័យថា ជនជាតិចាមបានស្លាប់ក្នុងអត្រាខ្ពស់ជាងជនជាតិខ្មែរកាន់ព្រះពុទ្ធសាសនា ។ ដោយសារតែខ្មែរក្រហមតម្រង់គោលដៅទៅលើអ្នកទាំងនោះដោយប្រើនូវគោលការណ៍ពីខ្ពស់ទៅទាប រួមមាន ការសម្លាប់អ្នកមានចំណេះដឹង បុព្វជិតសាសនា មេដឹកនាំសហគមន៍ និងអ្នកភូមិ សូម្បីតែស្ត្រីដូច្នេះការកម្ចាត់ចោលនូវប្រជាជនចាមប្រមាណមួយភាគបី គឺជាឧបសគ្គដ៏ធ្ងន់ធ្ងរមួយសម្រាប់ជនជាតិចាមក្នុងការពង្រឹងនូវអត្តសញ្ញាណរបស់ខ្លួន ។

យោងតាមលោក អ៊ីសា ឧស្មាន អ្នកចេះដឹងជនជាតិចាមជាច្រើនបានស្លាប់ក្នុងអំឡុងរបបខ្មែរក្រហម ។ ក្នុងចំណោម ហាកឹម ចំនួន ៣៣៩ នាក់ មានតែ ៤៥ នាក់ ប៉ុណ្ណោះដែលរួចរស់ជីវិតនៅក្នុងឆ្នាំ១៩៧៩ ។ ទួន ចំនួន២៦២ នាក់ (ក្នុងចំនួនសរុប ៣០០ នាក់) ត្រូវបានសម្លាប់ ។ នៅឆ្នាំ១៩៧៤ មាន ហាជីស ចំនួន ១.០០០ នាក់ តែនៅឆ្នាំ១៩៧៩ នៅសល់ ហាជីស តែ៣០ នាក់ប៉ុណ្ណោះ ។ មាននិស្សិតតែពីរនាក់ប៉ុណ្ណោះ ក្នុងចំណោមនិស្សិតដែលវិលត្រឡប់ពីបរទេស ចំនួន២៦ នាក់ ដែលនៅសេសសល់ ។ មន្ត្រីសាសនាជាន់ខ្ពស់ឈ្មោះ រ៉ាចា ធិបតី រេស ឡះ អមជា មួយនឹងអនុរបស់គាត់ពីរូបទៀតត្រូវបានសម្លាប់ ។

ដោយសារតែការបំផ្លាញសាលារៀន វិហារ គម្ពីរគួរ៉ាន់របស់ជនជាតិចាម ការផ្លាស់ប្តូរ ឈ្មោះ និងបម្រាមលើភាសាចាម ជនជាតិចាមត្រូវប្រឹងប្រែងយ៉ាងខ្លាំងក្លាក្នុងការស្តារឡើងវិញនូវអត្តសញ្ញាណរបស់ខ្លួនបន្ទាប់ពីរបបខ្មែរក្រហម ។ **អេង កុកថាយ**

## អានទស្សនាវដ្តីតាមគេហទំព័រ

ទស្សនាវដ្តីស្វែងរកការពិតទាំងអស់ត្រូវបានផ្សព្វផ្សាយតាមគេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ អ្នកអានអាចរកបានតាមៈ *http://d.dccam.org/Projects/Magazines/Magazine_Searching.htm* ។ ព័ត៌មានបន្ថែម សូមទាក់ទង សោម ប៊ុនថន ទូរស័ព្ទលេខ ០១២ ៩៩៦ ៧៥០ ឬ ០២៣ ២១១ ៨៧៥ ។

# មានសំណាងរស់រួចព្រោះឆ្លើយថា «ខ្ញុំមិនចាំ»

សុខ ថៃ ដែលមានឈ្មោះដើម គីន ថាយ មានអាយុត្រឹមប្រាំពីរឆ្នាំប៉ុណ្ណោះ ពេលដែលកងទ័ពខ្មែរក្រហមចូលដល់ទីក្រុងភ្នំពេញ ។

ថៃ បាននិយាយថា នៅល្ងាចថ្ងៃទី១៦ មេសា ឆ្នាំ១៩៧៥ ទីក្រុងភ្នំពេញមានសភាពជ្រួលច្របល់ដែលគាត់មិនដែលជួបប្រទះពីមុនមក ។ ល្ងាចនោះ សាច់ញាតិរបស់គាត់បានមកគោះទ្វារផ្ទះហៅឪពុកគាត់ចាកចេញពីទីក្រុង តែឪពុកជំទាស់ ។ នៅថ្ងៃបន្ទាប់គឺនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ប្រជាជននៅក្នុងទីក្រុងហាក់ដូចជាសប្បាយ និងអបអរសាទរយោធាអាវខ្មៅ ហើយនៅតាមផ្លូវ មានមនុស្សកុះករក្រវីទង់សដើម្បីស្វាគមន៍យោធាទាំងអស់នោះ ។ បន្តិចក្រោយមក យោធាទាំងនោះ បានបញ្ជាឲ្យប្រជាជនទាំងអស់ចេញពីទីក្រុង ។ ឪពុកម្ដាយរបស់ ថៃ ចាកចេញពីទីក្រុងតាមផ្លូវកាត់មុខព្រលានយន្តហោះ ។ ពេលទៅដល់មុខព្រលានយន្តហោះ ថៃ ឃើញទីនោះត្រូវបានភ្លើងឆេះយ៉ាងសន្ធោសន្ធៅ ។ ពេលទៅមុខបានបន្តិចហួសព្រលានយន្តហោះ យោធាខ្មែរក្រហមមួយក្រុមដែលមានគ្នាប្រមាណជាដប់នាក់ បានឃាត់រថយន្តឪពុកគាត់ឲ្យឈប់ និងឆែកឆេរនៅក្នុងរថយន្តនោះដោយយកសម្ភារមានតម្លៃនៅក្នុងនោះចេញ ។ ថៃ ឃើញច្បាស់គឺថាយោធាខ្មែរក្រហមបានយកនាឡិកាដៃរបស់ឪពុកគាត់ ។

ឪពុកម្ដាយរបស់ ថៃ បានបន្តដំណើរទៅមុខទៀតទៅដល់រង្វង់មូលចោមចៅ រួចចូលទៅផ្លូវជាតិលេខ៣ឆ្ពោះទៅកាន់ខេត្តកំពត ។ ការធ្វើដំណើរប្រកបដោយភាពណែនណាន់តាន់តាប់ពោរពេញដោយមនុស្សម្នាកកស្ទះយ៉ាងខ្លាំង ។ «ឪពុកម្ដាយខ្ញុំខិតខំរុញឡានដែលផ្ទុកឥវ៉ាន់ក្នុងនោះដើរទៅជាមួយហ្វូងមនុស្សទាំងនោះ» ។ ការធ្វើដំណើរជួបប្រទះនូវភាពនឿយហត់ជាខ្លាំង អ្នកខ្លះដួលសន្លប់ អ្នកខ្លះស្លាប់ក៏មាន ក្នុងនោះក៏មានមីងម្នាក់របស់ ថៃ ដែរ «មីងខ្ញុំបានស្លាប់ពេលជម្លៀសតាមផ្លូវ ដោយសារតែគាត់ហេវហត់ខ្លាំងពេក ហើយគាត់មិនដែលជួបប្រទះនូវការលំបាកបែបនេះ» ។

មួយរយៈខ្លីក្រោយមក គ្រួសាររបស់ ថៃ បានទៅដល់ទីរួមស្រុកឈូក ។ កម្មាភិបាលខ្មែរក្រហមបានបង្គាប់ឲ្យគ្រួសាររបស់គាត់បត់ទៅទិសខាងជើងត្រង់ម្តុំភូមិស្រះចក រួចឲ្យរស់នៅតំបន់នោះ ជាមួយគ្រួសារអ្នកមកទីក្រុងផ្សេងទៀត ។ នៅទីនោះឪពុករបស់ ថៃ ស្គាល់អ្នកភូមិម្នាក់ ហើយគាត់ក៏ស្នាក់នៅផ្ទះនោះដែរ ។ ថៃ រំឭកថា ផ្ទះនោះគឺជាផ្ទះធំបន្ទូរដែលម្ចាស់ផ្ទះប្រហែលជាកសិករថ្នាក់កណ្ដាល ព្រោះគ្រួសារមានជីវភាពសមរម្យ ។ ក្រោយមក កម្មាភិបាលខ្មែរក្រហមបានចាត់តាំងឲ្យគ្រួសាររបស់ ថៃ ទៅនៅកន្លែងផ្សេង ។ ខ្មែរក្រហមបានជម្លៀសគ្រួសារគាត់មកនៅវត្តមួយមិនឆ្ងាយប៉ុន្មានពីគ្រួសារដែលនៅជាមួយពីមុនប៉ុន្មានទេ ទីកន្លែងនោះហើយដែលគាត់បានបាត់ប្អូនប្រុសរបស់គាត់ ។ ប្អូនប្រុសរបស់ ថៃ ស្លាប់មិនបានប៉ុន្មានម៉ោងទេ បន្ទាប់ពីគ្រូពេទ្យអង្គការចាក់ថ្នាំមួយម្ជុលដោយជំងឺរាកមួល ពេលនោះម្ដាយរបស់គាត់ស្រែកយំយ៉ាងខ្លាំង ។

ប៉ុន្មានថ្ងៃក្រោយមកអង្គការបានបញ្ជូនគ្រួសារ ថៃ មកនៅភូមិសត្វពង ឃុំបានាវ ស្រុកឈូក (ខាងត្បូងផ្សារឈូក) ខេត្តកំពត ។ ឪពុករបស់ថៃឈ្មោះ ស៊ី ប៉ិចជី ម្ដាយឈ្មោះ តាន់ លាន ពេលមករស់នៅភូមិនោះមួយរយៈ អង្គការបានបញ្ជូនគាត់ទាំងពីរទៅលើកទំនប់ប្រឡាយ និងធ្វើស្រែចម្ការដូច អ្នក១៧ មេសា ផ្សេងទៀតដែរ ។ ប៉ុន្មានខែក្រោយមក អង្គការបានបញ្ជូន ថៃ ទៅកងកុមារ ។ ម្ដាយរបស់គាត់ទៅកងចល័តនារី ។ ឪពុកគាត់ជាអ្នកសែងលាមកដាក់ស្រែ ។ ថៃ បានជួបឪពុកគាត់ម្ដងម្កាលប៉ុណ្ណោះ ។ គាត់ឃើញឪពុកគាត់ស្គម គ្មានសាច់ឈាម ដើងដើរមិនបានលឿនដូចកសិករផ្សេងទៀត ។ ក្រោយមកគ្រួសារ ថៃ កាន់តែមិនសូវបានជួបគ្នាទៀត ។ គាត់បានជួបម្ដាយនៅពេលយប់ ដោយសារ ថៃ រត់ពីកងកុមារទៅជួបម្ដាយនៅភូមិផ្សេង ។ សម័យកាលនោះ កងចល័តច្រើនតែស្នាក់នៅក្នុងខ្ទមស្លឹកត្នោត ។ ច្រើនខែកន្លងទៅ នៅវេលាល្ងាចមួយអ្នកភូមិបានមកប្រាប់គាត់ថា «ឪពុកម្ដាយឯងត្រូវបានអង្គការបញ្ជូនទៅរៀនសូត្រហើយ» ប៉ុន្តែពេលនោះ ថៃ ហាក់ដូច

ជាមិនមានការភ័យ ឬពិបាកចិត្តទេគាត់មានតែឆ្លើយតបថា "តែកាលណា អ្នកណាគេធ្វើខុស អង្គការឲ្យទៅរៀនសូត្រហើយ" ។ នេះជាពាក្យសម្ដីក្មេងដែលបានលាងខួរក្បាលយ៉ាងស្អាតពីអង្គការ ។ ល្ងាចថ្ងៃក្រោយមក អ្នករស់នៅកងកុមារដូចគ្នាបានប្រាប់គាត់ថា ថ្ងៃស្អែកអង្គការនឹងបញ្ជូន ថៃ ទៅជួបឪពុកម្ដាយហើយ ។ ថៃ មិនមានភ័យតក់ស្លុតទេ ។ បើទោះជាគាត់បានឃើញសឹងតែរាល់ល្ងាចថ្ងៃលិច ។ មានកងឈ្លបម្នាក់ ឬពីរនាក់បណ្ដើរមនុស្សធំមួយខ្សែបួនដប់នាក់ ដោយមិនឲ្យនិយាយ ឬងាកឆ្វេងស្ដាំឡើយ ។ អ្នកទាំងនោះមើលទៅហាក់ដូចជាគោរពកោតខ្លាចអង្គការណាស់ ព្រោះពេលនោះគាត់មិនបានដឹងថា យកមនុស្សទៅសម្លាប់ទេ ។

ថៃ នៅចាំបានថាល្ងាចដែលអង្គការប្រមូលកុមារផ្សេងទៀតប្រហែលជាជាង១០នាក់ ។ កុមារដែលមានវ័យច្រើនជាងគាត់បានស្រែកយំដោយតក់ស្លុត ដោយសារអ្នកទាំងនោះហាក់ដូចជាបានដឹងរឿងអ្វីមួយមុនអ៊ីចឹង ។ នៅល្ងាចនោះ អង្គការបានរៀបបាយសម្លឲ្យហូបតែអ្នកទាំងអស់មិនព្រមហូបទេ ហើយចេះតែយំមិនឈប់សោះ ។ ថៃ មិនបានភ័យព្រួយអ្វីទេ ។ នៅយប់នោះបន្ទាប់ពីហូបបាយនៅរោងសហករណ៍ អង្គការបានបញ្ជូនគាត់មកដេកនៅផ្ទះក្បឿងធំមួយដោយមិនមានវត្តមានកុមារផ្សេងទៀតដែលយំនៅរោងបាយនោះទេ ។ គាត់មិនដឹងថាគេយកមនុស្សក្រុមនោះទៅទីណាទេ ។ គាត់ដេកនៅផ្ទះក្បឿងធំនោះតែឯង ហើយក៏មិនមានភ័យតក់ស្លុតដោយសារតែភាពងងឹតត្រជាក់នៅក្នុងភាពសាត់ជ្រងំ ។ លុះស្អែកឡើង អ្នកបរទេះគោ ឈប់សម្រាកនៅមុខផ្ទះ ហើយនិយាយថា ថៃ! ពូមកនាំឯងទៅជួបម៉ែឪឯង ទៅតាមផ្លូវអ្នកបរទេះមិនមាននិយាយអីក្រៅពី ថាបន្តិចទៀតឯងបានជួបឪម៉ែឯងហើយ ។

ក្រោយមក គាត់បានមកដល់វិទ្យាបាក់បែកមួយមានដើមស្វាយ និងដូងដុះជុំវិញផ្ទះ ។ ពេលនោះ អ្នកបរទេះបាននាំគាត់ទៅជួបសន្តិសុខ ។ ថៃ មិនដឹងថា ពួកគេនិយាយអ្វីទេ ។ សន្តិសុខម្នាក់បាននាំគាត់ទៅមុខអាគារឈើវែងមួយមានចាក់សោពីក្រៅ ។ សន្តិសុខបើកទ្វារុញ ថៃ ចូល ហើយប្រាប់ថា ទៅដេកនៅលើរនាបឫស្សី ។ ពេលនោះ ថៃ មានការតក់ស្លុតយ៉ាងខ្លាំងដោយឃើញទិដ្ឋភាពយ៉ាងវេទនា ។ ថៃ បានឃើញអគារឈើនោះ ដែលមានគ្រែឫស្សីវែង២ជួរសងខាង ។ នៅលើគ្រែឫស្សីនោះ មានមនុស្សពេញវ័យ និងមនុស្សចាស់ប្រុសស្រី ដែលមានរូបរាងស្គមកំព្រឹងនៅកជើងមានជាប់ខ្នោះទាំងអស់ ។ អ្នកទាំងនោះភាគច្រើនមានដំបៅងារស្អុយរលួយ នៅក្រោមគ្រែឫស្សីសុទ្ធតែលាមក ។ នៅពេលនោះ ទោះជា ថៃ មានវ័យក្មេងនៅឡើយ ។ តែ ថៃ ប្រៀបធៀបស្ថានភាពនៅទីនេះថាជាឋានខ្មោច ។ គាត់ស្រក់ទឹកភ្នែកដោយមិនដឹងខ្លួន ។ ខ្លួនប្រាណទាំងមូលចាប់ផ្ដើមញ័រ ។ គាត់ចាប់ផ្ដើមអស់សង្ឃឹម និងឯកោ ។ ពេលនោះហើយដែល ថៃ ចាប់ផ្ដើមនឹកឪពុកម្ដាយ តែមិនបានឃើញពួកគាត់ទេ ដោយសារតែភាពងងឹត ។ គាត់ក៏មិនហ៊ានសួរដែរ ។ ព្រឹកឡើងសន្តិសុខបើកទ្វាគុកឲ្យក្មេងៗចេញកាប់ដើមទន្ទ្រានខែត្រ និងធ្វើចម្ការ ។ ពេលនោះភ្លៀងធ្លាក់ឈូៗ ។ ប៉ុន្តែបើអ្នកណាមិនព្រមចេញពីទ្វារគុកទេ សន្តិសុខនឹងយករំពាត់វាយជាមិនខាន ។ ចំណែកអ្នកដែលជាប់ខ្នោះជាមនុស្សចាស់គេមិនឲ្យចេញទេ មានពេលខ្លះ ថៃ ធ្វើពុតជាឈឺមិនចេញធ្វើការទេ ព្រោះភ្លៀងខ្លាំង ។

ពេលបាយមនុស្សឈរតម្រៀបជួរ និងកាន់ចានរៀងៗខ្លួន ។ ចំណែកអ្នកដែលជាប់ខ្នោះត្រូវហូបបបរនៅរោងបាយខាងក្រៅទេ ។ ពេលហូបបបរគេមិនឲ្យអង្គុយហូបនៅក្នុងរោងទេ គេឲ្យអង្គុយនៅកណ្ដាលវាល ។ ជួនកាល ពេលភ្លៀងអង្គុយហូបកណ្ដាលភ្លៀងខ្លាតទឹកភ្លៀង និងដីចូលចានពេញ ។ របបពីរពេលនេះធ្វើឲ្យមនុស្សពិបាកនឹងរស់ណាស់ ។ ប៉ុន្តែពេលខ្លះ ក្មេងខ្លះមានសំណាងពេលចេញធ្វើការក្រៅគុកមាន ស្លឹកឈើ បន្លែ ផ្លែឈើព្រោះតំបន់នោះសម្បូរដំណាំដាំដុះណាស់ ។ មនុស្សទាំងអស់ដែលរស់ក្នុងគុកគឺជាទាសករ ។ ថៃ មិនដែលឮអ្នកណានិយាយ ឬសួរនាំគ្នាឡើយ ។ នៅក្រៅគុក សន្តិសុខក្មេងៗ ដែលមានអាយុពី១៥ ទៅ១៨ឆ្នាំបានបញ្ជាឲ្យអ្នកទោសបំបោលចូលគុម្ពព្រិចម្នាក់ម្ដងៗ ជាល្បែងកំសាន្តឲ្យពួកគេមើលយ៉ាងសប្បាយ ។ អ្នករត់ចូលមុនជាប់សុទ្ធតែបន្លា ។ ថៃ តូចជាងគេ ចូលក្រោយគេមិនសូវរងគ្រោះប៉ុន្មានទេ ។ កន្លងផុតប្រហែល១ឆ្នាំ មានយប់មួយកងសន្តិសុខបើកទ្វារ ចូលមកបំភ្លឺភ្លើងពិលចំមុខស្រែកសួរថាអ្នកណាមានបងប្អូនចាប់ពីពីរនាក់ឡើងឲ្យក្រោកអង្គុយ ។ តែ ថៃ មិនមានបងប្អូនទេ ។ គាត់ដេកធម្មតា ។ អ្នកមានបងប្អូនក្រោកអង្គុយ ។ ពួកគេត្រូវបានទាញឡើង

រទេះសេះ ។ មនុស្សប្រហែល១០នាក់ចេញទៅ ហើយពួកគេមិនឃើញត្រឡប់មកវិញទេ ។

រំលងបាន១ខែក្រោយសន្តិសុខបាននាំ ថៃ ទៅជួបមនុស្សប៉ុន្មាននាក់អាយុប្រហែល៣០ ទៅ៤០ឆ្នាំ ។ ពួកគេសួរដេញដោលថាជិនាន់លន់នល់ ឪពុកម្ដាយធ្វើអី នៅឯណាមួយលើកជា២លើក ប៉ុន្តែប្រហែលជាព្រះជាម្ចាស់នាំឲ្យមាត់ ថៃ និយាយត្រូវចិត្តគេ "ខ្ញុំមិនចាំ" ។ ពួកគេបានឲ្យគាត់នៅក្រៅគុកប្រហែលជាមួយអាទិត្យរួចហើយ ថៃ ទៅសួរជាលើកចុងក្រោយ បន្ទាប់មក ស្អែកព្រឹកសន្តិសុខបានបញ្ជូនគាត់ទៅរស់នៅភូមិបឹងនិមល ជាភូមិមួយនៅមិនឆ្ងាយពីគុកនោះប៉ុន្មានទេ ។ ពេលទៅដល់ភូមិនោះ មានមនុស្សមួយក្រុមទៀតមកទទួល និងបញ្ជូនគាត់ទៅជួបមនុស្សចំណាស់ប៉ុន្មាននាក់ ពួកគេសួរ ថៃ នូវសំណួរដដែលដូចក្នុងគុកអីចឹង រួចឲ្យគាត់មកហូបបាយនៅរោងបាយ ចុងភៅនៅរោងបាយនោះជាមនុស្សចិត្តល្អ គេបានដួសបាយស្រួយមួយចានធំ និងសម្លម្ជូរព្រលិតមកឲ្យ ថៃ ហេតុតែមិនបានហូបបាយយូរខែឆ្នាំហើយ ថៃ ហូបទាល់តែឆ្អែតហល់ សឹងនឹងស្លាប់ម្ដងទៀត គាត់បានរស់នៅក្នុងភូមិនោះរហូតដល់ថ្ងៃរំដោះឆ្នាំ១៩៧៩ ។ ក្រោយរំដោះ ថៃ បានដឹងថា កន្លែងដែលគាត់ធ្លាប់នៅនោះគឺជាគុក "ចម្ការស័ក្តិ៤" ទើបដឹងខ្លួនថាគាត់មានភ័ព្វវាសនាជាងកុមារឯទៀតដែលនៅជាមួយគាត់ ។

ថៃ បញ្ជាក់ថា ចាប់តាំងពីអង្គការបញ្ជូនគ្រួសារគាត់មកនៅភូមិសត្វពង ឃុំបានាវ ស្រុកឈូក ខេត្តកំពតមក គឺជាថ្ងៃចុងក្រោយដែលគាត់លែងបានជួបសាច់ញាតិបងប្អូនទៀតហើយ ។ សព្វថ្ងៃនេះ គាត់បានបម្រើការងារក្រុមហ៊ុនឯកជនមួយនៅទីក្រុងភ្នំពេញ គាត់បានបន្ថែមទៀតថាគាត់បានរស់ដល់សព្វថ្ងៃនេះគឺពិតជាបុណ្យព្រះជាម្ចាស់និងជីដូនជីតាតាមថែរក្សាទោះបីជាក្រទ្រព្យ ឬ មានទ្រព្យក៏មិនតូចចិត្ត គ្រាន់តែចង់ដឹងថា "តើអាចមានវាសនាជួបសាច់ញាតិសន្តានដែលបានបែកគ្នាមុនសង្គ្រាមវិញដែរឬទេ?" ។

**មីន សាណាស់**

# ដំណឹងស្វែងរកឪពុកមា

ខ្ញុំបាទឈ្មោះ ច័ន្ទ រិទ្ធី បច្ចុប្បន្នរស់នៅខណ្ឌសែនសុខ សង្កាត់ភ្នំពេញថ្មី ក្រុងភ្នំពេញ ។ ខ្ញុំបាទសូមប្រកាសរកឪពុកមា ឈ្មោះ សាប់ សំផន ដែលបានបាត់ខ្លួនក្នុងឆ្នាំ១៩៧៥ ក្រោយខ្មែរក្រហមរំដោះទីក្រុងភ្នំពេញ ។ លោកមា សាប់ សំផន មានស្រុកកំណើតនៅភូមិព្រៃលាភ ខេត្តកណ្ដាល ។ គាត់មានឪពុកឈ្មោះ សាប់ ឈុន (ស្លាប់) និងម្ដាយ ង៉ួន វ៉ាន់ (រស់) និងមានបងប្អូនប្រុសស្រី៦នាក់ រួមមាន ៖ ១) សាប់ សេរីឈុំ ភេទស្រី (ស្លាប់ក្នុងរបបខ្មែរក្រហម), ២) សាប់ សំផន ភេទប្រុស (បាត់ខ្លួនក្នុងរបបខ្មែរក្រហម), ៣) សាប់ ធីគន្ធ ភេទស្រី (ស្លាប់ក្នុងរបបខ្មែរក្រហម), ៤) សាប់ សុខារី ភេទស្រី, ៥) សាប់ វ៉ាន់នីន ភេទប្រុស, ៦) សាប់ ភូមិរិន្ទ ភេទស្រី ។

សូមបញ្ជាក់ថា ក្នុងរបបសាធារណរដ្ឋខ្មែរ លោកមា សាប់ សំផន ជាទាហាននៅបន្ទាយស៊ឹងមានជ័យ និងក្រោយមក ផ្លាស់ទៅធ្វើជាទាហានជើងទឹកនៅកំពង់សោម ខេត្តព្រះសីហនុ ។ ក្រោយថ្ងៃរំដោះ១៧មេសា ឆ្នាំ១៩៧៥ កូនទាហានម្នាក់បានជូនគាត់ឡើងគោកក្នុងគោលបំណងជូនលោកមាមករកក្រុមគ្រួសារ ហើយក៏បាត់ដំណឹងតាំងពីពេលនោះមក ។

អាស្រ័យហេតុនេះ បើបងប្អូនណាបានឃើញ និងស្គាល់លោកមារបស់ខ្ញុំឈ្មោះ សាប់ សំផន ដូចដែលបានរៀបរាប់ខាងលើ សូមទាក់ទងមកខ្ញុំបាទតាមទូរស័ព្ទលេខៈ ០១៦ ៨៧៩ ៣៩៨ ឬ ទំនាក់ទំនងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជា ផ្ទះលេខ៦៦, មហាវិថីព្រះសីហនុ, រាជធានីភ្នំពេញ ឬ តាមរយៈទូរស័ព្ទ ០២៣ ២១១ ៨៧៥ ។ ***សូមអរគុណ!***

# រសាត់តាមខ្យល់

**(តពីលេខមុន)**



ពេញមួយថ្ងៃនោះ ពួកខ្ញុំបានធ្វើដំណើរយ៉ាងស្រូតរូតម្នាក់ៗ គ្មានបន្ធូរជើងបន្តិចឡើយ ស្រូតយ៉ាងណាឲ្យឆាប់តែបានទៅដល់ស្រុកភូមិកំណើតរៀងៗខ្លួន ។

ប្រជាជនអ្នកជម្លៀស ធ្វើដំណើរទៅមកបន្តបន្ទាប់គ្នារហូតមិនដាច់ម្នាក់ៗទូលដងរែកដងនូវកម្មសិទ្ធិដែលមានសល់បន្តិចបន្តួចនាំគ្នាដើរកាត់វាលចូលព្រៃចេញពីព្រៃចូលវាល ។ មកដល់ស្នាយពលស្រុកស៊ីធរកណ្តាល ប្រជាជនអ្នកជម្លៀសដែលរួមដំណើរជាមួយពួកខ្ញុំ នៅសល់កាន់តែតិចគ្រួសារទៅៗ ។ នៅនឹងទីរួមស្រុកស៊ីធរកណ្តាល មានទីស្នាក់កាធំមួយដែលអង្គការបានរៀបចំចាំទទួលបាយទឹកបងប្អូនអ្នកជម្លៀសដែលបានធ្វើដំណើរឆ្លងកាត់ទីនោះ ។

តំណាងអង្គការស្រុកស៊ីធរកណ្តាល ក្នុងសម្លៀកបំពាក់ខ្មៅបង់កក្រមា បានស្រែកប្រកាសតាមមេក្រូ សូមឲ្យបងប្អូនចូលមកហូបបាយទឹកសិន រួចចាំបន្តដំណើរទៅមុខទៀត ។ នៅទីនោះដែលមានទាំងចាក់ខ្សែអាត់បទចម្រៀងបដិវត្តន៍កំដរផង ពួកខ្ញុំក៏បានចូលទៅហូបបាយនឹងគេដែរ ។ បាយដែលដណ្តាំនឹងខ្ទះត្នោតពីរបីតម្រៀបគ្នា ពួកខ្ញុំនៅបានហូបសម្លសោរសាច់ជ្រូកជាមួយបន្លែក្តិបខ្នុរ និងសម្លម្ជូរគ្រឿងសាច់គោ ដែលកំពុងតែពុះហុយយ៉ាងកញ្ជ្រោល ពីក្នុងខ្ទះត្នោតពីរទៀតក្បែរនោះ ។

គ្រាន់តែហូបបាយថ្ងៃត្រង់រួចភ្លាម ពួកខ្ញុំក៏បានចេញដំណើរបន្តទៅមុខទៀត ។ ជារៀងរាល់ថ្ងៃ តាមកំណាត់ផ្លូវដែលឆ្លងកាត់ភូមិតូចធំនានាក្នុងតំបន់រំដោះ ខ្ញុំបានប្រទះឃើញប្រជាជនអ្នកស្រុកអ្នកភូមិមានជីវភាពរស់នៅយ៉ាងក្រលំបាក ដែលមានប្រជាជនអ្នកភូមិខ្លះរកសំពត់រំលោះខ្លួនស្ទើរតែពុំជុំ ភាគច្រើនជាស្ត្រីភេទស្ថិតក្នុងវ័យកណ្តាលដែលឈរកាន់ដៃកូន ខ្លះទៀតពកូនតូចលែងខ្លួនទទេ នាំគ្នាឈរប្រឡបនឹងមាត់ផ្លូវក្នុងសំលៀកបំពាក់យ៉ាងកញ្ចាស់កណ្តេកកណ្តោចដូចស្មូមយាចក មានកាន់មាន់ ខ្លះយួរបំពង់ស្ករត្នោតនៅនឹងដៃរង់ចាំសុំដូរសំពត់អាវសារុងពីបងប្អូនអ្នកជម្លៀសយកទៅស្លៀកពាក់ ។

ពេលដែលបានឃើញភាពយ៉ាងគោកយ៉ាកបែបនេះ ខ្ញុំហាក់ដូចជាស្រងាកក្នុងចិត្តដែលផ្ទុយស្រឡះពីអ្វីដែលខ្ញុំធ្លាប់បានគិតថា ប្រជាជនដែលរស់នៅក្នុងតំបន់រំដោះក្រោមការដឹកនាំរបស់អង្គការបដិវត្តន៍ពិតជាមានជីវភាពរស់នៅសមរម្យ តែនៅពេលដែលបានមកជួប បានមកឃើញផ្ទាល់បែបនេះ ខ្ញុំខ្លួនឯងសឹងតែមិនជឿភ្នែក ។

អ្នកម៉ែ និង មីងណារុង បានយកអាវមួយនិងសារុងចាស់ជំនំបន្តិចទៅដូរបានស្ករត្នោតកន្លះបំពង់ និងមាន់មួយសំរាប់ធ្វើម្ហូប ។ ពេលជាមួយគ្នានោះ ខ្ញុំចង់សាកសួរពួកគាត់ពីការរស់នៅខ្លះៗក្នុងតំបន់រំដោះ តែត្រូវបានពួកគាត់បង្ហាញឲ្យខ្ញុំឃើញនូវភាពញញើតញញើម ដោយពួកគាត់មិនហ៊ាននិយាយស្តីអ្វីច្រើនជាមួយពួកអ្នកជម្លៀសឡើយ ។

ចេញផុតពីកូនភូមិតូចមួយនោះមក ពួកខ្ញុំក៏បានចេញមកដល់វាលដ៏ធំល្វឹងល្វើយមួយឆ្ងាយសន្ធឹមដាច់កន្ទុយភ្នែករកមើលកោះត្រើយមិនឃើញ ។ ក្រោមកម្តៅថ្ងៃខែចែត្រយ៉ាងក្តៅហែងស្ទើរបែកលលាដ៏ក្បាល ថប់ខ្យល់ស្អុះស្អាប់ សូម្បីតែម្លប់កូនឈើតូចមួយសម្រាប់ជ្រកក៏គ្មានផង ។

ពួកខ្ញុំដើរតាំងពីព្រលឹម រហូតដល់ពេលថ្ងៃជិតលិចទៅហើយ នៅមិនទាន់បានផុតពាក់កណ្ដាលវាលនោះផង ។ យប់នោះយើងនាំគ្នាសម្រាកនៅនឹងកណ្ដាលវាលសោះខ្យល់នោះ ។ លុះដល់ពេលយប់ជ្រៅបន្តិចស្រាប់តែធាតុអាកាសប្រែជាត្រជាក់ស្រឹបស្រៀវដល់ឆ្អឹងខ្នង មានទាំងធ្លាក់ខ្យល់ដំនោរយ៉ាងរងាស្ទើរទ្រាំពុំបាន លុះដល់ពេលព្រឹកព្រលឹមឡើងឃើញមានទឹកសន្សើមដោតស្មៅ ។ បន្ទាប់ពីបានដើរមួយកំណាត់ថ្ងៃមកទៀត ទើបពួកខ្ញុំបានដើរផុតពីវាលដីសោះខ្យល់នោះ ហើយបានមកដល់ភូមិមួយឈ្មោះ ភូមិជ្រៃដើមថ្នឹង ។ ក្រោយពីសម្រាកហូបបាយថ្ងៃត្រង់នៅនឹងភូមិជ្រៃដើមថ្នឹងរួច ពួកខ្ញុំក៏បានប្រញាប់ចេញដំណើរបន្តទៅមុខទៀត ។ ដើរអស់រយៈពេលពេញមួយថ្ងៃ ទើបបានមកដល់ភូមិទួលស្វាយជ្រុំ ពីភូមិទួលស្វាយជ្រុំពួកខ្ញុំដើរផ្លូវកាត់តម្រង់ទៅឃុំបារាយណ៍ ។ កំណាត់ផ្លូវពីឃុំបារាយណ៍ឆ្ពោះទៅកាន់ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ពុំមានគ្រួសារអ្នកជម្លៀសផ្សេងរួមដំណើរជាមួយពួកខ្ញុំទៀតឡើយ ។ ពីរថ្ងៃបន្ទាប់មកទៀត ពួកខ្ញុំក៏បានមកដល់ភូមិតានង់ ឃុំព្រែករំដេង ។ ចេញពីភូមិតានង់ទៅ ពួកខ្ញុំលែងស្រូតរូតដំណើរដូចមុនទៀតហើយ ព្រោះនៅសល់តែប៉ុន្មានភូមិទៀតទេដល់ភូមិកំណើត ពូជន ហើយ តាមផ្លូវ ពូជន មីងណារុង បានជួប និងចូលទៅជិរាបសួរបងប្អូនញាតិមិត្តគាត់ជាហូរហែ ។

ពីត្រើយម្ខាងភូមិតានង់ យើងបាននាំគ្នាដើរឆ្លងស្ពានឈើចាស់មួយ លាតសន្ធឹងតាមដងទន្លេតូច ពូជន បានប្រាប់ខ្ញុំថា ទន្លេតូចនេះឈ្មោះទន្លេត្បូង ។ រដូវទឹកសម្រក ទឹកទន្លេត្បូងស្រកនៅរាក់ត្រឹមក្បាលជង្គង់ តែតាមបណ្ដោយទន្លេត្បូងមានទេសភាពដ៏ស្រស់ត្រកាល ខ្ញុំហាក់ទទួលអារម្មណ៍យ៉ាងត្រេកត្រអាល ពេលដែលបានឃើញចម្ការពោត ចម្ការថ្នាំដក់ពណ៌បៃតងខ្ចី លាតសន្ធឹងយ៉ាងវែងដែលកំពុងតែត្រូវខ្យល់ដំនោរបក់រំភើយយ៉ាងត្រជាក់ ហើយមើលទៅគួរជាទីមនោរម្យ ។

ទីបំផុតយើងក៏បានមកដល់ភូមិកំណើត ពូជន ភូមិក្បាលកោះអណ្ដែត បន្ទាប់ពីបានធ្វើដំណើរថ្មើរជើងអស់រយៈពេលជាងដប់ថ្ងៃកន្លងមកនេះ ។ ឪពុកម្ដាយ បងប្អូន កូនក្មួយ ពូជន បាននាំគ្នាមកទទួលស្វាគមន៍យ៉ាងរាក់ទាក់កក់ក្ដៅ ។

ពេលរសៀលថ្ងៃដដែលនោះ ប្រធានសហករណ៍ភូមិក្បាលកោះអណ្ដែត បានមកហៅ ពូជន ដែលទើបតែនឹងបានជួបឪពុកម្ដាយគាត់ប្រមាណបីបួនម៉ោងមុននេះ ឲ្យទៅចុះឈ្មោះនៅទីស្នាក់ការភូមិ ។ ពេលដែល ពូជន ចេញដំណើរទៅ គាត់បានឆ្មៀតមកខ្សិបខ្សឹបដាក់ត្រចៀកខ្ញុំថា “ជួយលាក់ឲ្យជិត កុំប្រាប់អ្នកណាថា គាត់ធ្វើទាហានឲ្យសោះ...” ។ ពេលដែលប្រធានភូមិបាននាំប្ដីគាត់ទៅ មីងណារុងខ្វាយខ្វល់ក្នុងចិត្តយ៉ាងខ្លាំង ចំណែកលោកយាយ កំពង់សៀម និងអ្នកម៉ែបាត់មាត់ស្ងូនស្ងៀមឈឹងគ្មានចេញស្ដីមួយម៉ាត់ណាឡើយ ព្រោះតែនឹកបារម្ភខ្លាំងពេក ។

ពូជន ធ្លាប់បាននិយាយប្រាប់ខ្ញុំថា គាត់បានចាកចោលភូមិកំណើត និងឪពុកម្ដាយរបស់គាត់តាំងពីដើមឆ្នាំ១៩៧២មកម្ល៉េះ គឺពេលដែលពួកកងទ័ពខ្មែរក្រហមបានចូលមកកាន់កាប់ភូមិកោះអណ្ដែតជាស្ថាពរ ។

គាត់បានទៅរស់នៅ និងបន្តការសិក្សានៅឯក្រុងភ្នំពេញ ក្រោយពីបានប្រឡងបាក់អងជាប់មកដោយពុំមានលទ្ធភាពទ្រទ្រង់ជីវភាពរស់នៅ និងការសិក្សារៀនសូត្រតទៅមុខទៀត គាត់ក៏បានចូលធ្វើទាហាននៅក្នុងកងពលធំថ្មើរជើងទីពីរ ។ មួយឆ្នាំក្រោយមក គាត់ក៏បានរៀបការជាមួយ មីងណារុង ដែលកាលនោះប្រពន្ធគាត់កំពុងរៀនពេទ្យ នៅសាលាគិលានុបដ្ឋាយិកា និងឆ្មបរដ្ឋ ។

រហូតទាល់តែព្រលប់ងងឹតមើលគ្នាសឹងតែមិនស្គាល់ ទើបឃើញ ពូជន ត្រឡប់មកវិញ ដែលពេលនោះទាំងឪពុកម្ដាយ ពូជន ទាំង មីងណារុង កំពុងតែអង្គុយជុំគ្នាយ៉ាងស្ងៀមស្ងាត់នៅពីមុខចង្កៀងប្រេងល្ហុង ដែលកំពុងតែជះពន្លឺព្រឹមៗយ៉ាងស្រទន់ ។

ពូជន បានប្រាប់ឲ្យពួកខ្ញុំប្រញាប់ប្រញាល់រៀបចំអីវ៉ាន់ដើម្បីទៅសម្រាកនៅនឹងទីស្នាក់ការរួមមួយឯចុងភូមិ ដែលប្រធានភូមិកំពុងរង់ចាំពួកយើងនៅទីនោះ ។ ពេលទៅដល់ ប្រធានភូមិបាននាំពួកខ្ញុំដើរតម្រង់ទៅកាន់ផ្ទះឈើប្រក់ក្បឿងមួយខ្នងយ៉ាងធំ ដែលនៅតាមផ្លូវប្រកចូលមានដាំដើមចេកអមសងខាងជាច្រើនដើម ។ នៅកណ្ដាលល្វែងផ្ទះដែលវាលល្វឹងដូចសាលាឆទានមានប្រជាជនអ្នកជម្លៀសបីបួនគ្រួសារកំពុងស្នាក់នៅទីនោះ ហើយមុនពេលដែលប្រធានភូមិត្រឡប់ទៅវិញគាត់បានប្រាប់ពូជនថា ថ្ងៃស្អែកទើបគេមកកត់ ឈ្មោះពួកខ្ញុំបញ្ចូលក្នុងស្ថិតិប្រជាជនថ្មី ។

ជារៀងរាល់ថ្ងៃ ពូជន និងបុរសៗដែលជាមេគ្រួសារផ្សេងទៀតត្រូវបានអង្គការកោះហៅទៅសាកសួរប្រវត្តិរូបតាំងពីកើត

រហូតដល់បច្ចុប្បន្ន ជាញឹកញយ និងដោយខ្សែកៗពីគ្នា ។

អស់រយៈពេលបីថ្ងៃ ទើបប្រធានភូមិបានអនុញ្ញាតឲ្យពួកខ្ញុំ និងគ្រួសារអ្នកថ្មីដទៃទៀតវិលត្រឡប់ទៅរស់នៅតាមក្រុមគ្រួសាររៀងៗខ្លួនវិញ ហើយរង់ចាំការបែងចែកជាពួកជាក្រុម ដើម្បីប្រយុទ្ធធ្វើការងារទើបបានទទួលរបបស្រូវអង្ករហូបចុកតាមកម្រិតដែលអង្គការកំណត់ឲ្យ ។

តាំងពីពេលនោះមក នៅតាមសហករណ៍មូលដ្ឋានប្រជាជនអ្នកជម្លៀសមកពីភ្នំពេញ ត្រូវបានគេហៅថា "ពួកអ្នកថ្មី" ឬ "ពួកអ្នកដប់ប្រាំពីរមេសា" ចំណែកប្រជាជនដែលរស់នៅក្នុងតំបន់រំដោះគេហៅថា "ប្រជាជនចាស់" ឬ "អ្នកមូលដ្ឋានចាស់" រីឯគណៈសហករណ៍ដឹកនាំក្នុងភូមិត្រូវបានគេហៅថា "គណៈកម្មាធិការបម្រើប្រជាជនបដិវត្តន៍កម្ពុជា" ។

ចាប់ពីថ្នាក់តួនាទីជាប្រធានភូមិឃុំឡើងទៅត្រូវបានជ្រើសរើស និងចាត់តាំងឡើងដោយអង្គការបដិវត្តន៍ជាភ្នែកជាច្រមុះរបស់អង្គការ ហើយទាល់តែចេញពីវណ្ណៈភាពជាកូនចៅកម្មករ កសិករថ្នាក់ក្រោមបំផុត និងត្រូវមានគោលជំហរល្អ ស្មោះត្រង់ដាច់ខាតជាមួយខ្មាំង សត្រូវរបស់បដិវត្តន៍ ហ៊ានលះបង់អាយុជីវិត ដើម្បីមូលហេតុបដិវត្តន៍ ដោយពុំមានលក្ខខណ្ឌ ។

ពោលគឺ បដិវត្តន៍ត្រូវការតែគោលជំហរល្អ និងស្មោះត្រង់ ទោះជាមិនចេះអក្សរមួយតួ ក៏បដិវត្តន៍ដឹកនាំបានដែរ បដិវត្តន៍មិនត្រូវការសញ្ញាបត្រ សញ្ញាឃើញស្អីទេ នៅក្នុងតំបន់បដិវត្តន៍ ប្រជាជនមានសិទ្ធិស្មើគ្នា គ្មានអ្នកណាជិះជាន់អ្នកណាឡើយ ហើយក៏គ្មានអ្នកណាម្នាក់ដែលអត់មានការងារធ្វើដែរ ។

រាល់ព្រឹកព្រហាម មានឮសូរស្នូរជួងជាសញ្ញាទៅជួបជុំគ្នានៅនឹងទីស្នាក់ការភូមិ ដើម្បីរង់ចាំទទួលការបែងចែងមុខព្រួញការងារពីប្រធានភូមិ ។ តាំងពីថ្ងៃដំបូងម្ល៉េះដែលខ្ញុំត្រូវបានគេបញ្ជូលទៅក្នុងកងស្រួច ខ្ញុំបានជួបនឹងយុវជនអ្នក១៧មេសាដូចគ្នាជាច្រើននាក់ ។

នៅចំពីមុខទីស្នាក់ការភូមិ មានភ្នក់ភ្លើងមួយធំ ដែលពេញមួយយប់ទល់ព្រឹកនៅតែឆេះហុយៗជាប់រហូត ហើយដែលមីងៗអ្នកមូលដ្ឋានចាស់មួយចំនួនរស់នៅក្បែរខាងនោះ តែងតែមកជុំគ្នាអង្គុយ អាំងភ្លើងរៀងរាល់ព្រឹក ដោយរងារនឹងខ្យល់យ៉ាងត្រជាក់បក់មកពីមាត់ទន្លេ ។

អាំងភ្លើងបណ្ដើរ ពួកគាត់ជជែកគ្នាសើចលេងពីនេះពីនោះបណ្ដើរ ព្រឹកនោះស្រាប់តែមានឮស្នូរម៉ាស៊ីនម៉ូតូហុងដាឯនាយពីចុងភូមិ ក្នុងវិនាទីជាមួយគ្នានោះអ៊ុំស្រីម្នាក់បានលាន់មាត់ថា កូនគាត់មកពីភ្នំពេញបានរបស់ជ័យភ័ណ្ឌមកទៀតហើយ..... ។

ខ្ញុំចោលភ្នែកសម្លឹងមើលទៅគាត់ ដែលកំពុងតែអង្គុយឆ្ងាយបន្តិចពីភ្នក់ភ្លើង នៅនឹងក្រណាត់កាំម្ចីពណ៌ក្រហមក្រមៅមួយផ្ទាំង ដែលគាត់កំពុងតែដណ្ដប់ជាប់នឹងខ្លួន ក្រសែភ្នែកទាំងគូរបស់ខ្ញុំបានពើប ជំពប់នឹងអក្សរមួយជួរដែលសរសេរថា "*Ciné Kirirom*" ។

ទំនាក់ទំនងរវាងអ្នកមូលដ្ឋានចាស់ និងអ្នក១៧មេសា គឺចង្អៀតចង្អល់បំផុត ព្រោះនៅក្នុងសង្គមបដិវត្តន៍ មានការបែងចែកវណ្ណៈភាពយ៉ាងច្បាស់ ។ ក្នុងការរស់នៅ និងក្នុងការធ្វើការងាររួមរាល់ថ្ងៃ អ្នកថ្មីត្រូវបានអ្នកមូលដ្ឋានចាស់ក្ដាប់យ៉ាងណែន និងស្ថិតនៅក្រោមការតាមដានយ៉ាងហ្មត់ចត់ ពោលគឺអ្នកថ្មីរស់នៅក្នុងភាពគ្រោះថ្នាក់គ្រប់ជំហ៊ានដែលម្នាក់ៗត្រូវប្រុងប្រយ័ត្នបំផុត ជាពិសេសក្នុងការនិយាយស្ដី ។

អ្នកថ្មីទាំងគ្រួសារៗ ត្រូវបានប្រធានភូមិកោះហៅឲ្យទៅប្រជុំរៀនសូត្រនាពេលល្ងាចៗ ដើម្បីបំពាក់គោលជំហរនយោបាយបដិវត្តន៍ ហើយរាល់ពេលប្រជុំរៀនសូត្រ អង្គការនៅបានលើកឡើងដដែលៗ និងដោយមោទកភាពបំផុតនូវជ័យជម្នះថ្ងៃ១៧មេសាដ៏មហាលោតផ្លោះ មហាអស្ចារ្យ ដែលអង្គការបដិវត្តន៍បានរំដោះប្រជាជនទូទាំងប្រទេសឲ្យរួចផុតពីនឹមចក្រពត្តិ និងបរិវារ ។

មានពាក្យបដិវត្តន៍ច្រើនណាស់ ដែលថ្មីបំផុតសម្រាប់ប្រជាជនដប់ប្រាំពីរមេសា ដូចជាពាក្យ ម្ចាស់ការ ស្វួនតួ កសាង សន្ទុំសំចៃ កម្រិតខ្ពស់ អត្តនោម័តិ បោសសម្អាត ទិតៀន ស្វ័យទិតៀន សើរើ ដោះស្រាយរបបគោលនយោបាយ លើកកម្ពស់ស្មារតី ។ល ។ និង ។ល ។ ហើយរាល់ពេលចាប់ផ្ដើមបើកអង្គប្រជុំ គេតែងតែបានឮពាក្យ "ដើម្បីគឺថា...គឺថាដើម្បី" ជានិច្ច ។

ក្នុងឱកាសប្រជុំនាលាចថ្ងៃមួយ សមមិត្តប្រធានភូមិបានចោទប្រកាន់អ្នកថ្មី ដែលបាននិយាយពាក្យមិនសមរម្យ ជាពាក្យសម្ដីមើលងាយមើលស្រាលដល់បដិវត្តន៍ ដើម្បីនិយាយស្ដីឲ្យត្រូវតាមបែបបទបដិវត្តន៍ អ្នក១៧មេសា ត្រូវតែរៀនសូត្រ ។ បងប្អូនកុំយល់ច្រឡំដូចជាគណៈកម្មាធិការបម្រើប្រជាជនបដិវត្តន៍មិនមែន

គណៈកម្មាធិការប្រើប្រជាជនបដិវត្តន៍ទេ យើងនាំគ្នាសម្រុកលើកទំនប់ដីកប្រឡាយ មិនមែនយើងនាំគ្នាសម្រុកជីកទំនប់ទប់ប្រឡាយទេ ។ ពាក្យសម្តីទាំងអស់ខាងលើនេះ សុទ្ធតែជាពាក្យសំដីប្រឆាំងបដិវត្តន៍ ជាសំដីខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង ដែលបដិវត្តន៍មិនអាចអត់ឱនឲ្យបានឡើយ ។

នៅក្នុងក្រុមយុវជនកងស្រួច ដែលមានប្រធានកងឈ្មោះ មិត្តលាវ មុខសញ្ញាការងារជីកប្រឡាយទឹកធំ មួយនៅឯចុងភូមិកោះអណ្តែតរួមជាមួយនិងយុវជនកងស្រួចជាច្រើនកងទៀត ខ្ញុំបានស្គាល់អ្នកមូលដ្ឋានចាស់ម្នាក់ ដែលជាយុវជននៅក្នុងកងមិត្តលាវ ជាមួយខ្ញុំដែរ ។

តាំងពីថ្ងៃដែលបានស្គាល់គ្នាដំបូង ខ្ញុំបានសម្គាល់ឃើញមិត្តអៀន មានអត្តចរិតខុសប្លែកពីអ្នកមូលដ្ឋានចាស់ដទៃទៀត មិត្តអៀន តែងតែបង្ហាញឲ្យឃើញនូវសមានចិត្តស្រឡាញ់រាប់អានចូលចិត្តអ្នកថ្មីហើយដោយយើងមានអាយុប្រហាក់ប្រហែលគ្នានោះ ថ្ងៃមួយ មិត្តអៀន បានសូមកុំឲ្យខ្ញុំប្រើពាក្យ "មិត្ត" ដើម្បីឲ្យកាន់តែស្និទ្ធស្នាលយើងហៅគ្នា "អាទៅអាមក" តែម្តង ។ ជាញឹកញយ អាអៀន បានហៅខ្ញុំទៅលេងផ្ទះវា ផ្ទះ អាអៀន សង់ពីឈើធំណាស់នៅកណ្តាលភូមិមិនឆ្ងាយប៉ុន្មានពីមាត់ទន្លេ ដែលមានទីធ្លា និងមានចម្ការស្វាយយ៉ាងធំនៅពីក្រោយផ្ទះវារស់នៅជាមួយម្តាយមេម៉ាយ បងស្រីម្នាក់ និងប្អូនប្រុសពៅម្នាក់នៅតូច ។ អាអៀន បានរៀបរាប់ប្រាប់ខ្ញុំពីឪពុករបស់វា ដែលកាលពីឆ្នាំ១៩៧២ ពេលបដិវត្តន៍ចូលមកកាន់កាប់ភូមិកោះអណ្តែតនោះបានឡើងទៅចាប់គាត់ពីលើផ្ទះយកទៅសម្លាប់ទាំងកណ្តាលអាធ្រាត្រ ដោយត្រូវបដិវត្តន៍ចោទប្រកាន់ថា ជានាយទុនម្ចាស់ដី ។ កាលនោះម្តាយវានៅសរសៃខ្ចីទើបតែឆ្លងទន្លេរួចទាស់ធ្លាក់ខ្លួនឈឺស្គមរីងរៃស្ទើរតែក្លាយជាមនុស្សវិកលចរិត ហើយអាប្អូនពៅវាសព្វថ្ងៃ មិនដែលស្គាល់មុខឪពុកយ៉ាងម៉េចផង ។

រសៀលថ្ងៃមួយ អាអៀន បាននាំខ្ញុំដើរទៅលេងចម្ការស្វាយឯក្រោយផ្ទះ ដែលនៅនឹងព្រំដីចុងម្ខាងជាប់នឹងមាត់ផ្លូវ ខ្ញុំឃើញមានចេតិយធំមួយ ហើយនៅពេលដែល អាអៀន បាននាំខ្ញុំដើរតម្រង់ទៅចេតិយនោះ វាបាន ប្រាប់ខ្ញុំថា គឺជាចេតិយរបស់ជីតាវា ។

អាអៀន បានប្រាប់ខ្ញុំឲ្យចាំឃ្លាំមើលផ្លូវ ក្រែងមានអ្នកចម្លែកដើរមក រួចវាបានលូនលបៗចូលទៅក្នុងចេតិយបាត់ទៅមួយស្របក់ក្រោយមកពេលដែលវាលូនចេញមកវិញ ខ្ញុំឃើញនៅនឹងដៃវាមានកាន់ប្រអប់ដែកតូចមួយផង ។

អាអៀន ក្រឡេកងាកមើលឆ្វេងស្តាំ រួចចាប់បើកប្រអប់ដែកនោះឡើងបង្ហាញខ្ញុំ ខ្ញុំឃើញមានសុទ្ធតែរូបថតពេញក្នុងប្រអប់ដែកនោះ ។ វាបានហុចរូបថតម្តងមួយៗមកឲ្យខ្ញុំមើល ភាគច្រើនជារូបថតសខ្មៅ និងមានរូបថតពណ៌ធម្មជាតិខ្លះ ដែលនៅមានពណ៌ស្រកៗ ។ អាអៀន បានប្រាប់ខ្ញុំថា គឺជារូបថតរបស់បងប្រុសវាឈ្មោះ លឹម ប៊ុនថៃ ដែលបានទទួលអាហារូបករណ៍ទៅរៀននៅសាធារណរដ្ឋប្រជាធិបតេយ្យអាល្លឺម៉ង់ តាំងពីឆ្នាំ១៩៦៨ មកម្ល៉េះ ។ ស្តាប់ អាអៀន រៀបរាប់បណ្តើរ ខ្ញុំមើលរូបថតបងប្រុសវាបណ្តើរដោយពិនិត្យពិច័យ ។ កាលពីមុនឆ្នាំ១៩៧២ វានៅបានទទួលសំបុត្រពីបងប្រុសវាជារឿយៗតាមរយៈម្តាយមីងវានៅឯភ្នំពេញ ក្រោយពីនោះ វាបាត់ដំណឹងពីគាត់សូន្យឈឹងរហូតមកដល់សព្វថ្ងៃ ។

ខ្ញុំទទួលអារម្មណ៍រំភើបលាយឡំនឹងក្តីស្រមើស្រមៃយ៉ាងឥតព្រំដែន ពេលដែលបានឃើញរូបថត នារដូវស្លឹកឈើទុំពណ៌លឿងជ្រុះក្រាលពាសពេញដី មើលទៅគួរឲ្យស្រណោះស្រណោក រូបថតបងប្រុសវាឈរថតនៅកណ្តាលវាលទឹកកកសក្បុសដូចសំឡី និងរូបថតនារដូវស្លឹកឈើលាស់ រដូវផ្ការីកសាជាថ្មីយ៉ាងស្រស់ត្រកាល ។

ដោយសារផ្ទះរបស់ឪពុកម្តាយ ពូជន តូចចង្អៀតពេក ពួកខ្ញុំត្រូវបានអង្គការភូមិដោះស្រាយជម្រកថ្មីមួយ ដោយឲ្យទៅរស់នៅនឹងជង្រុកស្រូវរបស់ដង្កៅ អ្នកមានស្តុកស្តម្ភម្នាក់ដែលត្រូវជាឪពុកមាបង្កើតរបស់ អាអៀន ឈ្មោះដង្កៅរស់ ។

តាំងពីពេលដែលបដិវត្តន៍បានរំដោះ និងពីក្រោយពេលដែលអង្គការបានចាប់បងប្រុសរបស់គាត់ដែលជាឪពុករបស់អាអៀនយកទៅសម្លាប់មក ដង្កៅរស់បានលះបង់អ្វីៗសព្វបែបយ៉ាងទាំងអស់ ទាំងទ្រព្យសម្បត្តិទាំងដីធ្លីឲ្យតែបដិវត្តន៍ត្រូវការ ។ គាត់មានកូនប្រុសពីរនាក់និងកូនស្រីពីរនាក់រស់នៅជុំគ្នាដោយស្ងៀមស្ងាត់ ។

មិត្តលាវ ដែលជាប្រធានកងរបស់ខ្ញុំ ធ្លាប់បាននិយាយប្រាប់ខ្ញុំថា គាត់រស់នៅជាមួយឪពុកនិងម្តាយគាត់ក្នុងភាពយ៉ាងទីទល់ក្រីក្របំផុត គ្មានដីស្រែចម្ការ សូម្បីតែមួយអំពកនិងគេក៏គ្មានដែរ ។ មួយជីវិតរបស់ឪពុកគាត់ តរហូតមកដល់រូបគាត់ទៀតគ្មានមុខរបរអ្វីក្រៅ

ពីស៊ីឈ្នួលអារឈើឲ្យដង្ហើររស់ឡើយ ។

មិត្តលាវ នឹកដឹងគុណបដិវត្តន៍មិនស្មើរទេ ដែលបដិវត្តន៍បានរំដោះរូបគាត់ឲ្យរួចផុតពីវណ្ណៈភាពជាខ្ញុំកញ្ជះគេនេះ ហើយសព្វថ្ងៃនេះគាត់បានក្លាយខ្លួនជាម្ចាស់ស្រុកម្ចាស់ប្រទេសជាតិទាំងមូល មិនតែប៉ុណ្ណោះ គាត់បានក្លាយជាម្ចាស់លើវាសនាខ្លួនឯងថែមទៀតផង ។

រាល់ពេលដែលអវត្តមានពីមិត្ត លាវ នៅមានអនុប្រធានកងម្នាក់ទៀតឈ្មោះ មិត្តរស់ ជាអ្នកក្តាប់ និងដឹកនាំពួកខ្ញុំធ្វើការងារ ។ មិត្តរស់ដែលមានអាយុបងខ្ញុំពីរបីឆ្នាំមានចរិតជាមនុស្សស្ងប់ស្ងៀមនិយាយស្តីតិចបំផុតខុសស្រឡះពីមិត្ត លាវ ។

ល្ងាចថ្ងៃមួយពេលចប់ពីការងារ មិត្តរស់ បានហៅខ្ញុំទៅលេងផ្ទះគាត់ដែលស្ថិតនៅឯដើមភូមិ ។ ពេលទៅដល់ខ្ញុំមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង គ្រាដែលបានឃើញបុរសម្នាក់អាយុប្រមាណសាមសិបឆ្នាំកំពុងតែអង្គុយនទៀលផ្ទាល់នឹងដីក្រោមផ្ទះស្លៀកក្រមាលែងខ្លួនទទេមុខមាត់ប្រឡាក់ដីឲ្យស្រម៉ក សក់ក្បាលវែងកន្ទ្រើងរីងដូចសរសៃដែក បឺតបារីស្លឹកសង្កែមួយដើមធំប៉ុនមេដើង បង្ហុយផ្សែងឡើងលើយ៉ាងទ្រគោល ។

ខ្ញុំសម្លឹងមើលទៅរូបគាត់ ដោយក្តីអាណិតអាសូរហើយនៅពេលដែលខ្ញុំកំពុងតែនឹកឆ្ងល់ថាតើគាត់ជាអ្នកណានោះ មិត្តរស់បានប្រាប់ខ្ញុំថា គឺជាបងប្រុសតែមួយរបស់គាត់ឈ្មោះ ឃីម ដែលធ្លាក់ខ្លួនទៅជាមនុស្សវិកលចរិត តាំងពីដើមឆ្នាំ១៩៧២មកម៉្លេះដោយគាត់ភ័យស្លុតរង្វេងឡប់សតិស្មារតីនឹងស្នូរយន្តហោះទម្លាក់គ្រាប់បែកធុន B-៥២ ដែលបានហោះហើរមកទម្លាក់គ្រាប់បែកនៅនឹងភូមិកោះអណ្តែតនេះជាញឹកញាយ ។

តាំងពីបានមករួមរស់នៅនឹងស្រុកទន្លេប្រមាណជិតពីរខែកន្លងមកនេះ រូបខ្ញុំ និងអ្នកម៉ែថ្មីត្បិតតែជាអ្នកចំណូលថ្មី តែត្រូវបានទទួលនូវការស្រឡាញ់រាប់អានពីសំណាក់បងប្អូនអ្នកភូមិជាពិសេស ពីក្រុមគ្រួសារបងប្អូនកូនក្មួយ ពូផន យ៉ាងរាក់ទាក់ ។ ជីវភាពរស់នៅជាអ្នកចម្ការ មិនសូវមានអ្នកណាទំនេរដៃទេ ផុតពីការងាររួមនៅសេសសល់ពេលបន្តិចបន្តួចយ៉ាងហោចណាស់ក៏នាំគ្នាលើករងដាំដំណាំនេះដំណាំនោះក្បែរៗផ្ទះដែរ ។

ស្ទើរតែរាល់ល្ងាច បងស្រ៊ាង ប្តីបងសារ៉ុំ ជាក្មួយបង្កើតរបស់ពូផន បាននាំខ្ញុំដើរទៅរហូតដល់ទន្លេត្បូងរកកៀរកំពិស និងកូនត្រី ។ ជួនកាលមីងណារុងបាននាំខ្ញុំទៅដកព្រលិតពីក្នុងបឹងខាងក្រោយវត្តក្បាលកោះអណ្តែត យកមកឲ្យអ្នកម៉ែស្ងោរនឹងសណ្តាន់ខ្ទិះបង់ម្រះព្រៅ ។ ជាញឹកញាយ ខ្ញុំបាននិយាយលេងជាមួយអ្នកម៉ែថា សម្លម៉ែឆ្ងាញ់ណាស់ ខ្ញុំឆាញ់គ្រប់មាត់តែម្តង ។

បងសារ៉ុំ ក្មួយពូផន នៅមានប្អូនស្រីម្នាក់អាយុជប់១៦ឆ្នាំឈ្មោះ រំដួល មានសម្រស់ស្រស់ស្អាត និងមានបុកពារយ៉ាងសុភាពរាបសា ។ បងសារ៉ុំ និងប្តីគាត់ចូលចិត្តនិយាយលេងសើចច្រើនជាមួយខ្ញុំ តែខ្ញុំមិនដែលបានប៉ះសម្តីមួយម៉ាត់ជាមួយ នាងរំដួល ឡើយជង្រុកស្រូវដង្ហើររស់ស្ថិតនៅមិនឆ្ងាយប៉ុន្មានទេពីផ្ទះ បងសារ៉ុំ ។ ល្ងាចៗខ្លះ ពេលដែលខ្ញុំកំពុងតែពុះខសទុកឲ្យអ្នកម៉ែដណ្តាំស្ល ហើយនៅពេលដែលបានឃើញ រំដួល មកឈរអើតតាមមាត់បង្អួចផ្ទះនាងចំពីមុខខ្ញុំម្តងៗ ពេលនោះក្នុងចិត្តខ្ញុំ ហាក់ដូចជាអន្ទះសាប្របូកប្របល់រកស្មានមិនត្រូវ ។

ពេលខ្លះ បងស្រ៊ាង បាននាំខ្ញុំបររទេះទៅដឹកទឹកពីទន្លេមកចាក់បំពេញពាងនៅឯផ្ទះ ។ បងស្រ៊ាង ប្រហែលមិនចាប់អារម្មណ៍នឹងសំដីរបស់ខ្ញុំទេ ដែលជាញឹកញាយខ្ញុំបាននិយាយលេងនឹងគាត់ថាខ្ញុំចង់ធ្វើជាប្អូនថ្លៃគាត់ ។

ពីផ្ទះទៅកំពង់ទឹកឯមាត់ទន្លេ (កំពង់ដង្ហើររស់) បាំងទួលមួយខ្ពស់ មានចម្ងាយប្រមាណជិតកន្លះគីឡូម៉ែត្រ មើលទៅឃើញឆ្ងាយសន្ធឹម ដែលនៅអមទាំងសងខាងផ្លូវមានដំណាំអំពៅ កប្បាស និងថ្នាំជក់យ៉ាងខៀវស្រងាត់ ។ ល្ងាចៗឡើងអ្នកភូមិទាំងក្មេងចាស់ប្រុសស្រីនាំគ្នាដើរឲ្យគ្រសង ប្រុសៗមានវែកអម្រែកនៅនឹងស្មា ស្រីៗកណ្តៀត ក្អមមួយៗម្នាក់ ដើរតម្រង់ទៅផ្លូតទឹកឯមាត់ទន្លេ ។

នៅនឹងមាត់ច្រាំង ខ្ញុំចូលចិត្តអង្គុយលើទូកកញ្ចាស់មួយឆ្ងាយដាច់ពីគេតែម្នាក់ឯង អង្គុយរង់ចាំមើលព្រះអាទិត្យយាងចូលអស្តង្គតចោលរស្មីពណ៌មាសឆ្អិនឆ្អៅចាំងពន្លឺភ្លឺផ្លេក ដេញរមេញពេញលើផ្ទៃគង្គា ។

មានពេលខ្លះ ថ្ងៃលិចបាត់ទៅហើយ តែមុនពេលស្បៃងងឹតនៃរាត្រីកាលបានចូលមកដល់ ខ្ញុំនៅអង្គុយសម្លឹងមើលទៅដើងមេឃដ៏សែនឆ្ងាយ សម្លឹងសត្វហើរ អង្គុយស្តាប់ស្នូរទឹករលកតូចធំរត់ប្រដេញគ្នាមកបោកផ្ទប់នឹងមាត់ច្រាំងលាន់សូរមិនដាច់ ជាមួយនឹងបរិយាកាសជុំវិញដ៏សែនស្ងាត់ អារម្មណ៍ខ្ញុំរាយមាយអណ្តែតអណ្តូង

ឆ្ងាយទៅៗ យ៉ាងគ្មានកោះគ្មានត្រើយ ។

ដាច់ភ្នំពេញបានជាងពីរខែមកហើយនេះ សភាពការណ៍ដូចជាសន្តិភាព ស្ងប់ស្ងៀមល្អណាស់ ពុំដែលឮសូរស្នូរកាំភ្លើងមួយគ្រាប់ឡើយ ។ យូរៗម្តងយើងនៅឃើញមានអ្នកជន្លៀសមួយបួពីរគ្រួសារដើរឆ្លងកាត់ភូមិកោះអណ្តែតនៅឡើយ ។

ប៉ុន្តែចូលមកដល់ចុងខែមិថុនានេះ ស្ទើរតែរាល់ថ្ងៃគេឃើញមានសាកសពមនុស្សប្រុសស្រីជាច្រើនហើមរលេះរលួយអណ្តែតក្នុងទន្លេ ។ មានសាកសពខ្លះអណ្តែតមកទើរនៅនឹងកំពង់ទឹក ដៃជាប់ចំណង ខ្លះត្រូវគេចងមុខ និងមានសាកសពខ្លះទៀតស្រាតនទោលលែងខ្លួនទទេយ៉ាងអាណោចអាធ័ម ។

អ្នកស្រុកអ្នកភូមិបាននិយាយតៗគ្នាថា សាកសពទាំងនោះគឺជាសាកសពពួកទាហានទ័រួមខេត្តកំពង់ចាម ។ រាល់លើក ពេលដែលមានសាកសពអណ្តែតមកទើរនៅនឹងកំពង់ទឹក ពួកអ្នកស្រុកបាននាំគ្នាយកឫស្សីមួយកំណាត់ដើមវែងបន្តិច មករុញច្រានសាកសពទាំងនោះចេញពីកំពង់ឲ្យអណ្តែតរសាត់តាមបណ្តោយខ្សែទឹកហូរចុះទៅក្រោមបន្តទៀត ។

ពីមួយខែទៅមួយខែ សភាពការណ៍នៅក្នុងឃុំកោះអណ្តែតទាំងមូលមានសភាពកាន់តែតានតឹងទៅៗ ។ ប៉ុន្មានសប្តាហ៍ចុងក្រោយនេះ អង្គការបានមកកោះហៅពូៗមួយចំនួនឲ្យទៅរៀនសូត្រ ដែលភាគច្រើនពួកគាត់មានអតីតភាពជាទាហានរដ្ឋាភិបាលលាក់ប្រវត្តិរូប ហើយត្រូវបានអង្គការស៊ើបដឹង ។ អ្នកថ្មីដែលត្រូវបានអង្គការកោះហៅឲ្យទៅរៀនសូត្រ គេពុំដែលបានឃើញមានអ្នកណាម្នាក់វិលត្រឡប់មកជួបជុំគ្រួសារវិញឡើយ ។ ពូជន ស្រពាប់ស្រពោនខ្វាយខ្វល់យ៉ាងខ្លាំង ព្រោះតែគាត់មានខ្លួនមិនដឹងជាត្រូវអង្គការមកហៅគាត់យកទៅថ្ងៃណា ។ រាល់ថ្ងៃគាត់រស់នៅក្នុងសភាពភ័យខ្លាច និងប្រុងប្រយ័ត្នជានិច្ច ។

ចំណែកពួកខ្ញុំក្នុងកងយុវជនចល័តវិញ ក៏ស្ថិតក្នុងសភាពប្រុងប្រយ័ត្នគ្រប់វិនាទីទាំងអស់ដែរ ពេលសម្រាកម្តងៗពួកអ្នកថ្មីអង្គុយជុំគ្នាតែជាមួយអ្នកថ្មីគ្នាឯង មិនហ៊ានទៅអង្គុយជុំជាមួយអ្នកមូលដ្ឋានចាស់ទេ ព្រោះខ្លាច និយាយជ្រុលជ្រួសធ្លាយដល់រឿងពីសង្គមចាស់ នឹងត្រូវបដិវត្តន៍យកទោសចោទប្រកាន់ថា សេរីនិយមជាមិនខាន ។

ក្រៅពីពូៗជាទាហានរដ្ឋាភិបាល នៅមានពូៗជាមេគ្រួសារជាច្រើនទៀត ជាគ្រូបង្រៀន សាស្ត្រាចារ្យ និងជាអ្នករដ្ឋការស៊ីវិលដែលបានវិលត្រឡប់មករួមរស់នៅស្រុកកំណើតភូមិកោះអណ្តែតនេះ ។ ក្រៅពីនោះ នៅកណ្តាលភូមិកោះអណ្តែតមានអ្នកជន្លៀសខ្សែស្តេចមួយគ្រួសារមករស់នៅគឺទ្រង់ ស៊ីសុវត្ថិនិលរដ្ឋ ប្រពន្ធជាអ្នកស្រុកបាត់ដំបងឈ្មោះ សុវណ្ណ រ៉េត មានកូនពីរនាក់ កូនស្រីច្បងឈ្មោះ អាមុំ និងកូនប្រុសពៅឈ្មោះ អាជា ។ ទ្រង់ស៊ីសុវត្ថិនិលរដ្ឋរស់នៅជួបជុំគ្នាជាមួយប្រពន្ធកូន និងប្អូនថ្លៃប្រុសម្នាក់ដែលជានិស្សិតរៀននៅមហាវិទ្យាល័យច្បាប់ ឈ្មោះខ្សង ។

នៅសល់តែប៉ុន្មានថ្ងៃទៀតទេ ដល់ថ្ងៃបុណ្យភ្ជុំបិណ្ឌហើយតាំងពីថ្ងៃមួយរោជខែភទ្របទបិណ្ឌមួយអ្នកម៉ែ និងចាស់ៗក្នុងភូមិបាននាំគ្នាឆ្លៀតធ្វើចង្ហាន់យកទៅប្រគេនលោកនៅឯវត្តក្បាលកោះអណ្តែតដែលគង់នៅតែមួយព្រះអង្គគត់ ហើយដែលមានព្រះជន្មច្រើនព្រះវស្សាណាស់ទៅហើយ ។

ចំណែកសង្ឃអង្គក្មេងៗ ត្រូវបានអង្គការបង្ខំឲ្យផ្សឹកមកបំពេញពលកម្មតាមសហករណ៍វិញ ។ ចំពោះព្រះសង្ឃអង្គការមានទិសដៅដាច់ខាតខ្លាំងណាស់សម្រាប់បដិវត្តន៍សាសនាជាគ្រឿងញៀន វណ្ណៈភាពសង្ឃជាវណ្ណៈជិះជាន់ពលកម្មអ្នកដទៃ ក្នុងតំបន់រំដោះគ្មានអ្នកណារស់នៅដោយសារអ្នកណាឡើយ ។

ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់អង្គការបដិវត្តន៍ ប្រជាជនទូទាំងប្រទេសមានសិទ្ធិគ្រប់គ្រាន់ក្នុងការជឿ បុមិនជឿសាសនាតាមតែការយល់ឃើញរៀងៗខ្លួន តែសាសនាបែបប្រតិកិរិយាក្នុងតំបន់រំដោះ ត្រូវហាមឃាត់ដាច់ខាត ។

មុនថ្ងៃភ្ជុំបិណ្ឌបីថ្ងៃ ស្រាប់តែខ្ញុំបានជួបមិត្តរួមវិទ្យាល័យខ្ញុំម្នាក់ជាកូនទាហានស័ក្តិប្រាំឈ្មោះ អាសត្ថនា ។ ក្នុងសម្លៀកបំពាក់ដាច់ដាចនៅនឹងដៃវាមានកាន់ស្បោងកញ្ចាស់មួយផង អាសត្ថនា និងប្អូនស្រីវាកំពុងតែដើរសុំទានតាមផ្ទះអ្នកភូមិក្បាលកោះអណ្តែត ។ មុនពេលដែលខ្ញុំបានជួប អាសត្ថនា ជាញឹកញយនៅនឹងភូមិក្បាលកោះអណ្តែតនេះ គេតែងតែឃើញមានអ្នកថ្មីជាច្រើននាក់ភាគច្រើនជាស្ត្រីដើរមកសុំទានតាមផ្ទះអ្នកភូមិជាហូរហែ ។ ជួនកាលអ្នកភូមិអាណិតដាក់ទានឲ្យអង្ករឲ្យពោតមួយកំប៉ុងពីរ មានអ្នកថ្មីខ្លះទៀតដើរមកសុំទានពីឃុំបារាយណ៍ ដែលមានព្រំប្រទល់ជាប់គ្នានឹងស្រុកស្រីសន្ធរនេះ មិនហ៊ានមកសុំទានដៃទទេទេ ខ្លះឃើញមានកាន់

សំពត់អាវសារុងមួយបង្វិចតូច មកសុំដូរយកពោតអង្ករពីអ្នកភូមិពីផ្ទះមួយទៅផ្ទះមួយ ។

ខ្ញុំស្តាប់ អាសគ្គនា រៀបរាប់ដោយក្តីអាណិតអាសូរ វាប្រាប់ខ្ញុំថា វារស់នៅមិនឆ្ងាយពីខ្ញុំប៉ុន្មានទេ វានៅនឹងឃុំបារាយណ៍ ។ ពេលមកដល់បានតែបីថ្ងៃ ឪពុករបស់វាត្រូវបានអង្គការមកកោះហៅឲ្យទៅរៀនសូត្រ គាត់ទៅបាត់រហូត សព្វថ្ងៃវារស់នៅជាមួយម្តាយ និងបងប្អូនប្រុសស្រីបីនាក់ ។ អ្នកថ្មីនៅឃុំបារាយណ៍កំពុងតែជួបគ្រោះអត់ឃ្លានខ្លាំងណាស់ មានដាច់ពោះស្លាប់រាល់ថ្ងៃ ។ ឃុំបារាយណ៍ឆ្នាំនេះធ្វើស្រូវមិនបានគ្រប់គ្រាន់ផង ថែមទាំងអ្នកជន្លៀសមកពីភ្នំពេញរាប់រយរាប់ពាន់គ្រួសារទៀត អង្គការគ្មានលទ្ធភាពដោះស្រាយលើសពីរបបអង្ករ សម្រាប់មួយគ្រួសារមួយកំប៉ុងក្នុងមួយថ្ងៃនោះទេ ។ អាសគ្គនា វាសសើរសំណាងខ្ញុំដែលបានមករស់នៅនឹងស្រុកទន្លេនេះមិនជួបនឹងភាពអត់ឃ្លានដូចវា វាថានៅបារាយណ៍កុំថាឡើយបាយលាយសណ្តែក លាយពោត សូម្បីតែរកគល់ចេកគល់ល្ហុងសម្រាប់លាយក៏គ្មានផង ។

មុនពេលបែកពីខ្ញុំទៅ អ្នកម៉ែ និង មីងណារុង បានចូកអង្ករ និងគ្រាប់ពោតមួយស្បោងឲ្យទៅអាសគ្គនា និងប្អូនស្រីវា ។ រួមជាមួយអ្នកស្រុកអ្នកភូមិក្មេងចាស់ប្រុសស្រីជាច្រើន មកពីភូមិជិតឆ្ងាយ នៅថ្ងៃភ្ជុំបិណ្ឌ ខ្ញុំ និងអ្នកម៉ែ មីងណារុង និងលោកយាយ កំពង់សៀម ក៏បានទៅភ្ជុំនៅឯវត្តក្បាលកោះនឹងគេដែរ ។

ក្រោយពីបានចូលទៅអុជធូបថ្វាយបង្គំព្រះនៅក្នុងព្រះវិហាររួចមក យើងក៏បាននាំគ្នាឡើងទៅលើសាលាឆាន់ដើម្បីរៀបចំចង្ហាន់ប្រគេនព្រះសង្ឃ ។

ក្នុងចំណោមមនុស្សដ៏ច្រើនកកកុញ លាយឡំ និងក្លិនផ្សែងធូបទៀនហុយទ្រលោម ខ្ញុំចោលភ្នែកសម្លឹងមើលទៅជ្រុងម្ខាងក្រោមសាលាឆាន់ នៅនឹងចង្ក្រានដែកយ៉ាងធំមួយ ដែលកំពុងតែមានភ្លើងឆេះហុយៗ ខ្ញុំឃើញមាននំជាល នំអន្សមចេក អន្សមជ្រូកយ៉ាងច្រើនដាក់ឆ្អើរយ៉ាងរណ្តូករណែល ។

នៅជុំវិញចង្ក្រានដ៏ធំនោះ អ្នកសុំទានប្រុសស្រីមកពីឃុំបារាយណ៍ជាច្រើននាក់បានអង្គុយរង់ចាំឲ្យរហង់ ដោយក្តីស្រេចឃ្លាន គឺនៅទីនោះហើយដែលខ្ញុំបានជួប អាសគ្គនា និងប្អូនស្រីវាជាចុងក្រោយ ។

បុណ្យភ្ជុំបិណ្ឌរួចមានភ្លៀងធ្លាក់យ៉ាងជោគជាំរាល់ថ្ងៃ អង្គការបានដាក់ទិសដៅឲ្យសម្រុកការងារដកស្ទូងកាន់តែខ្លាំងក្លា ។ ពួកកងយុវជន យុវនារីទាំងអ្នកមូលដ្ឋានចាស់ ទាំងអ្នកថ្មីមានភារកិច្ចដកសំណាបឲ្យទាន់សម្រាប់កងវ័យកណ្តាលស្ទូង ។

ថ្ងៃមួយពេលដែលបានទៅដកសំណាបមួយថ្នាលធំនៅនឹងកណ្តាលភូមិ ខ្ញុំបានឃើញនាងវ៉ង្ហួលក្នុងសម្លៀកបំពាក់ខោអាវខ្មៅជួតក្បាលក្រមា កំពុងតែដកសំណាបបោកដីដាក់គ្នាទៅវិញទៅមកឡើងខ្វាយទឹកសំពោងជាមួយនឹងពួកយុវជន យុវនារីអ្នកមូលដ្ឋានចាស់ជាច្រើននាក់ទៀត ហើយនាំគ្នាសើចលេងសប្បាយយ៉ាងក្អាកក្អាយ ។

ចំណែកពួកអ្នក១៧មេសា មិនហ៊ានលេងនឹងគេទេ ម្នាក់ៗខំប្រឹងតែសម្រុកដកទៅមុខដោយស្ងៀមស្ងាត់ ។ លុះដល់ពេលសម្រាក ពួកអ្នកថ្មីទៅសម្រាកជុំគ្នានៅនឹងមាត់ស្រះជាប់នឹងរបងវត្តក្រោមម្លប់សណ្តាន់មួយដើមបែកមែកត្រឈុំត្រឈៃ ដែលមានផ្កាព្រលិតផ្កាវិចង់រីករហង់ពេញផ្ទៃទឹកដ៏ថ្លាយង់ ។ នៅនឹងផ្ទាំងថ្មមួយផ្ទាំងធំ ពួកយើងនាំគ្នាអង្គុយស្តាប់ បងតៃ មិត្តភក្តិ បងខ្យង ដែលជានិស្សិតរៀននៅមហាវិទ្យាល័យច្បាប់ដែរ ច្រៀងបទអកបីងកន្សែងតិចៗយ៉ាងពិរោះរងំ ។

ទន្ទឹមនឹងផែនការសម្រុកដកស្ទូងយ៉ាងប្រញាឹកដៃនេះ អង្គការភូមិនៅមានគោលនយោបាយបំប៉នប្រជាជន ដោយមានបើករបបសាច់ជ្រូកក្នុងរយៈពេលពីរសប្តាហ៍ម្តងដែលសមាជិកទាំងអស់ក្នុងគ្រួសារបានទទួលរបបសាច់ជ្រូកម្នាក់មួយខាំ ។

ល្ងាចថ្ងៃមួយ ក្រោយពីពេលដែលបានឮស្នូរជួងពីទីស្នាក់ការសហករណ៍ជាសញ្ញាឲ្យអ្នកភូមិទៅបើករបបសាច់ជ្រូក ខ្ញុំក៏បានទៅឈរតម្រង់ជួររង់ចាំក្នុងចំណោមប្រជាជនអ្នកភូមិជាច្រើននាក់ទៀតដែរ ។ នៅចំពីមុខខ្ញុំ មានតុធំមួយដែលសមមិត្តអនុប្រធានភូមិកំពុងតែឈរកាប់សាច់ជ្រូក រួចដាក់ថ្លឹងនឹងជញ្ជីងយ៉ាងកញ្ចាស់មួយ ។ នៅនឹងគ្រែរនាបឫស្សីមួយក្បែរនោះ សមមិត្តប្រធានភូមិកំពុងតែអង្គុយពែនភ្នែនបង្ហុយបារីស្លឹកសង្កែដែលមានក្រដាសបញ្ជីរាយនាមស្ថិតិគ្រួសារជាច្រើនសន្ធឹកនៅចំពីមុខផង ។

នៅខាងក្រោមតុសាច់ជ្រូក ខ្ញុំឃើញមានឆ្កែអង្កែស៊ីពីរក្បាលមួយសម្បុរត្នោត និងមួយទៀតសម្បុរខ្មៅ ដែលជ្រុះរោមអស់រលីង

ទៅហើយ នៅសល់តែស្បែកឡើងរលោងដូចផ្លែនីឡុង កំពុងតែត្រហឹមបញ្ចេញចង្កូមដាក់គ្នា ជួនស៊ុះទៅត្របាក់ខាំគ្នា ដណ្តើមកំទេចឆ្អឹងជ្រូកដែលសមមិត្តអនុប្រធានភូមិបានកោសសម្អាតជ្រុញទម្លាក់ចុះមកដីមើលទៅគួរឲ្យព្រឺខ្លាច ។

ឃើញដូច្នោះសមមិត្តប្រធានភូមិទ្រាំមិនបានក៏ស្រែកពីលើគ្រែមកថា ចុះមិត្តឯងម៉េចក៏មិនដេញ អានល់ និង អាតាំ ចេញឲ្យឆ្ងាយទៅ ។ ទាល់តែសមមិត្តអនុប្រធានភូមិលូកជើងទៅធាក់ឆ្កែអង្កែស៊ីទាំងពីរក្បាលនោះមួយជើងយ៉ាងអស់ទំហឹង ឲ្យខ្លាត់ប្រកាច់ប្រកិនចេញពីក្រោមតុទៅទើបខ្ញុំបានដឹងថាឈ្មោះប្រមុខរដ្ឋាភិបាលនៃរបបសាធារណរដ្ឋខ្មែរ ត្រូវបានគេស្អប់ខ្ពើម ហើយដែលគ្មានអ្នកណាម្នាក់នឹកស្មានដល់សោះថា ក្នុងតំបន់រំដោះត្រូវបាន គេយកឈ្មោះទៅប្រើសម្រាប់ដាក់ឲ្យសត្វឆ្កែទៅវិញ ។

នាដើមរដូវរំហើយ ក្នុងស្រុកស្រីសន្ធរទាំងមូលរំជើបរំជួលដោយមានលេចព្ញដំណឹងពីមាត់មួយ ទៅមាត់មួយពីផែនការរបស់អង្គការថ្នាក់លើដែលត្រូវជន្លៀសប្រជាជនដប់ប្រាំពីរមេសាឲ្យទៅរស់នៅតាមតំបន់ផ្សេងទៀត ។

គ្រាន់តែបានទទួលដំណឹងនេះភ្លាម ម្នាក់ៗសែនព្រួយខ្វាយខ្វល់ព្រោះនឹងត្រូវរើចបង្ខេចជាថ្មីម្តងទៀត ម្យ៉ាងអ្នកដែលបានមកដល់ស្រុកកំណើត បានមករួមរស់ជួបជុំបងប្អូន ឪពុកម្តាយអស់ហើយ នឹងត្រូវឃ្លាតបែកឆ្ងាយ ហើយលើកនេះទៀតមិនដឹងជាត្រូវរសាត់អណ្តែតទៅដល់ទីណាទេ ។

ប្រមាណពីរសប្តាហ៍ក្រោយមក អ្នកជន្លៀសទូទាំងឃុំត្រូវបានអង្គការឲ្យដឹងពីផែនការជន្លៀសអ្នកថ្មីពីតំបន់២១ខេត្តកំពង់ចាមឲ្យទៅរស់នៅតំបន់៤៣ខេត្តកំពង់ធំ ព្រោះនៅខេត្តកំពង់ធំមានដីស្រែទំនេរជាច្រើន ហើយអង្គការបានអះអាងថា សូមបងប្អូនកុំព្រួយបារម្ភ ទៅរស់នៅទីណាក៏ដូចជានៅទីណាដែរ ក្រោមការដឹកនាំរបស់អង្គការតែមួយ ។

ក្រោយពីថ្ងៃប្រជុំទូទាំងឃុំរួចមក គ្រួសារអ្នកជន្លៀសនីមួយៗបានរៀបចំអីវ៉ាន់ដែលមានបន្តិចបន្តួចត្រៀមលក្ខណៈជាស្រេចរង់ចាំថ្ងៃប្រកាសចេញដំណើរ ដែលគ្រាន់តែព្ទតៗគ្នាមកថា ប្រហែលជាក្នុងសប្តាហ៍ទីមួយឬទីពីរនៃខែតុលាខាងមុខនេះ ។

ល្ងាចថ្ងៃស្អែកឡើងត្រូវចេញដំណើរ មិត្តលាវ បានណាត់ឲ្យខ្ញុំទៅជួបគាត់នៅឯផ្ទះ ។ ល្ងាចនោះមុននឹង ទៅជួបមិត្តលាវ ខ្ញុំបានចូលទៅលា មិត្តរស់ និង អាអៀន ជាមុនសិន អាអៀន បានបោចថ្នាំជក់ឲ្យខ្ញុំមួយបង្វេចធំ ហើយថែមទាំងបាននិយាយផ្តាំផ្ញើខ្ញុំជាច្រើន ។ ខ្ញុំបានឈានជើងឡើងកាំជណ្តើរផ្ទះ មិត្តលាវ ដោយថ្នមៗផ្ទះស្លឹកតូចមួយ ក្រាលរនាបឫស្សីសង់ខ្ពស់ផុតពីដីបន្តិច ពេលខ្ញុំចូលទៅដល់ខ្ញុំបានឃើញឪពុកម្តាយមិត្តលាវដែលមានវ័យចំណាស់ប្រមាណជាង៥០ឆ្នាំអង្គុយទន្ទឹមគ្នានៅចំកណ្តាលផ្ទះ ចំណែកមិត្តលាវ អង្គុយបញ្ឈរជង្គង់ផ្អែកខ្នងទៅនឹងជញ្ជាំង បែរមុខមកមាត់ទ្វារទាំងអស់គ្នាហាក់ដូចកំពុងរង់ចាំទទួលខ្ញុំ ។

ខ្ញុំអង្គុយនៅចំពីមុខឪពុកម្តាយ មិត្តលាវ បន្ទាប់ពីបានជំរាបសួរគាត់ទាំងពីររួចមក ។ មិនបង្អង់ឲ្យខាតពេល មិត្តលាវ ក៏បានផ្តើមនិយាយមកកាន់ខ្ញុំថា ថ្ងៃស្អែកនេះមិត្តឯងត្រូវចេញដំណើរទៅកំពង់ធំហើយមុនពេលបែកគ្នានេះ ខ្ញុំចង់និយាយផ្តាំផ្ញើខ្លះៗ មិត្តលាវ បង្អង់បន្តិចរួចគាត់បានបន្តទៀតថា ជិត៦ខែកន្លងមកនេះ ខ្ញុំបានសម្គាល់ឃើញថា មិត្តឯងជាមនុស្សម្នាក់ស្លូតបូតគួរឲ្យអាណិតស្រឡាញ់ ខ្ញុំគ្រាន់តែចង់និយាយផ្តាំថា ទោះជាមិត្តឯងត្រូវទៅរស់នៅទីណាក៏ដោយក្នុងតំបន់បដិវត្តន៍ មិត្តឯងត្រូវខិតខំកសាងខ្លួនឲ្យបានល្អ ប្រុងប្រយ័ត្នខិតខំធ្វើការងារ ជាពិសេសមិត្តឯងកុំប្រកែកតវ៉ាឬតថ្លៃ និងបញ្ជារបស់អង្គការឲ្យសោះ ។

ខ្ញុំអង្គុយស្តាប់មិត្ត លាវ ផ្តាំផ្ញើដោយយកចិត្តទុកដាក់ គាត់នៅបានសុំកុំឲ្យខ្ញុំប្រកាន់ និងរូបគាត់ដែលរយៈពេលកន្លងមកនេះបើមានការលើសលួសយ៉ាងណាមកលើខ្ញុំ គាត់ថាគាត់សំដីអាក្រក់មែន តែចិត្តគាត់មិនអាក្រក់ទេ ។ ឪពុកម្តាយ មិត្តលាវ ពេលនោះនៅបានឆ្លៀតផ្តាំផ្ញើខ្ញុំថា កុំឲ្យខ្ញុំភ្លេចពាក្យសំដីគាត់ ក្នុងតំបន់បដិវត្តន៍ក្មួយឯងត្រូវចេះ ធ្វើថ្លង់...ធ្វើគ... ។

និយាយរួច មិត្តលាវ បានក្រោកឡើង ដើរចូលទៅក្នុងបន្ទប់ដែលខណ្ឌដោយវាំងននក្រណាត់មួយក្បែរនោះ ពេលដែលគាត់ចេញមកវិញគាត់បានហុចកញ្ចប់មួយមកឲ្យខ្ញុំ ។ ខ្ញុំបានទទួលកញ្ចប់នោះពីគាត់ គាត់បាននិយាយមកកាន់ខ្ញុំថា ខ្ញុំអត់មានអីឲ្យមិត្តឯងទេ! កញ្ចប់នេះមិត្តឯងបើកមើលឥឡូវក៏បានដែរ ។ ខ្ញុំក៏បានចាប់ផ្តើមលាកញ្ចប់របស់ មិត្តលាវ ដែលខ្ចប់ដោយក្រដាសទស្សនាវដ្តីកម្ពុជាប្រជាធិបតេយ្យដោយផ្តោតអារម្មណ៍យ៉ាងផ្ចិតផ្ចង់...ក្នុងកញ្ចប់នោះ

ខ្ញុំបានឃើញមានខោខ្មៅមួយអាវខ្មៅមួយចាស់ជិនបន្តិច ដែលមានទាំងស្នាមបំណាស់ពីរបីកន្លែងផង ហើយពេលដែលខ្ញុំបានលើកខោអាវនោះឡើង ខ្ញុំនៅបានប្រទះឃើញមានអំបោះខ្មៅមួយដុំតូចមានទាំងដោតម្ជុលដេរពីរដាប់ជាមួយផង ។

គ្រាដែលខ្ញុំលើកដៃសំពះអរគុណគាត់ មិត្តលាវ បាននិយាយមកកាន់ខ្ញុំថា ខ្ញុំអត់មានខោអាវថ្មីទេ មានតែខោអាវចាស់ជិនំនេះដែលម៉ែខ្ញុំបានបោកគក់ស្អាត និងដេរប៉ះរួចហើយ មិត្តឯងយកទៅទុកគ្រាន់បានស្លៀកពាក់ផ្លាស់ប្តូរគ្នា ។

ខ្ញុំបានចាកចេញពី មិត្តលាវ និងឪពុកម្តាយគាត់ដោយក្តីរំភើបក្នុងចិត្ត តាំងពីពេលនោះមកខ្ញុំនៅបានគិតថា សន្តានចិត្តដ៏ល្អរបស់គាត់ ខ្ញុំនឹងចងចាំជានិច្ច ចាំមិនភ្លេចទេក្នុងមួយជីវិតខ្ញុំនេះ... ។ ទង់បដិវត្តន៍ដ៏ក្រហមឆ្អិនឆ្អៅ និងទង់ជ័រលាចម្រុះពណ៌ជាច្រើន ដែលដោតតម្រៀបគ្នាជាជួរតាមបណ្តោយមាត់ប្រាំងទន្លេពីផ្លាដង្ហោរស់ រហូតដល់ផ្លាអន្តរជ័យកំពុងតែត្រូវខ្យល់ទន្លេនាដើមរដូវរំហើយបក់រវិចៗ ។ នៅនឹងទីស្នាក់ការបណ្តោះអាសន្នប្របនឹងមាត់ទឹកមួយដែលសង់ពីឫស្សីប្រក់ស្លឹកត្នោត ជាមួយនិងប្រដាប់បំពងសំឡេងដែលចងភ្ជាប់នឹងបង្គោលទង់ជ័រលាមួយយ៉ាងខ្ពស់ គេកំពុងតែបានឮសូរបទចម្រៀងបដិវត្តន៍យ៉ាងគ្រលួចតាំងពីព្រលឹមស្រាងៗមកម្លេះ ។ នៅនឹងមាត់ទឹកមានទូកម៉ាស៊ីនរបស់អង្គការជាច្រើនគ្រឿងចតតម្រៀបគ្នារង់ចាំចម្លងអ្នក១៧មេសាទៅត្រើយខាងពាមជីកង ។ បងស្រ៊ាង ក្រោកតាំងពីព្រឹករៀបចំគោររទេះ ចាំជួយដឹកជញ្ជូនអីវ៉ាន់ពួកខ្ញុំ ។ អ្នកជប់ប្រាំពីរមេសាមកពីទូទាំងស្រុកស្រីសន្ធរទាំងគ្រួសារៗ ខ្លះទូលខ្លះរែកកំពុងតែធ្វើដំណើរហូរហែមិនដាច់ឆ្ពោះទៅកាន់កំពង់ចម្លងផ្លាអន្តរជ័យ ។

ក្រុមគ្រួសារកូនក្មួយញាតិ មិត្តពូផន ម្នាក់ៗឃើញតែទឹកភ្នែករលីងរលោងមុនពេលបែកគ្នានេះ ។ ពូផន លុតជង្គង់ដល់ដីក្រាបបង្គំលាអ្នកមានគុណទាំងពីររបស់គាត់ដោយទឹកមុខស្រពាប់ស្រពោនក្រៀមក្រំ យាយជង ម្តាយពូផន ងាកមុខចេញទៅម្ខាងយកក្រមាជូតទឹកភ្នែកដែលកំពុងតែហូរធ្លាក់មកពុំឈប់ឈរ បងសារុំ ស្ទុះមកឱប មីងណារុង ហើយទ្រហោយំ បងស្រ៊ាង ជញ្ជូនអីវ៉ាន់ដាក់រទេះបណ្តើរ ហើយគាត់ចេះតែនិយាយបន្ទប់ពីនេះពីនោះជាមួយខ្ញុំបណ្តើរ ដើម្បីកុំឲ្យបរិយាកាសសោកនាដកម្មនេះគានតឹងខ្លាំងពេក ។

ចំណែកខ្ញុំគ្រប់វិនាទីទាំងអស់ ភ្នែកទាំងគូរខំរំពៃរកមើល "រំដួល" ដោយក្តីអន្ទោកអន្ទោលតក់ក្រហល់ក្នុងចិត្ត ។ បងស្រ៊ាងជញ្ជូនអីវ៉ាន់ដាក់រទេះរួចស្រេចហើយ ពេលចេញដំណើរក៏កាន់តែខិតជិតមកដល់ម្តេចក៏មិនឃើញស្រមោល រំដួល សោះ? ទ្រាំមិនបានខ្ញុំក៏ដាច់ចិត្តសួរ បងសារុំ ។ ខ្ញុំសែនសោកស្តាយរកទីបំផុតគ្មានគ្រាដែលបង សារុំ បានឆ្លើយប្រាប់ខ្ញុំថា រំដួលកំពង់តែពួនយំក្នុងបន្ទប់តែម្នាក់ឯង រំដួល មិនបានជូនដំណើរទេ ។

មកដល់ទីស្នាក់ការកំពង់ចម្លងផ្លាអន្តរជ័យ អង្គការបានបើករបបអង្ករឲ្យចំនួនដប់កំប៉ុងក្នុងមួយគ្រួសារ ។ ប្រជាជនអ្នកជម្លៀសរាប់រយគ្រួសារបានមកផ្តុំគ្នារង់ចាំអង្គការហៅឈ្មោះតាមគ្រួសារចុះទូក ដែលមានពួកយោធាជាច្រើនកងចាំជួយជញ្ជូនអីវ៉ាន់ផង ព្រោះខ្លាចដល់ថ្ងៃរសៀលមានធ្លាក់ខ្យល់ខ្លាំងពិបាកឆ្លង ។ ខ្ញុំអង្គុយចំកណ្តាលទូក ពេលដែលពួកមិត្តកំពុងតែបញ្ឆេះម៉ាស៊ីនហើយរុញក្បាលទូកឲ្យចេញពីប្រាំងខ្យល់ជំនោរត្រជាក់បក់មករំភើយៗធ្វើឲ្យរងាបន្តិចមែន តែផ្ទៃទឹកទន្លេទាំងមូលមានសភាពយ៉ាងស្ងប់ស្ងៀម ។ ខ្ញុំបោលភ្នែកសម្លឹងមើលកូនរលកតូចៗ ដែលចាំងឆ្លុះភ្លឺផ្លេកៗនឹងពន្លឺព្រះអាទិត្យកំពុងរត់ប្រដេញជាជួរបន្តបន្ទាប់គ្នា ទូកបោះពួយទៅមុខយ៉ាងលឿនលយរុញច្រានអង្កាញ់រលកតូចៗទាំងនោះឲ្យបកត្រឡប់ទៅផ្ទៃអន្តាវិញ ជូនបែកទឹកខ្ចាយសាចតិចៗមកលើទូក ដូចភ្លៀងរលឹមផ្សែងក្រុច ។

មកដល់កណ្តាលទន្លេដ៏ល្វឹងល្វើយ បទចម្រៀងបដិវត្តន៍ពីទីស្នាក់ការផ្លាអន្តរជ័យលាន់ឮកាន់តែខ្សោយទៅៗ កំពង់ដង្ហោរស់ដែលប្រាំងទើបតែនឹងបាក់ថ្មីឃើញកាន់តែឆ្ងាយសន្ធឹមទៅៗជិតៗនឹងចុងព្រឹក្សាដែលបណ្តាលឲ្យចិត្តខ្ញុំរីងរិតតែនឹកស្រណោះអាលោះអាល័យដល់រន្ធត់ភក្ត្រដ៏ជូរជង់ និងកែវភ្នែកទាំងគូរដ៏ស្រទន់របស់រំដួលនឹកមិនភ្លេច ។ លើសពីនេះទៅទៀត ទ្រូងខ្ញុំសែនចង្អៀតហាក់រងដោយក្តីចំបែង ព្រោះតែត្រូវឃ្លាតឆ្ងាយពីរំដួលកោះអណ្តែតដែលចិត្តធ្លាប់លួចគួចប្រាថ្នា ហើយខ្ញុំស្តាយ ដោយមុនពេលបែកគ្នានេះខ្ញុំមិនបានលានាងមួយម៉ាត់ឲ្យអស់ចិត្ត ។

**(តទៅលេខក្រោយ)**

**ប៉ុក ប៉ុនសូម៉ាង**

# សៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់ នៅក្នុងរបបខ្មែរក្រហម

មជ្ឈមណ្ឌលឯកសារកម្ពុជា គ្រោងនឹងបោះពុម្ពផ្សាយនូវសៀវភៅមានកត់ត្រាឈ្មោះរបស់អ្នកដែលស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងនូវឈ្មោះអ្នកដែលស្លាប់ជាង១លាននាក់រួចមកហើយ ។ ប្រសិនបើលោកយាយ លោកតា អ៊ំ ពូ មីង ប្រាថ្នាចង់ឲ្យឈ្មោះសមាជិកក្រុមគ្រួសារដែលបានស្លាប់បាត់បង់ជីវិតមាននៅក្នុងសៀវភៅនេះ សូមទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ អេង កុកថាយ ទូរស័ព្ទលេខ ០១២ ៧៩៧ ៣៩៤ ឬ អ៊ីម៉ែល ៖ truthkokthay@dccam.org ឲ្យបានឆាប់រហ័សតាមពេលវេលាដែលអាចធ្វើទៅបាន ។

**សូមផ្តល់ព័ត៌មានដូចខាងក្រោម៖**

១) ឈ្មោះអ្នកប្រកាសប្រាប់, ២) តើមានបងប្អូនបង្កើតរួមទាំងឪពុកម្តាយស្លាប់ប៉ុន្មាននាក់នៅក្នុងសម័យខ្មែរក្រហម? ៣) ឈ្មោះអ្នកស្លាប់, ៤) ភេទអ្នកស្លាប់, ៥) អាយុអ្នកស្លាប់ (បើអាចចាំបាន), ៦) ត្រូវជាអ្វីនឹងអ្នកប្រកាស (ឧទាហរណ៍៖ ឪពុក ម្តាយ បងប្រុស ប្អូនប្រុស បងស្រី ឬប្អូនស្រី), ៧) សាច់រឿងទាក់ទងនឹងការស្លាប់ (ឧទាហរណ៍ ៖ ស្លាប់នៅទីណា? មូលហេតុអ្វី?), ៨) វត្ថុតាងទាក់ទងនឹងអ្នកស្លាប់ (ឧទាហរណ៍៖ រូបថត ឯកសារ ឬវត្ថុផ្សេងៗ), ៩) ព័ត៌មានសម្រាប់មជ្ឈមណ្ឌលទាក់ទង (ឧទាហរណ៍៖ លេខទូរស័ព្ទ អាស័យដ្ឋាន) ។

**ប្រសិនបើចង់ស្វែងរកអ្នកដែលបាត់ខ្លួនសូមផ្តល់ព័ត៌មានខាងក្រោម៖**

១) ឈ្មោះអ្នកបាត់ខ្លួន, ២) ភេទ, ៣) អាយុ, ៤) ត្រូវជាអ្វី, ៥) សាច់រឿងទាក់ទងនឹងការបែកគ្នា, ៦) វត្ថុតាងទាក់ទងនឹងអ្នកបាត់ខ្លួន (ឧទាហរណ៍៖ រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ។










ដើម្បីយុត្តិធម៌និងការចងចាំ
ដែលជាមូលដ្ឋានដ៏សំខាន់ក្នុងការផ្សះផ្សាជាតិ

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយ ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ សហរដ្ឋអាមេរិក (USAID)
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម.៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ ៖ (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 189, 2015 ◆ Funded by USAID.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.